រឿង

# ស្នាមញញឹម

ប្រលោមលោកមនោសញ្ចេតនា

និពន្ធនិងគូរគំនូរលើក្របដោយ

**អ្នកស្រី កែវ ចន្ទ័បូរណ៌**

P.O.Box 600279
Saint Paul, MN 55119
USA
khmervissal@yahoo.com
651-442-8941
www.angkorwat.com

CHANBOKEO.COM

ខែឧសភា២០០០

រក្សាសិទ្ធិគ្រប់យ៉ាង

# ស្នាដៃខ្លះៗរបស់អ្នកស្រីកែវចន្ទ័បូរណ៍

១- រឿង សំនៀងស្នេហ៍កវី

២- រឿង និស្ស័យស្នេហ៍

៣- រឿង ផ្កាយរង្វេងមេឃ

៤- រឿង ស្នាមញញឹម

៥- រឿង កុលាបស្មឹងខៀវ

៦- រឿង ក្លិនផ្កាមាលតី

៧- រឿង លិខិតមរតកសម្ងាត់

៨- រឿង បំណុលជីវិត

៩- រឿង ចរណៃដួងទ័យា

១០- រឿង អំបែងអណ្តែត

១១- រឿង ស្នែកចាកផុតទៅ

១២- រឿង តន្ត្រីបេះដូង

១៣- រឿង សារាណីយមាតា

១៤- រឿង ទារុណដួងចិត្ត

១៥- រឿង បើសិននៅមានថ្ងៃស្អែក

១៦- រឿង លំអងផ្កាស្នេហ៍

១៧- រឿង ត្រៃមិត្ររតននារី

១៨- រឿង ខ្មើយវាសនា

១៩- រឿង បើសិនអាចបង្វិលផែនដី

២០- រឿង សីវបុរេកាល

២១- រឿង មេឃដ៏សក្តិសិទ្ធិ

២២- រឿង មួយពាន់ទំព័រ

២៣- រឿង អាមេរិកដែនដីមាស

២៤- រឿង អាត្រាតថ្ងៃរះ

២៥- រឿង បក្សីសួនសុបិន

២៦- រឿង ម្លប់អសោក

២៧- រឿង ពិជេដ្ឋភានុមា

២៨- រឿង ផ្ការីកក្រៅសួន

២៩- រឿង មន្តស្នេហ៍ស្រីខ្មៅ

៣០- រឿង អនង្គលាភា

៣១- រឿង ពណ្ណរាយពេជ្រ

៣២- រឿង សារិកា

៣៣- រឿង ផ្ការាជបឹងរាំង

៣៤- រឿង នភាមណី

៣៥- រឿង ស្រីនាថភ្លួងមាលា

៣៦- រឿង វាយោដួងចិត្ត

កំណាព្យ :

១- ឧទ្យានកំណាព្យ ភាគ១ : គុណ និង សីលធម៌ (១៣៣កំណាព្យ)

២- ឧទ្យានកំណាព្យ ភាគ២ : គុណ និង សីលធម៌ (១១០កំណាព្យ)

CHANBOKEO.COM

# សូមឧទ្ទិសចំពោះ

- លោក មេង សួង សុវណ្ណធី ជាស្វាមី
- កុមារី សុវណ្ណធី ធម្មិកា បារមីបុណ្យ ជាបុត្រី
- លោកឪពុក ប៊ុនថង និងអ្នកម្តាយ កែវយឿង
- លោកឪពុកក្មេក មេងសួង និងអ្នកម្តាយក្មេក កូវសារ៉ាន់
- លោកគ្រូប៊ុនឈុននាម លោកគ្រូប៊ុនណាំ អ្នកគ្រូអ៊ិកវ៉ាន់ថា លោកគ្រូរស់សាន់
- លោកគ្រូអ្នកគ្រូរបស់នាងខ្ញុំទាំងអស់ ។
- អ្នកគ្រូទូចសារៀង អ្នកគ្រូកែវសុផុន លោកគ្រូលីតាយហុង
- លោកគ្រូរើនរស់ អ្នកគ្រូម៉ៀចសុខារី អ្នកគ្រូស៊ីមចាន់យ៉ា
- អ្នកនាងប៉ក់ដារិនី អ្នកនាងមាយបេងយង់ លោកលេកស៊ីវហុង
- លោកខូតារាឫទ្ធិ នាយកគ្រប់គ្រង សម្ហូហកម្មអក្សរសិល្ប៍នូហាច ភ្នំពេញ
- ចំពោះប្រិយមិត្តដែលជា អ្នកនិពន្ធ គន្ថការី និងកវីទាំងឡាយ ។




អ្នកស្រី កែវ ចន្ទ័បូរណ៍

រដ្ឋមិនីសូតា សហរដ្ឋអាមេរិក

# វាចាអ្នកនិពន្ធ

រឿងស្នាមញញឹមជាខ្សែរឿងមនោសញ្ចេតនាដ៏ផ្អែមល្ហែមជ្រាលជ្រៅ ជាភាគ បន្តពីសាច់រឿងប្រលោមលោកចរណៃដួងច័យា ដែលបានចេញផ្សាយរួចមកហើយ ថ្មីៗនេះ ។ ស្នាមញញឹមលាតត្រដាងនូវទឹកចិត្តស្នេហានិងការពលីរបស់តួអង្គមួយរូប ដើម្បីបុគ្គលដែលគេស្រលាញ់ ដោយមិនគិតពីការសើចចំអករបស់សង្គមឡើយ ត្បិតគេយល់ថាសុភមង្គលពិតប្រាកដ ស្ថិតនៅលើចំណងដួងចិត្តដ៏មុតមាំរវាង មនុស្សពីរនាក់ តែមិនមែនស្ថិតនៅលើការសំរេចពីសង្គមជុំវិញខ្លួននោះឡើយ ។ បើគេតស៊ូប្តូរផ្តាច់នឹងគ្នាដោយចិត្តស្មោះស្មគ្រ័ភក្តីទៅហើយ ទោះបីជាមេឃរលំ ភ្នំរលាយក៏នៅតែមិនអាចបំបែកស្នេហារបស់គេបានជាដាច់ខាត ។

ចំពោះកំហុសអក្ខរាវិរុទ្ធដោយអចេតនាទាំងឡាយនៅក្នុងសាច់រឿង សូម ប្រិយមិត្តមេត្តាជួយកែសំរួលអោយបាន ត្រឹមត្រូវតាមវេយ្យាករណ៏ខ្មែរប្រពៃផង ។

នាងខ្ញុំអ្នកនិពន្ធ សូមទទួលនូវមតិយោបល់ពីប្រិយមិត្តអ្នកអាន តាមរយៈ អស័យដ្ឋានដូច ខាងក្រោមនេះ :

Pannalai Khmer Vissal
P.O.Box 600279
Saint Paul, MN 55119
USA
Khmervissal@yahoo.com

សូមប្រសិទ្ធិពរជ័យដល់ប្រិយមិត្តអ្នកអានទាំងអស់ ឱ្យបានជួបតែវឌ្ឍនសុខ សុវត្ថិភាព និងសុភមង្គលរាល់ទិវារាត្រី ។

អ្នកស្រី កែវ ចន្ទ័បូរណ៏

ខែឧសភា២០០០

CHANBOKEO . COM

# កំណាព្យ

## អំនួតខ្មែរ

ខ្មែរខ្ញុំស្រឡាញ់ក្រុមគ្រួសារ មាតាបិតាទីគោរព
ស្រឡាញ់បងប្អូនសួនគួរគាប់ ញាតិមិត្តក៏រាប់មិនរាយមាយ ។
ខ្មែរខ្ញុំស្រឡាញ់ដីភូមិករ ថែរាប់តំណ...តស្រឡាយ
ស្រឡាញ់ទន្លេស្ទឹងអន្លាយ ព្រៃភ្នំលាតឆ្ងាយដល់ជើងមេឃ ។
ខ្មែរខ្ញុំស្រឡាញ់ដំណែលកេរ ដូនតាលោកត្មែរគិតពន់ពេក
កូនចៅអើយថែសម្បត្តិឯក កុំអោយធ្លោយហែកចែកបរទេស ។
ខ្មែរខ្ញុំស្រឡាញ់ភាសាជាតិ ថែយ៉ាងវរនាថល្អវិសេស
មិនអោយជាតិគេជាន់ដកបេះ ប្រឡេះបោះបាត់ស្វាត់សូន្យបង់ ។
ខ្មែរខ្ញុំស្រឡាញ់ប្រពៃណី វន្ទាអញ្ជលីលើកដៃក្បង់
សន្សំរក្សាយ៉ាងផូរផង់ មិនអោយបាត់បង់សាបសូន្យទៅ ។
ខ្មែរខ្ញុំស្រឡាញ់សីលធម៌ សាងអំពើល្អនឹងញាតិផៅ
គោរពពាក្យគ្រូលោកប្រដៅ សខ្មៅវែកញែករែកគំនិត ។
ខ្មែរខ្ញុំស្រឡាញ់អ្វីជាខ្មែរ រក្សាធួនថែយ៉ាងវិចិត្រ
មិនធ្វេសប្រហែសចាកសុក្រិត រក្សាជីវិតជាតិខេមរារៀងអើយ ។

CHANBOKEO.COM

# ចង់រាក់អោយជីក ចង់រីកអោយហាលថ្ងៃ

បាយដាំស្ងួះឆ្នាំងចង់អោយរាក់    យកវែកជ្រោយជាក់អោយរសោះ
បាយប្រែពោរឡើងពេញឆ្នាំងអស់    រួចហើយដួសដោះឆីភោគ្គា ។
ដូចការសិក្សាមានជំរៅ    ចង់រាក់ជីកទៅអោយសព្វសារ
គាស់យកមករៀនច្រើនសាស្ត្រា    អាត្មាលែងលង់ជំរៅល្ងិត ។
ឯគរកប្បាសច្បាស់ជារីក    បេះប្រឡេះហែកហាលថ្ងៃពិត
សំពោងធំក្រៃសំបើមឫទ្ធិ    ច្រកខ្នើយកើយនិត្យចិត្តក្សេមក្សាន្ត ។
ចង់រីកចំរើនខាងភោគផល    ហាលថ្ងៃរចល់កុំអោយខាន
ធ្វើស្រែចំការ កបង្កើន    ឧស្សាហ៍ក្រវើនគង់សំរេច ។
ពាក្យចាស់លោកផ្តាំយើងចាំទុក    គំនិតនាំសុខកុំងាកគេច
ស្តាប់ហើយវិភាគន័យសារពេជ្រ    យើងច្បាស់សំរេចគោលដៅល្អ ។

CHANBOKEO . COM

## ជីកអូរបង្ហៃរទឹក ទុក

វែងទូកខ្លីចរក្នុងអូរ បត់បែនហែហូរតាមដងព្រៃ
ទូកវែងយ៉ាកបត់ចាញ់ទូកខ្លី ចរគេចគ្រោះភ័យមិនទាន់ចិត្ត ។
ចៃដន្យអ្នកថៃវប្តូរឱបាយ ជិះទូកវែងហើយផ្លាស់គំនិត
មិនបត់តាមទឹកទៅវិបរិត ត្បិតអូរឧក្រិដ្ឋហូរធ្លាក់ជ្រោះ ។
សូវជីកប្រឡាយបង្ហៃរផ្លូវ ឱ្យទឹកហូរទៅចាកផុតគ្រោះ
ទូកវែងថៃវបែរហែនាំមនុស្ស សំដៅត្រើយកោះរស់សប្បាយ ។
ទូកវែងជីកបានប្រយោជន៏ច្រើន សាមគ្គីក្រវើនគ្រប់ៗកាយ
មិនព្រមចរបត់តាមអូរឡើយ ស្តាយខ្លាចធ្លាក់ជ្រោះគ្រោះអវិចី ។
ច្នេះកុំអោយទឹកនាំធ្លោយការ ត្រូវប្រើប្រាជ្ញាដោះគ្រោះភ័យ
សាមគ្គីបង្ហៃរទឹកប្រឡាយ ថៃវទូកសប្បាយផុតជ្រោះកម្ម ។

CHANBOKEO . COM

# ឆ្អិនក្រៅឆៅក្នុង

បកចេកយកអាំងបង្ខំភ្លើង　　ក្រហមឆាប់ឡើងបេះយកឆី
ថ្ងៃដន្យចេកឆ្អិនក្រហមខ្ចី　　ឆៅក្នុងតិចអីចត់ពេញមាត់ ។
ចិញ្ចឹមកូនចៅអោយសូត្ររៀន　　ទូន្មានឱ្យបុត្រសូត្រចាំស្ទាត់
ថ្ងៃដន្យកូនចាំបានតែមាត់　　គំនិតបែរភ្លាត់ភ្លេចរៀនន័យ ។
ច្នេះពេលយើងប្រៀនរៀនពន្យល់　　អោយកូនស្គាល់ផលផងសេចក្តី
គំនិតជ្រៅរាក់លាក់អត្ថន័យ　　កុំចាំពាក្យម្តាយត្រឹមមាត់ក្រៅ ។
បើកូនមិនចាំសូត្រមិនបាន　　តែបុត្រគ្រប់ប្រាណយល់ជំរៅ
ប្រសើរជាងឆ្អិនតែខាងក្រៅ　　ក្នុងវិញបែរឆៅខានប្រយោជន៏ ។

CHANBOKEO.COM

**ចិត្តចង្អៀត**

ចិត្តដែលចង្អៀតតៀ្យតចង្អល់ អោយខ្លួនគិតខ្វល់អវិជ្ជមាន
ឱរាតុញ្ញតុះស្អុះរំខាន អ្វី១កល្យាណបែរស្រអាប់ ។
គំនិតចង្អៀតឃ្លាតចំរើន ផលមិនកកើនច្រើនអភព្វ
ត្បិតអាល័យគិតចិត្តមិនគាប់ ចង្អៀតឃ្លាតភព្វរាប់ពិបាក ។
បើកចិត្តទូលាយស្គាយខ្លឹមសារ ទទួលផលាមិនសំរាក
គិតសុទដ្ឋិនាំវៀរចាក ឧបទ្រពពិបាកស្រឡះអស់ ។
ចិត្តល្អទូលាយមានមង្គល ជីវិតនិមលផលសម្រស់
ធ្វើល្អនឹងញាតិមានអនុគ្រោះ យើងរស់ត្រកាលវិសាលអើយ...!

CHANBOKEO . COM

## កល្យាណមិត្តអមតៈ

យប់យន់ទន់កាយអស់កម្លាំង ប្រាសខ្លួនដេកភឹងទៅលើខ្នើយ
និទ្រាស្កប់ស្កល់កង្វល់ស្បើយ បានគុណជាតិខ្នើយខ្នល់កល់កេស ។
ពេលទុក្ខក្នុងខ្លួនពួនយំយែក ខ្នើយលាក់ទឹកភ្នែកមិនមានធ្វេស
ពេលហត់ពេលឈឺធ្លាក់មាត់ស្បែះ បានខ្នើយវិសេសកើយជាគ្នា ។
ពេលសុខកើយខ្នើយស្វែងភិសម័យ ពេលមានព្រួយភ័យកាយរងា
ស្រវាខ្នើយអោបផ្ទាប់ទ័យា ធ្វេចបិទនេត្រាស្វែងមង្គល ។
លុះគេងហេលហាលស្រោលកាយា ដៃលូកស្រវាភួយសោតសល់
ដណ្តប់កក់ក្តៅផុតអំពល់ បានភួយនិមលជាដៃគូ ។
ខ្នើយភួយជាមិត្តដ៏កល្យាណ នាំភាពក្សេមក្សាន្តបរិបូណ៌
ពីកើតដល់ស្លាប់មិត្តផ្តាច់ប្តូរ ភួយខ្នើយមួយគូបំរើលុះយើងក្ស័យ ។

CHANBOKEO.COM

## ដាំស្ពៃឬដាំស្វាយ

ចង់បានផលឆាប់ប្រឹងកាប់ដី ថ្នាលដាំកូនស្ពៃធ្វើអាហារ
ស្រែកទឹកព្រឹកល្ងាចស្រោចចំការ អស់ស្ពៃកាលណាដាំសាថ្មី ។
មួយឆ្នាំកាប់ដីដាំច្រើនដង ស្រែកទឹកស្រោចផងថៃល្ងាចថ្ងៃ
ផលវិញតិចតួចមិនសមថ្លៃ កម្លាំងកាប់ដីស្រែកទឹកស្រោច ។
បើចង់ផលច្រើនក្រវើនដាំ ស្វាយធំផលមាំមានប្រយោជន៍
យូរឆ្នាំចាំបេះពោះផ្សាខ្លោច ១០ឆ្លងរួចផលក្រាស់ក្រៃ ។
ដូចមនុស្សល្ងិតល្ងង់អវិជ្ជា ដាំស្ពៃជាគ្នានឿយរាល់ថ្ងៃ
រីឯបុគ្គលគិតវៀងវៃ មិនដាំទេស្ពៃដាំស្វាយវិញ ។
ស៊ូក្រមួយពេលស្រវារៀន វិជ្ជាថ្កើងថ្កានខ្ពស់ពេញលេញ
រៀនចប់ធ្វើការកើបយកវិញ បៀវត្សរ៍នោះមិញក្រាស់ហោប៉ៅ ។
ឱបុត្រទាំងឡាយគួរពិចារណា ដាំស្ពៃចំការឬបែរទៅ
ដាំស្វាយគួរគាប់បេះផលនៅ ថ្កុំថ្កើងតទៅរាល់ឆ្នាំមិនដែលខាន?

CHANBOKEO.COM

## ប៉ោត

ធុងប៉ោតទទេមិនមានទឹក គោះឮគគ្រឹកខ្ទ័រខ្ទារខ្លាំង
ប៉ោតប្រហោងក្នុងលាន់ក្នុងក្នាំង បញ្ចេញឮកខ្លាំងបង្អើលញាតិ ។
រីប៉ោតទឹកពេញហៀរដល់មាត់ មិនភ្លាត់ក្នុងក្នាំងបំភ្លៃស្មៀត
ស្ងាត់ៗមានទឹកពេញមាត់ប្រៀប បំរើផៅញាតិមិនអួតអាង ។
ដូចមនុស្សអ៊ុងអាត់អាងសំដី ប្រាជ្ញមុខធំក្រៃប្រឹងបំប៉ោង
លាន់ឮខ្ទ័រមេឃក្នុងប្រហោង ដូចប៉ោតក្នុងក្នាំងថាំងអត់ទឹក ។
រីឯអ្នកចេះតម្រេះជា ស្ងៀមមិនអួតក្លាបញ្ចេញឬក
បង្កើនប្រយោជន៍ទាំងល្ងាចព្រឹក ធ្វើការគគ្រឹកមិនឡូឡា ។
ថ្មេះឱមិត្តអើយគប្បីគិត ប្រាជ្ញដោយគំនិតរសសាស្ត្រា
និងប្រាជ្ញសំបកឥតខ្លឹមសារ គួរគិតពិចារណ៍ខ្លឹមអត្ថរស ។

CHANBOKEO.COM

## ចំរៀងខ្មោច

ស្តាប់ចំរៀងខ្មែរផងសព្វថ្ងៃ ក្នុងចិត្តសែនស្តាយជួសខេមរា
ត្បិតអស់តន្ត្រីល្បីពេញផ្សារ សុទ្ធសឹងជាស្នាដៃចម្លង។

ចំរៀងបទថៃទំនុកខ្មែរ អាគាំងចិនដែរប្រែច្រើនហោង
ច្រៀងខ្មែរកាច់តុងស្តាប់ញយដង សំនួនសែនឆ្គងសៀងខេមរា។

តន្ត្រីគ្រប់បទខ្នត់ខ្លីវែង បាត់ឈ្មោះអ្នកតែងសាងកិច្ចការ
រលត់អត្ថរសសូន្យអាសារ ស្តាប់ចប់កាលណាចិន្តាខ្លោច។

ស្តាយមែនព្រោះយើងគិតមិនដល់ បែរខ្វល់នាំគ្នាច្រៀងបទខ្មោច
បាត់នាមម្ចាស់ដើមផ្តើមប្រយោជន៍ អ្នកផងយំសើចយើងលួចគេ។

ថ្ងៃណាទើបយើងគិតភ្ញាក់ខ្លួន ស្វែងក្បួនទំនើបល្អឡើងទ្វេ
តែងតន្ត្រីសព្វស្តាប់សមខ្មែរ មិនលួចមិនកែពីបរទេស។

ខ្វះអ្វីអ្នកតែងឆ្លាតវៀងវៃ និពន្ធតន្ត្រីខ្មែរវិសេស
នាមយើងល្បីឡើងសមតម្រេះ ឱ្យពួកបរទេសខ្មាស់ខ្មែរវិញ។

CHANBOKEO.COM

## អតីតកាល បច្ចុប្បន្នកាល និងអនាគតកាល

អតីតកាលបានកន្លង ក្លាយស្រមោលផងលាយើងទៅ
នៅតែបច្ចុប្បន្នសល់ទុកនៅ អោយយើងត្រាយផ្លូវទៅមុខទៀត ។
ដើម្បីរុងរឿងបែរទៅមុខ កុំឡើយកើតទុក្ខប្រឹងប្រែឆ្លៀត
ងាកក្រោយសារដានឈឺចុកសៀត ឱ្យទ្រូងចង្អៀតលែងសប្បាយ ។
បច្ចុប្បន្នកាលពេលប្រពៃ ច្នេះគួរប្រុសស្រីត្រែកគ្រប់កាយ
សាងខ្លួនអោយមានប្រយោជន៍ក្រៃ ដើម្បីគ្រួសារញាតិបងប្អូន ។
រីអនាគតគឺជាគោល បណ្តុះបណ្តាលល្អសមសួន
ដាំក្តីសង្ឃឹមចំពោះខ្លួន ភ្លឺថ្លាឆពណ្ណ៍រឿងរង្សី ។
ច្នេះពេលវេលាដែលល្អល្អះ បច្ចុប្បន្នច្បាស់ជាបច្ច័យ
ចូរខំសាងខ្លួនអោយប្រពៃ កុំអោយហួសថ្ងៃនាំស្តាយក្រោយ ។

CHANBOKEO.COM

## វែកថ្មឡើងភ្នំ

ប្រព្រឹត្តសុចរិតសាងអំពើល្អ មិនខុសវែកថ្មចរឡើងខ្នងភ្នំ
ធ្ងន់ហើយពិបាកឈឺស្មាក្ដៅងំ ប្រព្រឹត្តឧត្ដមពិបាកសិបដង ។
អាក្រក់ដើរផុងមិនលង់ប្រកែក ធ្វើល្អបែរវែកពុនធ្ងន់កន្លង
ដាំដុះដំណាំបេះផលឆាប់ហោង ដាំសុចរិតផងក្រយើញផលគាប់ ។
ប្រព្រឹត្តអំពើបាបលើអ្នកក្រៅ រៀនលឿនពេកកូវឪមិនបាច់ប្រាប់
តែអំពើល្អទោះម៉ែបង្គាប់ ពិបាកនឹងស្ដាប់សណ្ដាប់លោកប្រៀន ។
បើសិនវែកថ្មចរដល់ខ្នងភ្នំ សង់ផ្ទះភិរម្យស្អាតដូចវិមាន
នៅលើកំពូលខ្ពស់ល្អថ្កើងថ្កាន នោះពិតក្សេមក្សាន្តឋានសួគ៌លោកិយ៍ ។

CHANBOKEO . COM

## តំណក់ទឹក

តំណក់ទឹកស្រក់អាចច្រោះថ្ម          តក់ៗយូរៗពេញបំពង់
ស្រក់ចុះតិចៗអាចលិចលង់          ស្រក់យូរៗគង់ដ៏បូលដាច ។
វិស័យរូបយើងអ្នកទាបខ្សោយ          រូបតូចតែមួយគង់សំរេច
បើប្រឹងតក់ៗយ៉ាងប្តូរផ្តាច់          ថ្ងៃមួយសំរេចការងារធំ ។
ពង្វាតអនាគតដោយប្រាជ្ញា          ស្មារតីហានក្លាថ្លាឧត្តម
សីលធមិតម្រេះជាគោលមុំ          ពង្រីកទីធំថ្កើងកល្យាណ ។
កុំឡើយលះបង់ចិត្តតស៊ូ          តក់ៗយូរៗគង់នឹងថ្កាន
ចេះតូចធ្វើតិចគ្រាន់ជាងខាន          យូរប្រមូលបានបំពង់ពេញ ។

CHANBOKEO . COM

## ចៃ

ចៃរស់លើក្បាលណាមិនស្អាត ម្ចាស់ភ្លេចសង្វាតថែទាំសក់
ចៃពិតរំភើបក្បាលកខ្វក់ អង្គែរុំសក់រស់សប្បាយ ។
ចៃខាំសាច់ក្បាលបឺតយកឈាម ជំទើតអង្កៀមឥតជិនណាយ
បើម្ចាស់រិតខ្ជិលចៃរីករាយ ម្ចាស់រិតរាយមាយចៃឡើងបុណ្យ ។
ក្នុងការិយាល័យក្នុងសង្គម ហ្វូងចៃលួចឃ្លាំពេលម្ចាស់ស៊ុន
ឃើញម្ចាស់ខ្ជីខ្ជាចៃរួសរាន់ ចេញមុខខាំលាន់អង្កៀមលាភ ។
ច្នេះឱខ្មែរអើយកុំភ្លេចខ្លួន ហ្វូងចៃជ្រកពួនក្បាលតម្រៀប
ចូរសំអាតក្អែលមានរបៀប ប្រយត្ន័ចៃកៀបអង្កៀមឈាមខ្មែរ..!

CHANBOKEO.COM

## ដៃឆ្វេងចាំដៃស្តាំលូក

ដៃឆ្វេងទំនេរស៊ូនៅចាំ ធ្វើឫកជាទ្រាំមិនកាយចូក
តែដៃស្តាំវិញកកាយលូក ក្តោបក្តាប់ចាប់ចូកមិនទំនេរ ។
ដូចកូនធ្វើល្អចំពោះមុខ អ្នកម្តាយឪពុកហាក់ពូកែ
ក្រោយខ្នងលួចព្រើលមាយាទប្រែ មិនអោយពុកម៉ែដឹងពុតត្បុត ។
ដូចអ្នកធ្វើការមិនស្មោះត្រង់ មុខចៅហ្វាយអង្គធ្វើបរិសុទ្ធ
មេកោយទៅបាត់ចាប់មិនភ្លាត់ លួចកេងសម្បត្តិដាក់ហៅប៉ៅ ។
ដូចជាបុគ្គលបំរើជាតិ ដៃមួយមាយាទហាក់ត្រឹមត្រូវ
មួយទៀតលួចច្បាមគ្មានសល់នៅ ចូកដាក់ហោប៉ៅធ្វើមិនដឹង ។
ពាក្យចាស់លោកផ្តាំចំណាំទុក លាក់អាថិសព្វមុខគ្រប់ជ្រោយជ្រុង
វិភាគមានន័យជ្រៅដល់ម្លឹង ប្រាប់កូនចៅដឹងចៀសឧក្រិដ្ឋ ។

CHANBOKEO.COM

## ក្បួនសម្លាប់ខ្មែរដោយចំហ

ក្បួនសម្លាប់ខ្មែរសែនត្រជាក់ មានច្រើនពុំលាក់ពាសរដ្ឋា
សេពយ៉ាងសេរីមានបៀវស្រា បារីហ៊ឺហាផឹកស៊ីជក់ ។
តាមសណ្ឋាគារមានម៉ាស្សា ស្រីពាក់លេខត្រាក្នុងកញ្ចក់
អង្គុយចាំភ្ញៀវជាវញ្ញីញ្ញក់ ពិភពលង់ភក់ថ្លុកអេដស៍រាយ ។
នៅក្រៅរបងកៀនសាលា ហាងហ្គេមត្រៀបត្រាដាក់ក្ដារប៉ាយ
ក្មេងវេះថ្នាក់រៀនចូលប្រញ្ញាយ ភ្នាល់លុយភ្លេចបាយភ្លេចសិក្សា ។
នៅវាលនេសាទផលិតត្រី ម្សៅគីមីថ្មីលាយសព្វសារ
ប្រលាក់សាច់ត្រីមុនចូលផ្សារ ដើម្បីការពាររុយតាមរោម ។
នៅរោងបិទស្រាមិនខុសគ្នា ជាតិម្សៅអង់ឱ្រីនចាក់ប្រលោម
លាយនឹងជាតិស្រាច្រកដបព្រម មនុស្សរត់ចោមផឹកផ្អើលស្រុក ។
នៅមានវិធីច្រើនថែមទៀត កវីសុំឆ្លៀតរាប់ប្រាំមុខ
ជូនលោកពិចារណ៍គិតអែអុក ក្បួនទាំងប្រាំមុខយ៉ាងណាដែរ?

*អ្នកស្រីកែវចន្ទ័បូរណ៍*
*អ្នកនិពន្ធ*

CHANBOKEO.COM

# វគ្គទី១
# និស្ស័យ

ផ្សារក្រោម ក្រុងបាត់ដំបង ឆ្នាំ១៨៦៣...

ស្ត្រីក្មេងមួយរូបដឹកដៃកុមារាអាយុប្រមាណបួនឆ្នាំ ដើរចេញពី ហាងលក់ថ្នាំ រួចក៏ចូលទិញក្រូចនៅតូបលក់ផ្លែឈើមួយ ដែលមាន តាំងផ្លែឈើប្លែកៗជាច្រើនមុខ ឃើញហើយគួរឲ្យស្រក់ទឹកមាត់ ចង់ឆីណាស់ ។ រំពេចនោះ ស្រាប់តែកុមារតូចធ្វើអោយជ្រុះផ្លែក្រូច មួយពីកញ្ច្រែង រមៀលធ្លាក់តុកៗចេញទៅ ។ កុមារតូចក៏ស្ទុះរត់ តាមត្រុយទៅរកចាប់ ដោយមិនបានចាប់ភ្លឹកមើលមុខមើលក្រោយ តាមចរិតក្មេងតូចវ័យរបស់គេ ។ ភ្លាមនោះ គេក៏រត់ទៅបុកជើង បុរសម្នាក់ ដែលទើបតែដើរចេញពីហាងថតរូបក្បែរនោះ ដួល ច្រងាប់ច្រងិល ។ កាលបើក្រលេកមកឃើញក្មេងដួលក្បែរជើង គេក៏ឱនចុះជួយចាប់លើកកុមារឡើង ហើយវាចាថា :

- ក្មួយប្រុសមានត្រូវត្រង់ណាទេ ?

តែក្មេងមិនឆ្លើយទេ ។ គេគ្រាន់តែសម្លឹងមុខបុរសរួចលូកដៃ ទទួលយកក្រូចពីបុរសនោះហើយក៏រត់ត្រលប់ទៅរកម្ដាយគេវិញ ។ បុរសនោះក៏ងើបឈរឡើងបែរមើលតាម ក៏ប្រទះនឹងម្ដាយរបស់ កុមារដែលរត់មកទទួលកូនយកទៅវិញ ។ ស្រាប់តែគេឧទានថា :

- ស្បៃរឿង ?

ពេលមាណវីក្រលេកឃើញបុរសសង្ហារបស់យើងពេលណា ឆវី ក៏ឈរធ្វើភាំង រួចហើយក៏អូសដៃកុមារដើរចេញទៅដោយមិនស្រដី អ្វីជាមួយនឹងបុរសមួយរូបនោះឡើយ ទុកបណ្ដោយអោយគេសម្លឹង មើលធិតាយ៉ាងភ្លឹកពីក្រោយ ដោយកិរិយាភ្ញាក់ផ្អើលរហូតដល់នាង ឡើងរ៉ឺម៉ក់ទៅបាត់ ។ បន្តិចមក គេក៏ឡើងជិះសូឡិចខ្មៅរបស់គេ ត្រលប់ទៅផ្ទះវិញ ។

CHANBOKEO.COM

បន្តិចក្រោយមក គេក៏បានមកដល់លំនៅឈើ ប្រក់ក្បឿងមួយខ្នងនៅភូមិផាស៊ីស្រាជិតផ្សារលើ ។ នារីសោភាមួយ រូបចុះដណ្តើរផ្ទះរត់មកទទួលទាំងទឹកមុខរីករាយ :

- បងភក្តី! ថ្ងៃនេះឆាប់ត្រលប់មកផ្ទះម្ល៉េះ ? មិនធ្វើការទេហ៍ ថ្ងៃ នេះបង ?

មាណពគ្រវីក្បាលមិនស្រដីទេ ។ គេដាក់ចតស្កូឡិចនៅក្រោម ដើមទឹកដោះគោមុខផ្ទះ ហើយដើរឡើងចូលទៅក្នុងបន្ទប់គេងធ្វើ កិរិយាស្ងៀមស្ងាត់ ។

ធិតាមួយរូបនោះឃើញដូច្នោះនឹកឆ្ងល់ណាស់ ក៏ដើរចូលមកតាម ហើយយកដៃស្ទាបថ្ងាសរបស់នាយ សួរថា :

- មិនស្រួលខ្លួនហ្អេស ? ត្រូវការថ្នាំអីទេ ? ចាំខ្ញុំទៅយកមកឲ្យ!
- មិនបាច់ទេណារី! បងគ្រាន់តែធឹងឆោងបន្តិចបន្តួច សំរាកបន្តិច ទៅ អស់អីហើយ ។ អូនមានអីធ្វើ ក៏ទៅធ្វើចុះ ។ បងសុំឆ្មេចមួយ សន្ទុះសិន ។

ណារីបែរមើលបុរសជាចុងក្រោយ ហើយក៏ទាញទ្វារឆ្ទុបមុននឹង ចាកចេញទៅ ។

នៅលើគ្រែភក្តីយកដៃគងថ្ងាស ដកដង្ហើមធំៗតែម្នាក់ឯង... ឱ តើគេកំពុងគិតអំពីអ្វីទៅ ? ពីរឿងស្រីក្មេងនឹកដៃកុមារតូចកាលពី ព្រឹកមិញនេះមែនទេ? មួយស្របក់ក្រោយមក គេក៏ស្ទុះរឹងសំដៅ ទៅជួបបុរសសង្ហាម្នាក់ ដែលកំពុងធ្វើការនៅមន្ទីពេទ្យឯកជនមួយ នៅផ្លូវលេខមួយជិតផ្សារ ។

- មានការអ្វីហ្នឹង ភក្តី បានដូចជាអន្ទះសាដូចមាន់រកពង ? នេះ ប្អូនមិនធ្វើការទេថ្ងៃនេះ ?
- បងវិចិត្រដឹងទេ ថាខ្ញុំបានប្រទះឃើញអូនស្បៃរឿងរបស់ខ្ញុំកាល ពីព្រឹកមិញនេះ ?
- អូហ៍ ? មែនហ្អេស ? នៅឯណា ?
- នៅផ្សារក្រោម មុខហាងថតរូប ពេលខ្ញុំយករូបថតទៅផ្តិតធ្វើ កាត ។
- ហើយស្បៃរឿងហ្នឹង មានសារៈសំខាន់ចំពោះប្អូនយ៉ាងណាទៅ បានជាឯងកន្ទុះរា នៅមិនសុខយ៉ាងនេះ ?
- ជាស្នេហាទីមួយណ៎ាបង តើអោយភ្លេចម្តេចបានទៅ ?
- ស្នេហាទីមួយ ទីពីរ ទីបីស្អី... ? បងឃើញឯងផ្លាស់សង្សារដូច ដូរម៉ូដអាវយ៉ាងនេះ បងមិនដឹងថាមួយណាសំខាន់សំរាប់ឯងទេ ។
- តែមួយនេះ ជិតជាប់អារម្មណ៍របស់ខ្ញុំជាងគេបំផុតហើយ ។
- ហើយបើឯងស្រលាញ់គេម្លឹងៗ ម៉្ញៗ ឃើញតែស្បៃរឿងអញ្ចេះ ស្បៃរឿងអញ្ចុះ ម៉េចក៏ឯងបណ្តោយអោយគេរបូតពីដៃបាន ?

CHANBOKEO.COM

- មកពីកាលនោះខ្ញុំនៅក្មេងហើយឆោតឆាវ... ចៃដន្យ...
- ចៃដន្យ យ៉ាងម៉េច ? គេគេចខ្លួនទៅរៀបការចោលឯងហ្នឹស ?
- ម៉េចក៏បងដឹង ?
- គឺទឹកមុខឯងហ្នឹងវាប្រាប់បង...!
- បងវិចិត្រឆ្លាតណាស់ ។ អញ្ចឹងហើយ បានជាខ្ញុំចូលចិត្តពិគ្រោះ
អ្វីៗជាមួយបង ក្រែងលោបងជួយខ្ញុំដោះស្រាយចេញ ។
- ដោះយ៉ាងម៉េចចេញ បើឯងមានណារីហើយ...
- គ្រាន់តែជាសង្សារបណ្ដោះអាសន្នតើហ៎!
- ហើយចុះ ស្បៃរឿងវិញ គេនៅទំនេរទេហ៎ ?

ឮប្រយោគនេះ ភក្ដីទម្លាក់ទឹកមុខ ។ មែនហើយ! គេមិនបាន
ជជែកនឹងស្បៃរឿងមួយម៉ាត់សោះ ធ្វើម៉េចគេនឹងដឹងថា នាងទំនេរ ឬក៏យ៉ាងណា ?
ពេលនេះសូម្បីតែនាងនៅឯណាក៏នាយមិនដឹងផង
តើធ្វើម៉េចនឹងដោះស្រាយបញ្ហាបេះដូងរបស់នាយចេញ ?

ភ្លាមនោះ វិចិត្រក៏វាចាថា :
- ភក្ដី! ល្មមចាស់ទុំហើយណ៎ាប្អូន! នេះឯងអាយុ២៥ឆ្នាំហើយមិន មែនក្មេងទៀតទេ
ហើយថែមទាំងមានវិជ្ជាខ្ពង់ខ្ពស់ផង ។ នេះបើ ឯងឈប់មានបេះដូងរាយមាយ
ប្រហែលជាជីវិតរបស់ឯងភ្លឺថ្លាជាង នេះមិនខាន មិនហ្មូហ្មងដូចពេលនេះទេ ។
- មកពីខ្ញុំខូចចិត្តនោះអីបង! តុកសុិកពេក ដែលស្បៃរឿងគេចាក ចេញពីជីវិតខ្ញុំទៅ
ទើបបានជាខ្ញុំផ្ដេសផ្ដាសអញ្ចឹង! បើសិនជាខ្ញុំ មានរូបនាងនៅជិត
ម្ល៉េះសមខ្ញុំឈប់ខិលខូចហើយ ។
- ឯងនិយាយផុយៗយ៉ាងនេះ នរណាគេជឿទៅភក្ដី ? បងឃើញ ឯងប្ដូច្រើនដងដាក់បងណាស់
សុទ្ធតែនារីដែលបេះដូងឯងត្រូវការ មិនបានពីរខែក៏បាត់រូប...
ហើយតាំងពីឯងចេញពីសាលាមកធ្វើការ ប៉ុន្មានឆ្នាំនេះ ឯងមានសង្សារប្លែកៗច្រើនណាស់
រហូតដល់បង ចំណាំលែងបានថាមួយណាពិតប្រាកដឡើយ ។
- តែខ្ញុំហ៊ានសន្យាថា ស្បៃរឿងជានារីតែម្នាក់គត់ដែលខ្ញុំត្រូវការ! បើសិនខ្ញុំមានរូបនាងជាគូជីវិត
ខ្ញុំសច្ចាថាខ្ញុំឈប់រវីរវល់នឹងនារីណា
ទាំងអស់ក្នុងលោកនេះ ។

CHANBOKEO.COM

- ស្លាប់ហើយ! នាងស្បែរឿងមានសារៈសំខាន់ចំពោះជីវិតរបស់ ប្អូនដល់ម្លឹងមែនហ្អេស?
- មែនណា៎បង! ខ្ញុំសូមស្បថ!
- អឺ! បងឮហើយ! ប៉ុន្តែកាលដែលឯងមកអង្គុយប្រូម៉ាព្រឹកដាក់ បងនេះត្រូវការអីដែរ?
- គឺ...ចង់សុំខ្ចីឡានបងប្រើបន្តិច...
- យកធ្វើអី?
- តាមរកស្បែរឿង...
- ពុទ្ធោ! មិនឲ្យទេ! យកឡានតាមរកស្រី គ្មានស្អីក្រៅពីវាយឬក សង្ហាបង្អួតគេថាឯងគ្រាន់នោះឡើយ ។
- បើបងដឹងហើយ ម៉េចក៏ចាំជាន់កែងប្អូនអញ្ចឹង?
- ព្រោះបងឃើញឯងគិតខុស! នែ៎! ស្នេហាពិតប្រាកដ គេមិន សម្លឹងឯងនឹងឡាន នឹងទ្រព្យរបស់ឯងទេ ព្រោះថាបើគេដកឥវ៉ាន់ អស់នោះចេញ ឯងជាមនុស្សមានតែសំបកប៉ុណ្ណោះ ។ យកល្អ ទុក ឲ្យនារីមើលឯងដោយតម្លៃពិតវិញ នោះទើបស្នេហាវាគង់វង្ស ។
- ពូកែទ្រឹស្តីអញ្ចឹង ម៉េចក៏មិនឃើញរកមួយបានទៅ បងវិចិត្រ? ចាស់ជាងខ្ញុំដល់ទៅពីរឆ្នាំ តែរកមួយផ្សំផ្គុំជាសង្សារបណ្តើរនឹងគេ ម្នាក់មិនបានសោះ... គឺមានតែគេរត់ចោល តែគ្មាននរណារត់ចូល បងឡើយ ។ ចំពោះខ្ញុំវិញ ហោចណាស់ក៏មិនកណ្តោចកណ្តែង ដូច រូបបងនោះដែរ ។

ដល់ឮភាសាបញ្ជើបញ្ជើរបស់ភក្តី វិចិត្រនឹកអន់ចិត្តព្រួច :

- នែ៎ និយាយបែបនេះ គឺអត់ឡានជិះរហូតហើយ ។ ហើយថ្ងៃនេះ ឯងជិះស៊ូឡិចកញ្ជាស់របស់ឯងទៀតទៅ ។ រឿងខ្ចីឡានវិញទុកជា មោឃៈទៅចុះណា៎ ។

ថាហើយលោកគ្រូពេទ្យវិចិត្រក៏ដើរចេញទៅ ទុកអោយភក្តីនៅ អង្គុយធ្វើមុខស្មើដូចអន់ចង់ ។

ការពិតអ្នកទាំងពីរជាបងប្អូនបង្កើតនឹងគ្នា ។ ឪពុកម្តាយរបស់ គេបានចែកស្ថានទៅជាបន្តបន្ទាប់ កាលពីប្រាំមួយឆ្នាំមុន ។ រីឯ ទ្រព្យធនមរតកទាំងឡាយក៏ត្រូវបែងចែកជាពីរចំណែកស្មើគ្នាអោយ ទៅគេម្នាក់ៗតាមពិន័យកម្មដែលឪពុកម្តាយបានចារទុក ។ ចៃដន្យ ភក្តីជាមនុស្សរាយមាយដើរលេងចាយវាយមិនដឹងមុខ.. របស់ទ្រព្យ

CHANBOKEO.COM

ដែលជាចំណែករបស់ភក្តីក៏ត្រូវរលាយបាត់បង់អស់ នៅសល់តែ
សូឡិចកញ្ចាស់មួយនិងផ្ទះក្បឿងមួយខ្នងប៉ុណ្ណោះ ។ គេទើបតែរត់ រកការធ្វើថ្មីៗនេះឯង
ក្រោយពេលដឹងខ្លួនថាខ្វះខាតហើយបានចូល ធ្វើការនៅស្ថានីយ៍រថភ្លើងកម្ពុជា ។

វីឯវិចិត្រវិញជាមនុស្សគត់មត់ មិនចេះចាយវាយមិនដើរលេង ទេ
ចេះត្រឹមតែធ្វើការសន្សំលុយទុក ពេលទំនេរអានសៀវភៅ អានកាសែត
អស់ច្រើនត្រឹមទៅអង្គុយសំកុកនៅសួនយុវន័ ឬសួន នាគបាញ់ទឹកនៅមុខឃោសនាការ
ឬក៏ទៅដើរលេងនៅសួនកុមារ មើលក្មេងរត់លេង រួចហើយក៏ត្រលប់មកផ្ទះវិញ ។ គេមិនចេះ
ដើរលេងទៅណាទេ ។ ទីណាក៏ប្រកបដោយភាពអផ្សុកជានិច្ចដែរ
វៀរលែងតែសៀវភៅចេញដែលគេចូលចិត្តអានជាប្រចាំ ។ សព្វ ថ្ងៃនេះ
គេជាវេជ្ជបណ្ឌិតម្នាក់នៅពេទ្យធំ ក្រុងបាត់ដំបង ហើយមាន បើកគ្លីនិកឯកជននៅផ្លូវលេខមួយ
គ្រាន់នឹងកំដរពេលកុំឲ្យទំនេរ ។ ហេតុអ្វីទៅហ្ន៎ដែលគេនៅលីវយូរម្ល៉េះ
មិនឃើញមានដៃគូអ្វីនឹងគេ សោះ ? ឬមួយគេធ្លាប់មានរបួសស្លាកស្នាមផ្លូវចិត្តពីមុនមក ទើប
គេបែររាងចាលនឹងស្នេហា ? ឬក៏ព្រោះតែហេតុហ្នឹងទេដឹង ដែល គេក្លាយខ្លួនទៅជាបុរសម្នាក់
ដែលរស់នៅយ៉ាងត្រមង់ត្រមោច បែបនេះ ?

ដោយហេតុថាគេមាននិស្ស័យមិនដូចគ្នា  អ្នកទាំងពីរមិនដែល
រស់នៅជាមួយគ្នាទេ តាំងពីឪពុកម្ដាយធ្វើមរណកាលទៅ ។ ថ្វីបើ វិចិត្រប្រឹងជួយផ្គត់ផ្គង់ប្អូនប្រុស
តាមលក្ខណៈជាបងប្រុសក៏ដោយ ក៏ការជួយរបស់គេ ចំពោះប្អូនមានកំរិតជានិច្ច
ទីមួយដោយហេតុថា ពេលវេលាជាមាសប្រាក់ ។ គេមិនព្រមចំណាយពេលសំរាប់រឿង
ឥតប្រយោជន៍ទេ ។ ទីពីរ គេជាមនុស្សម៉ឺងម៉ាត់ ធ្វើអ្វីត្រូវតែមាន
ប្រសិទ្ធភាពហើយប្រកបដោយលទ្ធផលល្អ ទើបគេធ្វើ ។ កាលបើ
ឃើញប្អូនប្រុសមានមារយាទខ្ជិលច្រអូស ជាពិសេសចំពោះនារី គេមិនសូវ
លូកដៃរវីរវល់នឹងរឿងរ៉ាវរបស់ប្អូនទេ យ៉ាងច្រើនត្រឹមអោយឡាន ប្អូនខ្ចីប្រើម្ដងម្កាល ។ ការពិត
ឡានដែលគេទិញសំរាប់ប្រើនោះ មិនជាឡូយឆាយប៉ុន្មានទេ គឺជាម៉ាកវ៉ុលវ៉ាហ្គិនពណ៌ស
រាងដូចស្នូក អណ្ដើកដ៏ចំណាស់មួយតែប៉ុណ្ណោះ ។

ព្រឹកនេះ កាលបើត្រូវប្អូនប្រុសសៀតមួយផ្លែ គេខ្នក់ចិត្តណាស់ តែគេមិនចេញស្ដីអ្វីទេ
ព្រោះគេជាមនុស្សកំណាញ់ កំណាញ់សូម្បី តែពាក្យនិយាយ ។ បើនិយាយត្រូវមានសាច់ការ
បើគ្មានសាច់ការ គេមិនខ្ជីនិយាយឡើយ ។ ភ្លាមនោះ គេក៏បររថយន្តមកដល់ពេទ្យ ធំ ។ តាមពិត

CHANBOKEO.COM

ថ្ងៃនេះជាថ្ងៃអាទិត្យ គេមិនត្រូវមកធ្វើការទេ ប៉ុន្តែ ដល់ត្រូវប្អូនប្រុសសិកម៉ាផ្លែ គេធុញថប់ក្នុងចិត្តពេកមិនដឹងទៅណា ក៏ បើកឡានចូលកន្លែងធ្វើការទៅ ។ ភ្លាមនោះ អ្នកគ្រូពេទ្យម៉ារ៉ាត់ ដែលត្រូវមានវេនយាមថ្ងៃនេះ ក៏ចេញមកទទួលហើយឧទានថា :

- អរគុណលោកវិចិត្រណាស់ ដែលឆៀងចូលមកមើលពេទ្យ ។ ពេលនេះ ខ្ញុំកំពុងត្រូវការជំនួយជាបន្ទាន់ ត្បិតមានអ្នកជំងឺថ្មីមក ដល់កាលពីអាធ្រាតមិញ ឃើញធ្ងន់ខ្លាំងហើយ មិនដឹងថាអាចជួយ សង្គ្រោះបានឬក៏យ៉ាងណាទេ ។ សូមលោកវេជ្ជបណ្ឌិតមេត្តាជួយទៅ មើលគេផង ។

    វិចិត្រមិនប្រកែកទេ ទោះយ៉ាងណា ក៏គេនៅមានសន្តានចិត្ត ជានិច្ច ចំពោះអ្នកជំងឺទាំងឡាយដែលមកមន្ទីរពេទ្យរង់ចាំទទួលការ ព្យាបាលពីរូបគេ ។

    នៅក្នុងបន្ទប់វះកាត់ បុរសម្នាក់កំពុងគេងស្តូកស្តឹងព្យួរសេរ៉ូម ដកដង្ហើមផុតផើយៗ ។ វិចិត្រសួរអ្នកគ្រូម៉ារ៉ាត់ថា :

- គេមានជំងឺអី ?

- គឺជាជាងផ្ទះ ត្រូវទទួលគ្រោះថ្នាក់ពេលកំពុងធ្វើការ ទើបតែដឹក មកពីសេរីសោភ័ណ ។

    វិចិត្រព្រមជាមួយគ្រូពេទ្យពីរនាក់ទៀតក៏ចូលបន្ទប់អាសន្នជួយ បុរសនោះភ្លាម ។ គ្រាន់តែក្រលេកឃើញវិចិត្រនាំគ្រូពេទ្យពីរនាក់ ទៀតចូលមកដល់ ស្រាប់តែបុរសអ្នកជំងឺនោះលូកស្រវាចាប់ដៃ វិចិត្រជាប់ហើយ ស្រដីខ្សិបខ្សាវៗ ដង្ហក់ៗ ថា :

- ខ្ញុំសូមផ្ញើ... ប្រពន្ធកូន... នឹងលោកគ្រូ...ពេទ្យ..ផង....

    ថាតែប៉ុននេះ បុរសនោះក៏ដាច់ដង្ហើមទៅ មុននឹងពេទ្យអាចធ្វើ ការសង្គ្រោះបាន ។ វិចិត្រលាតដៃមើល ឃើញខ្សែកវេញដោយ អំបោះក្រហម មានបន្តោងថៃកាច់ឆ្លាក់ជារូបផ្កាចំប៉ាឈ្មោលរលោង មួយ ។ គេគ្រវីក្បាលសោកស្តាយដែលគេមកមិនទាន់ពេល មិន អាចជួយសង្គ្រោះជីវិតបុរសនោះទាន់ពេលវេលាបាន ។

    មួយស្របក់ក្រោយមក គេក៏ដើរចេញមកវិញទាំងសោកសៅ រួចហើយស្រដីសួរទៅភ្ញៀវ ដែលកំពុងអង្គុយក្នុងបន្ទប់រង់ចាំជា ច្រើននាក់នោះថា :

- អត់ទោស តើនរណាមួយទៅជាសាច់ញាតិរបស់អ្នកជំងឺ ដែល ទើបដឹកមកពីសេរីសោភណ័ដែរពីព្រឹកមិញ ?

CHANBOKEO.COM

នារីសោភាមួយរូបងើបឈរឡើង ៖
- គឺនាងខ្ញុំ ចាស! នាងខ្ញុំជាភរិយារបស់គាត់ ។

ពុទ្ធោអើយ! ធិតាមានរូបសោភណ៍ស្រស់ត្រកាលណាស់ ថ្វីបើនាងមានទឹកមុខប្រកបដោយទុក្ខព្រួយយ៉ាងធំធេងក៏ដោយ ។ គ្រាន់តែវិចិត្រក្រលេកឃើញភក្ត្រនាងភ្លាម គេឈរធ្មើរាំងមួយស្របក់ដោយក្តីព្រឺព្រួចរំភើបញាប់ញ័រនៅក្នុងចិត្ត ហើយលួចលេបទឹកមាត់ ផ្សើមបំពង់ក... រំងាប់ភាពពុះកញ្ជ្រោលនៅក្នុងបេះដូង រួចហើយ ទើបមាណពស្រដីយ៉ាងស្រទន់ទៅរកធិតាថា ៖
- ខ្ញុំសោកស្តាយណាស់ ដោយមិនអាចជួយសង្គ្រោះគេបាន ។ អ្នកជំងឺបានអស់បុណ្យទៅហើយ ។

ស្រាប់តែនាងបើកភ្នែកធំៗដោយក្តីរន្ធត់ញាប់ញ័រ ៖
- ពុទ្ធោ!.... បង....

រួចស្រាប់តែនាងរលំដួលប្រួសទៅលើកំរាលឥដ្ឋបាត់ស្មារតីឈឹង តែម្តង ។ លោកដុកទ័រកម្លោះភ្ញាក់ព្រើតកាលបើឃើញដូច្នោះ គេក៏ ស្ទុះឱនចុះលូកដៃត្រកងនាងជាប្រញាប់ហើយបីនាងឡើងរត់សំដៅ ទៅគ្រែទំនេរមួយក្នុងបន្ទប់ក្បែរនោះ បន្ទាប់មកក៏ប្រញិបប្រញាប់ ចេញទៅយកម៉ាស៊ីនអុកស៊ីសែនមកជួយដង្ហើមរបស់នាងភ្លាម ។

មួយស្របក់ធំទៅហើយ នាងនៅតែមិនទាន់ដឹងខ្លួនមកវិញនៅ ឡើយ ។ វិចិត្រលួចឈរគយគន់សោភណ៍នារីយ៉ាងរន្ធត់ញាប់ញ័រ ក្នុងចិត្ត ។ មែនហើយ! ថ្វីបើនាងមានទឹកមុខស្លេកស្លាំង ហាក់ដូចជាមិនបានទទួលដំណេកមិនបានបរិភោគបាយយូរថ្ងៃហើយក៏ដោយ ក៏សម្ផស្សរបស់នារីនៅតែអណ្តែតលេចធ្លោយ៉ាងត្រកាលនៅចំពោះ មុខរបស់កម្លោះយើង ។ នេះជាលើកទីមួយហើយ ដែលបេះដូងដ៏ក្រៀមស្វិតរបស់គេបានទទួលចរន្តឈាមថ្មីមួយយ៉ាងក្តៅជ្រួលច្រាល ចម្លែកបំផុត ។ គេមិនយល់ទេ ថាហេតុអ្វីបានជាគេបែរជាមកចាប់អារម្មណ៍នារីចម្លែកមួយរូបដែលជាភរិយារបស់អ្នកជំងឺទៅវិញ...

រំពេចនោះ មាណវីក៏កំរើកខ្លួនឡើង ហៅខ្សិបៗ ៖
- បងខ្លា...!

វិចិត្រស្ទុះទៅជិតនាងហើយស្រដីសួរថា ៖

- អ្នកនាង...បានគ្រាន់បើខ្លះទេ ?

ស្រាប់តែនាងក្រោកអង្គុយហើយបើកភ្នែកសួរវិញថា :

- លោកនឹងទេ... ពេលនេះបងខ្ញុំគាត់នៅបន្ទប់ណា ?

វិចិត្រកាត់យល់ភ្លាមថានាងកំពុងសួររកស្វាមីរបស់នាង ។ ធិតាក៏ស្ទុះដើបទាំងទ្រេតទ្រោតដើរចេញពីបន្ទប់ ហើយស្រដីថា :

- សូមជួយនាំនាងខ្ញុំទៅរកគាត់ផង !

វិចិត្រយកដៃត្រកងស្មាជួយទប់ធិតាដែលប្រឹងដើរទាំងធីងធោងសំដៅទៅរករូបកាយស្តូកស្តឹងមួយដណ្តប់ ដោយសំពត់សនៅបន្ទប់ ជាប់នោះ ។ ស្នូរសម្លេងខ្សឹកខ្សួលរបស់មាណវីក៏បន្លឺយ៉ាងរន្ធត់ឡើង ធ្វើអោយបេះដូងរបស់ពេទ្យកម្លោះទទួលឥទ្ធិពលដ៏ចម្លែកមួយ ។ គេធ្លាប់ធ្វើការទីនេះចំនួនជាង៥ឆ្នាំហើយ អ្នកជំងឺធុនណាក៏គេធ្លាប់ប្រទះ អ្នកជំងឺដែលឆ្លងមិនរួចមរណកាលក៏ធ្លាប់ជួបប្រទះ ប៉ុន្តែ ហេតុអ្វីពេលនេះគេរំជួលចិត្តចម្លែកម៉្លេះ កាលបើគេបានឃើញទឹក ភ្នែកសោកសៅរបស់កល្យាណីមួយរូបនោះដែលគេមិនទាំងស្គាល់ ថានាងជានរណាផង... គេមានអារម្មណ៍ថាបេះដូងរបស់គេក៏កំពុងតែញាប់ញ័រក្នុងឱរា ហាក់ដូចជានឹកចង់ស្រក់ទឹកភ្នែកតាមធិតាម្តងៗ ទៅហើយ...

កំពុងតែឈរគិតភ្លេចខ្លួនយន់អារម្មណ៍នឹងការអាណិតស្រណោះ ធវីសោភាស្រាប់តែមានមនុស្សម្នាក់ជិះវ៉េសប៉ាមកដល់មុខពេទ្យ :

- សូមទោសលោកវិចិត្រ ! ឆាប់ទៅមើលភក្តីផង គេកំពុងមានរឿងរ៉ាវបន្តិចបន្តួច ត្រូវការជំនួយអន្តរាគមន៍ឥលូវនេះ ។

ឮដំណឹងដូច្នោះ វិចិត្រក៏ដោះអាវផាយពេទ្យចេញពីខ្លួន រួចស្ទុះយ៉ាងលឿនបើកឡានចេញទៅតាមក្រោយបុរសនោះ ។ មកដល់មុខផ្ទះក្បឿងខ្ពស់ផុតពីដីនៅភូមិផាស៊ីស្រោ ក៏ប្រទះឃើញភក្តីអង្គុយសំកុកនៅលើក្តារជើងក្រោមផ្ទះធ្វើមុខជូរដូចស្វាជាប់ជុច ដោយមានមនុស្សចាស់ពីរនាក់ទំនងជាអ្នកជិតខាង នៅអង្គុយក្បែរផង ។

- ជំរាបសួរបាទ !

មាណពលើកដៃសំពះសួរបុរសចំណាស់ពីរនាក់នោះដែលជាអ្នក ជិតខាងរួចហើយក៏បែរមករកប្អូនប្រុស សួរថា :

- មានរឿងអ្វីហ្នឹង ភក្តី ?

CHANBOKEO.COM

តែមាណពមិនឆ្លើយទេ ។ គេយកដៃឈ្លីសក់ហើយឈ្ងោកមុខ ចុះ ។ ស្រាប់តែស្ត្រីចំណាស់មួយរូបដើរចុះពីលើផ្ទះមក ស្រដីថា :

- បើលោកចង់ដឹង ឡើងទៅមើលនៅខាងលើទៅ!

វិចិត្របែរមើលមុខប្អូនប្រុសម្តងទៀត ហើយក៏ឡើងទៅលើផ្ទះ តាមសំដីស្ត្រីចំណាស់ ។ នៅទីនោះ គេប្រទះនារីមួយរូបដែលមាន របួសបែកឈាមពេញមុខព្រមទាំងមានស្នាមជាំលើដៃទាំងសងខាង ទៀតផង :

- មានរឿងអ្វីហ្នឹង ណារី ? ប្រាប់បងបានទេ ?

ណារីឈ្ងោកមុខមិនហ៊ានឆ្លើយទេ ។ វិចិត្រក៏កាត់យល់ភ្លាមថា មានរឿងអ្វីកើតឡើង :

- របួសទាំងនេះ...គឺជាស្នាដៃរបស់ភក្តីមែនទេ ?

ណារីនៅស្ងៀមហើយយំសសឹកឡើងជាថ្មី ។ មីងចំណាស់នោះ ក៏ឆ្លើយជំនួសឡើង :

- គ្រោះជាហើយដែលពួកយើងជិតខាងបានឮមកជួយទាន់ កុំអីមិន ដឹងជាយ៉ាងណាទៅហើយទេ ។ លោកជួយមើលប្អូនប្រុសរបស់ លោកផង!... គេប្រហែលជាត្រូវការការណែនាំច្រើនណាស់!

វិចិត្រសម្លឹងមុខណារីហើយស្រដីដោយចិត្តអាណិតអាសូរធិតា :

- ណារី! អោយបងសូមទោសជំនួសភក្តីផងណា៎ ដែលគេប្រព្រឹត្ត មិនគប្បីមកលើប្អូន ។

ថាហើយ វិចិត្រក៏ចុះមករកភក្តីយ៉ាងរហ័ស ។ កាលបើឃើញ ទឹកមុខដ៏មាំរបស់បុរសយើង អ្នកជិតខាងពីររូបនេះក៏ដើបចេញទៅ ទុកអោយបងប្អូនពីររូបនោះនិយាយគ្នា ។ វិចិត្រស្រដីថា :

- ហេតុអ្វីបានជាប្អូនប្រើហឹង្សាទៅលើនារីភេទ ? ដឹងទេថាឯងបាន ប្រព្រឹត្តធ្ងន់ធ្ងរប៉ុនណា ?

ភក្តីដើបមុខឡើង :

- មកពីនាងមាត់ធំមាត់តូចដាក់ខ្ញុំនោះអី ?

- មាត់ធំមាត់តូចមិនត្រូវការកណ្តាប់ដៃបិទមាត់ទេ ។ គេត្រូវការឲ្យ ឯងដូរមារយាទដែលឥតសណ្តាប់ធ្នាប់នោះចេញ! ដឹងទេថាឯងបាន ធ្វើជ្រុលបន្តិចហើយ ភក្តី!

- ហេតុម្តេចបងកាន់ជើងអ្នកដទៃជាងប្អូនខ្លួនឯងដូច្នេះ ?

- ខុសហើយ! បងការពារអ្នកដែលរងគ្រោះ ដោយការធ្វើបាបដ៏ អប្រិយពីមនុស្សអាត្មានិយមដូចឯងទៅវិញទេ ។

- កុំដាក់ទោសខ្ញុំ មុននឹងមិនដឹងរឿងដូច្នេះ បងវិចិត្រ!

CHANBOKEO.COM

- ម៉េចក៏ថាមិនដឹង ? គឺឯងបំរុងរកផ្លូវដោះដៃពីគេទៅរកថ្មីទៀត!
តើនារីណាទៅដែលសប្បាយចិត្ត កាលបើឯងធ្វើបែបនេះដាក់គេ បែបនេះ ? ឯងនិយាយមក!
- គឺខ្ញុំសូមគេចែកផ្លូវគ្នាស្រួលបួលតើហ៎ គឺខ្ញុំបំរុងត្រលប់ទៅរកអូន
ស្បែរឿងម្ចាស់បេះដូងទីមួយរបស់ខ្ញុំវិញ តែគេមិនសុខចិត្ត ។
- ហ៊ឺ... ភក្តីអើយ! ឯងកុំចាក់ទឹកពាងចោលមុនឃើញភ្លៀងធ្លាក់អី
ប្រយត្ន័សិយ ទៅមុខមិនរួច ថយក្រោយមិនកើត ។ ណារីបានកាត់ កេរ្តិ៍ឈ្មោះ
រត់ចោលផ្ទះមករួមរស់នៅជាមួយឯង តែឯងបែរក្លាយជា
ជនអាប់យសជិះក្របីចម្លងភក់ទៅវិញ...គឺហួសនិយាយហើយ!
- បើមិនបានជួយអីទេ បងកុំមកដាក់បណ្តាសាខ្ញុំអី! ទុកបណ្តោយ
ឲ្យខ្ញុំទទួលខុសត្រូវជីវិតរបស់ខ្លួនឯងចុះ ។
- បើសិនជាការទទួលខុសត្រូវក្នុងជីវិតរបស់ឯង មិនមករំខានបង ទេ បងក៏មិនមកដល់ទីនេះ
សូត្រធម៌អោយឯងដែរ ។ ឯងធ្វើជ្រុល បន្តិចហើយ ដឹងទេ? ដៃជើងរបស់ឯងធំៗណាស់
កាលបើឯងគ្រវី គ្រវាត់ទៅលើគេដែលមានខ្លួនតូចៗល្វតល្វន់ គេប្រាកដជាមិនអាច
ទ្រាំទ្រនឹងកម្លាំងដៃរបស់ឯងបានទេ ។ ទៅមើលគេផងទៅ...ថាតើ កម្លាំងដៃរបស់ឯង
បានធ្វើអោយរាងតូចល្វតល្វន់នោះ ប្រែទៅជា យ៉ាងណាហើយ ? បើមានភ្នែកហើយ
មើលមិនឃើញលទ្ធផល អំពីអំពើហឹង្សារបស់ប្អូនទៅលើនារីទេ បងគិតថាបងនឹងបញ្ជូន
ប្អូនឲ្យទៅរៀនកុមារដ្ឋានជាមួយក្មេងតូចៗសាជាថ្មីហើយ ។

កាលបើឮប្រយោគនោះ ភក្តីក៏ងើបមើលមុខបងប្រុសធ្វើកិរិយា
ហាក់ដូចជាកំពុងជាត្រូវទឹកត្រជាក់លាងមុខដូច្នោះឯង តែគេមិន ឆ្លើយតបអ្វីទៅវិញទេ ។
វិចិត្រឃើញកិរិយាផ្លាស់ប្តូររបស់ភក្តី ក៏សួរ
បន្ថែមទៀតថា :
- ត្រជាក់ចិត្តហើយនៅ ? បើត្រជាក់ចិត្តហើយ យកទឹកក្តៅមួយក្លាំ
និងកន្សែងពោះគោទៅជូតរបួសអោយគេផង ។ នេះលិខិតបញ្ជាថ្នាំ
សំរាប់យកទៅទិញថ្នាំបិទរបួស ។ ព្រឹកស្អែក បងសង្ឃឹមថាប្អូននឹង
ទៅជួបបងតាមទម្លាប់រាល់ដង... ទៅរាយការណ៍រឿងរ៉ាវជីវិតទាំង
ឡាយដែលកើតឡើងថ្មីៗក្នុងជីវិតរបស់ឯង ។ បងរង់ចាំស្តាប់ពាក្យ
ប្អូនរអ៊ូរទាំជានិច្ច មិនថាពេលណាទេ ។

ថាហើយ គេក៏ឡើងរថយន្តស្ទុកអណ្ដើករបស់គេចេញទៅ ទុកអោយភក្ដីនៅសំកុកតែម្នាក់ឯងមិនអស់មិនហើយ ។ បន្តិចមក ភក្ដីក៏ស្រវាចាប់លិខិតបញ្ជាទិញថ្នាំ ដែលបងប្រុសសរសេរអោយនោះយកមកមើល...រួចហើយក៏សម្លឹងទៅលើផ្ទះ ។ បន្ទាប់ពីដកដង្ហើម ចោលអស់ជាច្រើននរ:ដាច់ចិត្តឡើងទៅលើផ្ទះ ដោយមានកាន់ក្លាំទឹកក្ដៅនិងកន្សែងពោះគោទៅជាមួយផង ។

នៅលើផ្លូវលេខមួយប្របឆ្នេរស្ទឹងសង្កែ ក្រោមរស្មីព្រះអាទិត្យ ពណ៌ពណ៌ក្រហមដែលកំពុងឈានពន្លិចខ្លួនពួនផ្ទំ ពីក្រោយភ្នំព្រះ សុមេរុ វិចិត្របររថយន្តផងគិតរាយមាយវែងឆ្ងាយផង ។ អារម្មណ៍ របស់គេកំពុងច្របូកច្របល់នឹកទៅដល់មាណវីដែលគេបានជួប ប្រទះពីថ្ងៃមិញនៅមន្ទីរពេទ្យ ។ មិនដឹងជាយ៉ាងម៉េចទេ ស្រមោលរបស់ធវីចេះតែមកលងអារម្មណ៍របស់គេ អោយនឹកគិតទៅនាងឥត ឈប់ឈរ ។ គេកំពុងនឹកភ្នកថាចង់ត្រលប់ទៅរកមាណវី នៅមន្ទី រពេទ្យសាជាថ្មី ស្រាប់តែគេនឹកដល់វត្ថុចុងក្រោយដែលបុរសអ្នក ជម្ងឺមួយរូបនោះប្រគល់មកអោយគេ ។ បុរសក៏លូកទាញពីហោប៉ៅ យកមកមើលសាជាថ្មី ហើយក៏ឧទានខ្សិបៗថា :

- ខ្សែកអំបោះក្រហមបន្តោងថៃកាច់រូបផ្កាចំប៉ាឈ្មោល.. ?

គេក៏នឹកឃើញទៅដល់ពាក្យបណ្ដាំចុងក្រោយប៉ុន្មានម៉ាត់នៅមុនពេលបុរសនោះដាច់ដង្ហើមទៅ ។ ថៃដន្យ វិចិត្រអាល័យតែត្រូវរឿងរបស់ភក្ដីបន្លប់ស្មារតីអស់មួយល្ងាច គេក៏ភ្លេចដល់រឿងបន្តោងផ្កាចំប៉ាឈ្មោលនិងបណ្ដាំរបស់បុរសអភព្វ័នោះអស់រលីង ។ គេបើករថយន្តយ៉ាងលឿនសំដៅមន្ទីរពេទ្យធំវិញ! អ្នកគ្រូម៉ារាត់កំពុងរៀបចំខ្លួនដូរវេនចេញទុកអោយគ្រូពេទ្យថ្មចូលយាមជំនួស ។ លុះចេញមកដល់មាត់ទ្វារ អ្នកគ្រូក៏ប្រទះនឹងដុកទ័រកម្លោះ :

- យី! លោកវិចិត្រ! ថ្ងៃនេះមិនត្រូវវេនយាមផង តែលោកមក ពេទ្យដល់ទៅពីរដង ។

- ប៉ាទ..! គឺខ្ញុំមកសួរថាតើ អ្នកជំងឺដែលទទួលអនិច្ចកម្មពីថ្ងៃជា នរណាដែរ ?

- អូហ៍...មិនស្គាល់ទេ តែខ្ញុំឮថាគេបញ្ជូនមកពីពេទ្យសេរីសោភណ័ ថ្ងៃមិញនេះក្រុមគ្រួសាររបស់គេមកទទួលសពយកទៅបាត់ហើយ... លោកពេទ្យស្គាល់គេដែរ ?

CHANBOKEO.COM

- បាទ! អត់ទេ! គ្រាន់តែខ្ញុំមានឥវ៉ាន់ត្រូវអោយទៅក្រុមគ្រួសារ របស់គេ ។ តើអោយខ្ញុំទៅរកគេនៅឯណាទៅទើបឃើញ ?

- សូមទោសចុះលោកវិចិត្រ! ថ្ងៃនេះនៅមន្ទីរពេទ្យរវល់ជាងសព្វកាលទើបខ្ញុំមិនបានចាប់ភ្លឹកនឹងសួរពត៌មានឲ្យល្អិតល្អន់ទៅ ។

បន្តិចមក អ្នកគ្រូពេទ្យម៉ារ៉ាត់ក៏ធ្វើដំណើរចេញទៅ ។ វិចិត្រក៏ត្រលប់មកផ្ទះវិញទាំងមិនអស់ចិត្ត ។

នៅក្នុងបន្ទប់គេង...

មាណពអង្គុយក្តាប់ខ្សែករអំបោះក្រហម បន្តោងផ្កាចំប៉ាឈ្មោល នោះ អង្អែលចុះ អង្អែលឡើង... មិននឹងថាជាភព្វ័វាសនាឬក៏ ជាចៃដន្យអ្វីទេ ដែលជីវិតគេកំពុងដើរចូលទៅក្នុងភពងងឹតមួយ ដែលគេចង់នឹងក្រៃលែងថា តើវាសនាកំពុងដឹកដៃនាំគេទៅជួបឆវី ទៀតដែរឬក៏យ៉ាងណា ហើយ តើគេនឹងជំពប់ហេតុការណ៍ប្លែកៗអ្វី ខ្លះតទៅទៀត... ពេលនេះ គេចង់នឹងណាស់ថានារីមួយរូបនោះជា នរណា ។ តើគេនឹងត្រូវធ្វើយ៉ាងណាដើម្បីតាមរកនាងអោយឃើញ វិញ ដើម្បីប្រគល់វត្ថុចុងក្រោយរបស់ស្វាមីនាងទៅឲ្យឆវីវិញ ?

ពេញមួយយប់កន្លងទៅ... រង្វង់ភក្ត្រ័ដ៏ត្រកាលរបស់នារីមួយរូបនោះក៏វិលមកប្រលែងអារម្មណ៍របស់នាយទល់ភ្លឺដែរ ។ គេមិនយល់សោះថាហេតុអ្វីគេចាប់អារម្មណ៍នឹងកល្យាណីនោះម្ល៉េះ ? ថ្វីបើ មើលទៅនាងជានារីសាមញ្ញៗធម្មតាសោះ តែហេតុអ្វីក៏បេះដូង ដែកថែបរបស់គេប្រែរំជើបរំជួលខុសប្រក្រតីយ៉ាងនេះ ? ពេញ មួយយប់ហើយ... នរៈប្រឹងបិទនេត្រារំងាប់អារម្មណ៍ដ៏វិលវល់ ប៉ុន្តែ កាលណាគេកាន់តែប្រឹងរំលត់រូបនាងកាន់តែវិលត្រលប់មកលង
អារម្មណ៍របស់គេកាន់តែញឹកញាប់ឡើង ធ្វើអោយអារម្មណ៍របស់គេនឹកព្រឺព្រួចរំជួលចិត្តតែម្នាក់ឯងឥតឈប់ឈរ ។

ជិតភ្លឺហើយ... បុរសយើងនៅតែគេងមិនលក់ ។ ទីបំផុតនរៈក៏ស្ទុះដើបឡើងចាប់ស្លាបប៉ាកកាចាររឿងសម្ងាត់ក្នុងចិត្តរបស់គេ ទៅលើទំព័រសៀវភៅផ្ទាល់ខ្លួនរបស់គេមួយយ៉ាងក្រាស់ ។ អស់រយៈពេលប្រហែលមួយម៉ោងក្រោយមក គេក៏ដាក់ប៉ាកកាចុះហើយលើក

CHANBOKEO.COM

យកសៀវភៅនោះមកមើបដោយដួងចិត្តរំភើប ទើបដើបឡើងវិល ត្រលប់ចូលដំណេកសាជាថ្មី ។ ម្តងនេះ បុរសហាក់ដូចជាមាន អារម្មណ៍ស្ងប់ក្នុងចិត្តជាងមុន ។ មិនយូរប៉ុន្មាន មាណពក៏ត្រូវព្រះនាងនិន្ទ្រាទេវី សណ្តំបានដូចបំណង...

២២២២២២២២២២២២២២២២២២

២២២២២២

២

# វគ្គទី២
# រន្ទះស្នេហ៍

៦ខែក្រោយមក...

វិចិត្រគេងមិនលក់យូរថ្ងៃយូរខែមកហើយ គឺតាំងពីថ្ងៃដែលគេ បានប្រទះរង្វង់ភក្ត្រ័នារីចម្លែកមួយរូបនោះ នៅឯមន្ទីរពេទ្យធំក្រុង បាត់ដំបងមកម្ល៉េះ ។ គេខំឃាត់ចិត្តណាស់ដែរថាមិននឹក តែគេនៅ តែរសាប់រសល់ ។ ថ្ងៃណាក៏គេគិតទៅដល់រូបនាងដែរ មិនដឹងថា ជានិស្ស័យអ្វីមកចាប់ចងបេះដូងរបស់គេឲ្យមកចាប់អារម្មណ៍នឹងនារី សាមញ្ញមួយរូបនោះ ។ ប៉ុន្តែ តើអោយគេទៅតាមរកនាងនៅឯណា ហើយតើគេត្រូវសំដែងកិរិយាយ៉ាងណា បើសិនជាគេបានប្រទះរូប នាងសាជាថ្មី ? ថ្ងៃណាក៏គេនឹកទៅដល់រូបនាង... ថ្ងៃណាក៏គេអង្គុយ អង្អែលខ្សែកអំបោះក្រហមមួយនោះ សម្លឹងពិចារណាមិនអស់មិន ហើយ... ប៉ុន្តែ តើនាងនៅឯណា ? តើគេត្រូវធ្វើយ៉ាងណាដើម្បីយក ខ្សែកមួយនោះទៅសងនាងវិញបាន ? គេបានត្រឹមតែអង្គុយចាក់ ស្មុគប៉ុណ្ណោះ... ប្រាំមួយខែកន្លងមកហើយ... គេមិនដែលបានជួប នាងឬក៏ឮដំណឹងអ្វីបន្តិចសោះឡើយ...

ថ្ងៃនេះ វិចិត្រធ្វើដំណើរជាមួយមិត្តម្នាក់ឈ្មោះផានេត ទៅមោង ឫស្សីដើម្បីចូលរួមពិធីបុណ្យខួប១០០ថ្ងៃរបស់ជីដូនផានេត ចៃដន្យ គេមិនអាចស្នាក់នៅលេងមួយយប់បាន ត្បិតមានប្រជុំនៅថ្ងៃបន្ទាប់ ម្ល៉ោះហើយគេត្រូវចេញដំណើរមកបាត់ដំបងវិញទាំងកណ្តាលរាត្រីតែ ម្នាក់ឯង ។ ពេលនោះម៉ោងប្រហែលជិត១១យប់ទៅហើយ ។ លុះ គេធ្វើដំណើរមកដល់ជិតវាលបែកចាន ស្រាប់តែមានព្យុះភ្លៀងបក់ បោកយ៉ាងខ្លាំងមានទាំងផ្គរនិងរន្ទះយ៉ាងសាហាវ ។ ក្នុងខណៈដែល គេបររថយន្តមកដល់ចំណុចត្រង់ស្ពានយុវ៍នជិតផ្លូវបំបែកទៅសាលា ខេត្ត ស្រាប់តែរថយន្តរបស់គេរលត់ឈឹងលែងទៅមុខ ។ គេនៅ សំងំក្នុងឡានមួយស្របក់ក្រែងភ្លៀងរាំងនឹងអាលដើរទៅផ្ទះ ត្បិតអី ចំងាយពីទីនោះទៅផ្ទះ

CHANBOKEO.COM

ប្រហែលតែជាងមួយគីឡូម៉ែត្រប៉ុណ្ណោះ ។ ចៃដន្យ ភ្លៀងកាន់តែកាចឡើងៗ
រន្ទះផ្ទុះផ្ទូងផាំងៗឆ្វេលឆ្វាត់ស្មើរ តែលោះព្រលឹងមាណពម្តងៗទៅហើយ ។ រំពេចនោះ
ដើមឈូងពីរ ដើមនៅក្នុងសួនយុវវន័ក៏ដួលរលំគ្រាំងៗកាត់ផ្លូវជាតិ ។ ទាំមិន បាន
មាណពក៏បែរក្រលេកមើលទៅផ្ទះអ្នកស្រុក ដែលរស់នៅតាម ដងវិថីម្តុំនោះ
ឃើញផ្ទះថ្មមួយផ្ទាល់ដី មានភ្លើងភ្លឺព្រាលៗជះតាម ស្លាបព្រិលមកក្រៅ ។ គេក៏ញញឹមឡើង
នឹកក្នុងចិត្តថា ប្រហែលជា ម្ចាស់ផ្ទះមិនទាន់ចូលដំណេកហើយ ។ នរៈក៏ស្ទុះចេញពីរថយន្ត រត់
កាត់ស្បៃភ្លៀងសំដៅទៅទីនោះភ្លាម ។

តុក! តុក! តុក!

- នរណាហ្នឹង ?

សូរសម្លេងស្រីម្នាក់សួរពីក្នុងផ្ទះមក ។

- គឺខ្ញុំជាអ្នកដំណើរ ត្រូវត្រលប់ទៅផ្ទះ តែត្រូវខូចរថយន្តកណ្តាល ភ្លៀង ពេលនេះ
នៅខាងក្រៅមានព្យុះខ្លាំងពេក ខ្លាចគ្រោះថ្នាក់ ទើបខ្ញុំមកសុំស្នាក់ជ្រកភ្លៀងបណ្តោះអាសន្នសិន
ទំរាំស្ងប់ខ្យល់ ស្ងប់រន្ទះ ។

រំពេចនេះ ម្ចាស់ផ្ទះក៏បើកទ្វារឡើង ។ គ្រាន់តែទ្វារបើកភ្លាម
វិចិត្រភ្ញាក់ស្មារតីដូចគេចាប់គ្រវែងតែម្តង ពេលគេ យល់ភក្ត្រ័ម្ចាស់ ផ្ទះមួយរូបនោះ
ត្បិតមាណវីនោះក៏មិនអ្នកដទៃណាក្រៅពីនារី ដែល បេះដូងរបស់គេ បានដង្ហោយហៅរក
ជាយូរមកហើយនោះទេ ។ គេលេបទឹកមាត់ក្អឹកផ្ទើមបំពង់កបន្តិច ដើម្បីរំលត់ភាពញាប់ញ័រ
នៅក្នុងចិត្ត ទើបស្រដីថា :

- អរគុណណាស់ដែលអនុញ្ញាតអោយខ្ញុំចូលស្នាក់ជ្រកភ្លៀង ។

រីឯស្ត្រីក្មេងមួយរូបនោះវិញក៏ហាក់ដូចជាចាប់ភ្លឹកថា ធ្លាប់ស្គាល់ នរៈយើងដែរ ។
ឆរីក៏ឧទានឡើងថា :

- លោកវេជ្ជបណ្ឌិតវិចិត្រ ?

- បាទ គឺខ្ញុំមែនហើយ ។

គ្រាន់តែដឹងថា នរៈជាគ្រូពេទ្យដែលធ្លាប់ជួយសង្គ្រោះរូបនាង នាគ្រាមួយ
កល្យាណីយើងសម្តែងអាការៈហាក់ដូចជាទុកចិត្តហើយ មានការគោរពរូបគេជាងមុន :

- សូមលោកអញ្ជើញចូលខាងក្នុងសិនមក!

CHANBOKFO.COM

បុរសយើងក៏ឈានដើរចូលទៅក្នុងផ្ទះ ទាំងខ្លួនទទឹកជោគរហូត
ដល់នាយរងារណ្តំចង្កាតែម្តង ។ ធិតាក៏ប្រញាប់ទាញសន្លឹកទ្វារបិទ
វិញដើម្បីកុំអោយភ្លៀងសាចចូលផ្ទះ រួចហើយក៏ម្ទីម្ទារត់ចូលទៅ
យកកន្សែងពោះគោនិងខោអាវមួយបន្លាស់ ព្រមទាំងទឹកក្តៅមួយ បំពង់មកដល់ :
- នេះជាខោអាវរបស់ប្តីខ្ញុំ! លោកផ្លាស់សម្លៀកជូតខ្លួនអោយស្ងួត សិនទៅ
ទុកខ្លួនទទឹករងាយូរប្រយត្ន័គ្រុនផ្តាសាយ... ហើយនេះទឹក ក្តៅ! លោកពិសារបន្តិចទៅ
នឹងបានបែកញើសបាត់រងាហើយ ។

នាងមានឫកពា ហាក់ដូចជាស្គាល់សុខទុក្ខរបស់ភ្ញៀវណាស់ ។ ពេលនោះ
វិចិត្រសម្លឹងភក្ត្រ័មាណវីមិនដាក់ភ្នែកទេ ។ ជាយូរមក
ហើយគេមិនដែលមានស្ត្រីណាមកថៃទាំរូបគេដូច្នេះទេ ក្រៅពីម្តាយ របស់គេចេញ ។ ពេលនោះ
នរៈមានអារម្មណ៍រំភើបយ៉ាងណាមិន ដឹងដែលគេបានទទួលការរាក់ទាក់ពីម្ចាស់ផ្ទះយ៉ាងកក់ក្តៅ ។
បន្តិច មក មាណវីយើងក៏បែរទៅចាប់ការងារដែលនៅលើតុសរសេរបន្ត ទៀត ។
វិចិត្រលួចសម្លឹងមើលតាម នឹកគិតថាស្រីក្មេងរូបនោះជា
អ្នកនិពន្ធហើយព្រោះឃើញនាងកំពុងកែក្រដាសច្រើនសន្លឹកគរលើ គ្នា ។
វិចិត្រក៏បែរមើលជុំវិញខ្លួន ឃើញការតុបតែងផ្ទះរបស់នាង
មានរបៀបសាមញ្ញតែរៀបរយស្អាតបាត ។ រំពេចនោះគេដាក់ភ្នែក
ទៅកៀនក្បែរតុធ្វើការរបស់ធិតា ស្រាប់តែប្រទះឃើញកូនហ៊ឹងតូច
មួយមានតម្កល់ជើងធូបនិងរូបថតមួយធំពណ៌សខ្មៅជារូបបុរសម្នាក់
មានមាឌធំសង្ហាភក្ត្រ័ញញឹមស្លូតបូត ។ ការពិតរូបនោះក៏មិននរណា
ក្រៅពីបុរសរងគ្រោះនៅឯមន្ទីរពេទ្យថ្ងៃមុននោះដែរ ។ ពេលនោះ
គេក៏នឹកទៅដល់បណ្តាំរបស់បុរសនោះព្រមទាំងខ្សែកអំបោះក្រហម
បន្តោងចៃកាច់រូបផ្កាចំប៉ាឈ្មោល ។ ថៃដន្យគេមិនអាចប្រគល់របស់
នោះត្រលប់ទៅម្ចាស់ដើមពេលនេះវិញបាន ព្រោះគេមិនបានយក មកជាប់នឹងខ្លួន ។
វិចិត្រលេបទឹកមាត់ក្អឹក រំលត់ភាពញាប់ញ័រក្នុង ចិត្ត
ដែលរូបគេកំពុងដើរចូលអន្ទាក់វាសនាថ្មីមួយ...

បន្តិចមក គេដាក់ភ្នែកទៅកូនទូតូចមួយ ដែលនៅក្បែរខ្លួនគេ មានផ្ទុកសៀវភៅជាច្រើនក្បាល
នៅក្នុងនោះ មានទាំងសៀវភៅ ទស្សន៍ទាយរាសីនិងគូព្រេងផង ។

CHANBOKEO.COM

- ខ្ញុំសូមមើលសៀវភៅមួយក្បាលនេះបានទេ ?

វិចិត្រសួរធិតាទាំងកិរិយាញញើតញញើម ។

- ចាស អញ្ជើញដោយរីករាយ (ឆវីឆ្លើយវិញ)

វិចិត្រក៏ឈ្ងោកទាញយកសៀវភៅទស្សន៍ទាយនោះ មកបើក អាន ស្រាប់តែប្រទះនឹងកំណាព្យដ៏ខ្លីមួយនៅលើក្របខាងក្នុងដែល សរសេរថា :

ពេលបានជួបភក្ត្រជំពាក់ចិត្ត   បើនិស្ស័យពិតសូមជាគូ
ទោះមានឧបសគ្គក៏តស៊ូ   ជីវិតបងប្តូរដើម្បីអូន...
ស្រលាញ់អូនតែម្នាក់!

នៅខាងក្រោមកំណាព្យនោះ មានស៊ីញ៉េឈ្មោះជាភាសាឡាតាំង ផង ។ វិចិត្រឃើញហើយក៏លួចចោលកន្ទុយភ្នែកសម្លឹងធិតា តែ ឆវីកំពុងធ្វើកិច្ចការរបស់នាង មិនបានចាប់ភ្លឹកអ្វីទេ ។ មាណពយក ម្រាមដៃអង្អែលកំណាព្យមួយល្បះនោះយ៉ាងថ្នមៗស្រាលៗ ហើយ លួចញញឹម សម្តែងកិរិយាហាក់ដូចជាស្រលាញ់ពេញចិត្តអត្ថន័យ របស់កំណាព្យមួយនោះក្រៃលែង ។

មួយម៉ោងកន្លងទៅ...

ព្រះភិរុណនៅតែបង្អុរជោគជាំមិនព្រមស្វាងសោះ ។ មាណវីក៏ បញ្ចប់កិច្ចការ រួចហើយក៏បែរមករកវិចិត្រ ស្រដីថា :

- មើលទៅ លោកត្រូវជាប់ផ្លូវទីនេះមួយយប់ហើយ ។ សូមមេត្តា កុំថាអីថាវ៉ាន់ ព្រោះខ្ញុំទើបតែផ្លាស់មកនៅបាត់ដំបង កាលពីអាទិត្យ មុននេះទេ ទើបគ្មានអ្វីទទួលលោកអោយបានសមរម្យ ។

- បាទ មិនអីទេ អ្នកនាង! បានអនុញ្ញាតអោយខ្ញុំជ្រកភ្លៀងប៉ុន នេះ ចាត់ទុកជាសមានចិត្តដ៏ធំធេងទៅហើយ ។

ធិតាក៏ដើបទៅយកក្រមាអំបោះផ្ទាំងធំមួយ ព្រមទាំងខ្នើយមួយ មកអោយវិចិត្រ :

- សូមទោស ខ្ញុំក៏គ្មានមុងដែរ! លោកប្រហែលត្រូវសំរាន្តលើក្តារ ជឿ ទទូរក្រមា ការពារមូសមួយយប់ហើយ ។

CHANBOKEO.COM

វិចិត្រមិនហ៊ានរអ៊ូទេ ត្បិតមើលទៅម្ចាស់ផ្ទះ គេមានសន្តានចិត្ត ចំពោះនាយយ៉ាងល្អរកគ្មានរួចទៅហើយ ។ បន្តិចមក មាណវីក៏ចូល ទៅក្នុងបន្ទប់របស់នាងបាត់ទៅ ទុកអោយមាណពនៅខាងក្រៅតែ ម្នាក់ឯង គេងស្តាប់សូរសម្លេងខ្យល់បក់បោកគ្រាប់ភ្លៀង ទៅលើ ធម្មជាតិទាំងឡាយកណ្តាលយប់ស្ងាត់ ។ ថ្វីបើពេលនេះ រូបនាយ មិនធ្លាប់គេងនៅលើក្តារដើរីងៗដូច្នេះពីមុនមក ហើយទោះបីនៅ ក្នុងជំរៅដួងចិត្តរបស់គេនៅមានជិតដាមនូវភាពតប់ប្រមល់តិចតួច ខ្លះៗក៏ដោយ ក៏វិចិត្រមានអារម្មណ៍ថា បេះដូងរបស់គេកំពុងតែ ទទួលនូវសេចក្តីសុខក្នុងចិត្តយ៉ាងក្រៃមក្សាន្តលើសពេលណាៗទាំង អស់ក្នុងជីវិត ។ ថៃដន្យចម្លែកណាស់ ពេលមុនពេលគេបិទភ្នែក និទ្រាទៅ មាណពបានយកសៀវភៅទស្សន៍ទាយមួយនោះមកដាក់ ផ្ទាប់លើឱរារបស់គេ ហើយយកដៃដាក់ក្តោបអោបពីលើយ៉ាងណែន រួចក៏បិទភ្នែកនិទ្រាទាំងទឹកមុខញញឹមពព្រាយ ដោយដួងចិត្តរំភើប រីករាយតែម្នាក់ឯង ។

.........................................

- លោក! អញ្ជើញពិសារបបរ ទាន់ក្តៅៗ ?

វិចិត្របើកភ្នែកឡើង ឃើញព្រហាមស្រាងៗ ហើយឃើញធិតា យើងលើកបបរមួយស្លាកទុកអោយ ។ គេភ្ញាក់ព្រើតនឹកថា :

- នេះគេដាស់យើងទាំងព្រឹកអោយបរិភោគផង ? តើគេបំរុងដេញ យើងអោយឆាប់ចេញទៅ ? ឬក៏គេកំពុងត្រូវចេញទៅធ្វើការដែរ ?

នរៈដើបឡើងរៀបចំខ្លួន ស្រាប់តែមាណវីសួរថា :

- ផ្ទះរបស់លោកគ្រូពេទ្យនៅខាងណាដែរ ?

- បាទ! នៅមាត់ស្ទឹងត្រើយខាងកើតនេះឯង ជិតវត្តពោធិក្នុង ។

- អូហ៍ អញ្ជឹង មានឆ្ងាយឯណា!

បន្តិចមក ធិតាក៏ទាញកង់មួយចេញមក :

- នេះកង់! ខ្ញុំអោយលោកខ្ចីជិះទៅផ្ទះសិន! ចាំដល់លោកធ្វើ ឡានរួច ចាំយកមកសងខ្ញុំវិញចុះ ។

វិចិត្របើកភ្នែកក្រឡង់ សួរថា :

- ហើយចុះអ្នកនាងវិញ ? បានអ្វីជិះទៅធ្វើការដែរ ?

CHANBOKEO.COM

មាណពសួរទាំងមិនដឹងថានាងធ្វើការអ្វីផង ។

- អូហ៍ ខ្ញុំដើរក៏បានដែរ ព្រោះកន្លែងធ្វើការនៅជិតនេះឯង ។

ភ្លាមនោះ បុរសយើងហាក់ដូចជារំភើបចិត្តណាស់ដែលឆវីមាន សមានចិត្តចំពោះខ្លួន ហើយមើលទៅនាងហាក់ដូចជាទុកចិត្ត ទុក ថ្លើមរូបគេដល់ហើយ :

- អ្នកនាងមិនខ្លាចខ្ញុំយកកង់ទៅហើយមិនសងទេហ៍ ?

ស្រាប់តែធិតាឆ្លើយធ្វើហីថា :

- ចាស! មិនខ្លាចទេ!

- ព្រោះហេតុអ្វីទៅ ?

គេសួរទៅមាណវីវិញដោយនឹកគិតក្នុងចិត្តថា ប្រហែលជានាង យល់ថាគេជាដុកទ័រហើយទើបអោយខ្ចី តែនាងបែរតបវិញថា :

- ធ្វើអំពើល្អចំពោះញាតិ ព្រះលោកមិនដាក់ទោសឲ្យខ្ញុំបាត់កង់ទេ!

វិចិត្របាត់មាត់តែម្តង កាលបើនាងឆ្លើយដូច្នោះ ។ បន្តិចមកគេ ក៏មានគំនិតមួយ :

- ខ្ញុំគិតថា ខ្ញុំឌុបអ្នកនាងទៅផ្ទះខ្ញុំចុះ រួចហើយអ្នកនាងត្រលប់ជិះ កង់យកមកវិញដោយមិនបាច់ដើរខកដំណើរយឺតការងារផង ។ តើ អ្នកនាងយល់យ៉ាងណាដែរ ?

ដោយយល់ថា នោះជាយោបល់ល្អ ធិតាក៏ងក់ក្បាល ។ បន្តិច មក វិចិត្រក៏ឡើងធាក់កង់ឌុបមាណវីចេញទៅ ។ តាមផ្លូវ គេមាន អារម្មណ៍ហាក់ដូចគេនោះជានិស្សិតក្មេងមួយរូប ដែលកំពុងដឹកឌុប សិស្សប្អូនទៅរៀន ព្រោះអីធិតាស្ថិតនៅក្នុងសម្លៀកអាវសសំពត់ ខៀវមើលទៅស្រគត់ស្រគំគួរអោយស្រលាញ់ណាស់ ។ វិចិត្រក៏ លួចមានអារម្មណ៍រំភើបព្រឺព្រួចតែម្នាក់ឯង យ៉ាងណាមិនដឹងទេ ។ គេញញឹមបិទមាត់មិនជិតសោះ ចេះតែលួចរំជួលក្នុងចិត្ត រកថាមិន ត្រូវ ។ បន្តិចមក គេក៏បានមកដល់មាត់ទ្វាររបងផ្ទះរបស់ខ្លួន ។ ពូខេមឃើញហើយ ក៏ចេញមកទទួល :

- អ៊ុញ! លោកពេទ្យ! ឯណាឡាន ?

- យប់មិញ ឡានងាប់តាមផ្លូវកណ្តាលភ្លៀង បើកុំតែបានផ្ទះអ្នក នាងខាងនេះជ្រក កុំអីខ្ញុំយ៉ាប់ធំហើយពូខេម ។

រួចហើយគេក៏បែរមកកនារី :

- ចូលលេងខាងក្នុងផ្ទះសិនទេ អ្នកនាង ?

CHANBOKEO.COM

- ចាស មិនអីទេ (ធិតាគ្រវីក្បាល) ខ្ញុំដល់ម៉ោងទៅធ្វើការហើយ! ចាំពេលក្រោយចុះ ជំរាបលាលោកគ្រូពេទ្យ ជំរាបលាពូ ។

ភ្លាមនោះ ធិតាក៏ទាញកង់បែរក្រោយធ្វើដំណើរចេញទៅ ដោយមិនទាន់បានទទួលពាក្យអរគុណពីបុរសយើងផង ។ នរៈឈរមើលតាមក្រោយរហូតដល់ធិតាបាត់ស្រមោលទៅ ។

- អ្នកនាងនោះជាអ្នកនរណាដែរ ?

- គឺខ្ញុំខូចឡាន ចូលសុំផ្ទះគេជ្រកកាលពីយប់មិញ ។

ពូខេមមើលតាមនាងឡើងភ្លឹក :

- ហេតុសម្លឹងមើលគេភ្លឹកម្ល៉េះពូ ? (វិចិត្រសួរ)

- អ៊ឺ! មកពីឃើញគេស្រស់ស្អាតគួរអោយគយគន់នោះអី!

- ពូលួចចាប់ចិត្តលើរូបគេមែនទេ ?

- អត់ទេ ពូគិតថាចង់លួចផ្គូផ្គងអោយអ្នកខ្លះ!

- អូហ៍...ហើយពូចង់ផ្គូឲ្យនរណាគេទៅ ?

- ឲ្យនរណានៅម្តុំៗនេះ ដែលនៅទំនេរយូរអើយសែនយូរ គ្មាន នារីណាជួយថ្នាក់ថ្នមបេះដូងអោយបាត់រងានោះអី!

ពូពូខេមចំអន់ វិចិត្របាត់មាត់ឈឹង ឈ្ងោកមុខចុះធ្វើអឹមអៀន លែងហ៊ានស្រដីទៀត ។ ពេលនោះ ស្រាប់តែគេក៏ចាប់ភ្លឹកតែម្តង ថា គេមិនបានសួរឈ្មោះធវីសោះ... គឺគេភ្លេចសួរនាងអោយឈឹង សូន្យតែម្តង ។ គួរអោយស្តាយមែន!!

បីថ្ងៃក្រោយមក...

វិចិត្រត្រូវជិះទូកចម្លងទៅធ្វើការអស់ពីរបីថ្ងៃទំរាំជាងជួសជុល រថយន្តរួចរាល់ ។ រសៀលនេះ បន្ទាប់ពីទៅយករថយន្តត្រលប់មក វិញ គេក៏ស្ទុះបររឹងសំដៅទៅផ្ទះធិតាដែលគេគេងនឹកពីរបីច្រប្លុក ច្របល់ចិត្តពីរបីថ្ងៃមកហើយ ។ ចៃដន្យ ផ្ទះចំហទ្វារតែស្ងាត់ច្រៀប គ្មាននរណានៅសោះ ។ គេដើររោៗមួយស្របក់ជុំវិញសួនយុវ័ន យូរៗម្តងលួចចោលកន្ទុយភ្នែកលួចមើលទៅម្តុំផ្ទះធវី តែក៏មិន ឃើញនរណាចេញចូលទីនោះដដែល ។ កំពុងតែអង្គុយភ្លឹក ស្រាប់តែគេឮសម្លេងក្មេងសើចរអឹកនៅក្រោយខ្នង ។ លុះគេងាកបែរមើលក៏ប្រទះឃើញកុមារតូចម្នាក់រូបអាយុប្រហែលបួនឆ្នាំ កំពុងរត់ ចាប់មេអំបៅ

CHANBOKEO.COM

ដែលហើរទំលើកនៅក្រោមផ្កាម្លុលស្គុះស្គាយជុំវិញអាង
បេះដូងក្នុងសួនយុវ័នដោយមានយុវតីមួយរូបមានវ័យប្រហែល១០
ឆ្នាំកំពៀកប្អូនស្រីតូចម្នាក់ទៀតអាយុប្រហែលពីរឆ្នាំ ហើយក្តាប់កូន បាល់តូចមួយ
រត់តាមហៅពីក្រោយកុមារផង :

- ភក្រ្តា! កុំរត់លឿនពេកអូន ប្រយត្ន័ដួល!

ថាផុតពីមាត់ កុមារតូចក៏ដួលព្រួសទៅលើដីគ្រួសក្រហម រួចក៏
យំវ៉ាឡើង ។ វិចិត្រអង្គុយនៅជិតនោះ ឃើញហើយ ក៏ស្ទុះទៅ ជួយលើកកុមារឡើង :

- មានត្រូវត្រង់ណាទេ អូនតូច ?

កុមារងក់ក្បាលហើយចង្អុលទៅជើង ។ គេលើកជើងនាយយក
មកមើលឃើញរលាត់ស្បែកចេញឈាមរឹមៗ ។ គេក៏ជួយបបោសដី
ចេញពីស្នាមរបួសហើយលួងលោមថា :

- អូហ៍! អស់អីហើយ! នេះ អូនតូចឈប់យំទៅណ៎!

ពេលនោះ យុវតី ជាបងក៏រត់មកដល់ដែរ :

- ឃើញទេ អូនភក្រ្តា! បងថាកុំអោយអូនរត់ តែអូនចេះតែរត់
ឥលូវអូនដួលដាច់ជើងចេញឈាមអស់រលីង!

កុមារក៏ស្ទុះរត់ចេញពីដៃវិចិត្រ ហើយរត់ទៅអោបកយុវតី :

- បងម៉ៅ! (ថាបានតែប៉ុណ្ណោះក៏យំថែមទៀត) ត្រាយឺជើង...
- អឺៗ! បាត់យំទៅ! ចាំបងផ្លុំអោយ... ភាំង!

ឃើញមុខកុមារតូចនោះកាលណា វិចិត្រហាក់មានអារម្មណ៍ថា
គេមាននិស្ស័យនឹងក្មេងនេះណាស់ ។ គេសម្លឹងមុខកុមារដោយ ឥតពព្រិចភ្នែក
រួចនឹកស្រម័យដល់រូបនាយកាលនៅពីក្មេងតូចៗ ។ ភ្លាមនោះ ស្រាប់តែយុវតី
មួយរូបនោះស្រដីថា :

- អូនភក្រ្តា សំពះអរគុណលោកពូទៅអូន ដែលពូបានជួយបោស ដីឲ្យប្អូន ។

ភក្រ្តាជូតទឹកភ្នែកហើយបែរមកសំពះវិចិត្រវិញ ។ នរៈញញឹម តបវិញយ៉ាងទន់ភ្លន់ ។
ភ្លាមនោះ ស្ត្រីចំណាស់មួយរូបវ័យប្រហែល សែប្លាយបានដើរមកតាម :

- ម៉ៅអើយ! ប្រញាប់នាំប្អូនទៅផ្ទះវិញចៅ! បន្តិចទៀត ម៉ាក់មក
ដល់ផ្ទះវិញហើយ ប្រយត្ន័គាត់បន្ទោស ។

CHANBOKEO.COM

ពូឌួច្នោះយុវតីក៏នាំប្អូនៗដើរត្រលប់ទៅវិញ ។ វិចិត្របែរមើល
តាមដោយមិនអស់ចិត្ត ។ មើលទៅកុមារមួយរូបនោះគួរឲ្យអាណិត
ស្រលាញ់ណាស់ ។ គេចេះសំពះគួរសមជាមួយមនុស្សចាស់យ៉ាង ប្រពៃ
ហាក់បីដូចជាគេបានទទួលការអប់រំពីឪពុកម្ដាយយ៉ាងល្អ ។ ភ្លាមនោះ
ស្រាប់តែកុមាររត់គេចពីដៃបងស្រីត្រលប់មករកគេវិញ ថែមទាំងកាន់កូនបាល់មួយយកមកផង :
- ប៉ា! លេងបាល់ជាមួយត្រាបាទ!
មាណពភ្ញាក់ព្រើតកាលបើឮក្មេងតូនោះហៅគេថា ប៉ា ។ មិន ទាន់តបថាយ៉ាងណាផង
ស្រាប់តែកុមារគប់សំដៅទៅរកវិចិត្រភ្លាម តែម្ដង ។ នាយក៏លើកដៃចាប់ជាប់
ហើយព្រមៀលបាល់ត្រលប់មក អោយនាយវិញ ។
កុមារតូចឃើញហើយក៏ទះដៃសើចកក្អឹកឡើង ។ រួចកុមារក៏ចាប់បាល់គប់ទៀតឯដៃលជាងដៃល ។
បន្តិចមកអ្នកទាំង ពីរក៏ក្លាយជាកីឡាករប្រកួតបាល់យ៉ាងសប្បាយក្អាកក្អាយ ។ ពេល នោះ
វិចិត្រក៏ហាក់ដូចជាភ្លេចអស់នូវភាពតប់ប្រមល់ក្នុងខ្លួនរលីង តែម្ដង ។
គេហាក់ដូចជារំភើបចិត្តយ៉ាងណាមិនដឹងដែលមានក្មេង ម្នាក់មកហៅគេថាប៉ា ដោយថៃដន្យ
ឬប្រហែលជារូបគេមានមុខ មាត់ប្រហាក់ប្រហែលនឹងឪពុករបស់កុមារនោះក៏មិនដឹងបានជាក្មេង
តូចមួយរូបហៅនាយថា ប៉ា ដូច្នោះ ។
មួយស្របក់ក្រោយមក គេលើកដៃមើលនាឡិកា ឃើញថាខ្លួន
ត្រូវដល់ម៉ោងត្រូវត្រលប់ទៅការិយាល័យវិញ ។ គេក៏លាកុមារតូច
និងបងស្រីឈ្មោះម៉ៅដែលកំពុងពព្ធនស្រីតូចនៅក្នុងដៃ :
- ពូលាសិនហើយណាំនាងតូចទាំងបីនាក់ ព្រោះត្រូវទៅធ្វើការវិញ ហើយ ។ មើលហ្ន៎!
លោកយាយនៅចាំផ្លូវក្អួយឯណោះ!
លុះបែរក្រោយ ឃើញស្ត្រីចំណាស់នោះនៅឈរចាំមែន យុវតី
ឈ្មោះម៉ៅ កុមារភក្ត្រា ព្រមទាំងកុមារីតូចនៅលើចង្កេះរបស់នាង
ក៏នាំគ្នាលើកដៃបក់បោយលាមាណពយើង ។
ពីរបីថ្ងៃក្រោយមក វិចិត្រតែងតែឆ្លៀតពេលរសៀលមកលួច ឃ្លាំមើលផ្ទះរបស់មាណវីទៀត
តែក៏មិនបានជួបដូចបំណង ។ គេក៏
ត្រូវត្រលប់ទៅផ្ទះវិញទាំងខកចិត្តឥតឧបមា ។
នៅរវាងដំណាច់សប្ដាហ៍... ក្នុងអាទិត្យដដែល...
CHANBOKEO.COM

ផានេតដែលជាមិត្តរបស់គេ បាននាំវិចិត្រទៅចូលរួមពិធីជប់លៀងមួយនៅផ្ទះលោកសំអាតជានាយកស៊ុរិយោដីខេត្តបាត់ដំបង ។ ការពិត សង្សាររបស់ផានេតជាកូនស្រីទោលរបស់លោកសំអាតតែម្តង ។ នាងមានឈ្មោះថា សារិកា ។

នៅក្នុងបរិវេណសួនច្បារ ដែលមានតុបតែងភ្លើងពណ៌ចម្រុះដ៏ ល្អប្រណិតដោយមានអមទាំងវង់ភ្លេងសម័យមួយក្រុមផង វិចិត្រ និងផានេតអង្គុយក្រេបភេសជ្ជៈផងជជែកគ្នាផង យ៉ាងរីករាយតាម បែបកម្លោះៗ ។ ភ្ញៀវទាំងឡាយក៏បានមកដល់ជាបន្តបន្ទាប់ រួច កម្មវិធីក៏ចាប់ផ្តើមឡើង ។ សារិកាក៏ដើរឡើងទៅលើវេទិកាប្រកាស ទៅភ្ញៀវថា :

- ថ្ងៃនេះ លោកប៉ាដ៏សង្ហាររបស់ខ្ញុំបានចូលគំរប់វ័យ ៦០ឆ្នាំហើយ! នាងខ្ញុំ សារិកា ជាកូនព្រមទាំងញាតិមិត្តទាំងអស់សូមចូលរួម ជូនពរលោកប៉ាសូមអោយលោកប៉ានៅតែមាំមួនជាម្លប់ត្រជាក់ដល់ កូនចៅរហូតតទៅ!

ភ្ញៀវទាំងអស់ក៏ទះដៃឡើង ។ តន្ត្រីក៏ចាប់ប្រគំយ៉ាងរងំ ។ អ្នកដែលមានគូទាំងឡាយក៏ឡើងរាំលេងយ៉ាងសប្បាយ ទៅតាមចង្វាក់តន្ត្រីដ៏ស្រទន់លួងលោមអារម្មណ៍ ។ ផានេតក៏ចាប់ដៃសារិកាឡើងរាំ បាត់ទៅនៅសល់តែវិចិត្រដែលនៅអង្គុយក្រេបទឹកក្រូចម្នាក់ឯង គ្មានគូរាំនឹងគេ ។ រំពេចនោះគេដាក់ភ្នែកទៅចំនារីសោភាមួយរូប នៅអង្គុយស្ងាត់ស្ងៀមម្នាក់ឯងក្រោមដើមចំប៉ាស្រាប់តែគេញញឹម ឡើងដោយចិត្តសែនរំភើបត្រេកអរយ៉ាងចម្លែក រួចហើយគេក៏ដើរសំដៅរូបនាងយ៉ាងលឿន :

- អ្នកនាង!

វិចិត្រហៅនាងតិចៗពីក្រោយ ។ ធិតាងាកមុខមកយ៉ាងរហ័ស ហើយស្រាប់តែបើកភ្នែកធំៗឧទានថា :

- លោកគ្រូពេទ្យ ?

- បាទ! អ្នកនាងសុខសប្បាយទេ ?

- ចា៎ស! គឺធម្មតាៗទេ ។ ចុះលោកពេទ្យវិញ ?

- គឺធម្មតាដូចគ្នា...គ្រាន់តែ...

CHANBOKEO.COM

ស្រាប់តែវិចិត្រមានអារម្មណ៍ថាត្រជាក់ដៃស្រើត ។ ដំបូងគេនឹក ចង់ហៅនាងទៅរាំលេង តែលុះមកដល់ចំពោះមុខធិតា គេបែរជា និយាយមិនចេញទៅវិញ ។ ភ្លាមនោះ គេក៏ដាក់ខ្លួនអង្គុយចុះក្បែរ នាងរួចស្រដីថា :

- ខ្ញុំបានទៅរកអ្នកនាងនៅផ្ទះម្តងពីរដែរ តែមិនបានជួបគ្នាសោះ!

ធិតាញញឹម រួចសួរថា :

- អូហ៍! លោកមានការអ្វីដែរទៅ ?

- យី! អ្នកនាងភ្លេចហើយមែនទេ ? ខោអាវរបស់ខ្ញុំមួយកំប្លេនៅផ្ទះអ្នកនាង ហើយខោអាវមួយកំប្លេដែលអ្នកនាងឲ្យខ្ចី នៅជាមួយខ្ញុំ

ស្រាប់តែនាងនិយាយលលេងថា :

- ប្រហែលជាខោអាវរបស់ខ្ញុំមានតម្លៃតិចពេក សំរាប់ដូរគ្នាហើយ ទេដឹងបានជាលោកប្រញាប់តាមរកម្ចាស់ដូរគ្នាវិញម្ល៉េះ ?

ឮនាងចំអន់លេងដូច្នោះ គេខ្មាសក្តៅមុខតែម្តង ។ ពេលនេះ គេនឹកចង់សួរឈ្មោះធិតាណាស់ តែហារមាត់ស្រដីមិនរួចសោះ ។ គេក៏ឈ្ងោកមុខនៅស្ងៀមទៅវិញ ។ ការពិត គេនិយាយច្រើនតែជាមួយប្អូនប្រុសរបស់គេប៉ុណ្ណោះ ។ ក្រៅពីនោះ គេមិនសូវស្រដី រកនរណាទេ ។ អ្នកដែលមិនស្គាល់រូបគេច្បាស់ ច្រើនយល់ថាគេ ជាមនុស្សឆ្មើងឆ្មៃ តែចំពោះមិត្តភក្តិស្គាល់គ្នាវិញ គេជាមនុស្សដែល

និយាយតិចបំផុត ។ ឃើញនាយនៅស្ងៀម ធិតាក៏សួរឡើង :

- លោកជាសាច់ញាតិរបស់ម្ចាស់ផ្ទះនេះមែនទេ ?

- បាទ! អត់ទេ! ខ្ញុំជាមិត្តរបស់ផានេត ដែលជាសង្សាររបស់អ្នក នាងសារិកា ។

- ហើយថ្ងៃនេះគ្មានដៃគូទេ ទើបមិនឃើញលោកឡើងរាំហ្នឹងគេ ?

មាណពគ្រវីក្បាល លួចសម្លឹងភក្ត្រ័ធិតាវិញដោយក្រសែភ្នែកភ្លឺ ថ្លាផ្លេកៗ ហាក់ដូចជាបង្កប់នូវគំនួចអារម្មណ៍ដ៏សែនជ្រៅ ។ បន្តិច មក នរៈក៏សួរនាងវិញថា :

- ចុះឯណាដៃគូរបស់អ្នកនាងវិញនោះ ?

ស្រាប់តែមាណវីដាក់មុខជ្រប់ធ្វើមុខស្លូតតែម្តង ។ ពេលនោះ វិចិត្រហាក់យល់ស្ថានការណ៍ភ្លាម ក៏នឹកខកចិត្តចំពោះខ្លួនឯងណាស់ កាលបើឃើញកិរិយារបស់នាងហាក់ដូចជាសោកសៅចំពោះសំនួរ របស់នាយដែលមិនបានគិតវែងឆ្ងាយ ។

CHANBOKEO.COM

- សូមទោស ដែលខ្ញុំធ្វើអោយអារម្មណ៍អ្នកនាងល្អក់កករ...!
ឆវីគ្រវីក្បាល :
- មិនមែនជាកំហុសលោកទេ...
វិចិត្រនៅស្ងៀម មិនដឹងថាខ្លួនត្រូវសម្ដែងកិរិយាយ៉ាងណាឲ្យ សមទៀតទេ ។ គេក៏បែរនៅស្ងៀមសាជាថ្មី សម្លឹងមុខនាងដោយក្តី អាណិតក្នុងចិត្តក្រៃលែង ។ នៅក្រោមពន្លឺភ្លើងភ្លឺថ្លាស្រទន់នៃពិធី ជប់លៀង សោភណ៍ធិតាអណ្តែតឆ្លោឡើងយ៉ាងត្រកាល ធ្វើឲ្យវិចិត្រ លួចគយគន់សឹងតែភ្លេចដកដង្ហើមម្តងៗទៅហើយ ។ គេសឹងមិន ជឿការពិតទេ ដែលថាធិតាជានារីធ្លាប់មានគូស្រកររួចមកហើយ ។ បើសម្លឹងមើលទៅត្រឹមតែកិរិយាមារយាទនិងសំដី គេច្បាស់ជាទាយ ខុសថា នាងនៅក្រមុំមិនខាន ។ ថៃដន្យ គេធ្លាប់បានជួបនាងថៃម ទាំងបានជួបបុរសដែលជាស្វាមីរបស់នាងថៃមទៀតផង ទើបមិន ជឿមិនកើត ។ ប៉ុន្តែ តើនិស្ស័យអ្វីទៅហ្ន៎ ដែលធ្វើឲ្យគេបែរមក ចាប់អារម្មណ៍លើនារីដែលធ្លាប់មានគូស្រករហើយទៅវិញ ? ឬក៏រូប គេកំពុងតែត្រូវបណ្ដាសាពីទេវតា ?
កាលបើឃើញបរិយាកាសស្ងៀមស្ងាត់បុរសយើងក៏សួរនាងថា:
- តើអ្នកនាងផ្តល់កិត្តិយសឲ្យខ្ញុំទេ បើខ្ញុំសូមអ្នកនាងរាំមួយបទ ?
នាងងើបមុខឡើង តបថា :
- គឺ... មិនសមរម្យទេដឹង លោកគ្រូពេទ្យ ?
ស្រាប់តែវិចិត្រហុចដៃឡើង :
- សូមអញ្ជើញអ្នកនាងផ្តល់កត្តិយសដល់ខ្ញុំផងណា៎!
ទីបំផុត នាងក៏ត្រូវតែងើបឈរឡើងទាំងទើសទាល់ :
- អញ្ចឹង...ទាល់តែសូមលោកជួយណែនាំហើយ ។
ភ្លេងប្រគំឡើងយ៉ាងភិរម្យ ជាចង្វាក់មនោសញ្ចេតនាយ៉ាងផ្អែម ត្រជាក់ ។ វិចិត្រយកដៃស្តាំក្រសោបចង្កេះនារីពីក្រោយ ទាញខ្លួន នាងឲ្យផ្ទឹបកៀកជិតកាយរបស់គេ រួចលើកដៃឆ្វេងឡើងក្តាប់ដៃស្តាំ របស់នារីយើងយ៉ាងណែន ។ គេឈ្ងោកមុខសម្លឹងភក្ត្រ័នាង ដោយ ក្រសែភ្នែកដ៏ស្រទន់ បង្កប់នូវក្តីរំភើបយ៉ាងជ្រាលជ្រៅក្នុងចិត្ត ។ រីឯបេះដូងរបស់គេក៏រណ្តំភ្លាមឡើង ជាចំរៀងមនោសញ្ចេតនាយ៉ាង ចម្លែកមួយ

CHANBOKEO.COM

ដែលគ្មានពាក្យពេចន៍ណាអាចយកបរិយាយអោយសម ស្មើអត្ថន័យបានឡើយ ។ ថ្វីបើពេលនោះ កល្យាណីយើងបានធ្វើមុខ ញញឹមស្មើៗក៏ដោយក៏រង្វង់ភក្ត្រារបស់នាងបានបញ្ចេញនូវសម្ផស្ស សោភ័ណដ៏ត្រកាល គាប់ទ័យាមាណពកម្លោះយើងក្រៃលែង ។ គេ សម្លឹងរង្វង់ភក្ត្ររបស់នាងមិនឆ្អែតឆ្អន់ទេ ។ ដួងចិត្តរបស់គេរំភើប សែនរំភើប... គឺជាមនោសញ្ចេតនាដ៏ប្លែកមួយ ដែលបេះដូងគេមិន ដែលមានប្រតិកម្មដូច្នេះពីមុនមកម្តងណាឡើយ ។ គ្រានេះ មាណព ទទួលអារម្មណ៍ថា គេមានសេចក្តីសុខក្នុងចិត្តអ្វីម៉្លេះទេ កាលបើគេ បានឈរត្រកងកាយធិតាដ៏សោភាមួយ យ៉ាងជិតស្និទ្ធិបំផុតក្បែរ ដើមទ្រូងរបស់គេដែលធ្លាប់តែរងាជាយូរមកហើយ ។

ចំពោះកន្និដ្ឋាវិញ ថ្វីបើមិនសូវជាបានប្រលែងក្រសែភ្នែកជា មួយបុរសយើងប៉ុន្មានក៏ដោយ ក៏មាណវីទទួលអារម្មណ៍មិនតិចដែរ ថារូបនាងបានទទួលការចាប់អារម្មណ៍ ពីលោកគ្រូពេទ្យរបស់យើង យ៉ាងពិសេសបំផុត ។ ក្រុមតន្ត្រីប្រគំមួយបទហើយមួយបទទៀត ជាបន្ត... ចីបទជាប់ៗគ្នាកន្លងទៅហើយ ។ អ្នកទាំងពីរហាក់ដូចជា កាន់តែយល់អារម្មណ៍ទៅៗ រំភើបព្រឺព្រួចទោរទន់តាមចង្វាក់ភ្លេង មនោសញ្ចេតនា ដែលបបោសអង្អែលបេះដូងរបស់គេទាំងពីរឲ្យ ក្សេមក្សាន្តភិសម័យ រកអ្វីប្រៀបមិនបានឡើយ ។

រំពេចនោះ ស្នូរទះដៃក៏បន្លឺយ៉ាងរន្ថើនឡើង ពញ្ញាក់អារម្មណ៍ របស់អ្នកទាំងពីរអោយភ្ញាក់ក្រញាង ។ ការពិត ស្នូរទះដៃទាំងនោះ គឺសំរាប់សាវិកានិងផាតេនទេ ប៉ុន្តែ ចំពោះអ្នកដែលមានខ្លួនដូច វិចិត្រនិងមាណវីយើង គេរអៀសខ្លួនមិនតិចឡើយដែលនាំគ្នាឈររាំ ឡើងភ្លេចស្មារតីយ៉ាងដូច្នោះ ។ ភ្លាមនោះ នរៈក៏បែរកាន់ដៃនារី ដើរត្រលប់មកតុដើមវិញទាំងឱភារីករាយ ។

ទោះបីមើលពីក្រៅទៅ ធិតាយើងមានឥរិយាបថ ស្ងៀមស្ងាត់ មិនសូវញញឹម មិនសូវស្រដី តែវិចិត្របានលួចសង្កេត ដឹងថា នាងបានសម្តែងភាពទន់ភ្លន់ តបមករូបគេវិញ មិនតិចដែរទេ ។ បើមិនដូច្នោះ នាងពិតជាមិនព្រមឈរស្ទូទ្រាំឈរអោយបុរសយើង ស្រវាក្រសោបអោបចង្កេះនាង រាំរហូតដល់ទៅបីបទនោះឡើយ ។ កាន់តែគិត មាណពកាន់តែលួចរំភើបចិត្តតែម្នាក់ឯងខ្លាំងឡើងៗ ។ បន្តិចមក ធិតាក៏មកសំពះលារូបគេចេញទៅ :

- អ្នកនាងត្រលប់ទៅវិញហើយហ្ន៎ស ?

- ចា៎ស! ម៉ោងនេយប់ហើយ ខ្លាចអ្នកផ្ទះគេចាំ!

អ្នកផ្ទះ ? វិចិត្រឮដូច្នោះភ្ញាក់ព្រើត នឹកក្នុងចិត្តតែម្នាក់ឯងថា: - នាងមានអ្នកផ្ទះដែរ ? តើជានរណាទៅ ?"

ដោយនឹកពិភាល់ក្នុងចិត្ត គេក៏សួរធវីបន្តទៀត :

- ហើយចុះអ្នកនាងទៅផ្ទះវិញយ៉ាងណា ?

- គឺសុំអោយមិត្តភក្តិគេជូនទៅ...

- ចុះបើខ្ញុំសូមជូនអ្នកនាងទៅផ្ទះ តើបានដែរទេប៉ុទ ?

ធិតាបើកភ្នែកទំនងភ្ញាក់ផ្អើល :

- ដូចជារំខានលោកពេកទេដឹង ?

- ជាសន្តានចិត្តបន្តិចបន្តួច...មិនខុសត្រូវអ្វីទេ អ្នកនាង!

ភ្លាមនោះ ផានេតនិងសារិកាហាក់ដូចជាយល់សន្តានចិតរបស់កម្លោះយើង ។ សារិកាក៏ជំរុញបន្ថែម ត្បិតនាងមិនទាន់ចង់ចាក ចេញពីរង្វង់ពិធីដើម្បីជូនធិតាយើងទៅផ្ទះទេ :

- បើបានលោកពេទ្យជូនទៅនោះប្រសើរហើយ ព្រោះខ្ញុំទុកចិត្ត!

ដោយទើសទាល់ មាណវីក៏ឡើងរថយន្តជាមួយបុរសត្រលប់ ទៅផ្ទះវិញ ។

តាមផ្លូវ នាងនៅស្ងៀមមិនស្រដីអ្វីទេ មើលទៅដូចជាប្រយត្ន័ប្រយែងមាត់កណាស់ ទំនងហាក់ដូចជាធវីខ្លាចចិត្តមាណពយើង ហើយ ។ ចំណែកវិចិត្រវិញក៏រកនឹកពាក្យនិយាយទៅរកធិតាវិញ មិនបានសោះ ។ គេនៅអេះអុញៗតាមផ្លូវទំរាំហ៊ានហារមាត់សួរ នាងជាដំបូងឡើងថា :

- តើអ្នកនាងត្រូវជាអ្វីនឹងម្ចាស់ពិធីនារាត្រីនេះដែរ ?

- ចា៎ស! ស្គាល់គ្នាជាមួយអ្នកនាងសារិកា ធ្វើការជាមួយគ្នា ។

ស្រាប់តែរថយន្តដល់មុខផ្ទះល្មម ។ ធិតាលើកដៃជំរាបលា :

- អរគុណលោកណាស់ដែលជូនខ្ញុំត្រលប់មកវិញ!

- អ្នកនាងមិនហៅខ្ញុំចូលលេងទេ ? (មាណពសួរ)

មាណវីងាកទៅផ្ទះហើយបែរមកវិញ :

- នេះយប់បន្តិចហើយ... ដូចជាមិនសមទេដឹង លោកគ្រូពេទ្យ ?

- ខ្លាចចិត្តអ្នកផ្ទះហ្ន៎ស ?

CHANBOKEO.COM

- អត់ទេ...ប៉ុន្តែ...ខ្លាចភ្នែកញាតិផងជាជាង...

ឮធនីឆ្លើយដូច្នេះ គេក៏នៅស្ងៀម តែគេមិនដាច់ចិត្តបើករថ យន្តចេញទៅសោះ ។ គេនៅអង្គុយសម្លឹងតាមមើលធិតាដើរចូល ផ្ទះរហូតបាត់ស្រមោលទៅ ។ មួយស្របក់ក្រោយមកគេក៏បររថយន្ត ចេញទៅ តែមិនបានប៉ុន្មានម៉ែត្រផង ក៏ថយរថយន្តមកវិញ ។ ការ ពិតគេនៅមិនអស់ចិត្តទេដែលគេភ្លេចសួរឈ្មោះរបស់នាង ។ គេ អង្គុយសម្លឹងស្រមោលផ្ទះរបស់នាង ក្រោមពន្លឺបង្គោលភ្លើងពណ៌ស តាមដងផ្លូវ អស់រយៈពេលយ៉ាងយូរ ។ មិនដឹងយ៉ាងម៉េចទេ... គេ គិតចុះគិតឡើងនៅតែមិនដាច់ឈានជើងចេញទៅ ។ មួយសន្ទុះធំ ក្រោយមក គេក៏ដាច់ចិត្តចុះពីរថយន្ត ដើរសំដៅផ្ទះរបស់នាង តាមការស្រែកដង្ហោយនៃបេះដូងរបស់គេ ចំពោះនារីម្ចាស់ដួងចិត្ត តែមួយរបស់គេ ។

តុក! តុក! តុក!

- អ្នកនាង!....

ទ្វារបើកឡើង...ធនីសម្លឹងមុខបុរសយើងសម្ដែងការងឿងឆ្ងល់ ក្នុងចិត្ត :

- លោកគ្រូពេទ្យ ?.... អឺ... ភ្លេចអ្វីឬចាស ?

- បាទ... គឺ...ភ្លេច...ច្រើនដងហើយ...

- អ្វីទៅ ?

- សុំទឹកក្ដៅមួយកែវសិនបានទេ ?

- ថ្ងៃនេះមិនមានធ្លាក់ភ្លៀងផង ម្ដេចក៏រងាកើត ?

វិចិត្រសម្លឹងភក្ត្រ័ធិតាដោយក្រសែភ្នែកយ៉ាងស្រទន់ ហាក់ដូច ជាចង់បញ្ជាក់នូវក្ដីប្រតិពទ្ធ័របស់គេចំពោះរូបនាង :

- គឺ...ប្រហែលមកពី...ខ្ញុំ....បាត់ដៃគូរបស់ខ្ញុំទេដឹង ?

មាណវីនៅស្ងៀម ហាក់យល់អត្ថន័យសំដីបុរសយើង ។ បន្តិច មក នាងក៏រុញទ្វារបើកអោយទូលាយផ្លូវចូលបន្តិច :

- អញ្ចឹង.. សូមអញ្ជើញចូលពិសារទឹកក្ដៅមួយកែវសិនទៅ ក្រែង លោបានគ្រាន់បើ!

ឮនាងវាចាដូច្នេះ វិចិត្រប្រែមានទឹកមុខភ្លឺថ្លាស្រស់បំព្រង ប្រកបដោយក្ដីរំភើបក្នុងចិត្ត កាលបើឃើញមាណវីស្វាគមន៍នរៈ ដោយកិរិយាទន់ភ្លន់ ទំនងដូចជានាងមានអារម្មណ៍ល្អៗចំពោះរូបគេ មិនខុសពីអារម្មណ៍របស់គេចំពោះនាងប៉ុន្មានទេ ។

CHANBOKEO.COM

- អ្នកនាងរស់នៅទីនេះជាមួយញាតិមែនទេ ?
- ចាស មែនហើយ !
- ចុះ គេទៅណាអស់ហើយ ?
- គេងលក់ហើយ បើលោកចង់ជួបគេ ទាល់តែចាំព្រឹកស្អែកហើយ មើលទៅ ។

ថ្វីបើគេសន្ទនាជាភាសាធម្មតាៗ តែបុរសយើងហាក់ដូចជាមាន អារម្មណ៍ព្រឺព្រួចក្នុងចិត្តយ៉ាងចម្លែក រកថាមិនត្រូវ ។ បន្តិចមក ធីរីក៏យកអាវធំមួយកញ្ចប់មកហុចអោយ :

- នេះខោអាវរបស់លោក! ខ្ញុំបោកអ៊ុតជូនយ៉ាងស្អាតរួចហើយ!

មាណពភ្ញាក់ព្រើត ត្បិតគេមិននឹកស្មានថានាងធ្វើដោយដៃរបស់ ខ្លួននាងផ្ទាល់ :

- អរគុណណាស់ បាទ!

រួចហើយគេអេះអុញៗ ហាក់ដូចជាមិនចង់ត្រលប់ទៅវិញសោះ ទោះបីជាគេដឹងហើយថា ពេលនេះយប់ជ្រៅបន្តិចហើយក៏ដោយ ។ ចំណែកធិតាក៏មិនហ៊ានមាត់ថាម៉េចឡើយ នឹងបបួលអោយនៅលេង ក៏មិនសម នឹងដេញក៏មិនកើត ។ នាងក៏នៅឈ្ងោកមុខធ្វើស្ងៀមៗ មិនស្រដី មិនដឹងថានាងគិតយ៉ាងណាចំពោះបុរសយើងទេ ។ ទំរាំ បុរសយើងដាច់ចិត្តជំរាបលា នាឡិកាគោះអន្លង់ប្រាប់ថាម៉ោង១១ យប់ហើយ ។

- ស្អែកជាថ្ងៃអាទិត្យ ។ តើខ្ញុំអាចមកលេងអ្នកនាងបានទេ ?
- បើសិនជាលោកមិនទើសទាល់ ទីនេះស្វាគមន៍លោកជានិច្ច ។
- អញ្ចឹង ខ្ញុំសុំបាយថ្ងៃត្រង់មួយពេលផងណា៎!
- ចាស!

ធិតាញញឹមធ្វើកិរិយានឹងធឹង សម្លឹងតាមបុរសយើងដែលកំពុង ដើរចូលក្នុងរថយន្តហើយបបោយដៃ លានាងចេញទៅ...

នៅក្នុងវិឡារបស់មាណព...

វិចិត្រដាក់កេសាទៅលើខ្នើយ ភ្នែកសម្លឹងពិដាន លួចញញឹម តែម្នាក់ឯងក្នុងចិត្ត :

- មើលទៅនាង ដូចជាមិនស្អប់ខ្ពើមរូបយើងទេ... ប៉ុន្តែ...តើយើង នឹងមានសង្ឃឹមឬទេ បើសិនជាយើងដើរចូលក្បែររូបនាងកាន់តែ

CHIANBOKEO.COM

ជិតស្និទ្ធជាងនេះ ? ពេលនេះ... តើនាងមានអារម្មណ៍យ៉ាងណា ចំពោះយើងដែរទៅ ? ឱ វិចិត្រអើយ! តើឆវីនោះជាគូព្រេង.... ឬជាគូកម្មរបស់អ្នក ? ហេតុអ្វីបានជា... អ្នកចាប់អារម្មណ៍នឹងស្ត្រី មេម៉ាយដ៏ក្មេងមួយរូបនេះទៅវិញ ? ហេតុអ្វីក៏បេះដូងរបស់អ្នក.... រំភើបញាប់ញ័រពេលអ្នកជួបរូបនាង ? អ្នកកំពុងលង់ក្នុងជំរៅនៃ សេចក្តីស្នេហាមែនទេ ?

គេគេងពិចារណាចុះឡើង ដដែលជាដដែលមួយយប់ទល់ភ្លឺ... គេសួរចិត្តខ្លួនឯងមិនអស់មិនហើយ តែក៏នៅគឿងចម្លើយដដែល... ទីបំផុត គេក៏ប្រឹងបិទភ្នែកនិន្ទ្រាទាំងឱរាធុញថប់តប់ប្រមល់....

OOOOOOOOOOOOO

OOOOOO

O

CHANBOKEO .COM

# វគ្គទី៣
# សុភមង្គលថ្មី

ថ្ងៃរះក្រហមឯបូព៌ាទិស...

វិចិត្រតុបតែងខ្លួនយ៉ាងស្អាតបាតប្លែកតែម្តង ។

- ថ្ងៃនេះមានពិធីអ្វីពិសេសឬលោកគ្រូពេទ្យ ? (ពូខេមសួរ)
- អូហ៍ អត់ទេ...គ្រាន់តែចង់ធ្វើអោយមនុស្សម្នាក់គេចាប់អារម្មណ៍
- សង្សារមែនទេ លោកពេទ្យ ?
- ម៉េចក៏ពូនឹងកើត ?
- ព្រោះខ្ញុំមិនដែលឃើញលោកគ្រូពេទ្យមានឥរិយាបថប្លែកៗដូច្នេះ ពីមុនមកទេ... ថ្មីៗនេះខ្ញុំឃើញ...ហាក់ដូចជាអន្ទះសាខុសធម្មតា ។

វិចិត្រញញឹមហើយនៅស្ងៀម ត្បិតពូខេមនិយាយចំចំណុច ។ រំពេចនោះស្រាប់តែមានរថយន្តប៊ុហ្សថ្មីស្រឡាងមួយបរចូលមកដល់ ដោយនាំស្ត្រីចំណាស់ម្នាក់មកផង :

- អ្នកមីងផាន់ស៊ី ? (វិចិត្រលាន់មាត់)
- អើ គឺមីង! ម៉េចបានជាក្មួយធ្វើមុខដូចត្រូវខ្មោចលងឥចឹង ?
- អ្នកមីងមានការអ្វីដែរ ទើបមកដល់ទីនេះ ?
- ចាំបាច់តែមានការទើបមកបានឬវិចិត្រ ? ការពិតមីងខានមក លេងឯងយូរខែយូរអាទិត្យហើយ ។ ថ្ងៃនេះគិតថាមកហៅក្មួយទៅ បរិភោគបាយក្រៅមួយពេលជាមួយមីង ព្រោះអីមីងមានភ្ញៀវពី បារាំងចង់អោយក្មួយជួបគេផង ។
- ប៉ុន្តែ ថ្ងៃនេះក្មួយមានការចេញទៅក្រៅ...
- ការអ្វីទៅដែលធំជាងជួបមីងរបស់ឯងនោះ ? យ៉ាងណាក៏ឯង ត្រូវតែទៅជាមួយមីងដែរ ។

វិចិត្រនៅស្ងៀមមិនហ៊ានស្រដី ។ មែនហើយ! តើឲ្យគេធ្វើ យ៉ាងណាបើគេកំពុងតែជាប់សន្យា ។ ឥឡូវអ្នកស្រីផាន់ស៊ីមករារាំង

CHANBOKEO.COM

ធ្វើអោយនាយយើងត្រូវជំពាក់សន្យាគេហើយ ។ បន្តិចក្រោយមក
គេក៏ជិះរថយន្តជាមួយអ្នកស្រីផាន់ស៊ីជាម្តាយមីង ឆ្លងស្ពានសំដៅ
ទៅភូមិគ្រិះធំមួយនៅដំណាក់ហ្លួង ។ ថ្ងៃនោះ អ្នកស្រីផាន់ស៊ីបាននាំ
រូបគេទៅជួបគ្រួសារមួយដែលជាមិត្តរបស់គាត់ ព្រោះកូនស្រីរបស់
គេទើបតែវិលពីស្រុកបារាំងម្សិលមិញ ហើយចង់ណែនាំវិចិត្រអោយ ស្គាល់នាង
ត្បិតនោះជាទម្លាប់របស់អ្នកស្រីផាន់ស៊ីទៅហើយ គឺមិន អោយកម្លោះក្រមុំនៅទំនេរយូរទេ...
សូម្បីតែក្មួយប្រុសរបស់គាត់ក៏ គាត់មិនចង់អោយមានសេរីភាពយូរដែរ ។ កាលបើឃើញនរៈនៅ
លីវ ចាស់ជ្រុលបន្តិច គាត់រសើបដៃរសើបជើងនៅមិនសុខទេ ។

ក្រោយពីជួបចាស់ទុំរួច ចាស់ៗក៏ណែនាំនារីមួយរូបដែលមាន
រូបរាងស្រស់ស្អាតឈ្មោះអេឡែនដល់វិចិត្រតែនាងហាក់ដូចជាវាយ ឫករបៀបអ៊ីរ៉ុបបន្តិច ។
ចំពោះភ្នែកវិចិត្រ នាងជានារីស៊ីវិល័យ ជ្រុលជន្ទល់ ។ គេមើលមិនចូលភ្នែកទេ ។
ពីរម៉ោងដែលគេអង្គុយ លេងផ្ទះរបស់នាង ហាក់ដូចជាពីរឆ្នាំអញ្ចឹង គឺវាយូរអើយសែន យូរ
មិនចេះដល់ម៉ោងលាគ្នាសោះ ។ បន្តិចមក អ្នកស្រីផាន់ស៊ីក៏
លាម្ចាស់ផ្ទះហើយទទូចអោយបុរសយើងជូនគាត់ទៅរកភក្តីទៀត ។
ជួបមុខមិនទាន់បានសួរសុខទុក្ខផង អ្នកស្រីក៏សួរថាភក្តីថា :
- នែ៎ភក្តី! កាលណាបានលាងដៃលាងជើងសាងជីវិតត្រឹមត្រូវនឹង
គេហ្ន៎ស ? អាយុជិតសាបសិបហើយនៅឡេឡដូចក្មេង...!

រួចហើយគាត់ក៏ស្តីទៅណារីថា :
- នែ៎នាងល្អ! បើនឹងខ្លួន ប្រញាប់រកផ្លូវដោះស្រាយជីវិតទៅ!
ភក្តីនេះមិនមែនជាបុរសដែលនាងគួរយកជាទីបង្អែកទេ ប្រយត្ន័ ត្រូវជូតទឹកភ្នែកញឹកជាងនេះ ។

ថ្វីបើសំដីគ្រោតគ្រាតបន្តិច តែមើលទៅអ្នកស្រីក៏គ្មានបំណង អាក្រក់អ្វីដាក់ណារីដែរ ។
វិចិត្រមិចភ្នែកដាក់ណារីអោយនៅស្ងៀម មិនអោយតបអ្វីទៅអ្នកស្រីផាន់ស៊ីវិញទេ ។ បន្តិចមក
អ្នកស្រីក៏ បបួលភក្តី និងវិចិត្រ :
- ថ្ងៃណាទំនេរទៅអើតមីងខ្លះផង ។ ពេលនេះមីងនៅតែឯង តាំង
ពីពូឯងគេទៅនៅតែផ្ទះប្រពន្ធចុងមិនដែលមកផ្ទះទេ កូនចៅក៏មីង គ្មាននឹងគេ ។
បើឯងមិនអើត...មីងច្បាស់ជាអផ្សុកស្លាប់ហើយ ។

CHANBOKEO.COM

ឃើញកិរិយាម្តាយមីងដូច្នោះ ក្មួយទាំងពីរក៏សុខចិត្តទំលាក់កិច្ច ការផ្ទាល់ខ្លួនចោល តាមបំរើតម្រូវចិត្តគាត់ពេញមួយថ្ងៃ ។ បន្ទាប់ពី អ្នកស្រីផាន់ស៊ីចេញទៅបាត់ វិចិត្រសួរប្អូនថា :

- បងក៏ដូចជាបាត់មុខឯងយូរថ្ងៃដែរ...ប្រហែលជាមានសេចក្តីសុខ ហើយ បានមិនឃើញទៅរំអុកបងដូចសព្វដង ។

ភក្តីឈ្ងោកមុខនៅស្ងៀម ។ វិចិត្រក៏ស្រដីបន្តទៀតថា :

- យ៉ាងណាក៏គួររំសាយអតីតកាលចោលទៅហើយចាប់យកអ្វីដែល នៅបច្ចុប្បន្នវិញ រួចសាងជីវិតអោយបានប្រសើរបំផុតផង ឮទេ ?

ភក្តីងក់ក្បាលមិនប្រកែកអ្វីនឹងបងប្រុសទេ ។ បន្តិចមក វិចិត្រ ក៏ត្រលប់ចេញទៅវិញរួចក៏បង្ហួសទៅផ្ទះធរីម្ចាស់ចិត្តរបស់គេ តែ ផ្ទះនាងបិទទ្វារស្ងាត់ច្រៀបទៀតហើយ ។ គេចតឡានរួចដើរចុះដើរ ឡើងនៅសួនយុវ័ន រេរ៉េចាំមួយសន្ទុះធំដែរ នៅតែមិនឃើញម្ចាស់ផ្ទះវិលវិញដដែល ។ អស់ចិត្តហើយ បុរសយើងក៏ឡើងរថយន្ត បរចេញទៅ ។

នៅរសៀលថ្ងៃដដែល...

ភក្តីចេញមកផ្សារលើ រកទិញទឹកកកដុំយកទៅផ្ទះ ស្រាប់តែ ប្រទះនារីម្នាក់ជិះរ៉ឺម៉ក ជាមួយក្មេងប្រុសស្រីពីរបីនាក់ទៀតសំដៅ ទៅទិសវត្តកណ្តឹង ។ គេចាប់អារម្មណ៍ភ្លាម ក៏ជិះសូឡិចតាម ព្រម ទាំងស្រែកហៅនាងក្តែងៗថា :

- ស្បៃរឿង... ស្បៃរឿង ឈប់សិនអូន!

ធិតាងាកក្រោយ ។ កាលបើក្រលេកឃើញមុខបុរសយើង នាង ក៏ងាកទៅវិញ ដោយមិនមាត់មិនស្រដីអ្វីទាំងអស់ ។ ភក្តីជិះតាម នាងរហូតដល់ចុងស្ពានរទេះភ្លើងហួសវត្តសំពៅបន្តិច :

- ស្បៃរឿង... អោយបងសូមនិយាយជាមួយបានទេ ?

- យើងគ្មានអ្វីត្រូវនិយាយគ្នាទេ ភក្តី!

- តែ...បងមាន!... ហើយមានច្រើនទៀតផង... អោយបងសូម ពេលបន្តិចណា៎ ស្បៃរឿង ?

ធិតាធ្វើសញ្ញាអោយពូធាក់រ៉ឺម៉កនៅចាំ ហើយក៏បែរនិយាយជា មួយភក្តីវិញ :

- ខ្ញុំទុកពេលអោយប្រាំនាទី...ចង់និយាយអ្វី និយាយអោយអស់មក ហើយខ្ញុំនឹងអាលទៅកុំអោយហួសពេលណាត់របស់ខ្ញុំ ។

- គឺចំពោះរឿងអតីតកាលរបស់យើង...

CHANBOKEO.COM

- ខ្ញុំបានកប់វាចោលយូរណាស់ហើយ....មិនចង់រំលឹកវិញទេ
- តែបងចង់មកសូមទោសថា បងមិនមានបំណងអីអាក្រក់លើ ស្បែរឿងនាគ្រាមួយនោះទេ ។ កាលនេះ មកពីបងនៅក្មេងហើយ ភ្លើតភ្លើន មិនបានពិចារណាត្រឹមត្រូវ ទើបមានការជ្រុលជ្រួស...
- តែក៏ពិបាកនឹងជួសវិញដែរ ព្រោះកត្តិយសកេរ្តិ៍ឈ្មោះរបស់ខ្ញុំ បានបាត់បង់រួចទៅហើយ...
- ព្រោះតែអញ្ចឹងហើយ ទើបបងមកសុំទោសនេះអី... ហើយយើង នឹងចាប់ផ្ដើមសាជាថ្មី...
- តែហួសពេលហើយភក្តី... នេះខ្ញុំមិនមែនមនុស្សទំនេរអោយភក្តី មកចាប់អារម្មណ៍ទៀតទេ ។ ហ្អែក! ក្មេងៗគេនៅក្នុងរ៉ឺម៉ករង់ចាំខ្ញុំ យូរហើយ... លាសិនហើយណា! បើអ្នកគិតថា អ្នកនៅជំពាក់អ្វី ទៀតជាមួយខ្ញុំដោះស្រាយមិនទាន់អស់... នុ៎ះហ្ន៎ វត្តសំពៅ... ចូល បួសមួយវស្សា រំដោះចិត្តដែលរងទុក្ខដោយអំពើបាបរបស់ខ្លួននោះ ទៅ... ភក្តីនឹងបានភ្លឺស្វាងក្នុងចិត្តមិនខានឡើយ ។

ធិតាពោលបញ្ចេះទាំងទឹកមុខស្លូតថៃស ហាក់ដូចជាមិនមាន អារម្មណ៍សោកស្ដាយឬអាណិតបុរសយើងអ្វីបន្តិចសោះ ។ មើលទៅ ភក្តីប្រហែលជាធ្លាប់ប្រព្រឹត្តអ្វីអោយនាងឈឺចិត្ត កាលពីអតិតកាល ធ្ងន់ធ្ងរហើយ បានជានាងមានកិរិយាយ៉ាងនេះ ។ ភ្លាមនោះធិតា ក៏ឡើងរ៉ឺម៉កចេញទៅ ទុកអោយភក្តីនៅឈរធ្មឹងដូចរូបចម្លាក់ក្បែរ សូឡិចរបស់គេលើផ្លូវរទេះភ្លើង ។

នៅវិឡារបស់លោកវិចិត្រ...
- វាស្ទីទៀតហើយ ភក្តី! ព្រឹកមិញមុខថ្លាគ្រាន់បើហើយ ម្ដេច ពេលនេះវាខ្មៅមកវិញអញ្ចឹង ?
- គឺខ្ញុំបានជួបស្បែរឿងកាលពីព្រលប់នៅជិតវត្តសំពៅ ហើយនាង បានដេញខ្ញុំអោយទៅបួសថែមទៀតផង ។
- នាងនិយាយត្រូវហើយ! មើលទៅមានតែធម៌ព្រះទេ ដែលអាច ជួយតម្រង់ផ្លូវជីវិតរបស់ឯងអោយមានពន្លឺវិញបាន ។

ភក្តីឈ្ងោកមុខ រួចឆ្លើយទាំងមួម៉ៅថា :
- បើម៉ាក់ប៉ានៅរស់ ប្រហែលជាគាត់ជួយដោះស្រាយជីវិតអោយខ្ញុំ ហើយ.. ចំពោះបងវិចិត្រវិញឃើញតែបន្ទោស មិនឃើញជួយលើក ទឹកចិត្តប្អូនអ្វីបន្តិចសោះ ធុញណាស់!

CHANBOKEO.COM

ថាហើយ នាយក៏ឡើងសូឡិចជិះចេញទៅវិញយ៉ាងលឿន ទាំង ដួងចិត្តសែនហ្មួហ្មង ។ គ្រាន់តែប្អូនប្រុសចេញទៅផុតមិនទាន់ គេ ប្រញាប់បររថយន្តទៅរកធិតាម្ចាស់ចិត្តរបស់គេភ្លាម ។ ប៉ុន្តែថៃដន្យ សំណាងគេមិនល្អសោះ ផ្ទះបិទទ្វារចាក់សោរស្ងាត់ជ្រៀប គ្មាន ឃើញស្រមោលនរណាម្នាក់នឹងអោយសួរដំណឹងសោះ ។ វិចិត្រក៏ ត្រលប់មកផ្ទះវិញទាំងចិត្តកន្ទះរា ។

រាត្រីនោះ គេតប់ប្រមល់ក្នុងចិត្តសាជាថ្មី មិនដឹងថាតើមាណវី មួយរូបនោះមានអារម្មណ៍យ៉ាងណាចំពោះគេកាលបើគេមិនបានទៅ ជួបដូចពាក្យដែលខ្លួនបានណាត់សុំ ហើយ...តើពេលនេះទៀត តើ នាងចេញទៅណាបានជាមិនឃើញនៅផ្ទះ សូម្បីតែគេបានឆៀង ចូលរកនាងពីរដងរួចមកហើយ ក៏មិនបានជួប ។

- ឬក៏នាងផ្លាស់ផ្ទះទៅនៅខាងណាទៀតហើយទេដឹង ?

វិចិត្រនឹកភ័យជ្រួចក្នុងពោះ បារម្ភខ្លាចគេមិនបានជួបនាងសា ជាថ្មីម្តងទៀត ។ បើសិននាងដូរផ្ទះមែន តើគេត្រូវទៅតាមរកនាង ឯណាទៅ ? វិចិត្របានជួបនាងច្រើនដងហើយ តែហេតុអ្វីក៏រំលង មិនដែលសួរឈ្មោះ សួរប្រវត្តិនាងដូច្នោះ ? ពេលនេះ គេមិនទាំង ដឹងថានាងធ្វើការអី នៅកន្លែងណាផង ។ គិតៗទៅ គេក៏ក្រញីសក់ ខ្លួនឯង មិនយល់ថា ហេតុអ្វីគេភ្លេចសួរអោយរាល់តែដង ពេលគេ ជួបមុខនាង ។

ថ្ងៃបន្ទាប់មក...

វិចិត្ររៀបចំខ្លួនបំរុងចេញទៅធ្វើការដូចប្រក្រតី តែព្រឹកនេះ គេបររថយន្តវាងចេញទៅសួនយុវ័ន ដើម្បីស្កាត់រកកល្យាណីសោភា មួយរូបនោះ ក្រែងលោបានជួបនាង ។ លុះគេមកដល់មុខផ្ទះរបស់ ធិតា ស្រាប់តែគេញញឹមហើបគួចពីកៅអីឡាន ត្បិតគេបានមកស្កាត់ នាងទាន់ពេលមាណវីកំពុងដើរដឹកកង់ចេញមកក្រៅ ទំនងកំពុង ចេញទៅធ្វើការ ។ វិចិត្រចុះពីរថយន្តស្ទុះទៅរកនាងភ្លាម :

- អ្នកនាង!

នាងបែរមើលមកវិចិត្រសំដែងទឹកមុខប្លែកបន្តិច រួចក៏ធ្វើមុខ ស្មើៗវិញតែមិននិយាយអ្វីទេ ។ មាណពក៏ពោលបន្តថា :

- អោយខ្ញុំសូមទោសដែលខ្ញុំខកការណាត់របស់យើងម្សិលមិញ!

CHANBOKEO.COM

នាងញញឹមស្ងួត រួចតបថា :

- អូហ៍ ? យើងមានណាត់អ្វីទៅ ?...ខ្ញុំមិនចាំទេ ។

ពេលនោះ វិចិត្រទទួលអារម្មណ៍ភ្លាម ថានាងហាក់ដូចជាមិនសប្បាយចិត្តដែលគេមិនបានមកតាមការណាត់ :

- គឺខ្ញុំពិតជាមកសុំទោសមែនណា៎! បើអ្នកនាងអោយឱកាសខ្ញុំ ពន្យល់នោះអ្នកនាងក៏នឹងបាត់ភាពល្អក់កករក្នុងអារម្មណ៍មិនខាន!

- តែខ្ញុំគ្មានកត្តិយសគ្រប់គ្រាន់សំរាប់ទទួលពាក្យពន្យល់ពីលោកទេ

- អ្នកនាងកុំគិតអញ្ចឹងអី! ខ្ញុំដឹងថាខ្ញុំខកសន្យាហើយខ្ញុំក៏សុំឱកាសដើម្បីកែខ្លួនម្តងទៀត...បានទេ ? ណា៎ ? សុំជាមិត្តនឹងគ្នា សាជាថ្មី ម្តងទៀតបានទេ... អ្នកនាង ?

ធិតាងើបមុខសម្លឹងក្រសៃភ្នែកបុរសយើង ឃើញនរៈសម្តែង កិរិយាម៉ឺងម៉ាត់ នាងក៏ឆ្លើយថា :

- ខ្ញុំមិនចូលចិត្តទទួលសន្យាទេ ។ ពាក្យពេចន៍ពន្យល់អ្វី ក៏មិនមានតម្លៃស្មើនឹងការប្រព្រឹត្ត ដើម្បីបង្ហាញនូវទឹកចិត្តរបស់យើងដែរ...

- បើអ្នកនាងត្រូវការដូច្នោះ ខ្ញុំក៏នឹងបង្ហាញអោយឃើញមិនខាន ។

- ហើយខ្ញុំនឹងរង់ចាំទទួលការបង្ហាញទឹកចិត្តពិតប្រាកដរបស់លោកជានិច្ច បើសិនជាលោកប្រាថ្នាមកជាមិត្តដ៏ពិតប្រាកដមែន ។

ថាហើយ នាងក៏ឡើងជិះកង់ចេញសំដៅទៅទិសខាងកើតទុកឲ្យវិចិត្រឈរមើលនាងពីក្រោយយ៉ាងភ្លន់ភ្លឹក ។ ថ្វីបើធិតាស្លៀក ពាក់ដូចសិស្សសាលាចងសក់រៀបរយមើលទៅសាមញ្ញ សុភាពៗ ប៉ុន្តែបេះដូងគេនឹករំភើបព្រឺព្រួចនឹងសោភណ៍របស់នាងអ្វីម្ល៉េះទេ ។ គេមានអារម្មណ៍ហាក់ដូចជាខ្លួននាយកំពុងប្រែខ្លួន ជាក្មេងយុវជននិស្សិតដែលព្រើលលួចមើលរាងរៅរូបកាយនិស្សិតក្រមុំ ពីក្រោយ ដូច្នោះឯង ។ ស្រម័យចុះស្រម័យឡើងមួយស្របក់ គេគ្រវីក្បាល ហួសចិត្តនឹងអារម្មណ៍រាយមាយទាំងនោះបន្តិចមក ស្រាប់តែនឹក ភ្នកចង់ដឹងថានាងធ្វើការនៅឯណា ។ គេក៏ឡើងឡានរឹងបរតាមក្រោយធិតាយឺតៗមិនអោយនាងដឹងខ្លួន ។ ពេលនោះ គេបានឃើញមាណវីជិះកង់មកឈប់នៅមុខវិទ្យាល័យនេតយ៉ង់ រួចហើយ ក៏ចុះបណ្តើរកង់ចូលក្នុងសាលា :

- នាងជាគ្រូបង្រៀនវិទ្យាល័យនារី ? អញ្ចឹងតើ បានជាមានឫកពា និងសំដីមធ្យ័តម្ល៉េះ!

CHANBOKEO.COM

រសៀលនោះ វិចិត្រត្រូវទៅចូលរួមពិធីសូត្រមន្តនៅផ្ទះអ្នកគ្រូ ម៉ារ៉ាត់នៅជិតវត្តសង្កែ ។ គេក៏នាំផានេតទៅជាមួយដើម្បីកុំអោយ អផ្សុក ។ ការពិតផានេតនិងវិចិត្រជាមិត្តនឹងគ្នាតាំងពីនៅរៀន ហើយចេញធ្វើពេទ្យដំណាលគ្នាទៀតផង ។ នៅគ្រាដែលម្ចាស់ផ្ទះកំពុងទទួលភ្ញៀវ ផានេតអូសដៃវិចិត្រដើរទៅលេងនៅមាត់ស្ទឹង ហើយលួចនិយាយខ្សិបប្រាប់ថា :

- នែ៎ វិចិត្រ! គ្នាចំរុងក្លាយជាកូនកម្លោះឆាប់ៗនេះហើយណា៎!
- ពុទ្ធោ! មែនហ្ន៎ស?
- អឺ! ហើយឯងស្មគ្រ័ធ្វើកូនកំដរគ្នាទេ?

វិចិត្រមិនទាន់ឆ្លើយថាម៉េចផង ស្រាប់តែមានរថយន្តដេកាមីនីថ្មីស្រឡាងពណ៌សបើកដំបូលមួយ បានបរកាត់ទីនោះយឺតៗ ដោយ មានផ្ទុកនារីសោភាមួយរូបក្នុងសម្លៀកតែងកាយរបៀបអ៊ឺរ៉ុបកំពុង ជិះក្បែរនរៈសង្ហាជាអ្នកកាន់ចង្កូត ។ វិចិត្រមើលតាមគេទាំងពីរ ឡើងភ្លឹករហូតលែងឮពាក្យនិយាយរបស់ផានេតអស់រលីង ។ រីឯបុរសនារីនៅលើរថយន្តថ្មីស្រលាងមួយគូនោះ កំពុងតែជជែកគ្នា សើចរីករាយសប្បាយទំនងមិនបានឃើញវិចិត្រ និងមិត្តរបស់គេ នាមាត់ស្ទឹងសង្កែក្បែរវិថីដែលគេកំពុងបើកបរនោះទេ ។

- នែ៎ វិចិត្រ! ឯងសម្លឹងគេអីឡើងភ្លឹកយ៉ាងនេះ?
- នោ៎ះគឺលិនដាណា៎ ឯងមិនឃើញទេ?
- ចឹក៏មិនឃើញ ហើយវាយ៉ាងម៉េច?

ស្រាប់តែវិចិត្រដាក់ទឹកមុខជ្រប់ធ្វើមុខស្ងួតតែម្ដង ។ ផានេតឃើញហើយក៏យកដៃទះស្មាមិត្តលោមចិត្ត :

- បើឯងនិយាយចេញមកខ្លះ ប្រហែលជានឹងធូរចិត្ត នេះគ្នាអាច ឈរស្ដាប់រឿងឯងបានណា៎ កុំបៀមក្នុងចិត្តមុខក្រៀមអញ្ជឹងមើល៍!

តែវិចិត្របាត់រីករាយក្នុងចិត្តទៅហើយ នឹងហារនិយាយក៏លែង ចេញដែរ ។ ពេលនោះពិធីសូត្រមន្តក៏ចាប់ផ្ដើមឡើង ។ ផានេតក៏ ឡើងទៅលើផ្ទះអ្នកគ្រូម៉ារ៉ាត់ចូលរួមពិធីនឹងគេតែវិចិត្របែរជាដើរ ត្រលប់ក្រោយទៅមាត់ស្ទឹង សំកុកមើលទឹកហូរតែម្នាក់ឯង សម្ដែងកិរិយាហាក់ដូចជាចង់លោតទឹកអោយស្លាប់អញ្ជឹង ។ មួយស្របក់ មក គេក៏ដើរឈ្ងោកៗចេញទៅមិនដឹងថាចង់ទៅណាទេ ។ បន្តិច មកគេក៏មកដល់សួនកុមារ ។

- ប៉ា!

CHANBOKEO.COM

ក្មេងប្រុសម្នាក់រត់មកចាប់ជើងនាយជាប់ ។ វិចិត្រភ្ញាក់ព្រើតពី ការលង់អារម្មណ៍ក្នុងក្តីស្រម័យ ហើយក៏អោនឈ្ងោកមើល ស្រាប់ តែប្រទះនឹងកុមារាតូចដែលនាយបានជួបពីថ្ងៃមុន កាលនៅសួន យុវ័ន ។ អ្វីដែលគួរអោយភ្ញាក់ផ្អើលបំផុតនោះគឺ កុមារនោះហៅរូប គេថា ប៉ា ពីរដងហើយ ។ បុរសយើងស្ទុះចាប់លើកនាយពឡើង :

- ម៉េចបានមកលេងទីនេះតែម្នាក់ឯងឥចឹងអូនតូច ?

ស្រាប់តែកុមារចង្អុលទៅក្រោយ ឃើញបងស្រីរបស់នាង ដើរ ដឹកកង់មកដល់ :

- ការពិតអូនតូចមកជាមួយបងស្រីទេ ?
- បាទ!

កុមារសើចញញឹមដាក់វិចិត្រសម្តែងកិរិយាហាក់ដូចជាចូលចិត្ត រូបនាយណាស់ ។ បន្តិចមក វិចិត្រក៏សួរទៅនាងម៉ៅជាបងថា :

- ហើយចុះថ្ងៃនេះ បាត់ប្អូនស្រីតូចទៅណា ?
- ចាស់នៅផ្ទះ អូនបារមីមិនស្រួលខ្លួន ម៉ាក់មិនឲ្យខ្ញុំនាំដើរចេញ មកក្រៅផ្ទះទេ ។

បន្តិចមក នរៈក៏លើកពកុមារតូចឡើង ហើយក៏នាំក្មេងទាំងពីរ ទៅជិះទោងលេងយ៉ាងសប្បាយ ។ គេប្រលែងលេងជាមួយកុមារ តូចសើចរអឹកឥតឈប់ ។ មើលទៅកុមារភក្រ្តាមានអំណោយទាន ហើយស្លូតបូតគួរអោយស្រលាញ់ ។ ខណៈនោះមាណពភ្លេចអស់នូវ អារម្មណ៍ហ្មហ្មង ដែលរំខានចិត្តអំបាញ់មិញមុននេះ អស់រលីងតែម្តង ។ គេហាក់ដូចជាមាននិស្ស័យនឹងក្មេងតូចមួយរូបនោះ យ៉ាង ស្និទ្ធស្នាល ហើយមានអារម្មណ៍ហាក់ដូចជាកុមារនោះ ជាកូនរបស់ ខ្លួនបង្កើតអញ្ចឹង ។ មិននឹងហេតុអ្វីបានជាចិត្តគេចេះតែគិតប្លែកៗ របៀបនេះ ។ មិនយូរប៉ុន្មាន នាងម៉ៅក៏សុំខ្លួនឌុបប្អូនពីក្រោយ
កង់ ត្រលប់ទៅផ្ទះវិញ ។

រាត្រីនោះ វិចិត្រគប់ប្រមល់សាជាថ្មីទៀតហើយ ។ គេក៏ដើរ ចេញមកក្រៅ ទៅអង្គុយនៅរានហាលមុខផ្ទះ សម្លឹងមើលមេឃ នឹកទៅអតីតកាលមួយ ដែលនារីម្នាក់បានច្របាច់បេះដូងរបស់គេ អោយទន់ជ្រាយនិយាយមិនចេញ... ការពិតគេជាបុរសសង្ហាមួយ រូបដែរ ជានិស្សិតដែលរៀនពូកែបំផុតម្នាក់ដែរ ជាកូនសេដ្ឋីអភិជន ដែរ ជាវេជ្ជបណ្ឌិតដ៏ល្បីឈ្មោះម្នាក់ដែរ ប៉ុន្តែហេតុអ្វីក៏គេមានបញ្ហា បេះដូងទៅវិញ ?

CHANBOKEO.COM

តើគេមានអ្វីដែលល្អក់កករមករំខានជីវិតឬក៏ យ៉ាងណា
ទើបគេត្រូវឈឺចាប់ហើយខ្លាចរអាចំពោះស្នេហារហូត ទល់សព្វថ្ងៃនេះ.. ?

មួយស្របក់ក្រោយមក គេក៏ស្លៀកពាក់ហើយចេញបញ្ឆេះឡាន ស្រាប់តែពូខេមសួរ :

- លោកពេទ្យទៅណាដែរបាទ ?
- ទៅលំហែចិត្តបន្តិចពូ មួយស្របក់ទៀតខ្ញុំមកវិញហើយ ។

ពូខេមមើលតាមនរៈដែលបរឡានចេញទៅ ថែមទាំងនឹកឆ្ងល់ ក្នុងចិត្តមិនអស់មិនហើយថា :

- លោកគ្រូពេទ្យមិនដែលចូលចិត្តដើរលេងសោះ តែពេលនេះ
យ៉ាងម៉េចអញ្ចេះបានជាចេញទៅក្រៅទាំងយប់..ចម្លែកដល់ហើយ !

វិចិត្របរឡានមកដល់ស្ទួនយុវ័ន ហើយក៏ឈប់នៅមុខផ្ទះធិតា សោភារបស់គេ ។ ការពិត
គេនឹកនារីនោះទេតើ! បន្តិចមក គេក៏ ចូលទៅគោះទ្វារ ។ ពេលនោះ
ម៉ោង៩កន្លះយប់ទៅហើយ... កាល បើឃើញវត្តមានរបស់វិចិត្រនៅចំពោះមុខទាំងកណ្តាលយប់
ធិតា ភ្ញាក់ស្រលាំងកាំង :

- លោកគ្រូពេទ្យ ?
- គឺ...អោយខ្ញុំសូមចូលលេងផងបានទេ ?

ធិតាបើកទ្វារអោយវិចិត្រចូលទាំងចិត្តងឿងឆ្ងល់ តែមិនហ៊ាន សាកសួរអ្វីទេ
ត្បិតនាងឃើញទឹកមុខបុរសយើងប្រកបដោយភាព កង្វល់ ។ រំពេចនោះ ស្រាប់តែ :

- ប៉ា! ត្រានឹកប៉ាណាស់!

កុមារតូចម្នាក់រត់មកអោបជើងវិចិត្រទៀតហើយ ។ ទាំងវិចិត្រ
ទាំងមាណវីមើលមុខគ្នាសម្តែងការភ្ញាក់ផ្អើលទាំងពីរនាក់ ។ ការពិត គេនោះគឺជាកុមារតូច
ដែលវិចិត្របានជួបច្រើនដងច្រើនសារួចមក ហើយ ។ គ្រាន់តែឃើញវត្តមានរបស់កុមារតូចភ្លាម
វិចិត្រញញឹម ស្រស់តែម្តង រួចក៏សំរុតខ្លួនចុះ ទទួលគេក្នុងរង្វង់ដៃភ្លាមដែរ :

- យើងជួបគ្នាទៀតហើយ អូនតូច!

កុមារភក្ត្រាក៏ញញឹមឡើងរួចយកដៃស្រវាអោបកវិចិត្រ សំដែង
កិរិយាបថហាក់ដូចជាស្និទ្ធស្នាលគ្នា ហើយនឹករលឹកគ្នាណាស់ ។

ភ្លាមនោះ នាងតូចម៉ៅដើរដឹកដៃកូនស្រីតូច អាយុប្រហែលពីរ

CHANBOKEO.COM

ខួបចូលមកដល់ដែរ ។ វិចិត្រសម្លឹងទៅក្មេងទាំងបី រួចសម្លឹងមក ធិតាវិញ សម្តែងអាការៈហាក់ដូចជាមិនអស់ចិត្ត ។ ឃើញដូច្នោះ មាលាវីក៏ស្ទុះទៅទទួលភក្ត្រាកូនប្រុសរបស់នាងពីវិចិត្រវិញ :

- អោយខ្ញុំសូមទោសផងដែលកូនប្រុសខ្ញុំរពឹសបន្តិច ។
- បាទ! មិនអីទេ ។ គេជាកូនរបស់អ្នកនាងទាំងបីនាក់មែនទេ ?
- ចា៎ស! ពិតហើយលោកគ្រូពេទ្យ ។

ពេលនោះនាងក៏ប្រាប់កូនថា :

- ជំរាបសួរលោកគ្រូពេទ្យទៅកូន!

ទាំងបីនាក់លើកដៃសំពះម្តងមួយយ៉ាងមានរបៀប ។

- ពួកគេទាំងបី ពិតជាគួរអោយស្រលាញ់ណាស់!

វិចិត្រស្រដីទាំងទឹកមុខញញឹម ទំនងលបលួចរំជួលចិត្តតែម្នាក់ឯង ។ បន្តិចមកមាលាវីក៏ប្រាប់នាងម៉ៅអោយនាំប្អូនចូលដំណេក ។ ភ្លាមនោះវិចិត្រនឹកឆ្ងល់ក្នុងចិត្តតែម្នាក់ឯងថា មាលាវីយើងនៅក្មេង ស្រស់ស្អាត មិនសមនឹងមានកូនដល់ទៅបីនាក់ទេ ហើយគេចេះ តែលួចជួញចិញ្ចើមជាញឹកញយ ។ កិរិយារបស់មាលាពយើង មិន រំលងពីភ្នែករបស់កល្យាណីទេ ។ កល្យាណីហាក់ដូចជាស្ពានការណ៍ ក៏ស្រដីជំរាបទៅលោកគ្រូពេទ្យយើងវិញថា :

- ជីវិតជាស្ត្រីម៉េម៉ាយ មិនមានអ្វីគួរអោយចាប់អារម្មណ៍ទេ លោក គ្រូពេទ្យ! សូមមេត្តាកុំទើសទាល់ក្នុងចិត្តអី!
- អូហ៍! អត់ទេ! ការពិត ខ្ញុំកំពុងតែនឹកស្ងើចទៅវិញទេ ដែល អ្នកនាងមានភាពរឹងប៉ឹងទទួលខុសត្រូវជីវិតរបស់កូនបានយ៉ាងល្អ...

មាលាពនិយាយបន្លប់មិនអោយនាងមានអារម្មណ៍មិនល្អ ។

- គឺ...តាមតែលទ្ធភាពទេលោកគ្រូពេទ្យ..ព្រោះខ្ញុំមិនសូវមានពេល ជាមួយកូនប៉ុន្មានទេ អាល័យតែជាប់ធ្វើការ ម៉្ងៃៗយកកូនផ្ញើនឹងគេ រហូតដល់ក្មេងៗស្គាល់អ្នកជិតខាងជាងស្គាល់ម្តាយខ្លួនទៅហើយ ។

ធិតាស្រដីដោយទឹកមុខស្រងូតហាក់បីដូចជាកំពុងស្រណោះកូន ដែលមិនសូវមានវេលាជិតដិតនឹងរូបនាងជាម្តាយ ។ បន្ទាប់មក គេ ទាំងពីរនៅស្ងៀមស្ងាត់យ៉ាងយូរ មិនដឹងថាត្រូវនិយាយអ្វីដាក់គ្នា

CHIANBOKEO.COM

ទៀត ។ បន្តិចមក ធិតាក៏លើកទឹកត្រជាក់មួយកែវមកជូនលោកគ្រូពេទ្យយើង :

- ថ្ងៃនេះ មេឃដូចជាស្អុះស្អាប់បន្តិច ប្រហែលជាទឹកត្រជាក់មួយកែវនេះនាំឲ្យចិត្តលោកក្សេមក្សាន្តខ្លះៗ (មាណវីពោលឡើង)

វិចិត្រភ្ញាក់ព្រើត នឹកក្នុងចិត្តថា :

- ម៉េចក៏នាងដឹងកើត...ថាយើងកំពុងធុញថប់តប់ប្រមល់ក្នុងចិត្ត ? ឬក៏នាងកំពុងចាប់អារម្មណ៍មកលើរូបយើងដែរ ?

គេយកដៃទទួលកែវទឹកហើយមួយស្របក់ក៏ដាច់ចិត្តវាចាដោយត្រង់ៗទៅនាងថា :

- នេះយើងជួបគ្នាច្រើនដងហើយ តែយើងមិនដែលបានណែនាំខ្លួនអោយស្គាល់គ្នានៅឡើយទេណា៎! ថ្ងៃនេះយើងគួរនិយាយគ្នាម្តង បានទេ ដើម្បីអោយយើងមានការជិតដិតនឹងគ្នាជាងនេះ !

ធិតាងើបមុខឡើងសម្លឹងមុខលោកគ្រូពេទ្យ ហាក់ដូចជាយល់ចិត្តថាលោកគ្រូពេទ្យកំពុងមានបំណងចង់និយាយពីអ្វីហើយ :

- តើសមរម្យទេ ដែលលោកនិងខ្ញុំ ទៅមកនឹងគ្នាជិតដិតនោះ ? ហើយចុះចំពោះភ្នែកញាតិវិញ...តើគេនឹងគិតយ៉ាងណា ?

- ខ្ញុំមិនខ្វល់ទេថានរណាគិតយ៉ាងណា...ដែលខ្ញុំខ្វល់បំផុតគឺថាតើអ្នកនាងព្រមអនុញ្ញាតឲ្យយើងទាំងពីរស្គាល់គ្នាជិតដិតដែរឬទេ ?

កល្យាណីឈ្ងោកមុខមួយស្របក់ ទំនងគិតស្មានយល់នូវជំរៅអត្ថន័យនៃសំណើលោកគ្រូពេទ្យយើង ទើបស្រដីតបថា :

- លោកជ្រាបហើយតើហ៎ ថាខ្ញុំជាស្ត្រីមេម៉ាយ មានកូនដល់ទៅបី នាក់នៅក្នុងបន្ទុក មិនមានកត្តិយសអ្វីនឹងមកទទួលលោកជាមនុស្ស ជិតដិតបានទេ...
សង្គមខ្មែរយើងពិតជាចង្អៀតណាស់ មិនទុកផ្លូវ ទូលាយអោយស្ត្រីមេម៉ាយដូចរូបខ្ញុំ
មានសេរីភាពជ្រើសរើសបុរស
ថ្មីសំរាប់ជីវិតបានឡើយ ជាពិសេសបើសិនជាបុរសនោះនៅលីវ...

- ខុសហើយអ្នកនាង! សង្គមយើងនឹងទុកផ្លូវយ៉ាងទូលាយបំផុត សំរាប់យើងដើរទាំងពីរនាក់ បើសិនណាយើងកាន់ដៃគ្នាជិតដិតចិត្ត តែមួយ

CHANBOKEO.COM

រួចដើរទៅជាមួយគ្នាដោយភាពស្មោះស្នេហ៍ហើយថ្លៃថ្នូរ ។
សង្គមគេនឹងលើកកម្លាំងចិត្តយើងកាន់តែខ្លាំង ហើយគេច្បាស់ជា
នឹងសរសើរដែលយើងអាចស្វែងរកសេចក្តីសុខនិងសុភមង្គលបានសាជាថ្មីដោយជោគជ័យហើយរុងរឿង ។
- លោកមានប្រសាសន៍ ហាក់ដូចជាលោកអាចទទួលស្ថានភាព គ្រួសាររបស់ខ្ញុំបានអញ្ចឹង ?
យើងនៅមានអ្វីៗដែលត្រូវរៀនពីគ្នា ច្រើនទៀត... ជីវិតមនុស្សមានកូនចៅ
មិនដូចអ្នកនៅលីវទេ គឺមានភារៈទទួលខុសត្រូវច្រើនណាស់ ។
- ក្រែងអ្នកនាងចង់ឃើញការពិត តាមរយៈការប្រព្រឹត្តមែនទេ ? បើដូច្នោះមែន
អ្នកនាងអោយឱកាសខ្ញុំទេ បើខ្ញុំចង់បង្ហាញពីទឹកចិត្ត របស់ខ្ញុំ ថាខ្ញុំគិតយ៉ាងណា ប្រព្រឹត្តយ៉ាងណា
ចំពោះអ្នកនាងនិង បុត្រទាំងបី ?
- លោកមិនខ្លាចអ្នកផងគេសើចយំទេហ៍ ?
- ខ្លាចធ្វើអ្វី ? អ្នកសើចយំ គឺជាអ្នកដែលខ្វះមធ្យោបាយរកសេចក្តី
សុខសំរាប់ខ្លួនគេដោយសុក្រិតមិនឃើញ ទើបគេមានចិត្តគំនិតគិត ប្រទុស្តជាមួយអ្នកដទៃ...
នោះគឺជាសេចក្តីច្រណែនដែលជីវិតគេ វង្វេងរកពន្លឺរស្មីសុភមង្គលមិនបាន...
ម្ល៉ោះហើយគេគិតឃើញឬ
សម្លឹងឃើញតែពីភាពចង្អៀតចង្អល់ក្នុងជីវិតតែម្យ៉ាងប៉ុណ្ណោះ ។
- ចរណៃពិតជាសប្បាយចិត្តជាទីបំផុតបើសិនជាលោកគ្រូពេទ្យមាន
សមានចិត្តចំពោះយើងទាំងបួននាក់ដូច្នោះប្រាកដមែន ជាពិសេស
កាលបើលោកព្រមទទួលស្គាល់ជីវិតស្ត្រីម៉េម៉ាយដូចរូបខ្ញុំនេះ ដោយ
មិនរើសអើង ។

ខណៈនោះ លោកគ្រូពេទ្យញញឹមពព្រាយឡើង កាលបើឮធិតា
ហៅខ្លួនឯងថា"ចរណៃ" ។ ឃើញវិចិត្រសម្លឹងមុខនាងដោយ ក្រសៃភ្នែកយ៉ាងស្រទន់
ប្រកបដោយមន្តស្នេហ៍ផ្អែមត្រជាក់ ធ្វើ ឲ្យធិតាយើងហាក់ដូចជានឹករអៀសខ្លួនតែម្តង ។
ចរណៃឈ្ងោកមុខ មិនហ៊ានសម្លឹងតបទៅគេវិញទេ ហាក់ដូចជាញាប់ញ័រក្នុងចិត្តយ៉ាង
ណាមិនដឹង ។ ហេតុអ្វីទៅហ្ន៎បានជានាង ត្រូវខ្លាចក្រសៃភ្នែកនោះ ផង
កាលបើលោកគ្រូពេទ្យមានកិរិយា ទន់ភ្លន់សុភាពរាបសា ចំពោះរូបនាងដល់ម្លឹង ?

CHANBOKEO.COM

វិចិត្របាក់ដូចជាមានអារម្មណ៍រីករាយណាស់ពេលនេះ ដែលគេ
អាចនិយាយចុះសម្រុងជាមួយចរណៃបាន ថ្វីបើគេមិនទាន់ដឹងថា
នាងគិតយ៉ាងណាចំពោះនាយនៅឡើយក៏ដោយ ។ មែនហើយ! គេ នឹកខកចិត្តតិចៗដែរ
ដែលនាងជាស្ត្រីមេម៉ាយមានកូនដល់ទៅបី នាក់
ប៉ុន្តែគេនៅតែចាប់អារម្មណ៍ចំពោះរូបនាងក្រៃលែង រកកោះ រកត្រើយមិនឃើញទេ ។
គេមិនដឹងថាគេប្រតិពទ្ធ័ រូបនាងតាំងពី កាលណាឡើយ
គ្រាន់តែដឹងថាគេមានអារម្មណ៍ជាប់ជំពាក់ចំពោះ នឹងនារីរកពាក្យអ្វីថ្លែងស្មើមិនបានឡើយ ។
បែរមើលទៅមាណវី វិញក៏មានកិរិយាម៉ឹងម៉ាត់ សំដីរាក់ជ្រៅបង្ហាញនូវការមានជំនឿលើ
ខ្លួនឯងយ៉ាងមុតមាំ ។ រូបសម្ផស្សទៀតសោតក៏សមសោភា មើល យូរកាន់តែល្អ
កាន់តែស្រស់ស្អាត ថ្វីបើនាងមានទឹកមុខស្មើៗ មិន សូវញញឹមរីករាយប៉ុន្មានក៏ដោយ
ក៏សោភ័ណរបស់នាង អណ្តែត
លេចធ្លោឡើងជានិច្ច គាប់ទ័យានរៈយើងឥតឧបមា ។

មាណវីដើរចេញមកក្រៅជូនដំណើរលោកគ្រូពេទ្យទៅផ្ទះ ។

- សុំកាន់ដៃផងណា! (លោកគ្រូពេទ្យខិនខ្សិបតិចៗ ក្បែរត្រចៀក
កល្យាណីដោយវាចាយ៉ាងស្រទន់)

ចរណៃភ្ញាក់ព្រើតដែលវិចិត្រស្រវាកាន់ដៃនាង មុននឹងនាង ហើបមាត់អនុញ្ញាត្ត ។
នាងរំជួលញាប់ញ័រក្នុងខ្លួនភ្លាម តែមិនបាន ដកដៃមកវិញទេ
ត្បិតពេលនោះនាងមានអារម្មណ៍ថាខ្លួនបានទទួល សេចក្តីសុខយ៉ាងចម្លែកនៅក្នុងបេះដូង ។
ឃើញនាងមិនស្រដីអ្វី វិចិត្រក៏ ដើរកាន់ដៃឆវីរហូតដល់មាត់របងទាំងទឹកមុខញញឹមដោយ
ក្តីរំភើប..

- ស្អែកយើងជួបគ្នាទៀតទេ អ្នកនាង ? (វិចិត្រសួរ)
- លោកអាចឆ្លៀតមកលេងពួកយើងបានដែរ ?
- ម្តងនេះ ខ្ញុំមិនសន្យាទេ ខ្លាចធ្វើអោយអ្នកនាងខកចិត្តទៀត...
- ដឹងខ្លួនមុនដូច្នេះ... ល្អហើយ!

ឮនាងនិយាយដូច្នោះ វិចិត្រក៏ញញឹមឡើង រួចនិយាយលលេង តលប់ទៅវិញថា :

- ទើបតែខុសលើកទីមួយទេ នៅសល់ច្រើនដងទៀតឯណោះ...តើ អ្នកនាងអាចទទួលបានទេ ?
- អញ្ចឹងលោកសាកមើលទៅ...នឹងអាលឆាប់ដឹងលទ្ធផលផង ។

CHANBOKEO.COM

កាលបើឃើញនាងស្រដីតបទៅមកជាមួយគេ ដោយមិនសូវជា ខ្លាចចិត្តដូចមុន វិចិត្រហាក់ដូចជារំភើបរីករាយចិត្តណាស់ ។ គេ
បែរញញឹមដាក់នាងជាចុងក្រោយ :
- យប់នេះ សុបិនឃើញខ្ញុំផងណា៎ អ្នកនាង!
ស្រាប់តែធិតាញញឹមឡើង តបមករូបនាយវិញជាលើកដំបូង ។ នៅក្រោមពន្លឺភ្លើងគោមដែលចាំងពីផ្លូវថ្នល់ទៅ វិចិត្រឃើញថ្ពាល់ខួចយ៉ាងស្រស់មួយគូលេចធ្លោយ៉ាងត្រកាល ធ្វើឲ្យនាយនឹករំភើប ព្រឺព្រួចក្នុងអារម្មណ៍ឥតឧបមា ។ រំពេចនោះ មាណពក៏ឆក់ឱកាស យកច្រមុះទៅផ្ដិតលើថ្ពាល់ធិតាយ៉ាងរហ័ស រួចក៏ឡើងរថយន្តចេញ
ទៅ ទុកឲ្យចរណៃនៅឈរភ្ញាក់ផ្អើលញាប់ញ័រក្នុងចិត្តតែម្នាក់ឯង ។
រាត្រីនោះ មាណពគេងព្រឺព្រួចក្នុងហឫទ័យពេកក្រៃ ស្រម័យឃើញស្នាមញញឹមលើថ្ពាល់ខួចមួយគូនោះរហូតទាល់ភ្លឺ ។ នរៈគេងពិចារណាយ៉ាងល្អិតល្អន់ថាគេសំរេចចិត្តនេះខុសឬត្រូវ ។ តើគេពិតជាអាចទទួលយកនាងជាគូជីវិតបានឬក៏យ៉ាងណា ? នៅក្នុងក្រសែ ភ្នែករបស់គេ ចរណៃគឺជានារីដ៏ល្អម្នាក់ ។ ថ្វីបើនាងជាស្ត្រីមេម៉ាយ មានកូនចៅក៏ដោយ ក៏ឆវីមានការសិក្សា មានការងារជាគ្រូបង្រៀន នៅវិទ្យាល័យនារី មានកិរិយាឫកពាសមរម្យ ហើយជាពិសេសគឺរក្សាគ្រប់គ្រងកូនបានយ៉ាងប្រពៃ ទោះបីនាងគ្មានបុរសនៅក្បែរ
ចាំជួយជ្រោមជ្រែងពីក្រោយក៏ដោយ ។ នេះសបញ្ជាក់ថានាងជានារី
ដ៏រឹងប៉ឹងមួយរូបគួរអោយកោតសរសើរបំផុត ។ ម្យ៉ាងទៀត នាង មានចរិតលក្ខណៈជាស្ត្រីខ្មែរ និយាយស្ដីមានលក្ខណ៍មានជា ប្រកប ដោយការគិតវែងឆ្ងាយ ។
ប្រសិនមាណពភពប្រសព្វជីវិតជាមួយ នាង គេប្រាកដជានឹងបានទទួលនូវភាពស្ងប់សុខ មិនជ្រួលច្របល់ មិនភ្លើតភ្លើន ដូច្នោះជីវិតគ្រួសាររបស់គេច្បាស់ជាមានលំនឹងហើយ គង់វង្ស មិនប្រួលប្រែដូចសេចក្ដីស្នេហាយុវវ័យដែលស្គាល់តែភាព ពុះកញ្ជ្រោល ទីបំផុតក៏ចែកផ្លូវគ្នា ។
ពេញមួយរាត្រីកន្លងទៅ នរៈ គេងពិចារណាយ៉ាងល្អិតល្អន់ក្រៃលែង ថាថ្ងៃស្អែកនេះ នាយត្រូវធ្វើអ្វីខ្លះសំរាប់ជីវិតរបស់គេ ។
រីឯចរណៃរបស់យើងវិញ...

នៅចំពោះមុខរូបថតរបស់ស្វាមីនាង នាងអុជធូបលើកដៃទាំង គូប្រណម្យសំពះឡើង បន់ស្រន់ថា :

- បងខ្លា! តើអូនណែធ្វើខុសឬទេ ដែលអនុញ្ញាតអោយគេម្នាក់ នោះចេញចូលផ្ទះយើង? តើណែគួរទទួលគេបែបណា? មើលទៅ គេ ហាក់ដូចជាមានបំណងល្អមកលើណែនិងកូន... ប៉ុន្តែ...តើណែ គួររស់នៅរបៀបនេះរហូតទៅ ឬក៏ណែត្រូវរៀបដំណើរជីវិតថ្មីមួយ ទៀត? តើជីវិតបែបណា ដែលជាការជ្រើសរើសដ៏ត្រឹមត្រូវសំរាប់ អូននិងកូនរបស់យើង? បងខ្លា... ជួយពង្រឹងកម្លាំងចិត្តអូនផង ។ តាំងពីបងឃ្លាតពីយើងទាំងបួននាក់ទៅ អូនបានប្រឹងប្រែងគ្រប់បែបយ៉ាង ដើម្បីរក្សាភាពកក់ក្តៅ អោយកូនមានលំនឹងក្នុងជីវិត ។ ឥឡូវនេះ បុរសមួយរូបកំពុងដើរចូលមកក្នុងជីវិតរបស់អូនហើយ... អូនមិនដឹងថា តើអូនត្រូវតាំងចិត្តបែបណាទេ គ្រាន់តែដឹងថាអូន នឹងរក្សាព្រំដែនរបស់យើង អោយស្ថិតនៅក្នុងភាពថ្លៃថ្នូរជានិច្ច ។ ប្តីសម្លាញ់! ពេលនេះ បងជាបង្អែកកម្លាំងចិត្តតែមួយគត់របស់អូន សូមបងជួយណែនាំផ្លូវដល់អូនផងណា៎បង!

ប៉ុន្តែរង្វង់ភក្ត្រ័ពណ៌សខ្មៅរបស់បុរសនៅលើរូបថតនៅតែរក្សា ភាពញញឹមយ៉ាងបំព្រងចំពោះភរិយារបស់គេ ដោយគ្មានស្លាកស្នាម អារិចិត្តអ្វីឡើយ ។ បន្តិចក្រោយមក មាណវីក៏ចូលនិន្ទ្រាទាំងដួងចិត្ត ច្របូកច្របល់ ។

ព្រហាមឡើង...

ចរណៃក្រោកពីព្រហាមតាមទម្លាប់ ដាក់ឆ្នាំងដាំបបរអោយកូន ស្រស់ស្រូបពេលព្រឹក ។ លុះមាណវីដាក់ភ្នែកទៅចំហៀងផ្ទះឃើញ ផ្កាម្លិះរួតកំពុងរីកស្គុះស្គាយ ក៏នឹកភ្នករកបេះយកមកក្រងឲ្យកូន ស្រីពាក់លេង ។ កល្យាណក៏កាន់ផ្តិលសមួយទៅឈរបេះ ស្រាប់តែ មានដៃមួយបេះផ្កាម្លិះមួយទង យកមកសៀតសក់ឲ្យនាងផ្អមៗ ។ ឆវីបែរងាកមើលយ៉ាងរហ័ស ក៏ប្រទះនឹងបុរសម្នាក់ឈរពីក្រោយ ខ្នង កំពុងតែញញឹមពព្រាយដាក់នាង :

- លោកគ្រូពេទ្យ!

មែនហើយ! គេនោះជាវិចិត្រដែលកំពុងញញឹមយ៉ាងស្រស់ បំព្រងដាក់ចរណៃ ធ្វើឲ្យបរិយាកាសពេលព្រឹកនេះមានសោភ័ណ ខុសប្លែកពីធម្មតាតែម្តង :

- អរុណសួស្តី ទេពធិតាចរណៃដ៏ស្រស់ស្អាត! (វិចិត្រស្រដីឡើង)

មាណវីភ្ញាក់ក្រញាងកាលបើឮវិចិត្រហៅឈ្មោះនាងដូច្នោះ :

CHANBOKEO.COM

- ម៉េចក៏លោកស្គាល់ឈ្មោះនេះដែរ ?

វិចិត្រញញឹមតែមិនឆ្លើយទេ ត្បិតធិតាភ្លេចខ្លួនថានាងបានហៅឈ្មោះខ្លួនឯងកាលពីយប់មិញ ។ ឃើញធិតានៅតែឈរភាំងសម្លឹងមុខរបស់នាយ វិចិត្រក៏ស្រដីឡើង :

- ហេតុអ្វី ចរណៃធ្វើមុខចម្លែកម្ល៉េះ ?

វិចិត្រស្រដីហៅឈ្មោះធិតាចំៗ ហាក់ដូចជាចង់សំដែងនូវភាពស្និទ្ធិស្នាលរបស់ខ្លួនចំពោះនាង ។ ខណៈនោះ មាណវីតបវិញថា :

- ព្រោះ...មានតែមនុស្សម្នាក់ទេ ដែលធ្លាប់ហៅឈ្មោះខ្ញុំបែបនេះ

- ប្រាកដជាបុរសទីមួយរបស់ចរណៃហើយ មែនទេ ?

ស្រាប់តែនាងធ្លាក់ទឹកមុខជ្រប់កាលបើឮដូច្នោះ ។ វិចិត្រឃើញហើយប្រញាប់លោមវិញកុំអោយនាងស្រកស្រុតកម្លាំងចិត្ត :

- ប៉ុន្តែ ចរណៃក៏ជា... ទេពធិតាមួយរូបក្នុងចិត្តរបស់ខ្ញុំដូចគ្នាដែរ... សូមអនុញ្ញាត្តអោយខ្ញុំហៅដូច្នេះផងបានទេ ?

ភ្លាមនោះ ស្រាប់តែនាងស្រក់ទឹកភ្នែកតក់... មួយតំណក់ហើយ មួយតំណក់ទៀត ហាក់ដូចជាកំពុងញាប់ញ័រនឹងស្រមោលអតីតកាល ដែលត្រលប់មករណ្តំនៅដួងចិត្តរបស់នាងសាជាថ្មី ។ មាណពឃើញ ហើយ ក៏លើកដៃផ្តិតទឹកភ្នែករបស់នាង ដែលហូរស្រក់មកលើថ្ពាល់ ទាំងគូដ៏ក្រហមរលោង ហើយស្រដីលួងលោមថា :

- ចរណៃ! ការរំសាយស្រមោលអតីតកាលពីអារម្មណ៍ជាការពិបាក បំផុត ប៉ុន្តែជួនកាលយើងត្រូវតែពង្រឹងចិត្តទទួលយកបច្ចុប្បន្នវិញ ក្រែងឆ្លងផុតតំណក់ទឹកភ្នែកទាំងនោះ ហើយធ្វើដំណើរទៅមុខទៀត ដោយរឹងប៉ឹង ។ អតីតកាលមិនអាចវិលវិញមកជួបយើងម្តងទៀតឡើយ ប៉ុន្តែអនាគតទេតើ ដែលនឹងឈានចូលមកដល់ ។ ដូច្នេះ អ្នកនាងត្រូវតាំងចិត្តរឹងមាំថ្ងៃនេះ ដើម្បីទទួលយកអនាគតថ្មីៗល្អៗ ទាំងនោះវិញ នោះជីវិតនឹងចាកផុតអន្លង់ទុក្ខទាំងឡាយ ។ តាំងចិត្ត អោយរឹងប៉ឹងឡើងណា៎ ហោចណាស់អ្នកនាងនៅមានរូបខ្ញុំដែរជា កម្លាំងចិត្ត... យើងនឹងដើរទៅមុខជាមួយគ្នាដោយមុតមាំ... អ្នក នាងមានអតីតកាលដែលត្រូវរំសាយទៅ ។ ឯរូបខ្ញុំវិញក៏មានអតីត កាលដែលត្រូវរំសាយទៅដែរ ។ ពេលនេះ ដល់ពេលហើយទេដឹង

CHANBOKEO . COM

ដែលយើងទាំងពីរគួរដើរទៅមុខជាមួយគ្នាដើម្បីទទួលយកអនាគត ថ្មីដ៏ល្អហើយភ្លឺស្វាងបំផុតសំរាប់ជីវិតរបស់យើងទាំងពីរ ?

គ្រាន់តែឮប្រយោគនេះកាលណា ស្រាប់តែនិតាទ្រោបមុខលើ ដើមទ្រូងរបស់បុរសយើងយំខ្សឹកខ្សួលតែម្តង ធ្វើអោយបុរសយើង ភ្ញាក់ស្រលាំងកាំងមហិមា ។ គេក៏យកដៃទៅអង្អែលខ្នងឆរីបន្តើរៗ ថ្នមៗ ហាក់បីដូចជាកំពុងជួយបបោសលួងលោមដួងចិត្តរបស់នាង អោយបានធូរស្រាលឡើងវិញ :

- សូមឲ្យទឹកភ្នែកទាំងនេះ ជាទឹកភ្នែកចុងក្រោយបង្អស់ក្នុងជីវិត របស់ចរណៃ ។ ចាប់ពីថ្ងៃនេះតទៅ សូមអោយជីវិតថ្មីប្រកបដោយ ភាពញញឹមជានិរន្តន៍....

មួយស្របក់ក្រោយមក និតាក៏ងើបមុខឡើងជូតទឹកភ្នែកពីរង្វង់ ភក្រ្ត័ដ៏ស្រស់ស្អាត រួចហើយក៏វាចាទៅកាន់មាណពថា :

- អរគុណលោកណាស់ ចំពោះពាក្យណៃនាំដ៏ពិរោះ ហើយមាន អត្ថន័យបំផុតនេះ ។ ណៃនឹងខំពង្រឹងចិត្តអោយបានរឹងមាំជាងនេះ មិនខាន មិនអោយអតីតកាលមកធ្វើបាបដួងចិត្តអោយគ្រាំគ្រារហូត តទៅទៀតទេ ។

វិចិត្រសម្លឹងមុខនិតាមួយស្របក់ ក៏លូកស្រវាចាប់ដៃនាងយក មកកាន់យ៉ាងណែន ថែមទាំងស្រដីថា :

- ចរណៃ! បងធ្វើដំណើរមកជួបអូនយឺតពេលបន្តិចមែន ដែល បងមិនអាចធ្វើជាបុរសទីមួយក្នុងបេះដូងរបស់អូនបាន ប៉ុន្តែសូម ណៃអនុញ្ញាតអោយបងទទួលនាទី ជាបុរសចុងក្រោយបង្អស់របស់ ណៃ ចាប់ពីពេលនេះតទៅលុះអវសានជីវិត... បានទេ ?

និតាងើបសម្លឹងមុខវិចិត្រមួយស្របក់ ក៏ឆ្លើយវិញថា :

- ដូចជាលឿនពេកទេដឹង  លោកគ្រូពេទ្យ ? យើងមិនទាន់ស្គាល់ គ្នាច្បាស់នៅឡើយទេ មិនដឹងថាយើងអាចចុះសម្រុងនឹងគ្នាបាន ឬក៏យ៉ាងណា...

- បើអញ្ចឹង យើងរៀនស្គាល់គ្នាពីឥលូវនេះទៅ យ៉ាងម៉េចដែរ ?

- សូមលោកទុកពេលអោយខ្ញុំត្រៀមចិត្តផងណា៎!

- បាទ! ដោយសេចក្តីពេញចិត្តបំផុតពីជំរៅបេះដូងរបស់បង!

ពេលនោះ គេទាំងពីរក៏សម្លឹងកែវភ្នែករបស់គ្នាទៅវិញទៅមក ហើយញញឹមដាក់គ្នាឡើងជាលើកដំបូង... ជាស្នាមញញឹមដែលមាន

CHANBOKEO.COM

បង្កប់នូវសុភមង្គលថ្មីក្នុងដួងចិត្តយ៉ាងបំព្រងមួយ ។ នរៈបានទទួល អារម្មណ៍ថា បេះដូងរបស់គេកំពុងតែទទួលនូវកំស្ទួលនៃសេចក្តី សុខក្នុងដួងចិត្តមួយដ៏ត្រចះត្រចង់ ។ បន្តិចមក គេក៏ស្រដីទៅកាន់ ចរណៃបន្តទៀតថា :

- ណៃនឹងទេ ? ពេលណៃញញឹម អូនស្រស់ស្អាតណាស់! ដូច្នេះ អូនគួរតែញញឹមអោយបានច្រើនបំផុតណាអូន... ភាពញញឹមរបស់ អូននឹងធ្វើអោយអ្វីៗជុំវិញខ្លួនរបស់អូន រីកស្រស់បំព្រងហើយមាន សោភ័ណល្អត្រកាលប្រសើរឡើង រួមទាំងបេះដូងរបស់បងផង...!

ព្យប្រយោគដ៏ទន់ភ្លន់នេះកាលណា ធិតារំភើបចិត្តរហូតទឹកភ្នែក រលីងរលោង ។ ពេលនេះ គូស្នេហ៍ទាំងពីររូបហាក់ដូចជាយល់ចិត្ត គ្នាកាន់តែច្បាស់ជាងមុនឆ្ងាយណាស់ ។ ចំពោះវិចិត្រ គេមិនគិតទេ ថាចរណៃធ្លាប់មានអតីតកាលយ៉ាងណា ។ អ្វីដែលគេកំពុងគិតគឺគេ ស្រលាញ់ចរណៃ ហើយគេមានបំណងរួមអនាគតជាមួយនាងដោយ មិនរើសអើង ។ ចំពោះចរណៃ វិចិត្រមានអ្វីៗខ្លះៗស្រដៀងនឹង អតិតស្វាមីជាទីស្រលាញ់របស់នាង ជាពិសេសគឺចិត្តត្រជាក់ហើយ ស្ងប់ស្ងៀម និយាយស្តីអ្វីប្រកបដោយគតិភ្លឺថ្លា ធ្វើអោយចិត្តនាង ទទួលការកក់ក្តៅរកអ្វីប្រៀបមិនបាន ។ ថ្វីបើនាងទើបតែស្គាល់ វិចិត្រមិនបានប៉ុន្មានផង តែឥរិយាបថនិងនិស្ស័យរបស់គេ បានធ្វើ ឲ្យដួងចិត្តរបស់នាងមានភាពកក់ក្តៅគួរចាប់អារម្មណ៍ជាទីបំផុត ។

- ប៉ា! ម៉ាក់! ត្រាភ្ញាក់ពីគេងហើយ ។

វិចិត្រនិងចរណៃភ្ញាក់ព្រើត បែរក្រោយមើល ក៏ប្រទះនឹងកុមារ តូចដែលទើបតែភ្ញាក់ពីដំណេករត់មកដល់ ។ គ្រាន់តែយល់វត្តមាន របស់ភក្រ្តា វិចិត្រញញឹមភ្លាម ហើយក៏ស្ទុះទៅលើកកុមារពឡើង ថើបខ្សឺតដោយក្តីស្រលាញ់ ថែមទាំងស្រដីប្រាប់ចរណៃថា :

- អូនឃើញទេ ? សូម្បីតែកូនរបស់អូនក៏ព្រមទទួលស្គាល់បងជា សមាជិកគ្រួសាររបស់អូនដែរ... គេបានបងថា ប៉ា តាំងពីថ្ងៃដំបូង ដែលបងបានជួបនឹងគេនៅសួនយុវ័ននោះម្ល៉េះ ។ កាលនោះបង មិនទាំងដឹងផង ថាគេជាកូនប្រុសរបស់អូន ។

បន្តិចមក នាងម៉ៅក៏ពកុមារីតូចជាប្អូនពៅមកដល់ ។ ចរណៃក៏ ណៃនាំវិចិត្រអោយស្គាល់ :

- នេះ កូនម៉ៅ និងកូនស្រីពៅរបស់ខ្ញុំឈ្មោះបារមី ។ គេជាក្មេង ល្អ...សង្ឃឹមថាទាំងអស់គ្នាមិននាំឲ្យលោកចង្អៀតចង្អល់ចិត្តពេកទេ

CHANBOKEO.COM

- បងអាចទទួលបានណា៎... អូនកុំព្រួយអី!

វិចិត្រក៏លូកដៃទៅត្រកងនាងតូចបារមីពីដៃនាងម៉ៅជាបង រួច ហើយញញឹមឡើងថែមទាំងស្រដីថា :

- ប៉ាសូមទទួលស្គាល់កូនទាំងបីជាកូនរបស់ប៉ា ចាប់តាំងពីពេលនេះតទៅ...!!

មាណពស្រដីទាំងទឹកភ្នែករលីងរលោង ដោយការរំភើបចិត្ត ក្រៃលែង ដែលថ្ងៃនេះរូបគេលែងត្រមង់ត្រមោចតទៅទៀត ហើយ ។ រីឯចរណៃវិញក៏មិនខុសគ្នាដែរ ។ នាងមិនអាចប្រកែក បានទេ ថានាងមិនរំភើបចិត្តនោះ ទោះបីស្ថានការណ៍ថ្មីបានខិតចូលមកក្នុងគ្រួសាររបស់នាង យ៉ាងលឿនរហ័សបន្តិចពេកក៏ដោយ ។ កាលបើយល់កិរិយារបស់លោកគ្រូពេទ្យចំពោះកូនរបស់នាង ធិតាហាក់ដូចជារន្ធត់ញាប់ញ័រក្នុងចិត្តឥតឧបមា ដែលគេហ៊ានបើកចំហដួងចិត្តរបស់គេចំពោះនាងនិងកូនដោយឥតលាក់បាំង ។ មើលទៅគេហាក់ដូចជាបានត្រៀមចិត្តទុកតាំងពីកាលណាមកឥចឹង! សុខៗស្រាប់តែវត្តមានរបស់គេលេចធ្លោ មកក្នុងរង្វង់គ្រួសាររបស់មាណវី រួចហើយជួបគ្នាមិនបានប៉ុន្មានដងផង ស្រាប់តែមាណពមកបង្ហាញទឹកចិត្តយ៉ាងជិតដិតស្និទ្ធស្នាលចំពោះគ្រួសាររបស់នាង... ហេតុអ្វីក៏ លឿនម្ល៉េះ ? ធិតាពិតជាមិនយល់ទេ... ប៉ុន្តែទោះជាយ៉ាងណា នាងមិនត្រូវការចម្លើយតបចំពោះចម្ងល់នេះទាំងអស់នោះឡើយ ត្បិតអី ពេលនេះបេះដូងរបស់នាងបានទទួលនូវភាពកក់ក្តៅ យ៉ាងធំធេង ទៅហើយ ដែលមានបុរសចូលខ្លួនមកទទួលភារៈជាមេគ្រួសារ របស់នាង មិនឲ្យជីវិតរបស់នាងនិងកូនរងភាពរងាតទៅទៀត ។ ធិតាញញឹមឡើងយ៉ាងបំព្រង កាលបើនាងបានឃើញកូនទាំងបី ទទួលនូវសេចក្តីសុខក្នុងរង្វង់ដៃឃុំគ្រងរបស់បុរសថ្មីមួយរូប ដែលនាងកំពុងតែរៀនស្គាល់ចិត្តថ្លើមរបស់គេ... ថាតើគេជាបុរស ដែលនាងគួរផ្ញើកជីវិតជា មួយឬក៏យ៉ាងណា...

OOOOOOOOOOOOOO

OOOOOOO

CHANBOKEO.COM

# វគ្គទី៨
# រនាំងដួងចិត្ត

នៅវិទ្យារបស់វិចិត្រ...

- ពូខេម! ខ្ញុំសុំពិគ្រោះរឿងមួយបានទេ?
- បាទ!
- បើខ្ញុំរៀបការ តើពូគិតយ៉ាងម៉េចដែរ?
- ពុទ្ធោ! មែនហ្អែស? ពូសប្បាយចិត្តណាស់ព្រោះ លោកពេទ្យចាស់ទុំសមវ័យរៀបការហើយ ។ អញ្ចឹងតើហ៍ បានជាពេលថ្មីៗ នេះ ពូឃើញលោកពេទ្យហាក់ដូចជា... ហៃសៗ!

ពូខេមសើចរលាក់ មិនហ៊ានបន្ថែមទៀតទេ ក៏សួរប្រយោគថា :

- ហើយចុះនារីដែលបំរុងមកជាគូគ្រងរបស់លោកជាកូនចៅនរណា ដែរទៅ? ឬក៏ជាកញ្ញាដ៏ស្រស់ស្អាត ដែលលោកពេទ្យឌុបកង់កាល ពីថ្ងៃមុននោះ?
- បាទ គឺជាគេមែនហើយ!
- ក្រែងទើបស្គាល់គ្នាមិនប៉ុន្មានថ្ងៃនេះតើហ៍ ស្រាប់តែស្គាល់ចិត្តគ្នា ទៅហើយ? ពិតជាលឿនមែន...!
- អត់ទេ... ខ្ញុំស្គាល់គេយូរហើយ... គ្រាន់តែគេមិនស្គាល់ខ្ញុំប៉ុណ្ណោះ រួចហើយគេក៏មិនមែនជាកញ្ញាដែរ... គឺគេមានកូនដល់ទៅបីនាក់...
- កូនបី? ពុទ្ធោ!
- យ៉ាងម៉េចពូ? ម៉េចបានធ្វើមុខដូចជាត្រូវគោដេញជល់អញ្ចឹង?
- គឺ... គឺ...

ពូខេមស្លាក់កនិយាយលែង រួចដែលឮថាវិចិត្ររៀបការជាមួយ ស្ត្រីមេម៉ាយ ។

- មិនសមរម្យត្រង់ណាឬពូ? (វិចិត្រសួរ)
- គឺថា...លោកពេទ្យមិនខ្លាចអ្នកស្រុកគេសើចយំទេ?

CHANBOKEO.COM

- នរណាសើចអីក៏សើចទៅ... ខ្ញុំមិនគិតទេ ព្រោះខ្ញុំគិតថាខ្ញុំបាន
លង់ខ្លួនស្រលាញ់គេជ្រុលទៅហើយ ។
- រួចចុះលោកពេទ្យនឹងជំរាបអ្នកស្រីផាន់ស៊ី ថាយ៉ាងម៉េច កាលបើ អ្នកស្រីកំពុងផ្តួចផ្តើមអ្នកប្រុស
ទៅអ្នកនាងអេឡែននៅដំណាក់ហ្លួង នោះ ?
- ខ្ញុំនឹងជំរាបគាត់តាមត្រង់ ។
- លោកមិនខ្លាចគាត់ឡូឡាឆ្លើលរោងការពេញក្រុងបាត់ដំបងទេ ?

វិចិត្រឈ្ងោកមុខ :

- ឥចឹង ខ្ញុំគួររៀបការស្ងាត់ៗទេដឹង ពូខេម ?

ឃើញវិចិត្រធ្លាក់ទឹកចិត្ត ពូខេមក៏ស្រដីលួងលោមថា :

- ណ្ហើយចុះ! ជីវិតគូស្រករដែលមានសុភមង្គល វាស្ថិតនៅលើ
សេចក្តីស្រលាញ់រវាងបុគ្គលពីរនាក់ មិនមែនស្ថិតនៅលើការសំរេច
ចិត្តរបស់មនុស្សទីបីដែលមិនបានរស់នៅជាមួយយើងនោះឡើយ ។
ខ្ញុំថាលោកគ្រូពេទ្យធ្វើតាមដួងចិត្តរបស់លោកគ្រូពេទ្យដែលដង្ហោយ ហៅនោះទៅ ។
ពេលនោះជីវិតគូស្រកររបស់លោកនឹងបានទទួល សេចក្តីសុខមនា ទោះបីជាពេលខ្លះ
អ្នកទាំងពីរត្រូវចំហាយភ្លើងពី ប្រភពក្រៅបន្តិចបន្តួចក៏ដោយ ។ ការរៀបការដោយការបង្ខំចិត្ត
នឹងធ្វើអោយយើងបាត់បង់ភាពរមនា នៅក្នុងជីវិត ព្រោះយើងមិន
បានរស់នៅជាមួយមនុស្សដែលយើងស្រលាញ់ ។ បើសិនជាលោក
ពេទ្យមានជំនឿលើសេចក្តីស្នេហាដ៏មុតមាំរបស់ខ្លួន យ៉ាងជាក់លាក់ ពិតប្រាកដដូច្នេះទៅហើយ
ខ្ញុំថាឧបសគ្គអ្វី ក៏មិនអាចមករារាំងជីវិត គូស្រកររបស់លោកបានដែរ ។
អ្វីៗនឹងអាចដោះស្រាយបានជានិច្ច
បើអ្នកទាំងពីរពិតជាស្រលាញ់គ្នាទៅវិញទៅមកពិតប្រាកដមែន!

ពាក្យប៉ុន្មានម៉ាត់របស់ពូខេមនេះ មានឥទ្ធិពលប្រៀបបាននឹង
ទឹកអម្រិតពីស្ថានសួគ៌មកប្រស់ព្រំបេះដូងរបស់មាណព អោយរីក បំព្រងតែម្តង ។

- អរគុណពូខេមណាស់ ដែលផ្តល់កម្លាំងចិត្តដល់ខ្ញុំពេលនេះ ។

ពូខេមឈរញញឹម សម្លឹងតាមក្រោយបុរសយើងដែលបររថ យន្តចេញទៅ ។

នៅដំណាច់សប្តាហ៍ អាទិត្យដដែល...

- ណែ...អូនស្មៀកពាក់មក៏! បងចង់នាំអូនទៅចូលរួមពិធីមួយ ។

CHIANBOKEO.COM

- ពីធីអ្វីទៅលោកពេទ្យ ?
- គឺពិធីសម្ពោធអាងហែលទឹកថ្មីនៅទល់មុខសាលាខេត្ត ។
- ក្រែងគេធ្វើសំរាប់បុគ្គលិកសំខាន់ៗក្នុងសាលាខេត្តទេតើហ៍
- តែបងក៏បានទទួលសំបុត្រអញ្ជើញដែរ ។ នឹងទេ ថាបងក៏ជាបុគ្គលសំខាន់ម្នាក់ក្នុងមន្ទីរពេទ្យបាត់ដំបងនេះដែរណា៎ ។
- មិនសមរម្យទេនឹង ដែលណែត្រូវទៅជាមួយ.. ?
- ម៉េចក៏ថាមិនសម ? អូនជាអនាគតភរិយារបស់បងណា៎ ! គឺបងចង់នាំអូនចេញមុខជាផ្លូវការនោះអី ។

យើញបុរសយើងមានសំដីម៉ឺងម៉ាត់ ធិតាក៏លែងប្រកែកសួរ ។ បន្តិចមកអ្នកជិតខាងឈ្មោះមីងលឿមបានមកដល់ :
- សូមផ្ញើកូនទាំងបីផងណាមីង ! (ចរណៃផ្ដែផ្ដាំ)
- ចា៎ស អ្នកគ្រូ !

វិចិត្របាននាំធិតាមកដល់បរិវេណមន្ទីរសម្ពោធ ។ ភ្ញៀវសំខាន់ទាំងឡាយក៏បានមកដល់យ៉ាងកុះករ រួមទាំងផានេតនិងសារិកាផងៈ
- សួស្ដីណែ ! ខ្ញុំត្រេកអរណាស់ ដែលឯងបានមកចូលរួមដែរ ។

សារិកាលាន់មាត់ពេលឃើញវត្តមានរបស់ណែជាមួយលោកគ្រូ ពេទ្យវិចិត្រ ថែមទាំងលួចមិចភ្នែកស៊ីញ៉ូដាក់ចរណៃ ទំនងពេញចិត្ត ចំពោះវត្តមានគូគាប់ទាំងទ្វេហា ។ ភ្លាមនោះ ផានេតកេះវិចិត្រ ហើយខ្សិបសួរទៅនរៈថា :
- ឯងនិយាយគ្នាថាម៉េចខ្លះទៅ បានត្រូវគ្នាលឿនម្ល៉េះ ?
- និស្ស័យត្រូវគ្នា មិនបាច់ចាំយូរទេ (វិចិត្រតប) ដូចឯងអញ្ចឹង !

ផានេតញញឹម ហើយតបថា :
- នាងជាស្ត្រីដ៏ស្រស់ស្អាតមួយរូប ឃើញហើយគួរអោយចាប់ចិត្ត យ៉ាងណាក៏កុំអោយរបូតទៀតអោយសោះ ឮហើយនៅ ?

វិចិត្រញញឹមហើយលួចសម្លឹងទៅចរណៃនិងសារិកាដែលកំពុង សំណេះសំណាលគ្នា ។ ពិធីកាត់ខ្សែបូចប់សព្វគ្រប់ហើយ ចូលដល់ ពេលដែលភ្ញៀវទាំងអស់ធ្វើការណែនាំគ្នា មុននឹងការបំរើភេសជ្ជៈ ចូលមកដល់ ។ ភ្លាមនោះស្រាប់តែនារីឆើតឆាយម្នាក់ដើរចូលមកៈ

CHANBOKEO.COM

- ជំរាបសួរបងពេទ្យ! អេឡែនមិនបានដឹងទេថាបងពេទ្យមកដែរ អញ្ចឹង!
សុំធ្វើដៃគូរបស់អេឡែនម៉ាល្ងាចនេះបានទេ កំពុងតែអត់ ដៃគូរាំផង ។

វិចិត្រភ្ញាក់ព្រើត ឆ្លើយថា :

- អូហ៍សួស្ដីអ្នកនាងអេឡែន! សូមទោសផងណា៎ដែលខ្ញុំមានដៃគូ មកជាមួយដែរ ។

ឮដូច្នោះ អេឡែនស្លោះទឹកមុខភ្លាម ។ វិចិត្រក៏ណែនាំ :

- អេឡែន! នេះ អ្នកនាងចរណៃ ជាគូកំណាន់ចិត្តរបស់ខ្ញុំ!

ចរណៃលើកដៃសំពះគួរសម ស្រាប់តែអេឡែនបើកភ្នែកធំៗ :

- ថាម៉េចហ្នឹង ? បងពេទ្យមានគូកំណាន់ចិត្តរួចហើយ ? ហើយចុះ ដែលអ្នកមីងផាន់ស៊ីលើកថាស ចូលទៅស្ដីសួរប៉ាម៉ាក់របស់ខ្ញុំពីរឿង យើង កាលពីម្សិលនោះ តើបងពេទ្យគិតយ៉ាងណាទៅវិញ ?

វិចិត្រភ្ញាក់ព្រើត ។ ការពិត គេមិនបានដឹងទេ ថាម្ដាយមីង របស់គេបានធ្វើដូច្នោះ ។ មាណពក្រលេកមកចរណៃឃើញនាង ស្លោះទឹកមុខបន្តិចដែរ ។ គេក៏និយាយកម្លាភ្លាម :

- ក្រែងអ្នកមីងផាន់ស៊ីនិយាយលេងទេដឹង អ្នកនាងអេឡែន ?

- រឿងកត្តិយសរបស់នារី យកមកនិយាយលេងម្ដេចនឹងបាន ? ខ្ញុំនឹងទៅសួរអ្នកស្រីផាន់ស៊ីអោយដឹងរឿងពិតឥលូវនេះ!

ថាហើយនាងបែរខ្លួនថយវិញ ស្រាប់តែជល់គ្នានឹងមាណវីដ៏ សោភាមួយរូបទៀតចូលមកដល់ :

- គេចទៅណាលឿនម្ល៉េះ អេឡែន ?

អេឡែនឮហើយ ងាកមើលភ្លែត :

- អូហ៍ លិនដា! ឯងមកដែរ ? ចុះឯណាស្វាមីរបស់ឯងនោះ ?

- គេនៅខាងក្នុងជួបជាមួយមិត្តភក្តិ ។ ហើយនេះឯងធ្វើមុខដូចជា ខ្មោចដេញលងយ៉ាងនេះ មានរឿងអ្វីមែនទេ ?

អេឡែនមិនឆ្លើយទេ តែបែរជាក្រឡេករេកន្ទុយភ្នែកទៅវិចិត្រ ដែលកំពុងឈរទន្ទឹមនឹងអ្នកគ្រូចរណៃរបស់យើង ។ លិនដាក៏បែរ មើលតាមក្រសែភ្នែកអេឡែនទៅដែរ ក៏ប្រទាក់នឹងខ្សែភ្នែករបស់ វិចិត្រដែលកំពុងសម្លឹងមក ។ ឆវីសោភាបើកភ្នែកធំៗទំនងភ្ញាក់ ផ្អើល ហើយក៏ឧទានខ្សិបៗក្នុងមាត់ថា :

- បងវិចិត្រ ?

ភ្លាមនោះ នាងដាក់ភ្នែកក្រឡេកឃើញភក្ត្រ័របស់អ្នកគ្រូចរណៃ ស្រាប់តែនាងកាន់តែស្លោះទឹកមុខណាស់ទៅទៀត រួចហើយបើក

CHANBOKEO.COM

ភ្នែកធំៗសម្តែងឥរិយាបថហាក់ដូចជាភ្ញាក់ផ្អើលខ្លាំងណាស់ មិនដឹង ថាមានរឿងហេតុអ្វីទេដែលចូលមករំខានក្នុងឱភាររបស់នារី ។ មួយ ស្របក់ក្រោយមក ធិតាក៏រៀបឫកពាសាជាថ្មី ហើយក៏ប្រឹងញញឹម ឡើង រួចក៏ស្រដីទៅកាន់លោកវេជ្ជបណ្ឌិតសង្ហារបស់យើងថា :

- សួស្តី បងវិចិត្រ! ខានឃើញគ្នាយូរហើយ សុខសប្បាយទេ?

វិចិត្រក៏មានកិរិយាប្រកបដោយពិរុទ្ធមិនខុសពីលិនដាប៉ុន្មានទេ គេលេបទឹកមាត់ក្អឹកផ្ទើមបំពង់កដ៏សែនស្ងួត ហើយក៏ស្រដីថា :

- បងសុខសប្បាយទេ លិនដា! ចុះលិនដានិងក្រុមគ្រួសារវិញ?

តែលិនដាមិនឆ្លើយទេ ។ ទឹកមុខរបស់នាងសម្តែងនូវការខក ចិត្តនិងភាពសោកសៅជាខ្លាំង លាយឡំនឹងការភ្ញាក់ផ្អើល មើលទៅ ហាក់ដូចជាខំប្រឹងទប់អារម្មណ៍ក្នុងខ្លួនដល់ស្ទូរហើយ ។ ចរណៃនៅ ស្ងៀមយូរហើយ មិនមានមាត់មិនមានស្រដីអ្វីទេ ទុកអោយវិចិត្រ ជាអ្នកនាំមុខ ។ តែលុះឃើញកិរិយារបស់ធិតាសោភាមានសភាព ចម្លែកខុសធម្មតា នាងក៏ដើរចូលមកជិត ហើយស្រដីថា :

- ខ្ញុំមិនធ្លាប់ស្គាល់អ្នកនាងពីមុនមកទេ តែសុំចងមិត្តជាមួយអ្នក នាងផង បានទេ? នេះ ខ្ញុំឈ្មោះចរណៃ...

លិនដាប្រឹងញញឹមទាំងមុខស្ងួត :

- ចាស! អ្នកនាងចរណៃ! ខ្ញុំលិនដា...ធ្លាប់ជាមនុស្សជិតដិតម្នាក់ របស់បងវិចិត្រ តែសព្វថ្ងៃនេះ យើងឆ្ងាយគ្នាហៅលែងឮហើយ...

ខណ:នោះ ចរណៃទទួលអារម្មណ៍ថា រវាងវិចិត្រនិងលិនដា ប្រាកដជាមានអ្វីខុសធម្មតាមិនខាន គ្រាន់តែនាងមិនដឹងថាជាអ្វីនៅ ឡើយ ។ ស្រាប់តែវិចិត្រស្រវាលូកកាន់ដៃចរណៃយ៉ាងណែន រួច ហើយស្រដីទៅលិនដាថា :

- លិនដា! ចរណៃនេះជាគូកំណាន់ចិត្តរបស់ខ្ញុំ ហើយយើងក៏បំរុង រៀបការជាមួយគ្នាឆាប់ៗនេះហើយ.. សូមលិនដាជួយជូនពរយើង ទាំងពីរផងណា៎!

ចរណៃភ្ញាក់ព្រើតដែលវិចិត្រវាចាយ៉ាងចំហ អំពីទំនាក់ទំនង រវាងនាងហើយនិងវិចិត្រ ។ លិនដាប្រឹងញញឹមម្តងទៀត :

- គួរអោយសរសើរសំណាងបងវិចិត្រណាស់ ដែលទីបំផុត បងក៏ បានស្វែងរកឃើញម្ចាស់បេះដូងរបស់បងពិតប្រាកដ ។

CHANBOKEO.COM

បន្តិចមក នាងក៏ទាញដៃចរណៃទៅឆ្ងាយហើយខ្សិបប្រាប់ថា :
- មនុស្សយើងនេះ បើមើលតែពីសំបកក្រៅ យើងមិនអាចដឹង បានទេ
ថាគេជាមនុស្សយ៉ាងណា... ទាល់តែសម្លឹងឆ្ងាយជាងនោះ បន្តិចហើយ ។
សូមអ្នកនាងទុកឱកាសអោយខ្លួនអ្នកនាងរៀនស្គាល់ ដៃគូឲ្យបានហ្មត់ចត់បន្តិចសិន
មុននឹងរៀបការ នោះអ្នកនាងមិន បាច់ឆ្លងកាត់ទឹកភ្នែកនិងការខកចិត្តទៅថ្ងៃក្រោយ...
ថាហើយនាងក៏ញញឹមដាក់ចរណៃ ហើយលួចចោលកន្ទុយភ្នែក
ដាក់វិចិត្រសំដៅងទឹកមុខដ៏ចម្លែកមួយ រួចក៏ដើរចេញទៅ ។ គ្រា នោះ
ចរណៃមិនយល់ទេថាអ្វីដែលលិនដានិយាយមានសាច់រឿង យ៉ាងណា ?
តើលិនដានិងវិចិត្រធ្លាប់ជាអ្វីនឹងគ្នាកាលពីអតីតកាល ?
មើលទៅកិរិយាវិចិត្រវិញក៏មានពិរុទ្ធដូចគ្នាដែរ ។ តើគេបានធ្វើអ្វី
ខ្លះដែលមិនល្អទៅលើនាងលិនដា ? ទោះជាយ៉ាងណា មាណវីយើង
ទុកមុខទុកមាត់អោយដៃគូរបស់នាងណាស់ មិនហ៊ានបញ្ចេញឬកពា អ្វីអោយគេមានអារម្មណ៍ថា
នាងមានកំពុងមានការធុញថប់ក្នុងចិត្ត ឡើយ ។ កាលបើឃើញធិតាមិនសូវស្រស់
ហើយមានទឹកមុខស្មើៗ មិនរីករាយដូចកាលពីព្រលប់ វិចិត្រក៏ស្រវាដៃរបស់នាងមកចាប់
កាន់អង្អែលហើយស្រដីសួរថា :
- បើអូនមានអ្វីរំខានក្នុងចិត្ត អូនសួរបងមកណា៎! បងត្រៀមខ្លួន ចាំឆ្លើយសំនួររបស់អូនជានិច្ច
សុំកុំតែអូនស្រពោនក្នុងចិត្តទៅបាន ហើយ ណា៎ព្រលឹងមាសបង!
តែធ្វើម៉េចនឹងចរណៃហ៊ានសួរទៅ ? ហើយត្រូវសួរថាម៉េច ?
ធិតាញញឹមតិចៗហើយគ្រវីក្បាល :
- ណៃមិនមានរំខានចិត្តអ្វីទេ លោកកុំបារម្ភអី!
- តែទឹកមុខរបស់អូនបានបញ្ជាក់ប្រាប់... ឬក៏អូនកំពុងគិតពីរឿង អ្នកនាងអេឡែន ?
ឮដល់ឈ្មោះនេះ មាណវីភ្ញាក់ស្មារតីព្រើតឡើង ។ មែនហើយ
តើអេឡែនគេនឹងទៅអុកឡុកចាស់ទុំថាយ៉ាងម៉េច ហើយតើនឹងមាន អ្វីកើតឡើងដែរ
រវាងអេឡែននិងលោកគ្រូពេទ្យ ហើយតើចរណៃ
ត្រូវត្រៀមចិត្តបែបណាដើម្បីទទួលហេតុការណ៍ថ្មីដែលបំរុងនឹងកើត ឡើង ។ មិនឃើញធិតាតបអ្វី
វិចិត្រក៏ស្រវាដៃរបស់ធិតាយកមក ដាក់លើដើមទ្រូងរបស់គេ ហើយពោលបន្តថា :

CHANBOKEO.COM

- បេះដូងរបស់បងបានផ្តិតរូបនារីម្នាក់គត់ គឺរូបអូន...ទោះបីអូន ជឿ ឬមិនជឿក៏ដោយ តែបងនឹងបង្ហាញអោយឃើញ នៅពេល ណាដែលអូនទាមទារ ។

ពេលនោះ ចរណៃច្របូកច្របល់អស់ហើយ ។ តើនាងត្រូវជឿ នរណា ? ជឿលិនដា ឬក៏ជឿលោកគ្រូពេទ្យ ? ហេតុអ្វីបានជារូប
នាងស្ថិតនៅចំកណ្តាលនៃខ្សែជីវិតដ៏អាថ៌កំបាំងនោះផង ? ធិតានៅ ស្ងៀម
គិតតែម្នាក់ឯងក្នុងចិត្តមិនអស់មិនហើយ ។

វិចិត្រដើរជូនធិតាមកដល់មាត់ទ្វារផ្ទះ រួចគេសម្លឹងមុខនាងសា ជាថ្មី ត្បិតគេមានអារម្មណ៍ថា ចរណៃមានកិរិយា ហាក់ដូចជាស្រក
ស្រុតកម្លាំងចិត្ត ហើយហាក់ដូចជាកំពុងដកចិត្ត ដកខ្លួនឆ្ងាយពីរូប
គេជាងសព្វកាលដែលគេនៅជាមួយគ្នា :

- ណៃ! ការនៅស្ងៀមស្ងាត់មិនស្រដីដួនកាលមិនអាចដោះស្រាយ អ្វីបានទេ ។ បើអូនមានការអ្វីទើសទាល់នៅក្នុងចិត្ត អូនសួរបងណា៎
ព្រោះបងឃើញអូនផ្លាស់ប្តូរអារម្មណ៍ប្លែកណាស់ ។ បើសិនជារឿង អេឡែន
ឬរឿងលិនដាធ្វើអោយដួងចិត្តអូនហ្មងសៅ បងអាចបំភ្លឺ ជូនអូនបាន
បើសិនជាអូនចង់ស្តាប់ពាក្យពន្យល់ពីបង ។

តែចរណៃមិនមានអារម្មណ៍ទេ ។ ពេលនោះ នាងហាក់ដូចជា
រសេះរសោះដៃជើងអស់រលីងទៅហើយ :

- ចាំស្អែក យើងនិយាយគ្នាបានទេ ? ថ្ងៃនេះ ខ្ញុំមានអារម្មណ៍វិល វល់ច្របូកច្របល់ណាស់ ។
- បាទ! ស្អែកចាំនិយាយគ្នាក៏បាន ។ បងនឹងមកទទួលអូននិងកូន ពេលព្រឹក
ដើម្បីទៅបរិភោគអាហារនៅផ្ទះរបស់បងជុំគ្នាម្តងណា៎!

គេក៏បែកគ្នាទាំងស្ងៀមស្ងាត់ ។ ទោះជាយ៉ាងណាក៏ដោយ ក៏
បេះដូងរបស់គេម្នាក់ៗពុះកញ្ជ្រោលរណ្តំយ៉ាងចម្លែក ។ ចរណៃនឹក
គិតមិនអស់មិនហើយអំពីរឿងរបស់អេឡែននិងលិនដា ។ រីឯវិចិត្រ វិញ
គេងគិតមិនអស់មិនហើយដែលចរណៃមានចិត្តសង្ស័យមកលើ រូបគេ
តែមិនព្រមវាចាចេញអ្វីមួយម៉ាត់ ដើម្បីអោយគេមានឱកាស ពន្យល់អ្វីៗទាំងនោះទៅនាង ។
ពេលនោះម្នាក់ៗបែរជាអស់កម្លាំង ចិត្តនឹងប្រឈមការពិតទៅវិញ ។

មួយរាត្រីកន្លងទៅទាំងតប់ប្រមល់សំរាប់រូបគេទាំងពីរនាក់...

CHANBOKEO.COM

ព្រឹកស្អែកឡើង...

ចរណៃកំពុងអង្គុយក្រងសក់អោយនាងម៉ៅ នៅក្រោមម្លប់ដើម
ចំប៉ា នៅពេលដែលភក្ត្រាកំពុងរត់លេងប្រលែងគ្នាជាមួយនាងតូច
បារមីជាប្អូនស្រីក្បែរនោះ ។ ស្រាប់តែ វិចិត្រចូលមកដល់ ធ្វើមុខ
ញញឹមពព្រាយដាក់អ្នកទាំងបួន ។ គេមិនស្រដីអ្វីដាក់ចរណៃទេ
ស្រាប់តែចាប់ក្មេងដឹកដៃច្រករថយន្តរបស់គេ ម្តងមួយៗ រួចហើយ
ទើបអូសដៃចរណៃជាចុងក្រោយ :

- សូមអញ្ជើញអ្នកគ្រូឡើងរថយន្តបាទ!

ឃើញគេសម្តែងកិរិយាទំនងកំប្លែង ចរណៃក៏ញញឹមឡើង រួច
បណ្តោយអោយនរៈយើងដឹកដៃរហូតដល់រថយន្ត ។ បន្តិចក្រោយ មក
គេទាំងអស់ក៏បានមកដល់គេហដ្ឋានរបស់លោកគ្រូពេទ្យវិចិត្រ
ដែលមានទីធ្លាទូលាយដោយមានសួនច្បារដាំផ្កាលំអយ៉ាងប្រណិត ។ ពូខេមចេញមកទទួល:

- ជំរាបសួរអ្នកនាង!
- ចាស! ជំរាបសួរពូ!
- ពូខេមបានរស់នៅទីនេះជាមួយបងតាំងពីយូរមកហើយ (វិចិត្រ ស្រដីប្រាប់ចរណៃ)

បន្តិចមក គេក៏លើកបារមីពឡើង រួចដឹកដៃកុមារភក្ត្រា នាំមុខ ចរណៃនិងនាងម៉ៅ
ដើរមើលបរិវេណជុំវិញផ្ទះ រួចក៏នាំគេទាំងបួន ឡើងទៅខាងលើទៀត ។
ពូខេមលួចគយគន់ក្រុមភ្ញៀវរបស់លោក គ្រូពេទ្យជាលើកដំបូង ។ មែនហើយ!
វិចិត្រមិនដែលនាំភ្ញៀវចូល ផ្ទះទេ វៀរលែងតែអ្នកស្រីផាន់ស៊ីនិងភក្តីប៉ុណ្ណោះ ។ មើលទៅគេ
ប្រហែលជាគិតម៉ឺងម៉ាត់ហើយ អំពីជីវិតអនាគតរបស់គេជាមួយស្ត្រី
មេម៉ាយវ័យក្មេងមួយរូបនោះហើយបានជានាំមកដល់ផ្ទះ ។ ទោះជា យ៉ាងណា
ពូខេមញញឹមបិទមាត់មិនជិតទេ កាលបើឃើញចំណង
ជិតស្និទ្ធរវាងគូស្នេហ៍ទាំងទ្វេនៅចំពោះភ្នែកគាត់នោះ ។ គាត់យក
ដៃស្ទាបទ្រូងបបោយតែម្នាក់ឯង ទំនងចង់បង្ហាញថា សូម្បីតែខ្លួន
គាត់ក៏បានទទួលឥទ្ធិពលនៃចំហាយសុភមង្គលរបស់អ្នកទាំងពីរមិនតិចដែរទេ ។

កំពុងតែបរិភោគបាយថ្ងៃត្រង់ជុំគ្នាដោយមានពូខេមចូលរួមផង
ស្រាប់តែមានរថយន្តម៉ាក់ដឹសឺវោថ្មីស្រឡាងមួយបរចូលមកដល់ :

CHANBOKEO.COM

- នាយចិត្រ!

ស្ត្រីចំណាស់ស្លៀកពាក់ហ៊ឺហាម្នាក់ដើរចុះពីឡានហៅឈ្មោះនរៈ ខ្លាំងៗដោយមិនក្រែងចិត្ត ។ វិចិត្រងើបមុខឡើង ឃើញវត្តមាន របស់ស្ត្រីមួយរូបនោះកាលណា ក៏ឧទានឡើង :

- អ្នកមីងផាន់ស៊ី ?

- អឺគឺយើង! យ៉ាងម៉េច មីងមកលេងផ្ទះឯងផងមិនបានទេ បាន ជាធ្វើមុខដូចខ្មោចលងយ៉ាងនេះ ?

វិចិត្រស្ទុះរត់ទៅទទួល :

- សូមមីងអញ្ជើញចូលលេងបាទ!

ចរណៃឃើញមនុស្សចាស់ដើរចូលមកដល់ ក៏ឈប់បរិភោគ បាយហើយក៏នាំកូនចេញទៅជំរាបសួរ ។

- នាងជានរណា ? (អ្នកស្រីផាន់ស៊ីសួរ)

- ចាស! នាងខ្ញុំឈ្មោះចរណៃ ។

- ហើយក្មេងទាំងនេះជាកូនរបស់នាងហ្ន៎ស ?

- ចាស!

- យី! មុខនៅក្មេងសោះ ហេតុអីកូនច្រើនម្ល៉េះ ? មិនធ្វើការអ្វី សោះទេ ? ឬក៏មានមុខរបរសំរាប់តែបណ្តុះកូន ?

ចរណៃនឹកខឹងឆេវកាលបើឮសំដីប្រមាថដូច្នេះ តែខំទប់ចិត្ត មិនឆ្លើយទេ ។ មើលទៅអ្នកស្រីផាន់ស៊ីស្លៀកពាក់ថ្លៃថ្នូរណាស់ រួច ក៏មានទ្រព្យសម្បត្តិមិនតិចឡើយ ។ មើលហ្ន៎ក! អ្នកស្រីពាក់ខ្សែដៃ ខ្សែកមាសពេជ្រព្រោងព្រាត ឡើងចាំងពេញខ្លួន ស្ទើរខ្វាក់ភ្នែក តែហេតុអ្វីក៏បែរជាមានសំដីអសុរស ប្រកបដោយអគតិយ៉ាងនេះ ជាពិសេសគឺចំពោះមនុស្សដែលគាត់ មិនទាន់ស្គាល់ថាគេជានរណា ផង ។ គិតទៅ ទោះពាក់មាសស្រោចខ្លួនយ៉ាងណា ក៏មនុស្សយើង មិនអាចយកមាសស្រោបជិតគំនិតគិតល្អក់កកររបស់ខ្លួនបានដែរ ។ ឃើញធិតានៅស្ងៀម អ្នកស្រីក៏បានចិត្ត សួរថែមទៀតថា :

- ហើយចុះនាងស្គាល់នាយចិត្រតាំងពីរអង្កាល់ដែរ ?

វិចិត្រឮហើយឆ្លើយកាត់ភ្លាម :

- ខ្ញុំស្គាល់នាងតាំងពី...

CHANBOKEO.COM

- យើងមានបានសួរឯងពីអង្កាល់ នាយចិត្រ ?

អ្នកស្រីផាន់ស៊ីនិយាយកាត់ ។ វិចិត្រក៏បិទមាត់នៅស្ងៀមទៅ វិញ ។ ចរណៃឃើញដូច្នោះក៏ឆ្លើយរឹងឡើងយ៉ាងមធ្យ័តទៅវិញថា :

- ទើបតែស្គាល់គ្នាថ្មីៗនេះទេ អ្នកស្រី!
- អូហ៍! ទើបតែថ្មីៗទេ ? ហើយ ម៉េចហ៊ានឡើងចុះផ្ទះមនុស្ស ប្រុសផុយៗម៉្លេះ ? ឬក៏ថាខ្លួនមេម៉ាយមិនបាច់ "គីអ៊ិត" គិតឆ្ងាយ ?

ពួសំដីស៊កសៀតរបស់អ្នកស្រី ចរណៃទ្រាំស្ទើរមិនបាន តែនាង នៅតែរៀបឥរិយាបថនឹងនងដែល មិនអោយខូចសណ្តាប់ធ្នាប់ទេ រួចហើយក៏ឆ្លើយដោយសំដីស្ងប់ស្ងៀមថា :

- បើសិនការរាប់អានទៅមកនៅពេលថ្ងៃ ដែលមានចាស់ទុំ មាន កូនក្មេងជុំជិតខ្លួន ជាការមិនសមរម្យទៅហើយ នាងខ្ញុំក៏ចង់ដឹងដែរ ថាតើវេលាណាទៅជាពេលល្អសំរាប់យើងទៅមកនឹងគ្នា ? សូម អ្នកស្រីមេត្តាជួយណែនាំផង ។

ពូខេមឈរក្បែរនោះលួចញញឹមក្របួចមាត់ ។ ពួចរណៃឆ្លើយ ដូច្នេះអ្នកស្រីផាន់ស៊ីស្ងាត់មួយស្របក់ ទើបសួរចរណៃថែមទៀត :

- ហើយនេះ អ្នកទាំងពីរមានសម្ពន្ធ័នឹងគ្នាដល់ណាហើយ ?
- ទើបចាប់ផ្តើមហើយកំពុងតែរីកចំរើនធំលូតលាស់រាល់ថ្ងៃដែរ ។
- តែនាងជាស្រីមេម៉ាយ កូនដល់ទៅបីនាក់! ឯនាយចិត្រ វានៅ លីវ...វាមិនដែលមានប្រពន្ធពីមុនមកទេ...តើវាសមភ្នែកអ្នកផងទេ បើនាងនិងនាយចិត្រគិតចាប់ដៃគ្នានោះ ?
- ខ្ញុំមិនបានគិតចង់វាស់សុភមង្គលរបស់ខ្លួន ដោយសារភ្នែកញាតិ តែម្យ៉ាងនោះទេ ។ សុភមង្គល ស្ថិតនៅលើការសំរេចចិត្តរវាង បុគ្គលមនុស្សពីរនាក់ដែលស្រឡាញ់គ្នា ហើយដែលចេះទទួលខុស ត្រូវលើជីវិតរបស់ខ្លួនឯង ។ សេចក្តីស្នេហាតែម្យ៉ាង ក៏មិនអាច បណ្តុះសុភមង្គលបានឡើយ កាលបើរូបយើងមិនចេះទទួលខុសត្រូវ ហើយការសមរម្យទៀតសោត ក៏មិនមែនស្ថិតនៅលើភ្នែកញាតិតែ ម្យ៉ាងនោះដែរ បើសិនជាញាតិទាំងឡាយនោះជាមនុស្សដែលប្រកប ដោយគំនិតអគតិពេញខ្លួន ខ្វះសេចក្តីថ្លៃថ្នូរ សូម្បីតែការគិតល្អ ចំពោះញាតិផងទាំងពួង ។

CHANBOKEO.COM

ព្រូខេមនិងវិចិត្រលួចសម្លឹងមុខគ្នា ក្នុងខណៈដែលអ្នកស្រីធ្វើសវនាប្រាជ្ញនិងសំដីជាមួយចរណៃ ។
- ទើស្ដីបានណាស់ហ្ន៎! នាងជាគ្រូបង្រៀនមែនទេ ?
- ចា៎ស ពិតហើយ!
- អញ្ចឹងតើហ៍ ! ហើយបង្រៀននៅសាលាណាដែរ ? សាលា បឋមសិក្សាសោហី ?
- ចា៎ស! មិនមែនទេ... គឺនៅវិទ្យាល័យនេតយ៉ង់ ។
- ហើយចុះបង្រៀនមុខវិជ្ជាអ្វីដែរ ?
- ជាអគ្គានុរក្សប្រចាំសាលា ។
- អូហ៍! ជាអ្នកកាន់កាប់ខាងវិន័យផងហ្អែស ? បើដូច្នេះល្អហើយ ចូរកុំភ្លេចបង្រៀនខ្លួនផងថាតើប្រពៃណីខ្មែរគេសើចយំប៉ុនណាដែរ
ដែលស្រីមេម៉ាយមកភ្លើតភ្លើនជាមួយប្រុសកម្លោះៗនោះ ។
- បើសិនជាវិន័យទាំងនោះ មានចែងជាក្រិត្យក្រមសាលា ថាស្រីមេម៉ាយមិនអាចទៅមកជាមួយប្រុសកម្លោះបានពិតមែន នោះនាង ខ្ញុំនឹងអនុវត្តន៍តាមជានិច្ចចា៎ស ។

អ្នកស្រីផាន់ស៊ីបាត់មាត់ដូចគេចុក កាលបើត្រូវមួយខ្នាយ ។ បន្ទាប់មកអ្នកស្រីក៏ស្រដីជាមួយវិចិត្រវិញ :
- ហើយចុះរឿងអេឡៃន នាយចិត្រឯងគិតយ៉ាងម៉េច ?
- ខ្ញុំមិនដែលគិតម្ដងណាទេ អ្នកមីង!
- តែមីងបានទៅនិយាយជាប់មាត់ជាប់កនឹងគេរួចហើយ ។
- បើអ្នកមីងជាអ្នកចងភ្ជាប់ ដូច្នេះត្រូវតែជាអ្នកស្រាយហើយ...
- ក្មេងឆ្កួត! ឯងអោយមីងយកមុខទៅទុកនៅឯណា ?
- អញ្ចឹង ថ្ងៃក្រោយ មីងឈប់យកមុខមកជួយបាំងអោយខ្ញុំទៀត ទៅទុកឲ្យខ្ញុំទទួលខុសត្រូវខ្លួនឯងចុះ! បើសិនជាខូចមុខ សូមខូច តែមុខខ្ញុំម្នាក់ទៅបានហើយ កុំអោយអំពាល់ដល់មីងទៀត ។

អ្នកស្រីផាន់ស៊ីខឹងឆេវតែម្ដង កាលបើឮក្មួយប្រុសនិយាយយ៉ាង ដូច្នោះ ។ អ្នកស្រីក៏ដើបឈរឡើងហើយស្រដីចុងក្រោយ :

CHANBOKEO.COM

- យើងចង់ដឹងណាស់ថា តើអ្នកទាំងពីរខ្លាំងបានត្រឹមណាដែរទៅ ?
ប្រយត្ន័បានត្រឹមតែមួយឆាវហើយក៏រលត់សូន្យវិញ!

មានប្រសាសន៍ហើយ អ្នកស្រីក៏ឡើងរថយន្តត្រលប់ទៅវិញ ។ ពេលនោះ បរិយាកាសក្នុងផ្ទះរបស់វិចិត្រ ក៏ផ្លាស់ប្តូរអស់រលីង ។ វិចិត្រសង្កេតឃើញចរណៃជ្រួញចិញ្ចើមហើយឈ្ងោកមុខស្ងៀម ស្ងាត់មិនមានស្រដី ។ មុននេះបន្តិច នាងមានឫកពារឹងប៉ឹងហើយ វាចាម៉ឹងម៉ាត់ណាស់ តែពេលនេះ មើលទៅនាងហាក់ដូចជាបាក់ កម្លាំងចិត្តទៀតហើយ ។ ធិតាអង្គុយអោបបារមីធ្វើមុខស្រងូត ។ ភក្ត្រានិងនាងម៉ៅហាក់ដូចជាយល់ស្ថានការណ៍ ក៏នាំគ្នាអង្គុយនៅ ស្ងៀមស្ងាត់ក្បែរៗម្តាយរបស់គេ ។ ពូខេមវិញក៏រត់គេចទៅខាង ក្រោយផ្ទះបាត់ មិនហ៊ាននៅរំខានអារម្មណ៍របស់អ្នកទាំងពីរដែរ ។ វិចិត្រឈរសម្លឹងមុខចរណៃយ៉ាងយូរ ទើបដាក់ខ្លួនអង្គុយចុះក្បែរ នាង រួចយកដៃទៅអង្អែលខ្នងមាណវីបន្ថើរៗ ជាការលួងលោម លើកទឹកចិត្ត :

- អូនកុំយកពាក្យរបស់ម្តាយមីងបងដាក់ក្នុងចិត្តអី! គាត់ប្រហែល ជាគ្រាន់តែសាកសួរ ដើម្បីចង់ដឹងចិត្តអូនប៉ុណ្ណោះ ថាអូនជាមនុស្ស
យ៉ាងណា ។

ធិតាងើបមុខឡើងសម្លឹងវិចិត្រវិញ រួចហើយស្រដីថា :

- ខ្ញុំមិនយល់សោះថា គ្រាន់តែមាននាមជាស្ត្រីមេម៉ាយក៏មានកំហុស ដោយស្វ័យប្រវត្តិដែរ! នេះសង្គមខ្មែរយើងចង្អៀតចង្អល់ដល់ថ្នាក់ ហ្នឹងផងមែនទេ ? ស្ត្រីមេម៉ាយដែលព្រាត់ប្តីទៅហើយ ពិតជាគ្មាន ឱកាសទេ មែនទេ សំរាប់ជ្រើសរើសផ្លូវជីវិតថ្មីសំរាប់ខ្លួនឯង ដើម្បីអនាគតថ្មីដ៏រុងរឿង ល្អជាជាងលិចលង់នឹងទុក្ខវិបត្តិនៃអតីត កាល ? ហេតុអ្វីក៏សង្គមយើង ផ្តល់សិទ្ធិទៅអ្នកដទៃទិទៀនអោយ គេរិះគន់ ហើយមានសិទ្ធិចាត់ថ្នាក់សំរេចអ្វីៗ មកលើជីវិតរបស់ យើងម្ល៉េះ ? ហេតុអ្វីក៏យើងមិនអាចមានសិទ្ធិអ្វីៗលើជីវិតខ្លួនឯង សំរេចជីវិតខ្លួនឯងដោយខ្លួនឯងបាន ? ឬក៏គេកៀបស្ត្រីអោយរក្សា ភក្តីភាព ចំពោះតែបុរសម្នាក់គត់ សូម្បីតែគេស្លាប់ទៅហើយ ហើយស្ត្រីនោះក៏គ្មានសិទ្ធិទទួលយករស្មីជីវិតថ្មីបានឡើយ នៅពេល បុរសទីមួយព្រាត់ចេញទៅ ?

CHANBOKEO .COM

- ខុសហើយ ចរណៃ! ការពិតសង្គមយើង មិនអនុញ្ញាតឲ្យអ្នកដទៃគេសំរេចផ្លូវជីវិតរបស់យើងជំនួសខ្លួនយើងទេ ។ អ្នកដែលខ្វះ ជំនឿចិត្តលើខ្លួនឯងតើដែលពឹងផ្អែកលើការវាយតម្លៃពីសង្គម អោយគេកាត់តម្លៃជីវិតយើងថាគួរធ្វើដូចម្តេច ។ តែចំពោះបុគ្គល ដែលមានជំនឿមុតមាំលើខ្លួនឯង និងជឿលើសច្ចភាព នោះគេមិនខ្លាចសង្គមសើចចំអកទេ ហើយសង្គមក៏មិនហ៊ានសើចចំអកអោយ គេវិញដែរ ។ ណៃ! អូនជឿបងណា៎! យើងជឿចិត្តគ្នាទៅវិញទៅ មក! យើងមិនបណ្តោយអោយសង្គមក្រៅគ្រួសារនាំភាពប្រេះឆា ដល់ជំនឿចិត្តរបស់យើង ដែលមានចំពោះគ្នាទៅវិញទៅមកនោះ បានឡើយ ។

វិចិត្រលូកកាន់ដៃកូនទាំងបីនាក់ហើយស្រដីបន្តថា :

- បងបានសំរេចចិត្តហើយ ថាបងនឹងដើរផ្លូវមួយជាមួយណៃព្រម ទាំងកូនរបស់ណៃទាំងបីនាក់ ។ បើផ្លូវចង្អៀត យើងនឹងរួមដៃគ្នា ឆ្ការបន្លាមែកឈើព្រៃដែលរាំងផ្លូវយើងអោយផ្លូវទូលាយធំស្រឡះ ឡើង ។ តើអូនក្រោកឡើងដើរទៅមុខលើផ្លូវនោះជាមួយបងទេ ? ពេលនេះ យើងត្រូវតែរឹងប៉ឹងណា៎អូនណា៎ ដើម្បីជំនះនូវពាក្យទិទៀនអ្វីទាំងឡាយដែលសង្គមជុំវិញខ្លួនយើង កំពុងរង់ចាំទម្លាក់ រោយដណ្តប់ឥទ្ធិពលមកលើជីវិតរបស់យើងរាល់ថ្ងៃ ។

ឮប្រយោគនេះ មាណវីហាក់ដូចជាមានកម្លាំងចិត្តប្រឹសភ្លាមតែ ម្តង ។ នាងផ្តេកកេសាទៅលើស្មារបស់វិចិត្រហើយស្រដីបន្តថា :

- តើយើងនឹងហត់យ៉ាងណា ដែលយើងត្រូវប្រឈមប្រយុទ្ធនឹងការសើចយំរបស់សង្គមរាល់ថ្ងៃនោះ ?

- យើងមិនហត់ទេ ត្បិតយើងមិនទទួលនូវការសើចយំទាំងឡាយ គឺយើងទទួលត្រឹមតែពាក្យណែនាំល្អៗ សំរាប់គ្រួសារយើងប៉ុណ្ណោះ.. ចំពោះការសើចយំដែលគ្មានន័យ យើងទម្លាក់វាចោល មិនទុកក្នុងចិត្តឡើយ ហើយយើងនឹងញញឹមឡើង ញញឹមដើម្បីជោគជ័យថ្មី ក្នុងជីវិត ។

ចរណៃរំភើបចិត្តរកថ្លាថ្លែងមិនត្រូវទេ កាលបើឮប្រយោគទាំងឡាយដែលវិចិត្របានស្រដីលួងលោមចិត្តរបស់នាង ។ មែនហើយ មើលទៅហាក់ដូចជាគេសំរេចចិត្តមុតមាំណាស់ ថាគេនឹងចាប់ដៃ នាងជាគូជីវិត ។ ប៉ុន្តែនាងក៏ចង់ដឹងដែរថាតើគុណសម្បត្តិអ្វី ចំណាង អ្វី មូលហេតុអ្វីដែលបណ្តាលអោយបុរសម្នាក់នេះស្រលាញ់រូបនាង

CHANBOKEO.COM

ហើយហ៊ានប្តូរផ្តាច់ពុះពារអ្វីៗដើម្បីនាង... ? ហេតុអ្វី ? គេទើបតែស្គាល់រូបមិនបានប៉ុន្មានអាទិត្យផង ស្រាប់តែហ៊ានសំរេចចិត្តមោះ មុតដល់ម្លឹងសូម្បីតែនឹងហើយថាមាណវីជាស្ត្រីមេម៉ាយកូនបី ។ តើជំរៅចិត្តរបស់គេពេលនេះមានព្រំដែនដល់ណាពិតប្រាកដ ? ប៉ុន្តែ
ទោះបីជាយ៉ាងណាក៏ចរណៃនៅតែមានអារម្មណ៍ល្អហើយមាន អារម្មណ៍ថាបេះដូងរបស់នាងបានទទួលនូវភាពកក់ក្តៅជាទីបំផុត ពេលមានរូបគេនៅក្បែរ ។ តើសេចក្តីសុខនេះ នឹងមានស្ថិរភាពឬ ក៏ប្រែប្រួលយ៉ាងណាទៅវិញ ទៅអនាគត ?

oooooooooooooooo

oooooo

o

CHANBOKEO . COM

# វគ្គទី៥
# ក្លិនស្នេហ៍

- ណែ... ចាស់ទុំរបស់អូននៅឯណាខ្លះដែរ ?
- ចាស! ខ្ញុំមានតែម្នាក់ឯងទេ ។ សាច់ញាតិព្រមទាំងប្ដីជាទីស្រលាញ់បានចែកឋានទៅអស់ហើយ ។ សាច់ញាតិដែលនៅសល់គឺមានតែកូនទាំងបីនាក់នេះប៉ុណ្ណោះ ដែលជាកម្លាំងចិត្តឲ្យណែប្រឹងតស៊ូបានរហូតដល់សព្វថ្ងៃនេះ ។

ចរណៃឆ្លើយតបទាំងទឹកមុខស្រពោន ។ វិចិត្រសម្លឹងមុខនាង ដោយក្ដីអាណិតពេញបេះដូង :

- ឪពុកម្ដាយបងក៏អនិច្ចកម្មអស់ដែរ សល់តែម្ដាយមីងនិងប្អូន ប្រុសម្នាក់ ។ ពេលនេះបើបងសុំអូនរៀបការ តើបងត្រូវធ្វើដូច ម្ដេចដែរ ដើម្បីអោយសមរម្យ ?

ធិតាបើកភ្នែកមូលក្រឡង់ :

- លោកគ្រូពេទ្យ... ?
- បងនិយាយពិតមែនណា៎!

មាណវីលេបទឹកមាត់ផ្ទៀមបំពង់កហើយស្រដីថា :

- ណែមានស្រុកកំណើតនៅព្រះនេត្រព្រះ មានចាស់ទុំជាច្រើន ដែលណែគោរព ។

មិនយូរប៉ុន្មាន វិចិត្រក៏បររថយន្តនាំចរណៃទៅព្រះនេត្រព្រះ ។ ថែដន្យផ្លូវលំបាកបន្តិចទំរាំធ្វើដំណើរពីបាត់ដំបងទៅដល់ក៏រសៀល បន្តិចទៅហើយ ។ ម្យ៉ាងទៀតឡានរបស់វិចិត្រមិនអាចបរចូលទៅ ព្រះនេត្រព្រះបានដែរ ព្រោះពោះឡានទាបមិនអាចទ្រាំទ្រនឹងការ ផុងខ្សាច់សក្នុងដីភូមិបានទេ ។ គេក៏បង្ខំចិត្តយករថយន្តទៅសុំផ្ញើនឹងអ្នកភូមិជប់ម្នាក់ដែលចរណៃស្គាល់ ហើយសុំជួលរទេះគោគេឲ្យ គេជួយដឹកអ្នកទាំងប្រាំរូបរហូតដល់ដីភូមិកំណើតរបស់ចរណៃ ។ តាមផ្លូវ
ចរណៃសង្កេតឃើញវិចិត្រប្រលែងគ្នាសើចលាន់រអឹកជាប់ រហូតជាមួយនឹងភក្ត្រា

CHANBOKEO.COM

កូនប្រុសរបស់នាង ។ មើលទៅគេទាំងពីរ មាននិស្ស័យជិតដិតនឹងគ្នាក្រៃលែង ហាក់បីដូចជាឪពុកនិងកូន បង្កើតអញ្ចឹង ។ ចំណែកនាងតូចបារមី នៅគេងលក់ឈឹងលើដៃម្តាយ ។ រីនាងម៉ៅវិញមិនសូវចេះមាត់កទេ គឺនៅស្ងៀមៗធ្វើអ្វី តាមតែម្តាយប្រាប់ប៉ុណ្ណោះ ។ មួយសន្ទុះធំក្រោយមក ធិតាបាននាំ វិចិត្រនិងកូនមកដល់ផ្ទះឈើប្រក់ក្បឿងក្រហមមួយ ខ្ពស់ពីដីមិន ឆ្ងាយប៉ុន្មានពីដងអូរ ។ គេនាំគ្នាចុះពីរទេះគោដើរតម្រង់សំដៅទៅ ផ្ទះ ។ ភ្លាមនោះ មាណវីស្រស់ស្អាតមួយរូបពាកូនស្រីតូចមួយអាយុ ស្រករនឹងនាងតូចបារមី រត់ចេញមកទទួលដោយទឹកមុខរីករាយ :

- ជំរាបសួរបងណែ!

នាងហាក់ចុះមកស្រវាអោបបងស្រីដោយក្តីនឹករលឹក ។

- ចំណាន! អូនសុខសប្បាយទេ ? ចុះឯណាភុំ ប្តីរបស់ប្អូន ?
- គាត់ទៅផ្ទះតាញ៉ៅ ព្រោះអីតាំងពីអ្នកស្រុកគេតែងតាំងបងភុំជា មេឃុំថ្មីមក គាត់មិនសូវទំនេរទេ ហើយតែងតែទៅជួបតាញ៉ៅ អតីតមេឃុំជានិច្ច ដើម្បីពិគ្រោះការងារ ។

រំពេចនោះ ចំណានក៏បែរមកទទួលក្មួយៗ ស្រាប់តែបើកភ្នែករធ្វើភាំង កាលបើនាងប្រទះនឹងវត្តមានរបស់វិចិត្រដែលនៅ ឈរ ពីក្រោយខ្នងរបស់ចរណៃ ។ ឃើញដូច្នោះ ចរណៃក៏ណែនាំ អោយ ស្គាល់គ្នាឡើង :

- នេះគឺលោកគ្រូពេទ្យវិចិត្រ ធ្វើការនៅពេទ្យធំបាត់ដំបង! លោក គ្រូពេទ្យ នេះជាចំណានប្អូនស្រីរបស់ខ្ញុំ ។

ចំណានលើកដៃសំពះសួរ រួចក៏អញ្ជើញភ្ញៀវឡើងទៅលើផ្ទះ ។ បន្តិចមក នាងក៏លួចកេះបងស្រីហៅទៅខ្សិបប្រាប់ថា :

- បងណែ! ខ្ញុំមានអារម្មណ៍ថា ខ្ញុំហាក់ដូចជាធ្លាប់ស្គាល់លោកគ្រូ ពេទ្យម្នាក់នោះពីមុនមក ។
- មែនហ្អែស ? អូនធ្លាប់ជួបគាត់នៅឯណាដែរ ?
- ខ្ញុំរកនឹកមិនទាន់ឃើញទេបង.. ឬក៏មកពីគាត់មានរូបរាងប្រហាក់ ប្រហែលបងខ្លាទេដឹង បានខ្ញុំចេះតែមានអារម្មណ៍បៀបនេះ ។

ស្រាប់តែ ចំណានសើចកខឹកឡើង ចំអន់បងស្រីថា :

CHANBOKEO.COM

- ឬក៏ប្រហែលជាគាត់មានរូបរាងសង្ហា ស្រដៀងៗនឹងបងខ្លា ហើយ
បានជាបងស្រីរបស់ខ្ញុំចាប់អារម្មណ៍នឹងរូបគាត់ រហូតនាំមក លេងស្រុកកំណើតយ៉ាងដូច្នេះ
មែនទេបង ?

- ឆ្កួត! បងពេញចិត្តចរិតលក្ខណៈរបស់គេទេតើហ៎ មិនមែននៅ
លើរូបសម្បត្តិក្រៅខ្លួននោះឯណា ។

- គឺវារួមទាំងអស់ហ្នឹង! តែខ្ញុំក៏សប្បាយចិត្តជួសបងណាស់ដែល
មានបុរសល្អដើរចូលមកក្នុងជីវិតរបស់បងម្តងទៀត... សង្ឃឹមថា គេជាមនុស្ស
ដែលអាចផ្តល់សេចក្តីកក់ក្តៅជូនបងនឹងកូន ដូច ដែលបងខ្លាធ្លាប់ផ្តល់សេចក្តីសុខដល់បង
យ៉ាងរមនាដូច្នោះដែរ ។ ប្អូនសូមជួយត្រេកអរបងផង... ពិតមែនណា៎!

ចរណៃស្រវាអោបប្អូនស្រីទាំងចិត្តរំភើបបំផុត រកអ្វីប្រៀបមិន
បានឡើយ ដែលនាងតែងតែមានពាក្យពេចន៍លើកកម្លាំងចិត្តដល់ ធិតាយើងមិនដែលខានទេ ។
មួយសន្ទុះធំក្រោយមក ភុំក៏បានមក ដល់ផ្ទះ:

- ជំរាបសួរបងណៃ! ឃ្លាតបងយូរខែ ភុំនឹកបងដល់ហើយ!

លុះភុំដាក់ភ្នែកទៅវិចិត្រដែលកំពុងពបារមីនៅ ឈរលេងនៅ ចំហៀងផ្ទះជាមួយកូន
ស្រាប់តែធ្វើមាត់ចំហឆ្លុង :

- បងខ្លា ?

គេញីភ្នែកមើលម្តងទៀត ទើបដឹងថាគេច្រឡំ ត្បិតបុរសជា
ភ្ញៀវម្នាក់នោះគ្រាន់តែមានរូបរាងស្រដៀងៗ ប្រហាក់ប្រហែលនឹង នាយខ្លាប៉ុណ្ណោះ
តែគេមិនមែនជានាយខ្លាទេ ។ ភុំក៏លើកដៃសំពះ សួរឡើង ។
វិចិត្រក៏លើកដៃសំពះទទួលត្រលប់វិញ យ៉ាងរាក់ ទាក់ ។ រសៀលនោះ
គេទាំងអស់គ្នាបរិភោគបាយជុំគ្នា ហើយ សំណេះសំណាល
ក្នុងបរិយាកាសយ៉ាងសប្បាយរីករាយជាទីបំផុត ជាពិសេស ចំពោះចរណៃ
ដែលបាត់បង់បរិយាកាសបែបនោះយូរ ហើយ កាលបើនាងបានទទួលនូវភាពសុខដុមនោះសាជាថ្មី
ធិតា មានអារម្មណ៍ថា ជីវិតជុំគ្រួសារមានតម្លៃគួរអោយត្រេកត្រអាលជាទី បំផុត
រកអ្វីប្រៀបមិនបានឡើយ ។

បរិភោគរួចហើយ ភុំក៏បររទេះគោនាំអ្នកទាំងអស់គ្នាទៅវត្ត ព្រះនេត្រព្រះក្រោម ។ នៅទីនោះ
ចរណៃបានប្រទះនឹងតាញ្ចៅនិង ព្រះគ្រូចៅអធិការឧត្តរៈដែលកាន់តែជរាទៅហើយ តែព្រះអង្គនៅ

CHANBOKEO.COM

តែមានស្មារតីចងចាំគ្រប់បែបយ៉ាងនៅឡើយ ។ យាយព្រីងប្រពន្ធ
តាញ្នៅបានអនិច្ចកម្មយូរឆ្នាំហើយ ទើបតាញ្នៅមកសំណាក់ធម៌នៅវត្ត បំរើព្រះគ្រូវិញ ។
គ្រាន់តែយល់វត្តមានរបស់ចរណៃភ្លាម ព្រះគ្រូ ឧត្តរៈនិងតាញ្នៅត្រេកអរខ្លាំងណាស់ ។
ចរណៃក៏ប្រញាប់នាំវិចិត្រ ព្រមទាំងកូនទាំងពីរក្រាបបង្គំព្រះគ្រូហើយសំពះសួរតាញ្នៅដែលជា
ចាស់ទុំក្នុងភូមិតែម្នាក់គត់ ដែលស្គាល់គ្រួសាររបស់នាងច្បាស់ជាង គេ ។ ព្រះគ្រូមានដីការថា :
- អ្នកគ្រូណៃអើយ! តាំងពីអ្នកគ្រូផ្លាស់ទៅបាត់ដំបងមក ពួកអ្នក ស្រុកភូមិយើងទីនេះ
នឹកអ្នកគ្រូណាស់ ជាពិសេសគឺក្មេងៗតែម្តង
បើមានពេលឧស្សាហ៍មកលេងពួកយើងទីនេះផងណា៎ ។

បន្ទាប់មក ចរណៃក៏ធ្វើការណែនាំវិចិត្រទៅព្រះគ្រូនិងតាញ្នៅ ។
ទាំងព្រះគ្រូទាំងតាញ្នៅមានការភ្ញាក់ផ្អើលណាស់ដែលលោកគ្រូពេទ្យ
យើងមានលក្ខណៈអត្តចរិតប្រហាក់ប្រហែលនឹងនាយខ្នា ដែលជា
អតីតស្វាមីរបស់ចរណៃដែលបានចែកស្ថានទៅកាលពី៦ខែមុននេះ..
លុះឃើញលោកគ្រូពេទ្យក្រាបបង្គំព្រះអង្គ សូមរៀបការនឹងចរណៃ
ព្រះគ្រូឧត្តរៈក៏សូត្រប្រស់ព្រំជូនពរគូគាប់ទាំងពីរ ដោយមានតាញ្នៅ
ជាអាចារ្យចងដៃអំបោះសងល់គេ ដើម្បីភ្ជាប់ចំណងរវាងអ្នកទាំងពីរ
ជាគូស្វាមីភរិយាយ៉ាងពេញលក្ខណៈ ។ មេឃុំភុំ និងអ្នកគ្រូពេទ្យ ចំណានជាភរិយា
ព្រមទាំងសមាជិកតូចៗរបស់គេទាំងអស់ក៏បាន
ចូលរួមជាសាក្សីក្នុងពិធីមង្គលនោះយ៉ាងសោមនស្សបំផុតដែរ ។

លុះគេនាំគ្នាធ្វើដំណើរត្រលប់មកផ្ទះវិញ ព្រះគ្រូឧត្តរៈឧទានទៅ
កាន់តាញ្នៅថា :
- ពេលនេះ គ្រួសាររបស់អ្នកគ្រូចរណៃកំពុងទទួលសេចក្តីសុខ ដ៏កក់ក្តៅថ្មីមួយទៀតហើយ ។
ដោយសារតែគេជាមនុស្សល្អទើបគេ មានសំណាង បានជួបតែមនុស្សល្អជាគូជីវិត ។
អាត្មាសប្បាយព្រះ ទ័យណាស់ដែលសមាជិកភូមិយើងម្នាក់ មានវាសនាហោះអណ្តែត
ចេញពីជីវិតក្រីក្រនៅព្រះនេត្រព្រះនេះ ទៅដល់ទីក្រុងបាត់ដំបង
ទទួលការរៀនសូត្រចេះដឹងហើយបានត្រលប់បំរើសង្គមវិញ ។ ជា ពិសេសទៅទៀត
គេក៏បានជួបគូគាប់ដ៏ល្អ ដែលជាហេតុនាំអោយ
ជីវិតក្រុមគ្រួសាររបស់គេកាន់តែរុងរឿងឡើងថែមទៀត ។ ថ្ងៃ ក្រោយ

CHANBOKEO.COM

ស្រុកព្រះនេត្រព្រះយើងនេះ នឹងមានកេរ្តិ៍ឈ្មោះល្បីនៅ ក្នុងក្រាំងសង្គមជាតិខ្មែរទូទាំងប្រទេស ដោយសារតែមានគេម្នាក់ នេះហើយជាអ្នកនាំមុខ នាំផ្លូវ ។

តាញ៉ៅឈរញញឹមសម្លឹងរទេះគោ ដែលមេឃុំភុំបរនាំសមាជិក ក្រុមគ្រួសារចេញទៅ ហើយលើកដៃបៃបន់ថា :

- ចៅណៃអើយ! សូមអោយចៅនិងក្រុមគ្រួសារបានសុខសប្បាយ ជានិច្ចរហូតតទៅណ៎ាចៅ កុំអោយប្រទះជីវិតអភព្វ័តទៅទៀត!

បន្ទាប់មក អ្នកទាំងអស់បានឡើងទៅលើភ្នំព្រះនេត្រព្រះដើម្បី ធ្វើគារវកិច្ចចំពោះ វិញ្ញាណក្ខន្ធឪពុកម្តាយនិងបងស្រីរបស់ចរណៃ ព្រមទាំង នាយខ្លា ដែលជាអតីតស្វាមីដ៏ប្រសើរបំផុតរបស់ចរណៃ ផងដែរ ។

នៅព្រលប់ ថ្ងៃដដែល...

- ចំណាន! ភុំ! អូនប្រមូលឥវ៉ាន់ទៅណាហ្នឹង ?
- គឺយើងនាំគ្នាទៅគេងនៅចាំផ្ទះអោយតាញ៉ៅមេឃុំ ដើម្បីទុកផ្ទះ នេះជូនបងទាំងពីរសំរាក ។
- មិនបាច់ធ្វើដល់ម្លឹងទេអូន! នៅស្នាក់ទីនេះជុំគ្នាហើយនឹងអាល យើងបានជជែកគ្នាលេងផង ។ បងនឹកអូនណាស់ណ៎!

ស្រាប់តែចំណានឱនខ្សិបដាក់ត្រចៀកចរណៃថា :

- ប៉ុន្តែ នៅមានគេនឹកបងខ្លាំងជាងខ្ញុំទៅទៀត ។ ចាំស្អែកយើង ជួបនិយាយគ្នាក៏បានដែរ ។

ចំណានស្រដីហើយលួចមិចភ្នែកដាក់បងស្រីចំអន់លេង រួចក៏ ធ្វើសញ្ញា មិនអោយនាយភុំប្តីនាងនិងកូននៅរំខានគូស្នេហ៍ដ៏ថ្មីថ្មោង ដែលទើបតែទទួលពរថ្មីៗ ពីព្រះគ្រូឧត្តរៈនិងតាញ៉ៅនោះឡើយ ។ ឃើញបងស្រីធ្វើមុខទំនងអៀនខ្មាស ចំណានខ្សិបបន្ថែមថា :

- ប្រហែលជាគេត្រូវការវេលានៅជាមួយបងតែពីរនាក់ជាជាង!

បន្តិចមក ចំណាននិងភុំក៏នាំក្មួយទាំងបីនាក់ ព្រមទាំងកូនស្រី តូចរបស់គេឡើងរទេះគោចេញទៅអស់ រកតែចរណៃឃាត់ក៏មិន បានផង ។

គ្រាន់តែចំណានទៅផុតបានមួយភ្លែត ស្រាប់តែមានបុរសម្នាក់ ចំណាស់ប្រហែលសែសិបឆ្នាំ បានដើរមកដល់មុខផ្ទះ :

- អ្នកគ្រូណៃ!

ឮបុរសកូកហៅ ចរណៃងាកមើល ។ វិចិត្រក៏ខ្សិបសួរនាងថា :

CHANBOKEO.COM

- តើគេជានរណាហ្នឹង អូនណៃ ?

- ចាស! ជាអ្នកភូមិម្តុំនេះទេ ។

ថាហើយ ចរណៃចុះទៅទទួល :

- បងក្អាត់មានការអ្វីដែរ ?

- ខ្ញុំឮថាអ្នកគ្រូមកលេងស្រុក បានជាឆៀងចូលមកមើលនាងម៉ៅ.. តើកូនស្រីខ្ញុំសុខសប្បាយទេ ?

- បងក្អាត់ចេះបារម្ភពីកូនដែរ ?

- គឺ...ដល់បែកវាទៅ ខ្ញុំក៏នឹកវាខ្លះៗដែរ ។

- បើនឹកកូនហើយ... ដែលនឹកឃើញចង់កែខ្លួនវិញទេ ? ឬក៏បង នៅតែផឹកស្រា វាយប្រពន្ធកូនដដែល ?

- បើមិនអោយផឹក ធ្វើម៉េចនឹងបំបាត់សេចក្តីទុក្ខក្នុងខ្លួនរបស់ខ្ញុំបាន ទៅ ? ជីវិតជាអ្នកក្រ វាទាល់ច្រកណាស់!

- ទាល់ច្រកព្រោះតែយើងខ្វះសេចក្តីក្លាហាននឹងជំនះសេចក្តីខ្ជិល! ប៉ុន្តែបើកើតទុក្ខ រួចយកប្រាក់ទៅទិញស្រាផឹក តើវានាំប្រយោជន៍អ្វី ខ្លះដល់ជីវិតរបស់បងដែរ ក្រៅពីបង្កើនអំពើហិង្សាវាយប្រពន្ធកូន អោយឈឺចាប់វេទនា ? មិនត្រឹមតែប៉ុណ្ណោះទេ លុយកាក់ដែលគួរ ណាស់តែទុកប្រើសំរាប់សេចក្តីត្រូវការក្នុងគ្រួសារ បែរជារលាយទៅ លើស្រាទៅវិញ ។ តើនោះជាការជ្រើសរើសដ៏ល្អសំរាប់ដោះស្រាយ ភាពក្រីក្រ និងភាពទាល់ច្រករបស់បងបានទេ ? បងឆ្លើយប្រាប់ខ្ញុំ សិនមក៏...!

ពូក្អាត់នៅស្ងៀម ដាក់មុខចុះ ។ ចរណៃក៏វាចាបន្តថា :

- ហើយបងមកនេះ ដើម្បីមកសួរសុខទុក្ខនាងម៉ៅពិតមែន ឬក៏ មានបំណងអ្វីផ្សេងទៀត ?

- គឺខ្ញុំ...ចង់មកសុំនាងម៉ៅទៅវិញ គ្រាន់ទៅជួយមើលប្អូនដើម្បីឲ្យ ម៉ែវាទៅធ្វើស្រែ ។

- ខ្ញុំមិនអោយទេ! បងក្អាត់យកនាងម៉ៅទៅមើលប្អូនហើយអោយ ប្រពន្ធរបស់បងទៅធ្វើស្រែ ហើយចុះបងធ្វើអីដែរ ?

- ខ្ញុំកំពុងឈឺ... ពេទ្យថា រលាកថ្លើម!

- មែនហើយ! នោះព្រោះតែបងពិសារស្រា ទើបមានជំងឺនេះ ។ ថ្ងៃនេះខ្ញុំមិនអាចអោយនាងម៉ៅទៅបងវិញបាន ត្បិតគេត្រូវទៅ រៀនសូត្រ ដើម្បីថ្ងៃមួយគេមានវិជ្ជា ហើយមានធ្វើការល្អៗដូចខ្ញុំ ដែរ ក្រែងលោះអាចជួយតម្កើងជីវភាពក្រុមគ្រួសារ អោយប្រសើរ ជាងនេះ ។

- អញ្ចឹងអោយខ្ញុំសុំប្រាក់អ្នកគ្រូខ្លះបានទេ ដើម្បីយកទៅទិញថ្នាំ សង្កូវព្យាបាលជំងឺ ។
- បងយកប្រាក់ទៅទិញថ្នាំ ឬក៏យកប្រាក់ទៅទិញស្រាផឹកថែម ទៀត ? ខ្ញុំក៏មិនអោយដែរ ។ ចាំខ្ញុំប្រាប់អ្នកគ្រូពេទ្យចំណានប្អូនស្រី របស់ខ្ញុំអោយជួយព្យាបាលរោគបងដោយមិនយកប្រាក់ ដូច្នេះបង មិនត្រូវការប្រាក់យកទៅព្យបាលទេ...កុំថាខ្ញុំចិត្តអាក្រក់អីណា៎ !
- ពុទ្ធោអើយ ! សុំលុយទៅទិញថ្នាំផឹកក៏មិនអោយដែរ !

ពូក្អាត់ក្តាប់ដៃខាំមាត់ សំដែងអកប្បកិរិយាទ្រង់ខឹងផង ខកចិត្ត ផង ដែលគាត់មិនបានប្រាក់ដូចបំណង ។ ស្រាប់តែចរណៃស្រដី ថែមទៀតថា :
- បងក្អាត់កំពុងសំដែងកិរិយា ដែលប្រកបដោយហឹង្សាក្នុងដួងចិត្ត ទៀតហើយ ។ បងនឹងទេថា អំពើហឹង្សាបំផ្លាញក្រុមគ្រួសារយើង យ៉ាងណាខ្លះ ? ហើយតើខ្លួនយើងដែលជាអ្នកប្រព្រឹត្តអំពើហឹង្សា នោះបានទទួលជោគជ័យ មានសុភមង្គលដែរឬទេ បន្ទាប់ពីបាន ប្រព្រឹត្តអំពើហឹង្សាទៅលើអ្នកដទៃ ឬវត្ថុអ្វីៗ ជុំវិញខ្លួនរួចហើយ ?

ពូក្អាត់ឈ្ងោកមុខមិនហ៊ានតបវិញទេ ត្បិតចរណៃនិយាយត្រូវចំ ចំណុចខ្សោយរបស់គាត់ ។ មាណវីក៏ស្រដីបន្តទៀតថា :
- ការពិត អំពើហឹង្សា មិនត្រឹមតែបំផ្លាញអ្នកដទៃទេ គឺវាបំផ្លាញ ទាំងខ្លួនយើងផង ។ ល្មមដល់ពេលហើយបងក្អាត់ត្រូវបែរមើលខ្លួន ឯងហើយកែមារយាទឡើង កុំអោយចេះតែដើរធ្លាក់ទៅផ្លូវខុស កាន់តែឆ្ងាយទៅៗ ! បើយើងខំធ្វើស្រែឬធ្វើការងារអ្វីដទៃហើយ នៅ តែក្រខ្វះខាតទៀត ក៏គង់ញាតិជិតខាងនៅស្រលាញ់អាណិត រួច បោះដៃជួយខ្លះមិនខាន ។ ប៉ុន្តែបើបងក្រព្រោះញៀនស្រា ប្រព្រឹត្ត ហឹង្សាលើប្រពន្ធកូន គ្មាននរណាគេនឹកអាណិតស្រណោះបងទេ ។ ពេលនោះបងនឹងក្លាយជាជនឯកោលើលោកនេះ ហើយជីវិតរបស់ បងនឹងទទួលបរាជ័យសព្វយ៉ាង ។ ការជនះភាពក្រីក្រមិនមែនដោះ ស្រាយដោយស្រាទេ តែដោយសារភាពព្យាយាមទេតើ ព្យាយាម តស៊ូធ្វើការដោយសុចរិត ឈប់ធ្វើបាបអ្នកដទៃ ដោយសារតែយើង មានទុក្ខកង្វល់ក្នុងខ្លួន... ឈប់ធ្វើអោយកូនចៅប្រពន្ធកូនទឹកភ្នែក ដោយសារអំពើអគតិ របស់អ្នកដែលជាឪពុកនិងជាស្វាមី...

CHANBOKEO.COM

ពូក្លាត់បានឮវាចាទាំងនោះកាលណា ក៏ហាក់ដូចជាភ្លឺស្មារតី បន្តិចមកវិញ ។ ឃើញគាត់នៅស្ងៀមស្ងាត់ អ្នកគ្រូយើងក៏ស្រដី បន្តទៅទៀតថា :

- បងក្លាត់ទៅគេងគិតពិចារណាវិញសិនទៅ ។ ខ្ញុំនៅលេងភូមិ ព្រះនេត្រព្រះនេះពីរបីថ្ងៃ ចាំបងឆ្លៀតចូលមកលេងខ្ញុំទៀតផងណា៎ ក្រែងលោបានជួបនាងម៉ៅ ។ ពេលនេះ គេមិននៅទេ ។ គេទៅ លេងញាតិផងក្នុងភូមិបាត់ទៅហើយ ។

ស្រាប់តែពូក្លាត់សួរភ្លែតថា :

- ហេតុអ្វីនាងម៉ៅគេមិនចូលលេងម៉ែឪបង្កើតរបស់គេសោះ ពេល គេមកដល់ព្រះនេត្រព្រះនេះ ? តែគេបែរជាទៅលេងញាតិដទៃមុន ម៉ែឪទៅវិញយ៉ាងដូច្នោះ ?

ចរណៃញញឹមហើយស្រដីថា :

- បើសិនជាឪពុកម្ដាយថែរក្សាកូនដោយក្ដីស្រលាញ់និងភាពកក់ក្ដៅ នោះកូនចៅនឹងចងចាំជានិច្ចនៅក្នុងជំរៅចិត្តរបស់គេ នូវមេត្តាធម៌ ដែលគេធ្លាប់បានទទួលហើយពីឪពុកម្ដាយ ហើយគេនឹងទៅសំដែង កតញ្ញូចំពោះអ្នកមានគុណវិញមិនខាន ដោយមិនបាច់មានការរំលឹក ឬការបង្ខំចិត្តពីនរណាឡើយ ។ តែបើគេទទួលតែការឈឺចាប់និង ការគម្រាមកំហែងដោយអំពើហិង្សារបស់ឪពុកម្ដាយ កូនៗនឹងខ្លាច រអា ហើយតូចចិត្តបំផុត ។ គេប្រាកដជាមិនហ៊ានវិលវិញមកឃើញ ស្ថានភាពបែបនោះសាជាថ្មីទៀតទេ ព្រោះគេដឹងថាបេះដូងរបស់ គេនឹងទទួលនូវការឈឺចាប់ថ្មីម្ដងទៀត ពេលគេប្រទះមុខឪពុក ម្ដាយដែលមិនព្រមកែមារយាទ ។ ដូច្នេះមុននឹងបងធ្វើអ្វី ប្រព្រឹត្តអ្វី សូមបងលកលៃគិតដល់ចិត្តដល់អារម្មណ៍របស់កូនចៅផង ថ្វីបើគ្នា នៅក្មេងមិនអាចនិយាយអ្វីចេញមក អោយឪពុកម្ដាយយល់ចិត្តគេ បានក៏ដោយ ។ បងក្លាត់កុំបន្ទោសកូនតែម្ខាង...ការពិត បងត្រូវបែរ មើលខ្លួនឯងជាឪពុកគេផង ថាតើយើងបានធ្វើអ្វីខ្លះ ដើម្បីជាគំរូល្អ ដល់កូន និងដើម្បីជាបង្អែកដ៏កក់ក្ដៅសំរាប់កូន ឲ្យគេរស់នៅមាន សេចក្ដីសុខដូចគេផងទាំងពួង ?

ពូក្លាត់លែងហ៊ានតវ៉ាអ្វីទៀតហើយ កាលបើគាត់បានឮពាក្យ ពន្យល់របស់អ្នកគ្រូចរណៃនៅពេលនោះ ។ បន្តិចមកពូក្លាត់ក៏លើក ដៃសំពះលា ព្រមទាំងស្រដីថា :

- អរគុណណាស់អ្នកគ្រូចំពោះពាក្យណែនាំដ៏ល្អប្រពៃនេះ ។ ពេល នេះ ខ្ញុំមិនស្ដាយក្រោយទេ ដែលអោយនាងម៉ៅទៅអ្នកគ្រូចិញ្ចឹមជា កូន ។

CHANBOKEO.COM

សង្ឃឹមថាគេនឹងក្លាយជាមនុស្សល្អប្រពៃហើយមានអនាគត ខ្ពង់ខ្ពស់ដូចអ្នកគ្រូដែរ ព្រោះអ្នកគ្រូជាមនុស្សគួរអោយគោរពបំផុត នៅភូមិព្រះនេត្រព្រះយើងនេះ ក្រៅពីព្រះគ្រូឧត្តរៈនិងតាញ៉ៅអតីត មេឃុំរបស់យើងចេញ ។

និយាយចប់ ពូក្អាត់ក៏ដើរត្រលប់ទៅវិញ ទាំងអារម្មណ៍ស្ងប់ក្នុង ខ្លួនជាងមុន ។ នៅលើរានហាលខាងមុខផ្ទះ វិចិត្របានឈរស្ដាប់ ឮសព្វវាចាដែលធិតាធ្វើការណែនាំអ្នកភូមិ ។ គេឈរញញឹមដោយ សេចក្ដីពេញចិត្តចំពោះឧត្ដមគតិដ៏ថ្លៃថ្នូររបស់នាង ។ ខណៈនេះ គេហាក់ដូចជារំភើបចិត្តកាន់តែខ្លាំងឡើងៗចំពោះមាណវីមួយរូបនេះ... កាន់តែបានស្គាល់ជិតដិត គេកាន់តែប្រតិពទ្ធ័លើរូបនាងកាន់តែខ្លាំង ស្ទើរទប់ចិត្តទប់អារម្មណ៍មិនបានសោះ គឺចង់តែស្ទុះទៅត្រកងថៃ ថើបអោយសមនឹងចិត្តបេតីដែលកំពុងពុះកញ្ជ្រោលពេញឱរា...

ស្បៃអន្ធការក៏លាតស្បៃដណ្ដប់ប្រថពី... ពិភពលោកទាំងមូល ក្លាយជាស្ងាត់ជ្រងំក្សេមក្សាន្ត ក្រោមដំនោររាត្រីបក់ត្រសៀកៗហាក់ បីដូចជាកំពុងបបោសអង្អែលថ្នាក់ថ្នមសត្វលោកទាំងឡាយ អោយ រសាយពីកង្វល់ ។

នៅរានហាលចំហៀងផ្ទះ ចរណៃឈរស្ញៀមស្ងាត់បង្អើរដួងចិត្ត ទៅស្រមោលអតីតកាលមួយ ដែលនាងធ្លាប់បានទទួលនូវក្លិនក្លែប សុភមង្គលដ៏ល្អត្រកាល ។ មែនហើយ! នាងពិតជារន្ធត់ញាប់ញ័រ ក្នុងចិត្តណាស់ កាលបើនាងបានវិលវៃមកឃើញទីនេះម្ដងទៀត ។ អ្វីដែលនាងបាត់នោះ គឺម្ចាស់ផ្ទះក្បឿងមួយនេះ ។ គេស្លាប់ទៅ ហើយ... ដោយមិនបានលានាងមួយម៉ាត់ ប៉ុន្តែ រូបគេមិនទាន់រលប់ ស្រមោលពីបេះដូងរបស់នាងនៅឡើយ ថ្វីបើពេលនេះ បេះដូង របស់នាងកំពុងទទួលឥទ្ធិពលទឹកដមស្នេហាដ៏ល្អប្រណិត ពីបុរសថ្មីម្នាក់ទៀតក៏ដោយ ។ រំពេចនោះទឹកភ្នែកពីរដំណក់ក៏ហូរចាកនេត្រា មកប្រលែងនឹងថ្ពាល់ខួចទាំងគូរបស់នាង...

ចរណៃកំពុងតែលង់អារម្មណ៍ ស្រាប់តែ...

- អូនណៃ..!

ឮសំលេងបុរសហៅរកដូច្នេះ ចរណៃក៏ប្រញាប់យកដៃជូតទឹក ភ្នែកភ្លាម ហើយងាកបែរមករកម្ចាស់សម្លេង ក៏ប្រទះនឹងមាណព រូបសង្ហាស្ថិតក្នុងសំលៀកដំណោករបស់នាយខ្លា ។ ធិតាបើកភ្នែក ធំៗ ឈរធ្វើភាំង សំដែងការភ្ញាក់ផ្អើល :

- បងខ្លា ?

CHANBOKEO.COM

- នេះគឺបងវិចិត្រទេ អូនណៃ!

និតាប្រញាប់ញីភ្នែកហើយងើបមើលម្តងទៀត :

- ហេតុអ្វីក៏លោកមានសម្លៀកបំពាក់របស់បងខ្លាដែរ ?

វិចិត្រញញឹម ហើយឆ្លើយវិញថា :

- ភ្លេចហើយឬថា មានគេបានអោយសម្លៀកនេះមកបងខ្ចីពាក់នៅ រាត្រីដែលបងមកសុំផ្ទះគេជ្រក កណ្តាលព្យុះភ្លៀងដ៏ធំមួយនោះ ? ហើយបងក៏មិនទាន់បានប្រគល់ជូនម្ចាស់គេវិញឯណា ?

និតាឈរសម្លឹងមុខបុរសយើងដោយឥតព្រិចភ្នែក ។ មែន ហើយ! ពេលនេះ នាងទើបតែចាប់ភ្លឹកថា បុរសដែលកំពុងឈរ នៅចំពោះមុខនាង មានភិនភាគប្រហាក់ប្រហែលនាយខ្លា ប្តីដ៏ល្អ របស់នាងក្រៃលែង ។ ប្រហែលជាមូលហេតុនេះទេដឹងដែលនាង តែងតែចាប់អារម្មណ៍លើរូបគេតាំងពីរាត្រីភ្លៀងធំនោះមក :

- សូមទោសដែលណៃភ្លេច... ព្រោះបងខ្លាចូលចិត្តស្លៀកសំលៀក ស្រោបខ្លួនជិតជានិច្ចមិនដែលលេងខ្លួនទទេម្តងណាឡើយ ។

- ព្រោះហេតុអ្វីទៅ ?

- ព្រោះគាត់ធ្លាប់មានរបួសស្លាកស្នាមពេញខ្លួន...ដោយសាររលាក ភ្លើង ពេលទៅជួយរំដោះក្រុមគ្រួសារណៃពីអគ្គីភ័យមួយដែលចោរ ភ្នំដញ្ជាំងបានបង្កឡើង នៅព្រះនេត្រព្រះនេះកាលពី១៥ឆ្នាំមុន...

- បងខ្លាជាមនុស្សក្លាហាន ហើយមានទឹកចិត្តណាស់មែនទេ ?

មាណវីងក់ក្បាល ។ វិចិត្រដើរមកឈរក្បែរស្រីនាថហើយក៏ វាចាទៀតថា :

- ហើយ ផ្ទះឈើមួយនេះ ក៏បង្កប់នូវភាពមនោរម្យ គួរឲ្យចង់រស់ នៅក្រៃលែង!

- ចាស! គឺជាស្នាដៃផ្ទាល់របស់បងខ្លា ដែលសង់ឡើងដើម្បីចងដៃ ណៃ ពេលយើងរៀបការ... ថៃដន្យ ខ្ញុំមានអារម្មណ៍ទន់ខ្សោយពេក មិនអាចប្រឈមនឹងការពិតបាន ចំពោះការដែលខ្ញុំបានឃើញផ្ទះ នេះរាល់ថ្ងៃ តែមិនបានឃើញម្ចាស់ទៅវិញ ទើបដាច់ចិត្តរត់គេច ទៅនៅធ្វើការឯក្រុងបាត់ដំបង ដើម្បីរំសាយខ្លួន ពីរណ្តៅនៃពិភព សោកាអាល័យ...

CHANBOKEO.COM

និតាស្រដីក្នុងសំនៀងក្រៀមក្រំ ។ ឃើញអាការៈសោកសៅរបស់កល្យាណីម្ចាស់ដួងចិត្តរបស់គេភ្លាម វិចិត្រក៏ស្រវាចាប់ដៃនាង ដើរចូលទៅក្នុងផ្ទះ :

- ណែមកតាមបងមក...!

គេដាក់ខ្លួនចុះ ហើយក៏អុជធូបនៅចំពោះមុខកូនហឹងតូចមួយ ក្បែរសសរកន្លោងផ្ទះដែលមានតាំងរូបថតនាយខ្លា ពណ៌សខ្មៅ នៅទីនោះផង បន្ទាប់មកក៏ទាញនិតាឲ្យលុតជង្គង់ទន្ទឹមនឹងនាយ ។ ចរណៃសម្លឹងតាមកាយវិការរបស់គេឥតពព្រិចភ្នែក ។ ខណៈនោះ បុរសយើងលើកដៃប្រណម្យឡើង :

- បងខ្លា! សូមជូនពរយើងទាំងពីរផងណា៎បង! ថ្ងៃនេះ វិចិត្រខ្ញុំសូមចូលមកបញ្ជាក់ប្រាប់វិញ្ញាណក្ខន្ធ័របស់បង ថាខ្ញុំស្រលាញ់អូនណៃ ហើយខ្ញុំនឹងថែរក្សាថ្នាក់ថ្នមនាងនិងកូន អោយបានសុខគ្រប់ប្រការ ដោយជីវិតនិងញើសឈាមរបស់វិចិត្រផ្ទាល់ ។ វិចិត្រនឹងស្រលាញ់ រូបនាងអោយបានច្រើនបំផុត មិនអោយចាញ់ចិត្តស្រលាញ់ដែល បងខ្លាធ្លាប់មានចំពោះនាងឡើយ... វិចិត្រអរគុណបងណាស់ដែល បងបានចាប់ដៃខ្ញុំអោយបានវិលមក ជួបនារីម្នាក់ដែលបេះដូងរបស់ខ្ញុំដង្ហោយហៅរកជាយូរមកហើយ ។ សូមបងអភ័យទោសដល់ វិចិត្រផងចំពោះកំហុសទាំងឡាយពីអតីតកាល...ហើយសូមណៃនាំផ្លូវវិចិត្រនិងអូនណៃឲ្យបានយល់ត្រើយសុខរៀងរហូតទៅ...

រួចហើយវិចិត្រក៏ឈ្ងោកមុខក្រាបបង្គំបីដងយ៉ាងសមរម្យ ប៉ុន្តែ ចរណៃវិញបែរជាបើកភ្នែកសម្លឹងលោកគ្រូពេទ្យដោយក្រសែភ្នែក ងឿងឆ្ងល់បំផុត ត្បិតនាងមិនយល់ទេថា ប្រយោគចុងក្រោយរបស់ លោកគ្រូពេទ្យយើងមានន័យយ៉ាងម៉េច ។ តើគេកំពុងមានកំហុសអ្វី ហើយហេតុអ្វីគេត្រូវមកសូមទោសនាយខ្លាផង ? នាងអង្គុយសម្លឹង មុខមាណពលួចពិចារណាក្នុងចិត្តមិនអស់មិនហើយ ។

កាលបើឃើញមាណវីសម្លឹងមកនាយមិនដាក់ភ្នែកសោះ មួយ ស្របក់ធំមកហើយ វិចិត្រក៏លូកស្រវាចាប់ដៃនាងឡើង :

- ណៃ! បងមានអ្វីមួយចង់បង្ហាញអូនណា៎...

- ចា៎ស... គឺអ្វីទៅ ?

មាណពយកដៃរបស់និតាទៅដាក់លើដើមទ្រូងរបស់នាយ :

CHANBOKEO.COM

- គឺលាក់ទុកនៅក្នុងអាវរបស់បងនេះ ។ អូនដោះអាវបងសិនទៅ នោះអូននឹងបានឃើញហើយ!

ស្រាប់តែធិតាដកដៃវិញយ៉ាងរហ័ស :

- អត់ទេ!.... តើលោកកំពុងគិតអ្វីហ្នឹង ?

មាណពក៏ស្ទុះចាប់ដៃនាងត្រលប់ទៅវិញជាលើកទីពីរ :

- បងគ្មានចេតនាអាក្រក់ទេ អូនណែ... គឺបងបាននាំបញ្ញើពិសេស យកមកផ្ញើអូនទេតើហ៍! អូនពិនិត្យមើលសិនទៅ...

ចរណៃសម្លឹងមុខមាណព ហាក់កំពុងស្ទង់ទឹកចិត្តថាគេកំពុងតែ លេងល្បិចអី ។ តែលុះនាងប្រទះក្រសែភ្នែកដ៏ទន់ភ្លន់ផ្អែមល្ហែម របស់វិចិត្រថាគ្មានពិសពុលអ្វី ធិតាក៏លូកដៃបេះឡេវអាវបុរសចេញ យឺតៗ ថ្នមៗ... ។ ឯបេះដូងរបស់នាងវិញក៏ចាប់ផ្តើមរន្ធើនចង្វាក់ កាន់តែញាប់ឡើងៗ ។ កិរិយារបស់បុរសយើងពេលនេះ បានរំលឹក នូវស្រមោលអតីតកាលមួយដែល នាយខ្លាស្វាមីរបស់នាងធ្លាប់បាន សំដែងចំពោះនាងម្តងរួចហើយ ។ ធិតាគិតក្នុងចិត្តថា ប្រហែលជា មាណពកំពុងប្រាថ្នាហែកបេះដូង បង្ហាញដួងចិត្តសម្ងាត់របស់គេ ចំពោះរូបនាងហើយ ។

អាវបុរសក៏ចំហឡើងបង្ហាញនូវសាច់ដុំលើទ្រូងបុរសយ៉ាងសង្ហា នៅចំពោះមុខធិតា... ហើយនៅលើទ្រូងរបស់គេ បន្តោងចែកាច់រូប ផ្កាចំប៉ាឈ្មោលមួយ កំពុងរយោលទៅយោលមកចុះឡើង នៅចុង ខ្សែអំបោះវេញពណ៌ក្រហម... ធិតាបើកភ្នែកធំៗដោយកិរិយាភន្ត់ ភាំងហើយញាប់ញ័រ :

- បងខ្លា ?...

ថាហើយ នាងក៏យកដៃចាប់បន្តោងនោះព្រមទាំងសួររន្ធើនថា:

- ហេតុដូចម្តេចបានជា.... ខ្សែកបងខ្លា.... មកនៅលើខ្លួនរបស់ លោកពេទ្យទៅវិញ ?

វិចិត្រក៏ចាប់ដៃរបស់នាងដែលកំពុងកាន់បន្តោងផ្កាចំប៉ានោះមក ផ្ទិបនឹងទ្រូងរបស់គេយ៉ាងណែន :

- គឺព្រេងនិស្ស័យណ៎ា អូនណែ! ព្រេងនិស្ស័យដែលបងខ្លាបាន ចងភ្ជាប់រូបបងជាមួយនឹងអូននោះអី!

ចរណៃសម្លឹងកែវភ្នែកបុរស ហើយស្រដីវិញថា :

- ណែមិនយល់ទេ...

CHANBOKEO.COM

- ការពិត... គឺបងខ្លាបានប្រគល់ខ្សែកនេះអោយបង នៅមុនពេល គាត់អស់បុណ្យទៅ ។

និតាសម្លឹងមុខបុរសយើងដោយក្រសែភ្នែកយ៉ាងមុតទំនងហាក់ដូចជាជឿបន្តិច មិនជឿបន្តិច...

- មែនណា៎អូនណៃ! (វិចិត្រនិយាយបញ្ជាក់) បងខ្លាបានដោះខ្សែកនេះឲ្យបងមុនពេលគាត់ផុតដង្ហើម ហើយបានផ្តាំផ្ញើរូបអូនជាមួយ នឹងបងទៀតផង... ចៃដន្យពេលបងបានជួបអូន បងតែងតែភ្លេច ខ្សែកនេះនៅឯផ្ទះ ទើបមិនបានប្រគល់អោយ ។ ក្រោយមក បង បានពាក់យកមកតាមខ្លួនច្រើនដង គិតថានឹងយកមកសងអូនវិញ តែបងនៅតែភ្លេចដដែលជាដដែល ហើយក៏ចេះតែពាក់ជាប់ករបស់បងរៀងរហូតមក...

ចរណៃស្រដីឡើងទាំងរលីងរលោងទឹកភ្នែក :

- នេះគឺជាខ្សែកមង្គល ដែលពុកបានចងដៃ អោយអូននិងបងខ្លា ម្នាក់មួយ នៅមុនពេលគាត់ចែកស្ថានទៅ...

នាងវាចាបានតែប៉ុណ្ណោះក៏អួលដើមកនិយាយលែងរួច ។ នរៈក៏យកដៃទៅជូតទឹកភ្នែកអោយធរី រួចស្រវាកាយនាងអោប បបោស ខ្នងបន្ថើរៗ ហើយលួងលោមថា :

- បងដឹងថា អូននៅមានការរំភើបចិត្ត ចំពោះបុរសដ៏ល្អម្នាក់ដូចបងខ្លាដែលធ្លាប់ផ្តល់នូវសេចក្តីសុខដល់ជីវិតអូនយ៉ាងបរិបូណ៌ ទើប អូនសម្រក់ទឹកភ្នែកដូច្នេះ... ប៉ុន្តែពេលនេះ បងក៏សូមសន្យាដូចគ្នា ដែរថា បងនឹងធ្វើជាមនុស្សដ៏ល្អរបស់អូន ហើយប្រគល់សុភមង្គល គ្រប់បែបយ៉ាងដល់គ្រួសារយើង ដើម្បីអោយអូនរំភើបចិត្តចំពោះបងដូចគ្នា... គឺមិនអោយតិចជាងបងខ្លាឡើយ...

និតាដើបភក្ត្រ័ឡើងសម្លឹងកែវភ្នែកបុរសយើងសាជាថ្មីយ៉ាងយូរ រួចស្រាប់តែដាក់មុខទ្រោបលើទ្រូងបុរស យំសសឹកអាណិតខ្លួនផង រំភើបចិត្តផងច្របូកច្របល់គ្នា ។ នរៈយកដៃអង្អែលខ្នងមាណវី ស្រាលៗ បន្ថើរៗ ហើយលួងលោមបន្តទៀតថា :

- អូនណៃ... នេះ ជារាត្រីមង្គលសំរាប់យើងទាំងពីរណា៎...ឈប់យំ ទៅអូន! ណៃត្រូវតែទទួលស្គាល់ថាអតីតកាលបានកន្លងទៅហើយ សូមអូនរំសាយវាទៅ ហើយអូនគួរតែញញឹមឡើងដើម្បីទទួលយក សុភមង្គលថ្មីរបស់យើងវិញណា៎អូនណា៎...

CHANBOKEO.COM

ថាហើយគេក៏ស្រវាអោបនាងពេញរង្វង់ដៃដោយសេចក្ដីអាណិត
និងស្រលាញ់បំផុតពេញបេះដូងរបស់គេ ជាពិសេសពេលគេឃើញ រង្វង់ភក្ត្រ័នាងពេលណា
បេះដូងរបស់គេប្រែទន់ជ្រាយអស់ហើយ... ចំពោះធវីវិញ
សំនឹងត្រជាក់ហើយក្បេមក្សាន្តរបស់វិចិត្រ បានធ្វើ
ឲ្យនាងរំភើបក្នុងឱរាចង់តែយំសាជាថ្មីទៀតទេ ។ ចែដន្យពេលនេះ
មាណវីបានត្រៀមចិត្តសំរាប់អនាគតថ្មីមួយទៀតហើយ ។ ធិតាងើប
មុខឡើងញញឹមឡើងយ៉ាងបំព្រង កាត់ដំណើរទឹកភ្នែក រួចក៏ផ្ដេក កេសាលើទ្រូងបុរស
សម្ដែងនូវទឹកចិត្តរំភើបព្រឺព្រួចចំពោះរូបគេ ជាលើកដំបូង ។ បន្ទាប់មក
នារីលូកដៃស្រវាអោបចង្កេះមាណព វិញ យ៉ាងណែនពេញរង្វង់ដៃ... ភ្លាមនោះ មាណពបានទទួល
អារម្មណ៍ថា ចរណៃកំពុងឆ្លើយតបចំលើយដួងចិត្តយ៉ាងផ្អែមល្ហែម មួយ ចំពោះរូបគេវិញហើយ ។
បេះដូងរបស់គេក៏រណ្ដំចង្វាក់តន្ត្រី ស្នេហាដ៏ពិរោះមួយបទឡើង
សណ្ដំដួងទ័យានរៈយើងឲ្យយល់នូវ សោភណ័ស្នេហាភិសម័យយ៉ាងស្រស់ត្រកាលបំផុត ។
មាណពភ្ញើយចង្កាកល្យាណីឡើង សម្លឹងមុខក្រ្តានធវី ដោយ ឱរារំដើបរំជួល
បន្ទាប់មកក៏បង្អោនយកនាសាទៅផ្ទិតលើផែនថ្ពាល់ ដ៏រលើបរលោង
រួចក៏បង្អូសមកលើបបូរមាត់ក្របាមធម្មជាតិរបស់ នាង ស្រាប់តែមាណវីយកដៃមកទប់ជាប់ :
- គឺ...ខ្ញុំសុំនិយាយរឿងមួយជាមួយលោកពេទ្យសិនបានទេ ?
- ចាំស្អែកទៅណា៎... ព្រោះពេលនេះបងចង់ថ្នាក់ថ្នមអូន...
- អត់ទេ... ខ្ញុំចង់និយាយពេលនេះ មុននឹងយើងជ្រុលដំណើរ...
វិចិត្រងើបមុខឡើង សួរទំនងនឹកឆ្ងល់ :
- ជ្រុលដំណើរ ? រឿងអ្វីទៅ ?
- គឺ... ជារឿងដ៏អាមាសមួយរបស់ណៃ... សូមពិគ្រោះគ្នាបន្តិចណា៎
ត្បិតណៃមិនចង់អោយលោកខកចិត្តនៅពេលក្រោយនោះទេ ថាណៃ ជាមនុស្សកុហក
បន្លំខ្លួនធ្វើជាមនុស្សល្អ ។
វិចិត្រងើបឡើងយកដៃក្រសោបចង្កេះនាងពីក្រោយហើយយក
ចង្កាដាក់លើស្មាធិតាក្បែរថ្ពាល់របស់នាងសម្ដែងនូវកិរិយាដែលមាន
ជំនឿទុកចិត្តចំពោះនាង រួចស្រដីថា :
- អញ្ចឹង អូននិយាយប្រាប់បងមកចុះ បងរង់ចាំស្ដាប់អូនហើយ...

CHANBOKEO.COM

ធិតាឈ្ងោកមុខ លេបទឹកមាត់ផ្សើមបំពង់ក ហើយក៏ស្រដីថា :

- ការពិត ណៃក៏ធ្លាប់បានសារភាពជាមួយបងខ្លា នៅរាត្រីថ្ងៃមង្គល ហើយពេលនេះ ណៃក៏សូមសារភាពជាមួយលោកគ្រូពេទ្យ នៅថ្ងៃ មង្គលដូចគ្នាដែរថា... ណៃមិនមែនជានារីល្អបរិសុទ្ធផូផង់ទេ នៅ មុនពេលណៃរួមរស់ជាមួយនឹងបងខ្លាជាស្វាមីភរិយា... ព្រោះណៃ បានត្រូវបុរសម្នាក់បំពាន... ជាន់ឈ្លីព្រហ្មចារីយ៍...

ថាតែប៉ុណ្ណោះ ចរណៃទុចដ៏ក់ហើយក៏រលីងរលោងទឹកភ្នែក ។ វិចិត្រអង្គុយអោបធិតា ធ្វើស្ងៀមស្ងាត់កាលបើឮសំដីនាងដូច្នោះ ។ ពេលនោះ មាណវីវាចាបន្តថែមទៀតថា :

- ប៉ុន្តែណៃសង្ឃឹមថា លោកគ្រូពេទ្យនឹងសណ្តោសណៃ ដូចដែល បងខ្លាធ្លាប់មានមេត្តាចំពោះណៃដូចគ្នា... ព្រោះណៃចង់អោយលោក ពេទ្យទទួលដឹងការពិត ថានារីដែលខ្លួនរៀបការជាមួយមានប្រវត្តិ អតីតកាលយ៉ាងណា ។ ធ្វើជាគូជីវិតនឹងគ្នា យើងត្រូវតែមានការ ស្មោះត្រង់នឹងគ្នា... បើលោកពេទ្យអាចទទួលណៃបាន នោះណៃនឹង មានការរំភើបចិត្តបំផុត ។ ប៉ុន្តែបើលោកពេទ្យទទួលមិនបាន នោះ ក៏មិនទាន់យឺតពេលដែរដែលលោកពេទ្យចង់ដូរចិត្ត ត្បិតយើងនៅ មានទាន់បានរួមដំណើរជីវិតជាមួយគ្នានៅឡើយ ។

ធិតាឈ្ងោកមុខដកដង្ហើមបន្ធូរទ្រូវមួយស្របក់ទើបបន្តទៀតថា:

- តាមពិត ភក្ត្រាមិនមែនជាសាច់ឈាមរបស់បងខ្លាទេ ថ្វីបើគាត់ ស្រលាញ់ថ្នាក់ថ្នមថែរក្សាកូនភក្ត្រា មិនខុសពីកូនបង្កើតរបស់គាត់ យ៉ាងណាក៏ដោយ... រីឯលោកគ្រូពេទ្យវិញក៏មិនមែនបុរសទីពីរក្នុង ជីវិតរបស់ណៃ បន្ទាប់ពីបងខ្លាដែរ...

ចរណៃឈ្ងោកមុខ វាចាទាំងអួលអាក់ ។ តែវិចិត្រមិនបាន សម្តែងការភ្ញាក់ផ្អើលអ្វីបន្តិចទេ ។ ផ្ទុយទៅវិញ គេបែរជាយកដៃ អង្អែលមាណវី ដោយដួងចិត្តអាណិតអាសូរទៅវិញ :

- នរណាថាបងជាមនុស្សទីពីរ ទីបីរបស់អូនណៃ... ? ការពិត បង គឺជាបុរសទីមួយរបស់អូនតើហ៍! ណៃ! អូនឈប់គិតអ្វីវែងឆ្ងាយ អ្វីទៀតទៅ...ណា៎...!

ចរណៃងើបមើលមុខវិចិត្រភ្លាម កាលបើឮសំដីគេដូច្នោះ :

- លោកពេទ្យមានប្រសាសន៍នេះ មានន័យថាម៉េច ?

វិចិត្រញញឹមឡើង ហើយដូរប្រយោគបន្លប់ភ្លាម :

- អូនណៃ! ឈប់ហៅបងថា "លោកគ្រូពេទ្យ"ទៀតទៅបានទេ ?

CHANBOKEO.COM

ស្តាប់ទៅដូចជាមិនជិតជិតនឹងគ្នាទាល់តែសោះ ។
- តែលោកមិនទាន់ឆ្លើយទេ ថាលោកនឹងអភ័យទោសអោយណៃ...
- ចាំអោយបងអភ័យទោសអូនធ្វើអីទៅ បើវាមិនមែនជាកំហុស របស់ណៃផងនោះ... ?
ណៃ...ហៅបងថា បងៗ សិនមក៏ នោះបង
នឹងទទួលថាបងជាបុរសតែមួយគត់របស់អូនរហូតតទៅ...ហើយអូន
ត្រូវតែឈប់គិតពីអតីតកាលអ្វីទាំងអស់... បានទេ ?

ចរណៃធ្វើមុខស្មើ... វិចិត្រឃើញហើយ ក៏លួងលោមថា :

- មើល៍..! យើងបានទទួលពរពីព្រះគ្រូរួចហើយ ថាយើងនឹងចាប់ ដៃគ្នាជាគូជីវិត...
បងចង់ឮពាក្យរបស់អូនហៅថា បងៗ ណាស់.. ហៅដើម្បីឲ្យបងបានដឹងថា
អូនពិតជាយល់ព្រមទទួលបងជាបុរស ដ៏សំខាន់តែម្នាក់របស់អូន ចាប់ពីថ្ងៃនេះរហូតតទៅ...
- អញ្ចឹងលោកសន្យាសិនមក៏ ថាលោកអភ័យទោសអោយណៃ..!
- ដូចគ្នាដែរ បងក៏ចង់អោយអូនអភ័យទោសអោយបងដូចគ្នាដែរ
បើសិនណាបងមានកំហុសឆ្គាំឆ្គងចំពោះអូនពីអតីតកាល...
- ថាម៉េច ? លោកធ្លាប់មានកំហុសពីអតីតកាលដែរ ?
- បាទ!...ជាកំហុសដ៏ធំមួយ...ដែលបងចង់អោយណៃអភ័យទោស អោយបងដូចគ្នា ។
- ក្នុងក្រសែភ្នែករបស់ណៃ លោកគ្រូពេទ្យជាមនុស្សល្អ រឿងអី
ដែលណៃត្រូវប្រកាន់ទោសពៃរ៍ផងនោះ ?
- មានន័យថា ណៃនឹងអភ័យទោសអោយបងសព្វយ៉ាង ចំពោះ
កំហុសរបស់បងពីអតីតកាលហើយហ្ន៎ស ?

មាណវីងក់ក្បាល :

- ចា៎ស! គឺដើម្បីសេចក្តីសុខក្នុងគ្រួសាររបស់យើង ។

វិចិត្ររំភើបចិត្តពេក ក៏ចាប់ដៃកល្យាណី យកមកថើប :

- ណៃ! បងស្រលាញ់អូនណាស់ ដឹងទេ... ? ស្រលាញ់តាំងពីយូរ ហើយ...
ហើយក៏ស្រលាញ់រហូតតរៀងទៅ...បងមិនស្តាយក្រោយ ឡើយ
ដែលបងបានជ្រើសរើសអូនជាគូជីវិត ។

គេក៏ស្រវាអោបនិតាសាជាថ្មីដោយដួងចិត្តញាប់ញ័រ ។

- អញ្ចឹងបងប្រាប់ណៃសិនមក៏ ថាបងស្រលាញ់ណៃពីអង្កាល់ ?

CHANBOKEO.COM

ធិតាឱ្យបសួរតិចៗដាក់ត្រចៀកគូស្នេហ៍ ។

- គឺ...ពីថ្ងៃដែលបងបានឃើញថ្ពាល់ខួចរបស់អូនជាលើកដំបូង...
- តាំងពីពេលណា ?
- គឺ... ពេលដែលបងបានប្រទះស្នាមញញឹម... ដ៏ស្រស់ស្អាតមួយ នៅលើ...ផែនថ្ពាល់ខួចមួយគូនោះឯង...
- នោះឯណា ? ហេតុអ្វីក៏បងចាំនិយាយរតាក់រតុបផង ?
- អូនសួរបងអីច្រើនម្លេះ ? ទុកសួរស្អែកខ្លះបានទេ ? ថ្ងៃនេះ បងមានការ...
- អញ្ជឹង បងមានការអ្វីដែរទៅ... ?

តែគេឈប់ឆ្លើយតទៅទៀតហើយ ។ គេបែរជាយកបបូរមាត់របស់ខ្លួនទៅផ្ទិបលើបបូរមាត់នារីយ៉ាងណែន មិនអោយនាងស្រដី សួរអ្វីបានទៀតឡើយ រួចហើយគេក៏ផ្តួលកាយមាណវីទៅលើគ្រែដ៏ ប្រណិតមួយដែលមានខ្នើយមាសកម្រាលមន្តរង់ចាំទទួលសោភ័ណ សុភមង្គល នារាត្រីដំបូងបង្អស់ រវាងរូបគេទាំងពីរកាយា ។ វិចិត្រក៏ថ្នាក់ថ្នមគូនៃបនិត្យរបស់គេ យ៉ាងផ្អែមល្ហែម តាមអំណាចកំសួល ពុះកញ្ជ្រោលក្នុងបេះដូងដោយឥទ្ធិពលនៃដួងចិត្តប្រតិពទ្ធ័ដ៏សែន ជ្រាលជ្រៅរបស់នរៈចំពោះធិតាជាយូរមកហើយ ។

នៅខាងក្រៅផ្ទះ សម្លេងស្លឹកដូងបបោសលើដំបូលក្បឿងលាន់ ខ្សាកៗ ចុះឡើងៗទៅតាមជំនោរវាតានៃរាត្រីដ៏សែនស្ងាត់ ហាក់បីដូចជាកំពុងបបោសអង្អែលហឫទ័យគូគាប់ទាំងពីរ អោយកាន់តែ រំភើបព្រឺព្រួចស្រើបអារម្មណ៍លង់លិចទៅក្នុងសេចក្តីស្នេហាដ៏មាន ជំរៅធំធេងឥតព្រំដែននឹងវាស់បានឡើយ ។

ooooooooooooooooooo

oooooooooooo

o

CHANBOKEO.COM

# វគ្គទី៦
# ព្យុះក្នុងដួងចិត្ត

ក្រុងបាត់ដំបង ជាងពីរខែកន្លងមក...

វិចិត្របានទទួលចរណៃនិងកូនៗ មករស់នៅជាមួយគេយ៉ាង ពេញមុខ តាំងពីគេត្រលប់មកពីព្រះនេត្រព្រះវិញ ។ ថ្វីបើអ្នកស្រី ផាន់ស៊ីបានមាត់ធំមាត់តូចជាច្រើនដងជាមួយគេក៏ដោយ ក៏គេចេញ មុខការពារជីវិតគូស្រករបស់គេយ៉ាងម៉ឺងម៉ាត់បំផុត ដោយមិនព្រម បណ្តោយអោយអ្នកទីបីមកសម្រុតកម្លាំងចិត្ត និងសេចក្តីស្រលាញ់ របស់គេចំពោះចរណៃនិងកូនរបស់នាងបានឡើយ ។ តើហេតុអ្វីទៅ ហ្វ៊ុ ដែលធ្វើអោយគេក្លាហាន ហ៊ានប្រឈមមុខការពារក្រុមគ្រួសារ ថ្មីរបស់គេដល់ម្លឹង ? ហើយចុះពេលនេះ ភក្តីនៅឯណា ? ហេតុ ដូចម្តេចបានជាបាត់មុខអោយឈឹង មិនឃើញទៅមកជាមួយនឹង បងប្រុសរបស់ខ្លួនដូច្នេះ ?

ទោះជាយ៉ាងណា ពេលនេះវិចិត្រមានអារម្មណ៍ថាគេបានទទួល នូវសេចក្តីសុខ និងសុភមង្គលយ៉ាងពេញលក្ខណៈដោយឥតប្រកែក បាន ។ រីឯធិតាយើងក៏បានប្រគល់នូវភាពទន់ភ្លន់ និងខ្លឹមសម្ផស្ស ជីវិតដ៏ស្រស់ត្រកាល ជាការឆ្លើយតបទៅនឹងការថ្នាក់ថ្នមរបស់នរៈ យើងយ៉ាងបរិបូណ៌បំផុតដូចគ្នាដែរ ។ គេស្រលាញ់គ្នាណាស់...! គេ ថ្នាក់ថ្នមគ្នា... គេលើកកម្លាំងចិត្តគ្នា... ហើយមានជំនឿចិត្តចំពោះគ្នា ទៅវិញទៅមកយ៉ាងជ្រាលជ្រៅឥតព្រំដែន ។ ខណៈនេះ ចំរៀង អ្វីក៏មិនពិរោះស្មើនឹងចំរៀងស្នេហាសុភមង្គលរបស់គេទាំងពីរនៅនា បច្ចុប្បន្ននេះឡើយ ហើយគេតែងតែគិតថាប្រហែល ជាគេទាំងពីជា គូជីវិតតែមួយគូគត់ ដែលមានសុភមង្គលជាងគេបង្អស់នៅលើ លោកយើងនេះ ។

នៅរសៀលថ្ងៃមួយ...

CHANBOKEO.COM

វិចិត្រតែងតែចេញទៅប្រកបកិច្ចការ ជាវេជ្ជបណ្ឌិតនៅពេទ្យធំ ដូចប្រក្រតី ។ ចំណែកចរណៃក៏នៅតែរក្សាការងារនៅវិទ្យាល័យនារី ដដែល ។ នាងម៉ៅបានចូលរៀននៅបូព៌ាសាលាបន្តទៀត ។ ប៉ុន្តែ ពីរនាក់ទៀតត្រូវចរណៃយកផ្ញើជាមួយមីងលឿម ដែលតែងតែ មក ជួយមើលក្មេងតូចៗទាំងពីរនាក់ នៅផ្ទះវិចិត្រតែម្តង ។

ថ្ងៃនេះ វិចិត្រត្រូវចូលវេនយាមមិនបាននៅផ្ទះទេ ។ ឯចរណៃ ក៏ត្រូវយកចង្ហាន់ទៅវត្ត ដើម្បីបង្សុកូលបុណ្យខួបលើកទីបីរបស់ លោកចំណាប់និងអ្នកស្រីចិន្តា ឪពុកម្តាយចិញ្ចឹមរបស់ចរណៃហើយ ដែលត្រូវជាឪពុកម្តាយបង្កើតរបស់អ្នកគ្រូពេទ្យចំណាន ។ លោក ទាំងពីរបានចែកស្ថានទៅទាំងពីរនាក់ ក្នុងគ្រោះថ្នាក់ចរាចរមួយនៅ ប្រទេសបារាំង ។ សព្វថ្ងៃ អ្នកគ្រូចរណៃបានដម្កល់ធាតុរបស់លោក នៅចេតិយមួយក្នុងវត្តគរដែលជាភូមិកំណើតរបស់លោកចំណាប់ ។

បន្ទាប់ពីប្រគេនចង្ហាន់បង្សុកូល ជូនវិញ្ញាណក្ខន្ធរបស់អ្នកមាន គុណហើយ ធិតាយើងក៏បែរខ្លួនបំរុងនឹងហៅរ៉ឺម៉កជិះត្រលប់ទៅផ្ទះ វិញទៅហើយ ស្រាប់តែប្រទះនឹងរថយន្តមួយបរចូលមកដល់ ។ រំពេចនោះ នាងឮសម្លេងស្រីម្នាក់ស្រដីរួសរាយដាក់នាងពីក្នុងឡាន មួយនោះមកថា :

- សួស្តី អ្នកគ្រូចរណៃ! សុខសប្បាយទេ ?
- អូហ៍ អ្នកនាងលិនដា! ជំរាបសួរចា៎ស!

មែនហើយ នោះគឺលិនដាដ៏ស្រស់សោភា ។ ធិតាចតរថយន្ត រួចក៏ដើរសំដៅមករកចរណៃភ្លាម ។

- អ្នកនាងមកលេងសាច់ញាតិនៅម្តុំនេះមែនទេ ? (ចរណៃសួរ)
- ចា៎ស! ជាសាច់ញាតិខាងប្តីរបស់ខ្ញុំ... គាត់មកសំណាក់ធម៌ទីនេះ តែថ្ងៃនេះខ្ញុំត្រូវទទួលគាត់ទៅផ្ទះវិញ ។ ហើយចុះអ្នកនាងសុខទុក្ខ យ៉ាងណាដែរ ? នៅទៅមករាប់អាននឹងលោកគ្រូពេទ្យវិចិត្រទេ ?

ឮប្រយោគដូច្នោះ ចរណៃយល់ភ្លាមថានាងមិនបានដឹងពីរឿង វិចិត្ររៀបការជាមួយចរណៃទេ ត្បិតគេទាំងពីរបានរៀបការស្ងាត់ៗ នៅឯស្រុកកំណើតរបស់នាង ទើបគ្មានញាតិមិត្តណាមួយដែលនៅ បាត់ដំបងបានដឹងទេក្រៅពីអ្នកស្រីផាន់ស៊ីចេញ ព្រោះគាត់ឧស្សាហ៍ ទៅអើតវិចិត្រញឹកញាប់ ។ ចរណៃមិនហ៊ានស្រដីអ្វីតបវិញទៅនារី

CHANBOKEO.COM

សោភាឈ្មោះលិនដានោះដែរ គ្រាន់តែញញឹមតបវិញប៉ុណ្ណោះព្រោះ
មិនចង់អោយល្អក់ទឹកចិត្តលិនដា ។ ភ្លាមនោះ ស្រាប់តែលិនដាដើរ
មកជិតនាងហើយខ្សិបប្រាប់បន្ថែមទៀតថា :

- លិនដាសូមប្រាប់យកបុណ្យចុះណា៎... កុំថាអីថាវ៉ាន់ ព្រោះយើង ជាស្រីដូចគ្នា ។
ខ្ញុំមិនចង់អោយអ្នកនាងត្រូវជូតទឹកភ្នែកដូចរូបខ្ញុំនា គ្រាមួយក្នុងអតិតកាលនោះទេ ។ ការពិត
ខ្ញុំនិងលោកវិចិត្រធ្លាប់ជា គូដណ្ដឹងនឹងគ្នា ជិតនឹងរៀបការទៅហើយ... ថៃដន្យលោកដុកទ័រ
ក្មេងនោះបានប្រព្រឹត្តអនាចារ្យទៅលើរូបស្រីក្រមុំម្នាក់ ហើយត្រូវខ្ញុំ ចាប់បានផ្ទាល់ភ្នែក
ទើបយើងត្រូវចែកផ្លូវគ្នា ។ អ្នកនាងដឹងទេ ថាពេលនោះ ខ្ញុំឈឺចាប់ហើយអាមាសយ៉ាងណា
ដែលគេធ្វើដូច្នោះ ដាក់ខ្ញុំ ?

លិនដានិយាយដល់ត្រង់នេះ ក៏រលីងរលោងទឹកភ្នែក បន្តិចមក ក៏យកដៃផ្ចិតទឹកភ្នែកវិញ
ទើបនិយាយបន្តថា :

- ខ្ញុំបានចាំគាត់ជាច្រើនឆ្នាំ ទំរាំគាត់រៀនដុកទ័រចប់ លុះដល់គាត់ ចេញធ្វើការ
ស្រាប់តែគាត់បែរទៅជាប្រព្រឹត្តអំពើមិនគប្បីយ៉ាងនោះ ទៅវិញ ខ្ញុំឈឺចាប់ហើយអាមាសណាស់...
យើងក៏បែកផ្លូវគ្នាតាំង ពីនោះមក ។ ប៉ុន្តែអ្វីដែលខ្ញុំស្ដាយបំផុតនោះគឺ...ខ្ញុំមើលមនុស្សខុស
រលីងធេង ។ សំណាងល្អដែរដែលខ្ញុំមិនទាន់ជ្រុលជ្រួស កុំអី...

លិនដាលេបទឹកមាត់ផ្សើមបំពង់កហាក់ដូចជាកំពុងញាប់ញ័រនឹង អតីតកាលខ្លាំងណាស់ ។
ព្រមជាមួយគ្នានេះដែរ ចរណៃក៏ញាប់ញ័រ រន្ធត់ក្នុងចិត្តក្រៃណា ក្រោយពីបានឮពត៌មាន
ដែលលិនដារៀបរាប់ ប្រាប់ ។ លិនដាក៏វាចាបន្តទៀតថា :

- បើអ្នកនាងទៅមកជាមួយនឹងលោកវិចិត្រ មើលៗផងណា៎ ក្រែង
លោត្រូវធ្លាក់ផ្លូវឆ្គោយចិត្តដូចខ្ញុំ... ថ្វីបើសព្វថ្ងៃនេះ ខ្ញុំរៀបការរួច ទៅហើយ
តែការសំរេចចិត្តដោយតក្កហលព្រោះឈឺចាប់ដែលបុរស មួយរូបនោះក្បត់ចិត្ត
ធ្វើអោយខ្ញុំរើសយកគូស្រករដែលខ្លួនមិនបាន ស្រលាញ់ជាគូទៅវិញ ម្ល៉ោះហើយ
ខ្ញុំក៏ត្រូវរស់ចៀមទិប្បដិសារី...

ទាំងពីរនាក់នៅស្ងៀមស្ងាត់មួយស្របក់ រំងាប់ចិត្តពុះកញ្ជ្រោល ទំរាំចរណៃក៏ដាច់ចិត្ត
សួរទៅលិនដាវិញទាំងញាប់ញ័រក្នុងចិត្តថា :

- ហើយចុះអ្នកនាងស្គាល់ទេ ថានារីដែលត្រូវវិចិត្រធ្វើបាបនោះជា នរណា
ហើយគេនៅឯណាដែរពេលនេះ ?

CHANBOKEO.COM

លិនដាសម្លឹងមុខចរណៃមួយស្របក់ ទើបឆ្លើយថា :

- ខ្ញុំចំណាំមុខគេមិនច្បាស់ទេ ត្បិតអាល័យតែតក់ស្លុតខ្លាំងពេក ចំពោះហេតុការណ៍ដែលខ្លួនកំពុងប្រទះនៅនឹងភ្នែក ហើយខ្ញុំក៏រត់ចេញមក... មកទល់នឹងពេលនេះ ខ្ញុំក៏មិនដឹងដែរថានារីរងគ្រោះនោះជានរណាទេ...

ចរណៃរន្ធត់ចិត្តអ្វីម៉្លេះទេ កាលបើបានទទួលដំណឹងនេះកាល ណា ។ តើឲ្យនាងគិតយ៉ាងណា ធ្វើយ៉ាងណា ចំពោះពត៌មាននេះ ? តើវាជាការពិតទេ ?បើលិនដាកុហកនាង តើគេធ្វើក្នុងគោលបំណង អ្វីដែរ ? មើលទៅអកប្បកិរិយារបស់នាងដ៏ញាប់ញ័រនៅពេលនេះ មាណវីប្រហែលជាមិនភូតភរចរណៃទេ ប៉ុន្តែ តើនាងមកបង្ហើប រឿងនេះប្រាប់ដល់ចរណៃធ្វើអ្វី ? ចរណៃពិចារណាក្នុងអារម្មណ៍មិន អស់មិនហើយ...

ធិតាក៏វិលមកផ្ទះ ប្រណិបតន៍ស្វាមីយ៉ាងល្អ តាមដែលនាងធ្លាប់ ធ្វើជាប្រក្រតី ។ នៅលើរានហាលមុខផ្ទះ វិចិត្រកំពុងអង្គុយលើ ទោងដ៏ស្រស់ស្អាតមួយ នាំបារមីនិងភក្ត្រាអានសៀវភៅកុមារដែល មានគំនូរផ្សេងៗ ។ មើលទៅគេហាក់ដូចជាទទួលខ្លួនជាឪពុក របស់ក្មេងយ៉ាងពេញលក្ខណៈ ។ កិរិយារបស់គេចំពោះក្មេងទាំងពីរបានបង្ហាញនូវភាពទទួលខុសត្រូវ និងក្តីស្រលាញ់យ៉ាងជ្រាលជ្រៅ ដោយឥតក្លែងបន្លំ ។ នៅតុមួយក្បែរនោះ នាងម៉ៅអង្គុយធ្វើ លំហាត់ សាលាដោយស្ងៀមស្ងាត់ ។ យូរម្តងៗ នាងបែរសួរវិចិត្រ ហើយហៅគេថាប៉ាៗពេញមាត់ ។ ឯវិចិត្រវិញក៏ឆ្លើយតបនាងម៉ៅដោយគំនិតរាក់ជ្រៅប្រកបដោយឆន្ទៈអប់រំកូនយ៉ាងប្រពៃ ។ មើល ទៅកូនរបស់នាងទាំងអស់ក៏ហាក់ដូចជាបានទទួលសុភមង្គលជីវិត យ៉ាងកក់ក្តៅបំផុតនៅក្រោមការគ្រប់គ្រងរបស់វិចិត្រ ។ ថ្វីបើគេ មិនដែលមានក្រុមគ្រួសារពីមុនមក ក៏វិចិត្រទទួលនាទីបានយ៉ាងល្អ ប្រសើរ ដែលធ្វើឲ្យចរណៃរំភើបចិត្តចំពោះគេមិនលែង ។ ពេល នេះ តើគួរឬទេដែលនាងត្រូវយកចំងល់ ដែលលិនដានាំមកប្រគល់ ដល់នាងកាលពីថ្ងៃ មកកកូរកកាយសួរវិចិត្រ ឲ្យរំខានដល់សេចក្តីសុខរបស់នាងនិងកូនៗ ? តែ.. បើមិនសួរទេ ដួងចិត្តនាងក៏នៅតែច្របូកច្របល់មិនអស់មិនហើយ ចេះតែអន្ទះសាក្នុងអារម្មណ៍ យ៉ាងណាមិនដឹង ។ នាងមិនព្រមជឿទេថា វិចិត្រធ្លាប់ប្រព្រឹត្តអំពើ គួរអាមាសពីមុនមក តែចំពោះអ្នកនាងលិនដាវិញ ក៏មិនសមហេតុ ផលអ្វីដែលនាងនឹងមកកុហកចរណៃដែរ កាលបើនាងស្រដីប្រាប់ចរណៃទាំងទឹកភ្នែកទឹកសំបោរ នៅក្នុងបរិវេណវត្តយ៉ាងនេះ ។ ពេលនេះ

CHANBOKEO.COM

តើចរណៃត្រូវធ្វើបែបណា ដើម្បីអោយបានដឹងការពិត ដោយមិនរំខានផ្លូវចិត្តនរណាទាំងអស់ ជាពិសេសគឺកុំអោយរំខាន សេចក្តីសុខដែលកូនរបស់នាងកំពុងបានទទួលពេលនេះតែម្តង ។

យប់ជ្រៅបន្តិចហើយ...

ចរណៃអង្គុយកាន់សៀវភៅអានផង គិតផង យ៉ាងច្របូក ច្របល់រកកោះត្រើយមិនឃើញ ។ ពិតមែនតែនាងហាក់ដូចជាមាន អាការៈស្ងប់ស្ងាត់នៅសំបកខាងក្រៅ ប៉ុន្តែដើមទ្រូងរបស់នាងបាន បង្កប់ពោរពេញទៅដោយកម្លាំង ខ្យល់ព្យុះបោកបក់រណ្តំលាន់ឮ យ៉ាំងគគ្រឹកគគ្រេងក្រៃលែង ។ ចរណៃញាប់ញ័រក្នុងចិត្តយ៉ាងណា មិនដឹង រកថាមិនត្រូវសោះ ។ ហេតុអ្វីនាងត្រូវគិតពីអតីតកាល របស់គេផង កាលបើវិចិត្រមិនដែលរវល់គិតអ្វីអំពីអតីតកាលរបស់ នាងសូម្បីបន្តិច ។ គេព្រមទទួលនាងសព្វយ៉ាងទាំងអស់ ហើយចុះ នាងវិញទទួលគេបានទេ កាលបើនាងមិនបានដឹងអតីតកាលរបស់ គេជាក់ច្បាស់ ? ពេលនេះ នាងបានរៀបការនឹងគេទៅហើយ... ជា អាពាហ៍ពិពាហ៍ ដែលនាងបានសំរេចចិត្តយ៉ាងរហ័ស បន្ទាប់ពីបាន ស្គាល់គ្នាមិនបានប៉ុន្មានអាទិត្យផង ។ តើនាងខុសឬទេ ដែលខ្លួន នាងមិនព្រម ផ្តល់ពេលវេលាអោយខ្លួនឯងសម្លឹងពិនិត្យរូបវិចិត្រ អោយបានយូរ ដើម្បីកុំអោយប្រទះវិប្បដិសារី ? តើវិចិត្រនៅមាន អ្វីលាក់បាំងជាមួយនាងទៀតដែរឬទេ ? បើនាងសាកសួរប្រវត្តិ អតិតរបស់គេ តើគេនឹងមានអារម្មណ៍ប្រតិកម្មមកនាងវិញយ៉ាង ណា ? ហេតុអីនាង មិនដែលនឹកឃើញចង់ដឹងពីប្រវត្តិរបស់គេម្តង ណាសោះកាលពីមុនពេលរៀបការ ? ហេតុអ្វីរឿងខ្សិបបន្តិចបន្តួច របស់នារីមួយរូបនោះ អាចធ្វើឲ្យបេះដូងរបស់នាងប្រាសចាកនូវ សេចក្តីសុខអស់រលីងយ៉ាងនេះ ? ហើយហេតុអ្វីមាណវីបែរជាមក ចង់ដឹងរឿងពិត ពីអតិតកាលរបស់វិចិត្រ នៅពេលនេះទៅវិញ ? តើនាងកំពុងសង្ស័យអ្វីពីគេ ដូចអ្នកនាង លិនដានិយាយប្រាប់នោះ មែនទេ ?

- អូនណៃ !

ចរណៃភ្ញាក់ព្រើតដែលវិចិត្រឱនឈ្ងោកខ្សឹបហៅមាណវី ក្បែរ ត្រចៀក ក្នុងខណៈដែលនាងកំពុងគិតភ្លឹកភ្លេចស្មារតី ។ នាងបែរ ញញឹមដាក់គេភ្លាមយ៉ាងរហ័ស :

- បងមិនទាន់សំរាន្តទេ ?

- នៅទេ ព្រោះបងចាំចូលដំណេកដំណាលគ្នាជាមួយប្រពន្ធ ។

CHANBOKEO.COM

ថាហើយគេក៏ដាក់ខ្លួនចុះលើអង្រឹងដែកក្បែរនាង ហើយយោល យឺតៗ រួចហើយក៏សួរភរិយាថា :

- បងសង្កេតឃើញអូនហាក់ដូចជាស្ងៀមស្ងាត់ណាស់ថ្ងៃនេះ ។ អូនមានរឿងអ្វីរំខានក្នុងចិត្តមែនទេ ណែ ?

និតាផ្ដេកកេសាលើស្មាស្វាមី គិតក្នុងចិត្តថា តើនាងត្រូវឆ្លើយ ដូចម្ដេចដើម្បីកុំអោយល្អក់កករអារម្មណ៍គូជីវិត ដែលគេកំពុងផ្ដល់សេចក្ដីសុខចំពោះនាងនិងកូនយ៉ាងបរិបូណ៌នោះបាន ។ម្យ៉ាងទៀត នាងក៏មិនដឹងដែរថា ការចង់ដឹងពីអតីតកាលរបស់គូស្រករ អោយ គេកកាយរឿងចាស់ៗមកនិយាយប្រាប់គ្នា តើបានប្រយោជន៍អ្វីដែរ ទៅសំរាប់នាង និងសំរាប់ជីវិតគូស្រកររបស់នាង ? តើវានឹងធ្វើឲ្យសុភមង្គលកាន់តែប្រសើរឡើង ឬក៏រិតតែត្រូវស្រកស្រុតវិញ ? តែ បើមិនសួរ មិនដឹងចម្លើយ ចិត្តសង្ស័យក៏នៅតែរំខានបេះដូងរបស់ នាង ហើយក្ដីរំខាននោះនឹងធ្វើអោយរូបនាងក្រៀមក្រំ ហើយក៏មិន អាចទទួលសេចក្ដីសុខពេញលក្ខណៈដូចគ្នា ។ តើនាងត្រូវជ្រើសរើសយកផ្លូវមួយណា ?

- បងចិត្រ...! (ចរណែហៅស្វាមីរបស់នាង)

- បាទ!

- យើងរួមរស់ជាមួយគ្នាជាងពីរខែហើយ... តែអូនមិនដែលឮបងសួរអូនអំពីប្រវត្តិអតីតកាលរបស់អូនទេ ។ បងមិនចង់ស្គាល់អូន មិនចង់ពីអូនទេថាអូនមានប្រវត្តិបែបណា ?

- បងមិនហ៊ានសួរទេព្រោះបងខ្លាចអូនត្រូវក្រៀមក្រំចិត្តដោយសារ ជីវិតអតីតកាលមករំខាន នាំអោយអូនស្រកស្រុតកម្លាំងចិត្តទទេៗ ជាពិសេស បងមិនចង់អោយសេចក្ដីសុខដែលយើងកំពុងទទួល ពេលនេះ មានភាពល្អក់កករ ។

- តែយើងជាប្ដីប្រពន្ធនឹងគ្នា... យើងគួរស្គាល់ប្រវត្តិគ្នាទៅវិញទៅ មកអោយច្បាស់លាស់ មិនមែនទេ ?

វិចិត្រងក់ក្បាល :

- បើសិនជា ការបកស្រាយអតីតកាលរបស់យើង ប្រាប់គ្នាទៅវិញ ទៅមកនោះ មិនរំខានដួងចិត្តនិងសេចក្ដីសុខរបស់យើងពេកទេ បងពិតជាចង់ស្គាល់អូនណែជាងនេះមែន

CHANBOKEO.COM

ព្រោះបងក៏មានរឿងចង់ ប្រាប់អូនវិញដែរ ដើម្បីកុំអោយអូនមានចិត្តសង្ស័យ រួចហើយក្លាយជាខឹងហើយស្អប់បងវិញនៅថ្ងៃណាមួយដូចគ្នាដែរ ។

- ចា៎ស! មែនហើយ! អូនគិតថា បើយើងជជែកគ្នាដោយចំហ ប្រកបដោយគតិនិងស្មារតីភ្លឺថ្លា យើងក៏អាចកែសម្រួលហើយរៀនពីជីវិតបានច្រើនជាងមុនមិនខាន រួចបើសិនយើងមានកំហុសអ្វីពី អតិតកាល យើងក៏អាចឆ្លៀតឆក់យកពលបច្ចុប្បន្ននេះ ដើម្បីកែឆ្នៃសម្រួលជីវិតយើងអោយល្អមកវិញបានទាន់ពេលវិញផង ។ បងចិត្រព្រមស្ដាប់រឿងជីវិតរបស់អូនខ្លះៗទេ ?

ធិតាស្រដីបែបនេះ ដើម្បីកុំអោយបុរសគិតថានាងចង់ដឹងពី ប្រវត្តិរបស់គេតែម្ខាង ។ ការពិតនាងគ្រាន់តែចង់បង្ហាញនូវភាពស្មោះត្រង់រវាងគូស្រករទាំងសងខាងត្បិតភាពស្មោះត្រង់ជាបណ្ដូលសំខាន់របស់សុភមង្គលក្នុងគ្រួសារនិមួយៗ ។

- បាទ! អ្វីដែលទាក់ទងនឹងជីវិតអូនណែ បងពិតជាចង់ដឹងសព្វ បែបយ៉ាងទាំងអស់ ។

- អញ្ជឹង! ដល់ពេលអូននិយាយរឿងជីវិតអតីតកាលរបស់អូន ជវាបបងចប់ហើយ បងនិយាយរឿងរបស់បងប្រាប់អូនវិញណា៎ ។

- ដោយពេញចិត្តបំផុតណា៎ ភរិយាសម្លាញ់ចិត្តបង ។ យប់នេះ អូននិយាយរឿងអូនអោយបងស្ដាប់ ហើយយប់ស្អែក បងនឹង និយាយរឿងបងម្ដង...

- ម៉េចចាំដល់ស្អែកផង បងចិត្រ ?

- មកពីបងចង់ស្ដាប់អូនបរិយាយពិស្ដាររអំពីរឿងរបស់អូននោះអី! កុំលួចកាត់ខ្លីសង្ខេបៗប្រាប់បងណា៎! បងមិនសុខចិត្តទេ!

ថាហើយ គេស្រវាថើបភរិយាដោយដួងចិត្តរំភើបបំផុត ។ រីឯបរិយាកាសគ្រួសារក៏ប្រែធូរស្រាលមនោរម្យមកវិញដែរ ។

oooooooooooooooo

oooooo

CHANBOKEO.COM

# វគ្គទី៧
# ជ្រោះជីវិត

ក្នុងមន្ទីរពេទ្យធំ ក្រុងបាត់ដំបង ឆ្នាំ១៩៤៨...

- បងចំណាប់! ក្មេងស្រីជំទង់ដែលគេងស្ដូកស្ដឹងនោះជាកូនចៅ នរណាដែរ ?

- នាងឈ្មោះកងណៃ ជាកូនអ្នកភូមិព្រះនេត្រព្រះណាំអូនចន្ថា ។ ឪពុកម្ដាយរបស់នាងនិងបងស្រី ត្រូវចោរភ្នំដញ្ញាំងសម្លាប់អស់ ហើយ ។ រីឯនាងវិញក៏មានរបួសធ្ងន់ធ្ងរ ទទួលបងត្រូវប្ដូរវេន ត្រលប់មកក្រុងវិញ ឲ្យក្រុមថ្មីចេញទៅកំចាត់ក្រុមចោរដ៏សាហាវ ទាំងនោះជំនួស ទើបបងដឹកនាងមកព្យាបាលនៅបាត់ដំបងនេះតែ ម្ដងទៅ ។

- មើលទៅនាង មានមុខមាត់ស្រស់ស្អាតគួរអោយស្រលាញ់ណាស់ បើយើងយកនាងចិញ្ចឹមជាកូនរបស់យើង ប្រហែលកូនចំណានគេ សប្បាយចិត្តណាស់ ព្រោះគេនឹងមានបងស្រីម្នាក់គ្រាន់កំដរ មិននៅ ឯកាជាកូនទោលអផ្សុកតទៅទៀត ។

- បងក៏គិតដូច្នេះដែរណាំអូន ។

អ្នកស្រីចន្ថាក៏ញញឹមឡើងដោយក្ដីត្រេកអរ ។

មិនយូរប៉ុន្មាន កងណៃក៏បានជាសះស្បើយ ហើយក៏បានទៅ រស់នៅក្នុងគ្រួសារលោកចំណាប់ ។ នៅក្នុងគ្រួសារនេះ នាងបាន ទទួលសេចក្ដីសុខយ៉ាងកក់ក្ដៅជាទីបំផុត តែនាងមិនបានសប្បាយ ចិត្តឡើយ ហើយចេះតែទារត្រលប់ទៅស្រុកវិញ ។ ថៃដន្យ ស្ថាន ការណ៍ស្រុកទេសមិនសូវស្រួល ។ ការធ្វើដំណើរទៅព្រះនេត្រព្រះ ប្រកបដោយគ្រោះថ្នាក់ជានិច្ចមិនថាពេលណាវេលាណា ។ដោយសារ តែការបារម្ភពីសុវត្ថិភាពរបស់នាង លោកចំណាប់មិនអនុញ្ញាត្ត អោយកងណៃត្រលប់ទៅស្រុកម្ដងណាឡើយ ។ ក្រោយមកកងណៃ ក៏ដាក់កិច្ចសន្យាជាមួយលោកចំណាប់និងភរិយាថា បើសិនណានាង រៀនចប់ការសិក្សាធ្វើការជាគ្រូបង្រៀន លោកចំណាប់ដាច់ខាតត្រូវ តែជូននាងត្រលប់ទៅស្រុកវិញ

CHANBOKEO.COM

ដើម្បីបំពេញកិច្ចការផ្ទាល់ខ្លួនមួយ ដែលនាងទម្លាក់ចោល មិនទាន់បានបំពេញតាមពាក្យបណ្ដាំរបស់ឪពុកនាងនៅឡើយ ។ លោកចំណាប់មិនបានដឹងទេថាជាបណ្ដាំអ្វី ប៉ុន្តែលោកបានជំរុញបណ្ដុះបណ្ដាលនាងយ៉ាងល្អ ទៅក្នុងការសិក្សា ដោយមិនរើសអើងថានាងជាកូនអ្នកជនបទឬយ៉ាងណាទេ ។

ចំណានជាកូនស្រីតែមួយរបស់លោកចំណាប់និងអ្នកស្រីចន្ថា ។ នាងមានវ័យតិចជាងកងណៃបីឆ្នាំ ។ ដោយកងណៃជាក្មេងស្រុក ស្រែ នាងខករៀនអស់បីឆ្នាំ ដូច្នេះនាងក៏ត្រូវរៀនថយបីឆ្នាំមកវិញ ស្មើនឹងចំណានដែរ ។ ទាំងពីរនាក់ចំណាននិងកងណៃស្រលាញ់គ្នា ណាស់ មិនខុសពីបងប្អូនរួមឧទរតែមួយឡើយ ។ ទីណាដែលឃើញ ចំណាន ទីនោះក៏ឃើញកងណៃដែរ ។ ដោយហេតុថាមិត្តភក្តិក្នុងថ្នាក់រៀនជាមួយគ្នាគេចំអកចំអន់ ចំពោះឈ្មោះរបស់នាងនឹងចម្លែក ព្រោះអ្នកក្រុងគេមិនដែលឮ ធិតាក៏សូមលោកចំណាប់ដូរឈ្មោះថ្មី វិញថា ចរណៃ គឺជាឈ្មោះដែលនាងជ្រើសរើសតាមការប្រតិស្ឋ របស់បុរសម្នាក់ដែលមានស្រមោលភ្លិបភ្លែតៗនៅក្នុងបេះដូងរបស់ នាងតាំងពីកុមារភាព ហើយដែលនាងមិនអាចលុបរូបភាពនោះ ចោលពីអារម្មណ៍បាន ទោះបីជានាងប្រឹងបំភ្លេចយ៉ាងណាក៏ដោយ ។ ធិតានៅតែនឹកទៅដល់គេហើយបារម្ភពីគេជានិច្ច...គ្រាន់តែមិនហ៊ាន ស្ដីប្រាប់នរណាតែប៉ុណ្ណោះ ។

១០ឆ្នាំកន្លងទៅ...

ក្រុងបាត់ដំបង ឆ្នាំ១៩៥៨...

ចរណៃក៏ប្រលងជាប់ជាគ្រូបង្រៀន បានចូលធ្វើការនៅសាលា បឋមសិក្សានារីសោហ៊ី ក្រុងបាត់ដំបង ។ ចំណែកចំណានជាប់ខាង ផ្នែកពេទ្យនៅឆ្នាំដំណាលគ្នាដែរ តែមិនទាន់ចូលធ្វើការទេ ។ រាល់ ថ្ងៃ តាំងតែចប់ការសិក្សា ចេញធ្វើការមក ចរណៃយើងតែងតែរំអុកសុំអោយលោកចំណាប់ នាំនាងត្រលប់មកព្រះនេត្រព្រះដែលជាទឹកដីកំណើតរបស់នាងវិញ ។

ថ្ងៃមួយ ចំណានលលេងបងស្រីថា :

- បងណៃ! ដូចជានឹកព្រះនេត្រព្រះអន្ទះសាដល់ហើយ ប្រហែលជាបងមានបុរសម្ចាស់ដួងចិត្តនៅរង់ចាំទីនោះមែនទេ ?

CHANBOKEO COM

- ឆ្កួត! កុំនិយាយផ្ដេសផ្ដាស ខ្មាសគេ ។ បងគ្រាន់តែចង់ទៅជួប
មនុស្សដែលធ្លាប់មានគុណលើបងតើហ៍ ។ គេធ្លាប់ជួយជីវិតរបស់ បង ។ ពេលនេះ
យើងបែកគ្នាដប់ឆ្នាំហើយ មិនដឹងថាគេប្រែប្រួល ឬមានសុខទុក្ខយ៉ាងណាទេ ?
- ខ្ញុំថាបើអ្នកមានគុណជាមនុស្សចាស់ៗ បងមិនអន្ទះសាងល់ម្លឹង ទេ ។
តែបើជាប្រុសកម្លោះវិញ... បែកគ្នា១០ឆ្នាំ ប្រហែលជាគេ មានកូនមានប្រពន្ធបាត់ហើយ...
បងកុំទៅគិតសង្ឃឹមច្រើនពេកអី ប្រយត្ន័ខកចិត្តណា៎បង!
- ឆ្លាតយោបល់មែនអូនណាន! ទោះជាយ៉ាងណាក៏ដោយ បើយើង បានទទួលដំណឹងពីគេ
វាអាចធ្វើអោយបេះដូងយើងស្ងប់ជាងការ
ដែលយើងមិនដឹងសោះ ទោះបីជាពេលនោះគេបានគេរៀបការ ចោលយើងក៏ដោយ ។
- នេះបងសារភាពហើយមែនទេ ថាបងមានបុរសនៅរង់ចាំបង ឯ
ព្រះនេត្រព្រះ ?
- ខុសហើយអូនណាន! បងមិនដឹងថា គេរង់ចាំបងឬក៏អត់ទេ ។ បងគ្រាន់តែដឹងថា
បងរង់ចាំដំណឹងពីគេជានិច្ចតែប៉ុណ្ណោះ ។
- ហ៊ឺ! បងស្រីរបស់ខ្ញុំស្មោះត្រង់នឹងស្នេហាដល់ហើយហ្ន៎! ខ្ញុំសូម
បន់ស្រន់អោយបងឆាប់បានជួបគាត់វិញណា៎បង!
- អរគុណអូនណាន! បងក៏បន់អញ្ជឹងដូចគ្នាដែរ ។

ចំណាននឹងសុខទុក្ខរបស់បងស្រីណាស់ មិនដែលនិយាយលេង
អ្វីប៉ះពាល់ទឹកចិត្តអោយនាងល្អក់កករអារម្មណ៍ទេ ត្បិតខ្លាចបងស្រី ខឹង
នោះគេនឹងអស់មាននរណាញ៉ិកញ៉ក់ទៀត ។ ចរណៃវិញក៏ថៃ
ទាំប្អូនមើលការខុសត្រូវជាបងស្រីជានិច្ច មិនអោយម្ដាយឪពុកហត់
មាត់កដោយសារគេទាំងពីរទេ ។ ឆ្នាំដដែលនោះ លោកចំណាប់ក៏
ត្រូវបានទទួលការតម្លើងឋានន្តរសក្តិជាភូឈ្មួយខេត្ត ព្រោះបាននាំ
ទ័ពវាយបង្ក្រាបពួកចោរភ្នំជញ្ជាំងបានជោគជ័យ ។ ភូមិភាគខាង
ជើងនៃខេត្តបាត់ដំបងក៏បានសាន្តត្រាណឡើងវិញ លែងមានភ័យ
អាសន្នដោយការធ្វើទុក្ខបុកម្នេញពីចោរព្រៃតទៅទៀតដែរ ។

ថ្ងៃមួយ...

នៅគេហដ្ឋានរបស់លោកចំណាប់ កូនស្រីពៅរបស់លោកបាន
រៀបចំពិធីជប់លៀងជួបជុំមិត្តភក្តិមួយ ដែលទើបនឹងរៀនចប់បាន ចេញធ្វើការ ។
នាងបានអញ្ជើញមិត្តប្រុសស្រីបួនដប់នាក់មកចូល រួម ។
រីឯលោកចំណាប់និងភរិយាមិនបាននៅចូលរួមទេ ត្បិត
អាល័យទៅភ្នំពេញធ្វើសាវនាពិសេសមួយ ។ ដូច្នេះពិធីនោះមានតែ
ភ្ញៀវក្មេងៗស្រករចំណានឬចរណៃតែប៉ុណ្ណោះ ។ ដោយហេតុថា
ចរណៃជាកូនចិញ្ចឹមហើយក៏ជាអ្នកជនបទ នាងតែងប្រយត្ន័ព្រំដែន របស់នាងជានិច្ច
មិនសូវចងមិត្តនឹងនរណាទេ មានតែម្នាក់ពីរ ប៉ុណ្ណោះ
ហើយគេទាំងនោះក៏មានក្រុមគ្រួសារអស់ទៅហើយ ។ ខុសអ្វីតែចំណានដែលរួសរាយបំផុត ។
នាងមានមិត្តគ្រប់កន្លែង មានប្រុសមានស្រី ថែដន្យមិនទាន់ត្រូវចិត្តនឹងបុរសណានៅឡើយ ទេ
ព្រោះនាងស្រលាញ់យុវភាពណាស់ ។ ពេលនេះ ទោះបីជាបាន ចេញធ្វើការក៏ដោយ ក៏នាងគិតថា
នាងចង់មានសេរីភាពចាយវាយ លុយកាក់ដែលរកដោយកម្លាំងខ្លួនឯងមួយស្របក់សិន
ទើបគិតគូរ រឿងគូស្រករតាមក្រោយ ។

មិត្តរបស់ចំណានក៏បានមកដល់ជាបន្តបន្ទាប់ ។ ចរណៃលួចរត់
ទៅពួននៅចង្ក្រានបាយរហូតមិនចេញមុខមកទេ ព្រោះនាងមិន
ចូលចិត្តបុរសនារីហ៊ឺហាបែបអ្នកជាន់ខ្ពស់ ម្យ៉ាងដោយសារនាងគិត ថានាងជាកូនអ្នកក្រ
មិនអាចវាយឫកតាមពួកគេបានឡើយ ។ រួច ដៃហើយ
នាងក៏គេចទៅអានសៀវភៅនៅចំហៀងផ្ទះ ទុកឱកាស
អោយប្អូនស្រីជួបជុំសប្បាយជាមួយមិត្តរបស់នាង ។ ដោយសារការ ស្គាល់អត្តចរិតរបស់បងស្រី
ចំណានក៏មិនបានរំខានចិត្តបងស្រីដែរ នាងក៏នាំមិត្តភក្តិនិយាយសើចសប្បាយ
ទៅតាមរឿងរបស់នាងទៅ ដោយមិនចូលទៅរំអុកបងស្រីរឿងអ្វីឡើយ ។ កំពុងតែអានសៀវ
ភៅ ស្រាប់តែចរណៃឮសំលេងរថយន្តមួយមកដល់មុខផ្ទះ ហើយក៏ ឮចំណានស្រែកហៅឡើងថា
:

- ជំរាបសួរបងភក្តី! យី! តាំងពីត្រលប់មកបាត់ដំបងវិញ ប្អូន មិនដែលជួបមុខបងសោះ...
បានការធ្វើហើយនៅ ?

តែចរណៃមិនបានចាប់ភ្លឹកតទៅទៀតទេ បន្ទាប់ពីឮសំដីរបស់

CHANBOKEO.COM

ប្អូនស្រីដូច្នោះរួចហើយ ។ បន្តិចមក នាងក៏ដើបដើរតាមចំហៀង ផ្ទះរកចេញទៅក្រៅ ដើម្បីសំដៅទៅសួនយុវវ័នដែលមានស្រះនៅ ចំកណ្ដាលសង់ជារាងបេះដូង មានដាំឈូកដែលកំពុងបញ្ចេញផ្កា រហង់យ៉ាងស្រស់បំព្រង ។ នាងគិតថានឹងទៅអង្គុយអានសៀវភៅ នៅក្រោមដើមចំប៉ាវិញ ក្រែងទទួលខ្យល់អាកាសល្អជាង ។ លុះ មកដល់ទ្វាររបង នាងក៏ដើរជ្រុលទៅទង្គិចទ្រូងបុរសម្នាក់ឈរវ៉េវ៉ នៅខាងក្រៅរបងផ្ទះនាង ហាក់បីដូចជាកំពុងរង់ចាំនរណាម្នាក់ ។ ជាតិជាស្ត្រីខ្មែរពេញវ័យក្រមុំ កាលបើមកពើបទង្គិចខ្លួនប្រាណ ប៉ះ សាច់បុរសយ៉ាងនេះ តើនរណាទៅមិនខ្មាសហើយមិនភ័យ ? ធិតា អៀនពេកមិនហ៊ានដើបសម្លឹងមុខបុរសចំៗនោះទេ ។ នាងគ្រាន់ តែញញឹមបន្តិចរួចលើកដៃសំពះបុរសនោះជាការគួរសម :

- សូមទោស! សូមទោសចា៎ស!

នាងវាចាដោយសុភាពចំពោះគេ ត្បិតធិតាឃើញគេស្ថិតនៅ ក្នុងសម្លៀកយ៉ាងថ្លៃថ្នូរមានតម្លៃ ។ នាងគិតថា គេម្នាក់នោះច្បាស់ ជាបុគ្គលត្រកូលអភិជនណាមួយហើយ ។ នាងមិនហ៊ានខ្វះការគួរ សមទេ ខ្លាចក្រែងនឹងឮដល់ត្រចៀកលោកចំណាប់និងអ្នកស្រីចន្ធា ដែលជាអ្នកគ្រប់គ្រង នាំតែលោកខកចិត្តដោយសាររូបនាង ។ ឆរី ស្រដីហើយក៏ឈ្ងោកមុខដើរចេញទៅ ទាំងបេះដូងញាប់ញ័រតែម្នាក់ ឯង ។ ប៉ុន្តែទោះបីមិនហ៊ានមើលមុខគេចំមែន តែលុះដើរហួសទៅ នាងក៏នឹកភ្នកចង់ស្គាល់ ថាគេមានមុខមាត់យ៉ាងណា ក្មេងឬចាស់ ឬក៏បុរសម្នាក់នោះជាមិត្តម្នាក់របស់ចំណាន ។ មាណវីក៏លួចចោល កន្ទុយភ្នែកទៅមើលគេ ស្រាប់តែឆរី ប្រទះនឹងក្រសែភ្នែករបស់គេ កំពុងសម្លឹងមករកនាងវិញដូចគ្នា ។ ធិតាងាកមុខចេញយ៉ាងរហ័ស ហើយនឹកភ័យខ្លួនយ៉ាងណាមិនដឹង ដែលនរៈចាប់កន្ទុយភ្នែករបស់ នាងបាន ថែមទាំងលួចញញឹមតបមករកនាងវិញទៀតផង ។

បន្ទាប់ពីបានអង្គុយមួយអានសៀវភៅ នៅក្នុងសួនមួយស្របក់ មក នាងក៏លួចបែរមើលគេម្ដងទៀត ស្រាប់តែនាងប្រទះនឹងកែវ ភ្នែកដ៏ភ្លឺថ្លា ព្រមទាំងស្នាមញញឹមលើផ្ទៃមុខរបស់គេ ចំពោះនាង ដដែល ។ ធិតាភ្ញាក់ព្រើត បែរមុខចេញភ្លាម ហើយនឹកឆ្ងល់ក្នុងចិត្ត ថាតើគេនោះជានរណា ហេតុអ្វីក៏គេលួចគន់នាងម្ល៉េះ ? មើលទៅគេ មានរូបរាងសង្ហាគួរឲ្យនារីចាប់អារម្មណ៍បំផុត ។ រីឯស្នាមញញឹមលើ

CHANBOKEO.COM

ផ្ទៃមុខរបស់គេវិញក៏ហាក់ដូចជាមានបង្កប់លាក់អត្ថន័យយ៉ាងជ្រាល
ជ្រៅធ្វើអោយនាងលួចញាប់ញ័រក្នុងចិត្តខ្លាំងណាស់ ។ ចំណែករស្មី
កែវភ្នែករបស់គេក៏មានអនុភាពលើបេះដូងរបស់មាណវីយើងយ៉ាង ចម្លែក
គឺអោយតែប្រទះក្រសែភ្នែករបស់គេម្តងៗ បេះដូងរបស់
នាងលោតកញ្ជ្រោលឱបខាក់ៗខុសចង្វាក់តែម្តង ។

រសៀលហើយ ធិតាក៏ដើរត្រលប់មកផ្ទះវិញ ។ ពេលនោះនាង ចាប់ភ្លឹកថា
បុរសដដែលនោះនៅឈរក្បែររថយន្តមួយ ក្រោម
ដើមចន្ទន៍មុខផ្ទះរបស់នាងកំពុងសម្លឹងមករកនាងទៀតហើយ តែ
នាងធ្វើពើមិនខ្ចីងាកមើលមុខគេវិញទេ ព្រោះនាងមិនចូលចិត្តនរៈ
ដែលឈរសម្លឹងនារីរហូតដល់នាងរអៀសខ្លួន ។ ធិតាក៏ដើរចូលទៅ
ក្នុងរបងដើរតាមចំហៀងផ្ទះដដែល ។ មួយស្របក់ក្រោយមក នាង
ក៏បែរលួចមើលទៅខាងក្រៅរបងសាជាថ្មី ហើយក៏នៅតែប្រទះនឹង
កែវភ្នែកភ្លឺថ្លាមួយគូនោះសម្លឹងមកធិតាយើងវិញដដែល ។ មាណវី ភ្ញាក់ព្រើត
នឹកញាប់ញ័រក្នុងចិត្តភ្លាម កាលបើឃើញបុរសសង្ហាម្នាក់ នោះលួចគយគន់រូបនាងមិនឈប់ឈរ :

- យី! នរណាគេអញ្ចេះ ? តាមដានយើងក្នុងគោលបំណងអ្វីទៅ ?  តើគេជានរណា ? ថ្ងៃនេះ
លោកប៉ាមិននៅផ្ទះផង...តើយើងនិង
ប្អូនចំណាននឹងមានសុវត្ថិភាពដែរទេ ?

ភ្ញៀវរបស់ចំណានក៏ចេញត្រលប់ទៅវិញម្តងមួយៗ ។ ចរណៃ ក៏លេចខ្លួនមកជួយសំអាតផ្ទះ
ចំពេលដែលចំណានកំពុងលាគ្នាជា
មួយនឹងមិត្តម្នាក់ជាចុងក្រោយ ។ គ្រាន់តែគេក្រលេកឃើញវត្តមាន
របស់ចរណៃនៅក្នុងផ្ទះភ្លាម បុរសនោះក៏សួរថា :

- ចំណានមិនណែនាំអោយបងស្គាល់សមាជិកគ្រួសាររបស់ប្អូនទេ ?

ចំណានហាក់ដូចជាយល់បំណងរបស់មិត្តក៏ស្រដីថា :

- អូហ៍ អាល័យតែសប្បាយ ចំណានក៏ភ្លេចណែនាំទៅ ។

នាងក៏ទៅអូសដៃចរណៃអោយមកស្គាល់គ្នាជាមួយបុរសជាមិត្ត របស់នាង
ដែលជាបុរសដ៏សង្ហាមួយរូប :

- បង! នេះបងភក្តី ជាសិស្សច្បងរបស់ខ្ញុំកាលពីនៅរៀនមធ្យម សិក្សា ។ ហើយអ្នកខាងនេះ ជាបងស្រីរបស់ខ្ញុំឈ្មោះ....
- ស្បៃរឿង សូមជំរាបសួរចាស! (ចរណៃនិយាយកាត់)
- បាទ! ជំរាបសួរអ្នកនាងស្បៃរឿង!
ចំណានបើកភ្នែកមូលក្រឡង់ កាលបើឃើញបងស្រីប្រែឈ្មោះ យ៉ាងចម្លែកដូច្នោះ ។ ភក្តីនៅអែអង់មួយស្របក់ ធ្វើកិរិយាហាក់ ដូចជាមិនទាន់ចង់ទៅផ្ទះសោះ :
- នៅផ្ទះចំណាន បាយឆ្ងាញ់ណាស់ ។ ល្ងាចនេះ បងសុំម៉ាពេល ទៀតបានទេ ?
ឮដូច្នោះ ចរណៃលួចមិចភ្នែកដាក់ប្អូនមិនអោយយល់ព្រម ។ ពេលនឹងថាបងស្រីមិនចូលចិត្តមានភ្ញៀវប្រុស ចំណានក៏ឆ្លើយថា :
- អត់បានទេ ។ ចំណានអស់កម្លាំងហើយ ចង់សំរាក! ចាំថ្ងៃ ក្រោយទៅចុះណា៎បងភក្តី ។
ឃើញម្ចាស់ផ្ទះបិទផ្លូវ ភក្តីក៏លាចេញទៅ តែគេមិនភ្លេចចោល កន្ទុយភ្នែកមួយជាចុងក្រោយទៅចរណៃដែរទេ... មើលទៅគេហាក់ ដូចជាកំពុងតែចាប់អារម្មណ៍លើនិតាយើងដល់ស្អូរហើយ ។
លុះភ្ញៀវទៅអស់ ចំណានក៏ពោលលលេងទៅបងស្រីថា :
- ខ្ញុំមិនដឹងសោះថាបងមានឈ្មោះស្បៃរឿង...!
- ព្រោះបងមិនចង់អោយបុរសណាហៅបងថាអូនណៃនៅមុនពេល ដែលបងបានជួបនឹងបុរសម្នាក់នៅព្រះនេត្រព្រះនោះទេ ។
- ពុទ្ធោ! យូរហើយ ម៉េចក៏បងមិនប្រាប់ប្អូន ? ខំតែឆ្ងល់ ។
ចំណានសើចខឹកៗយ៉ាងរីករាយ ។
យប់នោះ ចរណៃរត់បិទទ្វារបិទបង្អួចតាំងពីព្រលប់ ។ ឃើញ កិរិយាចម្លែក ចំណានក៏សួរ :
- មានរឿងអ្វីបងណៃ បានជាច្រាសច្រាល់ខុសធម្មតា ?
- ព្រោះបងឃើញមនុស្សចម្លែកមកឈររវេរនៅមុខផ្ទះរបស់យើង កាលពីថ្ងៃរសៀលមិញ ។
- មានមនុស្សចម្លែកពីណា សុទ្ធតែជាពួកម៉ាករបស់ចំណានហ្នឹង ?
- អត់ទេ គេមិនបានចូលមកខាងក្នុងផ្ទះដូចមិត្តរបស់ប្អូនដទៃទៀត ទេ ។ គេនៅឈរខាងក្រៅរបងផ្ទះយើង រាប់ម៉ោងឯណោះ ហើយ គេតាមមើលបងមិនដាក់ភ្នែកសោះ ។

CHANBOKEO.COM

ស្រាប់តែចំណានសើចខឹកៗ ៖
- សង្ស័យតែមានបុរសមកលួចឆ្មក់មើលសម្រស់នឹសោភារបស់បង ស្រីខ្ញុំហើយ ។
បងឯងសំណាងតើហ៎ ដែលមានគេចាប់អារម្មណ៍...
- កុំនិយាយតែផ្តាស គ្មានអារម្មណ៍សំរាប់សើចលេងទេ ។
- បង! ស្រុកយើងសុខសាន្តគ្មានចោរទេ ។ បងទៅភ័យធ្វើអី ?
- ប្រយត្ន័ក៏គង់ប្រសើរជាងធ្វេសប្រហែសដែរអូន ។
ចំណានស្ងាត់មាត់តែម្តងកាលបើបានឮប្រយោគនោះ ។
ចាប់តាំងពីថ្ងៃនោះមក ភក្តីតែងតែមកលេងអ្នកទាំងពីរជាញឹក
ញាប់ ដោយមានបញ្ញើឯលិចឯកើតមកផ្ញើអ្នកទាំងពីរផង តែចរណៃ
មិនចូលចិត្តទទួលអ្វីពីបុរសនោះទេ ។
- ហេតុអ្វីក៏បងមិនចូលចិត្តបងភក្តី ? (ចំណានសួរ)
- អូនមើលឫកពាគេទៅ ក្រឡេមក្រឡឹមចំពោះស្រីណាស់ គ្រាន់តែ ស្គាល់ពីបីថ្ងៃ
ចង់លូកថ្លើមទៅហើយ ។
- គាត់តែប៉ុនហ្នឹងឯងបងអើយ! កុំប្រកាន់នឹងគាត់អី ។ ការពិត គាត់គ្រាន់តែខិលមាត់ខិលក
មិនបានការអីទេ ។
- បងថា គាត់ហ្នឹង មិនមែនត្រឹមតែខិលមាត់ខិលកទេ គឺប្រហែល ឆ្ងាយជាងហ្នឹងទៅទៀត ។
- ម៉េចក៏បងនឹងកើត ?
- គឺបងមានប្រផ្នូលក្នុងចិត្តចម្លែកៗណាស់ ។
ចំពោះចរណៃ ភក្តីគឺជាជនពាល ព្រោះគេមានឫកពាព្រាននារី ដែរពឹស ។
គេធ្លាប់បន្លំយកដៃចាប់សក់នាងលេង ពីរបីដងហើយ
សូម្បីតែនាងបានហាមឃាត់រួចហើយក៏ដោយ ក៏គេមិនរក្សាព្រំដែន ថ្លៃថ្នូរចំពោះនាងសោះ
ជួនកាលបន្លំចង់រកប៉ះខ្លួននាងទៀតផង ។ ឃើញវត្តមានភក្តីកាលណា
ចរណៃតែងគេចខ្លួនបាត់ជានិច្ច ។
ទោះជាយ៉ាងណា ក៏ភក្តីមិនបោះបង់ការព្យាយាមរបស់គេទេ ។
កាលបើឃើញចរណៃវាយឫកឆ្មើងឆ្មៃដាក់ខ្លួន គេគិតក្នុងចិត្តថា ៖
- ខំវាយឫកអោយខ្លាំងទៅ... ថ្ងៃណាមួយគង់តែនឹងទេ... ថាភក្តីដៃ
ខ្លាំង តិចថាមកអង្វរយើងចុះ... នោះនឹងអោយស្គាល់ថ្នាំខ្លាំងខ្លះមិន

CHANBOKEO.COM

ខាន កុំអោយថើងរអើងអញ្ជឹងពេក ។

ភក្តីមានឫកពាស្លូតផងកាចផងដាក់ចរណៃជាញឹកញយ ។ ភាព គ្រោតគ្រាត អាងរូបសង្ហា អាងទឹកប្រាក់និងទ្រព្យធនរបស់មាណព បានធ្វើអោយនាងកាន់តែមិនចូលចិត្តភក្តីខ្លាំងឡើងៗ ។ ជួនកាល ភក្តីធ្វើឫកជាយករថយន្តដឹកនារីស្អាតៗកាត់មុខផ្ទះរបស់នាងឲ្យនាង នឹកច្រណែនប្រចណ្ឌនារីទាំងនោះ តែធិតាមិនព្រមយកភ្នែកមើល សោះឡើយ ។ ដោយហេតុនេះហើយ ភក្តីក៏ក្លាយជាមានកំហឹងនឹក ចងគំនិតប្រទុស្តនឹងចរណៃ ដោយមិនដឹងខ្លួន ព្រោះអីនាងបាន បដិសេធជាច្រើនដងចំពោះការរាក់ទាក់របស់គេ ។ ពេលនោះ គេ ក៏រកល្បិចល្បួងផ្លូវផ្សេងម្តង ។

ចរណៃតែងតែជិះម៉ូតូជាមួយមិត្តទៅធ្វើការរាល់ថ្ងៃ តែថ្ងៃនេះ មិត្តរបស់នាងគ្រុនផ្តាសាយមិនបានទៅធ្វើការ ទើបនាងត្រូវជិះរ៉ឺម៉ក ទៅសាលាវិញដើម្បីកុំអោយខកការងារ ។ រសៀលនោះ ចរណៃជិះ រ៉ឺម៉កចាស់មួយត្រលប់មកវិញ ។ មកដល់ត្រង់មុខមន្ទីរឃោសនាការ រ៉ឺម៉កក៏បែកកង់ ។ ពេលនោះ ម៉ោងប្រាំកន្លះរសៀលទៅហើយ ។ នាងក៏ឈររង់ចាំហៅរ៉ឺម៉កថ្មីជិះ ស្រាប់តែប្រទះភក្តីបររថយន្តមួយ មកដល់ :

- សួស្តីស្មេរឿង! ត្រូវការអោយបងជូនទៅផ្ទះទេ ?

គេចូលចិត្តហៅខ្លួនគេថាបងៗណាស់ ពេលគេនិយាយជាមួយ នារីយើង ធ្វើអោយចរណៃរិតតែធុញថប់ឡើងជាលំដាប់ព្រោះនាង មិនចូលចិត្តបុរសនេះសោះ ។ នាងក៏ស្ទុះដើរឡើងលើចិញ្ចើមថ្នល់ ធ្វើជាមិនឃើញភក្តី :

- ស្មេរឿង! អូនកុំឆ្មើងពេកមើល៍! នេះបងកំពុងមានសមានចិត្ត ចំពោះអូនណា៎ ។ ម៉ោះ! ឡើងឡានមក! បងជូនអូនទៅផ្ទះ ។

តែចរណៃមិនចាញ់បោកទេ ។ នាងខ្លាចគេបររថយន្តនាំនាង ទៅកន្លែងផ្សេង ម្ល៉េះហើយក៏ចេះតែឈ្ងោកមុខដើរតទៅទៀត ។ មកដល់មុខមន្ទីរឧបនាយកយោធិនក្រុងបាត់ដំបង ស្រាប់តែភក្តី អស់ចិត្តនឹងអង្វរចរណៃតទៅទៀត ។ គេក៏បញ្ឈប់រថយន្តហើយក៏ ស្ទុះទៅចាប់ដៃនាង :

- កុំវាយឫកពេកមើល៍ព្រលឹង...! ម៉េចក៏សំងៃងខ្លួនហាក់ដូចជា ខ្លាចបងម្ល៉េះ ?

តែធិតារលាស់ដៃចេញ តែរលាស់មិនរួច ។ ភក្តីក៏ញញឹមហើយ ចំអកថា :

CHANBOKEO.COM

- រាងល្វតល្វៃបែបនេះ ចង់ទៅទៅណា ? បងនិយាយស្រួលៗមិន ចង់ ចង់អោយបងបង្ខំមែនទេ ?
- លែងដៃខ្ញុំទៅ ! (ធិតាស្រែក)
- មិនបាច់ស្រែកទេ ប្រយត្ន័អ្នកស្រុកគេច្រឡំស្មានថា ប្ដីប្រពន្ធ ឈ្លោះគ្នា ។

ភ្លាមនោះ ចរណៃរលាស់ដៃភិលរបូតផុតពីការចាប់ខ្វាមរបស់ មាណពភ្លាម ។ នាងក៏ស្ទុះរត់យ៉ាងលឿនគេចចេញទៅ ដោយការ ភិតភ័យយ៉ាងតក្កមា ស្រាប់តែឆវីរត់ទៅជល់នឹងទ្រូងបុរសម្នាក់ ភឹង ។ ធិតាភ្ញាក់ក្រញាងភ័យស្មើរលោះព្រលឹងតែម្ដង ។ រំពេច នោះ គេចាប់ដៃនាងជាប់ហើយអូសនាងយកទៅលាក់នៅពីក្រោយ ខ្នងរបស់គេ ព្រមទាំងស្រដីប្រាប់នាងខ្សិបៗថា :
- ឈប់ភ័យទៀតទៅ ! បុរសនោះមិនអាចធ្វើអ្វីអ្នកនាងបានទេ ។

ខណ:នោះ ភក្ដីរត់មកដល់ភ្លែតដែរ :
- ស្បៃរឿង... អូនរត់គេចពីបងធ្វើអ្វី ?

ស្រាប់តែភក្ដីធ្វើមាត់ចំហធ្លុង ពេលគេប្រទះបុរសចម្លែកមាឌធំ ធំបងម្នាក់នៅឈរចំពោះមុខ កំពុងយកខ្លួនរាំងផ្លូវមិនអោយនាយ រត់តាមស្បៃរឿង រួចហើយ...គេបិទមាត់ឈឹង បន្ទាប់មកក៏ដកជើង ថយក្រាកៗ ហក់ឡើងរថយន្ត បរចេញទៅដោយមិនស្រដីអ្វីមួយ ម៉ាត់ទៀតសោះឡើយ ។ បុរសចម្លែកនោះក៏បែរមកមាណវី ដែល កំពុងភិតភ័យញ័រចំប្រប់ពេញអង្គប្រាណ :
- ឈប់ភ័យទៅ អ្នកនាង ! គេទៅបាត់ហើយ ហើយផ្ទះអ្នកនាង នៅឯណាដែរ ? បើមិនឆ្ងាយទេ ចាំខ្ញុំដើរតាមពីក្រោយ ជួយរក្សា សុវត្ថិភាពអោយអ្នកនាងចុះ ។
- ចា៎ស នៅម្ដុំសួនយុវន័នេះឯង ។

ធិតាឆ្លើយទាំងញាប់ញ័រតែមិនហ៊ានងើបមើលមុខគេវិញទេត្បិត ខ្មាសអៀននឹងហេតុការណ៏ដែលភក្ដីធ្វើមកលើរូបនាងពេលនោះ ។
- អូហ៏ មាននៅឆ្ងាយឯណា ។ ម៉ោះ ! ខ្ញុំជូនទៅ ។

ចរណៃក៏ឈ្ងោកមុខដើរទៅមុខទៀត ឆ្លងតាមស្ពានថ្មនៅមុខ សាលាខេត្ត សំដៅទៅសួនយុវ័ន ដោយមានបុរសនោះដើរតាមពី ក្រោយរហូត ។ ចៃដន្យ មាណពម្នាក់នោះដើរស្ងៀមស្ងាត់ មិនឮ ស្រដីជាមួយនាងទេ តាមផ្លូវរហូតទាល់តែដល់មុខផ្ទះឆវី ។

CHANBOKEO.COM

- អរគុណលោក ដែលជូនខ្ញុំដល់ផ្ទះ ។

ចរណៃលើកដៃសំពះថ្លែងអំណរគុណនរៈ ទាំងដួងចិត្តញាប់ញ័រ ភិតភ័យនៅឡើយចំពោះហេតុការណ៍អំបាញមិញ រួចហើយនាងក៏ ដើរចូលទៅក្នុងផ្ទះភ្លាម ។ បន្តិចមក នាងក៏បែរក្រោយលួចមើល មុខបុរសនោះ ស្រាប់តែប្រទះខ្សែភ្នែករបស់គេដែលសម្លឹងមករក នាងយ៉ាងភ្លឺថ្លា ។ ធិតាហាក់ដូចជានឹកខ្មាសនរៈភ្លាម រួចដាក់មុខចុះ ឈ្ងោកដើរលែងហ៊ានងាកក្រោយតែម្តង ។ ប៉ុន្តែទោះបីជានាងមិន ងើបមុខសម្លឹងបុរសនោះពេញភ្នែក តែនាងចំណាំបានថា គេនោះ ជាបុរសម្នាក់ ដែលនាងធ្លាប់ដើរជល់ទ្រូងនាយថ្ងៃមុននៅមុខផ្ទះ ម្តងរួចមកហើយ ។ តែហេតុអ្វីថ្ងៃនេះ វាសនាថៃដន្យនាំនាងឲ្យរត់ ជល់ទ្រូងរបស់គេជាថ្មីទៀតអញ្ចឹង ? តើគេជានរណា ? ហើយហេតុ អ្វីបានជាគេយកចិត្តទុកដាក់នឹងរូបនាងម្ល៉េះ ? ហេតុអ្វីក៏នាងមាន អារម្មណ៍អៀនខ្មាសក្តៅមុខក្តៅមាត់យ៉ាងចម្លែក នៅពេលដឹងថាគេ កំពុ ផ្តោតអារម្មណ៍មកលើរូបនាងយ៉ាងពិសេសបែបនេះ ?

ការពិតធិតាយើងក៏ចាប់ភ្លឹកដែរថា នាងធ្លាប់បានឃើញមុខហ្នឹង រាងហ្នឹងកាលពីចូលឆ្នាំខ្មែរ ប៉ុន្មានថ្ងៃមុននេះ ហើយថែមទាំងធ្លាប់ បានអង្គុយលើកៅអីថ្មតែមួយក្បែររូបនាងក្នុងវត្តកណ្តាល មើលគេ លេងឈូងផង ។ ថៃដន្យ នាងមិនធ្លាប់ស្គាល់គេទេថា គេជានរណា គ្រាន់តែចាំថា នៅថ្ងៃចូលឆ្នាំនោះ គេស្លៀកពាក់ស្អាតបាតនៅអង្គុយ ស្ងៀមឈឹងតែមួយកន្លែងមួយថ្ងៃវាស់ល្ងាច មិនងើបដើរទៅណា មកណាសោះ មិនធ្វើមាត់ មិនមានចូលលេងអ្វីនឹងគេទេ ឃើញតែ អង្គុយធ្វើមុខញឹមៗដាក់នាង ។ អ្វីដែលថៃដន្យបំផុតនោះគឺ គេបាន ទិញសៀវភៅមួយយកអានកំដរអផ្សុក ជាសៀវភៅទស្សន៍ទាយ ដូចគ្នាបេះបិទនឹងសៀវភៅរបស់ចរណៃដែលកំពុងអានដែរ ។

តាំងពីពេលនោះមក ចរណៃដូចជាប្រទះបុរសសង្ហាយើងដូច ញឹកញាប់ខុសធម្មតា ទំនងដូចជាគេកំពុងលួចតាមដានរូបនាងរៀង រាល់ថ្ងៃឥចឹង ។ មាណវីនឹកភ័យព្រួចក្នុងចិត្តតែម្តង មិនដឹងថា គេតាមដាននាងព្រោះតែគេលួចប្រតិពទ្ធ័ឬក៏យ៉ាងណា ? ហេតុអ្វី បានជានាងលួចរំភើបញាប់ញ័រហើយអៀនខ្មាសក្នុងចិត្តអ្វីម្ល៉េះ ពេល នាងប្រទះខ្សែភ្នែករបស់គេម្តងៗ ? តើនាងកំពុងចាប់អារម្មណ៍លើ បុរសនោះវិញដែរឬអ្វី ?

ចរណៃគេងគិតតែម្នាក់ឯងមិនអស់មិនហើយ ។ ឃើញបងស្រី រសាប់រសល់ ចំណានបើកភ្លើង ហើយងើបពីគ្រែសួរថា :

CHANBOKEO.COM

- បងណែត្រិះត្រុះ នឹកនរណាគេហ្នឹង ?
- អូហ៍! បងយល់សប្តិមិនល្អ មិនហ៊ានគេងវិញ ។ សូមទោសអូន
ណាដែលបងប្រែខ្លួនញឹកពេក ធ្វើអោយរំខានដំណេករបស់អូន ។
- នឹកបុរសដែលនៅព្រះនេត្រព្រះនោះមែនទេ ? ចាំថ្ងៃអាទិត្យនេះ
ពេលប៉ាម៉ាក់ត្រលប់ពីភ្នំពេញមកវិញ ចាំខ្ញុំជួយទទូចសុំអោយគាត់ នាំបងទៅស្រុកកំណើតម្តង ។
ចរណៃលែងហ៊ានធ្វើមាត់ហើយ ។ នាងនៅស្ងៀមហើយមិច
ភ្នែកអោយប្អូនជាសញ្ញាថានាងកំពុងចូលដំណេកវិញ ។ ចំណានក៏ ពន្លត់ភ្លើងចូលនិន្ទ្រាដែរទៅ ។
បីថ្ងៃក្រោយមកលោកចំណាប់និងភរិយាក៏ត្រលប់មកដល់ផ្ទះ ។
ចំណានក៏លួចទៅនិយាយជាមួយឪពុកម្តាយរបស់នាងស្ងាត់ៗ អំពី រឿងរបស់ចរណៃ ។
លោកទាំងពីរក៏មិនប្រកែកអ្វីដែរ ព្រោះអី
លោកក៏ធ្លប់បានសន្យានឹងនាងថានឹងជូននាងទៅលេងស្រុកកំណើត
តាំងពីយូរមកហើយ ។
គ្រាន់តែឮដំណឹងថា ចរណៃមានបំណងត្រលប់ទៅធ្វើការនៅ ស្រុកកំណើតរបស់នាងវិញ
ភក្តិហាក់ដូចជាអន្ទះសាយ៉ាងណាមិន ដឹងទេ ។ គេមានអារម្មណ៍ហ្មួហ្មងខុសពីសព្វកាល
បាយលែងឆ្ងាញ់ គេងលែងលក់តែម្តង ។ មែនហើយ! គេធ្លាប់មាននារីច្រើនដែល
រត់តោងរូបគេប្រសេចប្រសាច លង់ស្នេហ៍នឹងភាពសង្ហារបស់គេ
ព្រមទាំងលុយកាក់ដែលគេចាយវាយទាំងខ្ទាស់ៗមិនដែលគិតព្រោះ គេសំបូរចាយមិនចេះអស់ ។
ចៃដន្យអីចំពោះនារីមួយរូបដូចចរណៃ នាងមិនព្រមយកភ្នែកមើលនរៈដោយល្អម្តងណាសោះ ។
ពេលនេះ គេនឹកចង់លេងល្បែងចាញ់ឈ្នះជាមួយចរណៃហើយ ។
នៅវេលាព្រលប់មួយ...
លោកចំណាប់ទៅប្រជុំនៅឯសាលាខេត្តបាត់ ។ ចំណែកអ្នកស្រី
ចន្ថាទៅជួយកំដរមិត្តម្នាក់ដែលមានជំងឺនៅមុំពោធិហ្សស្រី ព្រមទាំង នាំចំណានទៅជាមួយផង ។
ថ្ងៃនេះ ចរណៃនៅផ្ទះតែម្នាក់ឯង ។ ព្រលប់នេះ នាងដើរទៅសាខោអាវពីស្នួចំហៀងផ្ទះ
ប្រមូលយក មកបត់ទុក ហើយក៏រៀបរបចិទទ្វារចាក់សោរផ្ទះដែរ ។ ភ្លាមនោះ
ស្រាប់តែមានស្រមោលមួយផ្លោះរបងស្ងាត់ៗ ចូលមកចាប់ខ្ទប់មាត់ មាណវីជាប់
ហើយប្រវាយប្រតប់អូសនាងចេញទៅ ។ ចរណៃខំរើ បំរះយ៉ាងពេញទំហឹង
តែក៏ត្រូវបុរសនោះដាល់មួយដៃចំពោះទីកធ្វើ ឲ្យនិតាន្តិតន្លល់សឹងសន្លប់បាត់ស្មារតី

CHANBOKEO.COM

តែនាងនៅមើលឃើញច្បាស់ ថា នាងស្គាល់រថយន្តដែលបុរសកំពុងបើកឡានដាក់នាងចូលទៅ ។ បន្ទាប់មក គេចាប់នាងចងមាត់មិនអោយស្រែកហើយចងដៃចង ជើងនាងទៀត ។ តាមផ្លូវចរណៃខំរើប្រឹងបំរះយ៉ាងអស់ទំហឹងតែក៏ មិនអាចយកជ័យជំនះលើខ្សែនីឡុង ដែលចងខ្លួននាងបានឡើយ ។ ឆវីភិតភ័យបែកញើសស្រាក់ៗ ក្នុងចិត្តបែបន់អស់ហើយគុណទឹកដោះម៉ែ គុណព្រះរតនត្រ័យ អោយលោកតាមថែរក្សាការពាររូប នាង អោយផុតគ្រោះភ័យពេលនោះ ។

បន្តិចមក បុរសនោះបានលើកនាងបីចូលទៅផ្ទះល្វែងមួយនៅ ទីក្រុងបាត់ដំបង ។

- អោយខ្ញុំសូមអង្វរចុះ លោកភក្តី កុំធ្វើបាបខ្ញុំអីណា៎!

ធិតាស្រែកអង្វរបុរសនោះភ្លាម ពេលគេស្រាយមាត់ឲ្យនាង ។ កាលបើឮនាងហៅចំឈ្មោះ បុរសនោះភ្ញាក់ក្រញាង ហើយប្រញាប់ ដោះស្រោមមុខខ្មៅនោះចេញ រួចឧទានថា :

- នេះ ស្បែរឿងចាប់អារម្មណ៍ពីបងដែរមែនទេ បានជាអូនសង្កេត ភិនភាគ ក៏ភ្លាមស្គាល់ថាជាភក្តី ?

តែចរណៃមិនឆ្លើយទេ ។ ភក្តីក៏ដាក់នាសាបំរុងនឹងជំពិតថ្ពាល់ ធិតាទៅហើយ ស្រាប់តែនាងស្តោះទឹកមាត់ដាក់ឆែត :

- ហេតុអ្វីក៏លោកប្រព្រឹត្តរឿងដែលគួរអាមាសយ៉ាងនេះ ?

- ធ្វើបែបនេះ ព្រោះតែបងស្រលាញ់អូន...

គេឆ្លើយវិញទាំងខឹង ព្រោះត្រូវទឹកមាត់ពេញមុខ ។

- តែខ្ញុំមិនបានស្រលាញ់លោកទេ...

- ទោះយ៉ាងណាក៏បងនឹងធ្វើអោយអូនស្រលាញ់បងមិនខាន ។

ថាហើយគេក៏ស្ទុះទៅទ្រោបលើខ្លួនមាណវី ស្រាប់តែត្រូវធិតា ធាក់មួយជើងចំកណ្តាលមុខ បែកអំពិលអំពែកព្រោងព្រាតតែម្តង... គេខឹងណាស់ ក៏ស្ទុះមកទះកំភ្លៀងនាងពីរបីដៃ រួចហើយក៏ស្ទុះទៅ យកដបថ្នាំម្យ៉ាង មកចាប់ច្របាច់មាត់នាងបង្អកភ្លាម ។ ដោយចាញ់កម្លាំងដៃរបស់ភក្តីដែលទះកំភ្លៀងហើយបង្អកថ្នាំនាងទៀត មាណវី ទន់ខ្លួនល្វត់ ហើយដួលប្រូសទៅលើកំរាលឥដ្ឋ បាត់ស្មារតីឈឹងតែ ម្តង ។

CHANBOKEO.COM

មិននឹងជាអស់ពេលយូរប៉ុណ្ណាទេ... ពេលនាងនឹងស្មារតីមកវិញ ស្រាប់តែឃើញរូបកាយនាងអាក្រាតននល ដណ្តប់ដោយក្រណាត់ ភួយពណ៌ស ។ គ្រានោះកល្យាណីមានអារម្មណ៍ថា នាងបានបាត់បង់ នូវភាពបរិសុទ្ធរបស់នាងទៅហើយ... ។ ធិតារន្ធត់ញាប់ញ័រណាស់ ចង់យំក៏យំមិនចេញ ចង់ស្រែកក៏ស្រែកមិនឮ ។ តើនាងមានកម្មពៀរអ្វីខ្លះទៅ ដែលនាងត្រូវមកប្រទះគ្រោះអាក្រក់ក្នុងជីវិត មិន អស់មិនហើយ ។ ធិតាយើងក្រលេកមើលជុំវិញខ្លួន មិនឃើញមាន ស្រមោលនរណាទាំងអស់ សូម្បីតែទ្វារក៏បើកចំហដែរ ។ នាងនឹក ពិភាល់ក្នុងចិត្តយ៉ាងខ្លាំង លាយឡំនឹងក្តីឈឺចាប់ដ៏ធំធេង ។ ធិតា ប្រឹងក្រោកឡើងទាំងទីងធោង ស្រវារកសម្លៀកបំពាក់របស់នាង ដែលនៅមានសភាពល្អទាំងអស់មិនមានរហែកដាច់ដោចអ្វីបន្តិច ។ ទឹកភ្នែកជាច្រើនដំណក់បានប្រដេងគ្នា ហូរកាត់ផ្ទៃមុខរបស់មាណវី ទំលាយនូវការពើតផ្សាក្នុងចិត្ត ដែលព្រានឫស្យាមានឱកាសឆក់ យកព្រហ្មចារីយ៍របស់នាងបានដោយងាយៗយ៉ាងដូច្នេះ ។

បន្តិចមក នាងក៏ដើរចេញពីផ្ទះល្វែងមួយនោះទាំងទុរន់ទុរាធីង ធោង បន្តិចមកក៏បែរក្រោយរកចំណាំផ្លូវ ទើបនាងដឹងថា ផ្ទះល្វែង មួយនោះជាកូនក្លីនិកដែលទើបបើកថ្មីនៅបាត់ដំបង តាមបណ្តោយ ផ្លូវលេខមួយប្រហមាត់ស្ទឹងសង្កែ ។ ធិតាប្រឹងត្រដរដើរទាំងយប់ ស្ងាត់តែម្នាក់ឯង ពេលនេះ នាងលែងខ្លាចអ្វីហើយ ក្រៅពីការចង់ ស្លាប់តែម្យ៉ាងគត់ប៉ុណ្ណោះ ។ តើនាងត្រូវរស់ដើម្បីអ្វី កាលបើតម្លៃ របស់នារីក្រមុំបានរលត់រលាយសូន្យទៅហើយ... នាងអង្គុយយំ ក្រោមដើមឆ្នួងតែម្នាក់ឯង យំរហូតដល់ទឹកភ្នែកខះ លែងហូរតទៅ ទៀត...

មួយសន្ទុះធំក្រោយមក ធិតាក៏ងើបដើរទៅមុខ សំដៅទៅ រកលំនៅរបស់នាងវិញ ។ ថ្មើរនោះ មិននឹងជាម៉ោងប៉ុន្មានហើយ ទេ ។ ចរាចរតាមផ្លូវក៏ស្ងាត់ ជនោរខ្យល់ក៏ស្ងាត់ ចង្រិតក៏លែងយំ ដែរ ។ ធិតាមើលមិនឃើញអ្វីសោះ ក្រៅពីភាពងងឹតតែម្យ៉ាង ។ ភ្លាមនោះ នាងចាប់ភ្លឹកថា មានស្រមោលមនុស្សម្នាក់ដើរឆ្លងផ្លូវ សំដៅមករករូបនាង ។ នៅក្រោមពន្លឺខែព្រឹមៗនៃរាត្រីចុងខ្មើត នាងសំគាល់ភិនភាគរបស់គេបាន ថាគេជាមនុស្សប្រុសម្នាក់ ។ ពេលនោះនាងនឹកភ័យភើតក្នុងពោះតែម្តងដោយគិតថាគេគឺជាភក្តី បុរសចិត្តកំណាចមួយនោះ ។ មាណវីក៏ប្រឹងស្ទុះរត់ទាំងរូបកាយ ទុរន់ទុរា ប្រឹងក្រោកដើរទៅមុខទៀតយ៉ាងលឿន ។ ថៃដន្យ នាងឈាន មិនបានប៉ុន្មានជំហានផង ក៏ងងឹតមុខដួលប្រួសទៅដី ដោយចាញ់កម្លាំងថ្នាំ ដែលនៅសល់ឥទ្ធិពលក្នុងខ្លួននាងនៅ ឡើយ ។

CHANBOKEO.COM

- អ្នកនាង..!

ចរណៃឮសូរសំលេងមនុស្សប្រុសហៅនាងខ្សិបៗក្បែរត្រចៀក តែនាងអស់កម្លាំងណាស់ និយាយមិនរួចទេ បានត្រឹមតែពោលថា:

- ខ្ញុំ...ចង់ទៅផ្ទះ...

ឮដូច្នោះ បុរសនោះក៏ស្រវាលើកបីនាងឡើង ។ ពេលនោះ ធិតាយើងទន់ខ្លួនល្វក់ បាត់ស្មារតីវិញទៅហើយ... នាងមិនបានដឹង ថា តើបុរសនោះបីយកខ្លួននាងយកទៅណាទេ ។

លុះនាងបើកភ្នែកឡើងសាជាថ្មី ធិតាឃើញខ្លួនឯងនៅក្នុងផ្ទះ របស់នាងវិញដដែល ។ នាងយកដៃញីភ្នែក ញីហើយញីទៀត ច្រលំក្រែងភពមួយណាជាសុបិន មួយណាជាការពិត ។ ប៉ុន្តែទោះបី ជានាងញីភ្នែកប៉ុន្មានដង ក៏ការពិតនៅតែជាការពិតដដែល... គឺការ ពិតដែលថានាងត្រូវព្រានរំលោភព្រហ្មចារីយ៍ទៅហើយ មិនអាចកែ ប្រែបានទេ... ប៉ុន្តែហេតុអ្វីបានជានាងបានត្រលប់មកដល់ផ្ទះរបស់ នាងវិញ ? តើនរណាជាអ្នកមកជួយសង្គ្រោះរូបនាង ហើយហេតុអ្វី ក៏គេមកជួយយឺតពេលម្ល៉េះ ? ម៉េចមិនមកជួយឲ្យបានមុនពេល នាងត្រូវព្រានអប្រិយបំពារបំពានរូបនាងផង ? នឹកឡើងកាលណា នាងកាន់តែខ្ញាញ់ចង់តែយកកាំភ្លើងទៅបាញ់សម្លាប់បុរសដែលមាន ឈ្មោះថាភក្តីនោះឲ្យស្លាប់ធ្លាក់នរកទាំងរស់តែម្តង..!

CHANBOKEO.COM

ប្រហែលពីរម៉ោងក្រោយមក លោកចំណាប់ក៏បានមកដល់ផ្ទះ វិញ ព្រមជាមួយគ្នានឹងភរិយាព្រមទាំងចំណាន ស្រាប់តែប្រទះនឹង ចរណៃដួលដេកនៅក្នុងថ្លុកឈាម នៅលើកំរាលឥដ្ឋ ។

- ចរណៃ! កូនយ៉ាងម៉េចហ្នឹងកូន ?

អ្នកស្រីចន្ថាខមានឡើង ។ លោកចំណាប់លើកខ្លួនចរណៃឡើង មកពិនិត្យ ស្រាប់តែលាន់មាត់ឡើងដែរថា :

- ចរណៃបានអារកដៃសម្លាប់ខ្លួនណ៎ម៉ាក់វា...!

- ពុទ្ធោបងណៃ!

ចំណានលាន់មាត់ ។ លោកចំណាប់ក៏បីកូនស្រីដាក់រថយន្តបរ សំដៅទៅពេទ្យធំដើម្បីអោយគេសង្គ្រោះនាងជាបន្ទាន់ ។ គ្រោះល្អ ចរណៃមិនទាន់អស់ជីវិតនៅឡើយទេ ។ នាងក៏បានត្រូវលោកវេជ្ជ បណ្ឌិតសង្គ្រោះទាន់ពេលវេលា ហើយក៏បានរួចផុតគ្រោះថ្នាក់ ។

នៅក្នុងបន្ទប់អ្នកជំងឺ...

ចរណៃគេងបិទភ្នែកស្ងៀមស្ងាត់តែម្នាក់ឯងដើម្បីរំងាប់អារម្មណ៍ ដែលពុះកញ្ជ្រោលក្នុងទ្រូងគ្មានស្រាកស្រាន្ត ។ នាងទើបតែដឹងខ្លួន មិនប៉ុន្មាននាទីមុននេះទេ តែនាងមិនព្រមចង់ដឹងខ្លួនវិញឡើយ ។ នាងចង់តែធ្មេច...ធ្មេច... ដើម្បីកុំឲ្យនាងបានឃើញពិភពលោកដ៏ ល្អក់កករដូចនរកអវិចីនោះតទៅទៀត ។ ភ្លាមនោះ នាងចាប់ភ្លឹក

ថា មានដៃមួយមកស្ទាបថ្ពាសនាងបន្ថើរៗ :

- លោកប៉ា! (ចរណៃឧទានខ្សិបៗ)

តែមិនមែនឯណា! លុះនាងបើកភ្នែកឡើង ក៏ប្រទះនឹងដុកទ័រ សង្ហាមួយរូបដែលមានវ័យក្មេងណាស់មិនលើសពី២៦-២៧ឆ្នាំទេ ។ គេពិនិត្យរូបនាងដោយយកចិត្តទុកដាក់តែក៏មិនមានមាត់កអ្វីជាមួយ នាងដែរ ។ ធិតាភ្ញាក់ព្រើត ព្រោះគេជាបុរសដែលនាងធ្លាប់ជួបនៅ វត្តកណ្តាល ធ្លាប់រត់ដល់គេដល់ទៅពីរដងហើយធ្លាប់ប្រទះខ្សែភ្នែក គេជាញយដងរាប់មិនអស់ ពេលគេលបតាមដានរូបនាងថ្មីៗនេះ ។ បន្តិចមកធិតាក៏បិទភ្នែកវិញ ត្បិតអីពេលនេះនាងស្អប់មនុស្សប្រុស ណាស់ ។ ក្នុងលោកនេះ នាងលែងទុកចិត្តបុរសណាទៀតហើយ ក្រៅពីអ្នកមានគុណរបស់នាងចេញ ។ ថ្ងៃនោះ មាណវីចំណាំបានថា លោកគ្រូពេទ្យក្មេងនោះបានមកពិនិត្យអាការៈរបស់នាងជាច្រើនដង ហើយមានកិរិយា ហាក់ដូចជាខ្វល់ខ្វាយចំពោះសុខទុក្ខរបស់មាណវី ក្រៃលែង ។ គេអន្ទះសាដូចមាន់រកពង ឆ្លេឆ្លាចុះឆ្លេឆ្លាឡើង តែ នាងមិនខ្វល់នឹងនិយាយរកទេហើយក៏មិនសួរពីអ្វីដែរ ថែមទាំងខឹង មួម៉ៅនឹងលោកគ្រូពេទ្យនោះទៀតផង ដែលមកជួយសង្គ្រោះនាង ឲ្យផុតពីសេចក្តីស្លាប់ ព្រោះពេលនោះនាងលែងចង់រស់នៅឃើញ ពិភពលោកតទៅទៀតហើយ...

មិនថានាងមានអាការៈមួម៉ៅត្រមាត់ត្រមុយដាក់គេយ៉ាងណាទេ លោកគ្រូពេទ្យក្មេងមួយរូបនោះ តែងតែមកពិនិត្យអាការៈរបស់នាង យ៉ាងហ្មត់ចត់ ហើយញឹកញាប់រៀងរាល់ថ្ងៃ ថ្វីបើគេមិនសូវជាបាន និយាយស្តីអ្វីជាមួយនាងយ៉ាងណាក៏ដោយ ។ គេរក្សាការអត់ធ្មត់ ហើយស្ងាត់ស្ងៀម មិននិយាយមិនស្តី ហើយមានការយកចិត្តទុក ដាក់ នឹងការព្យាបាលរូបនាងយ៉ាងដិតដល់បំផុត ។

CHANBOKEO.COM

បីបួនថ្ងៃ កន្លងទៅ...

- បងណៃ! ពេលបងបានជាស្រួលបួលពីជំងឺពេលណា ប៉ាម៉ាក់នឹងជូនបងទៅព្រះនេត្រព្រះហើយ...

- មែនឬ អូនណាន ?

- ចាស! មែនហើយ ។ លោកប៉ាមានប្រសាសន៍ថាអោយណានជូនបងទៅរស់នៅទីនោះចំនួនមួយឆ្នាំ ដើម្បីឲ្យបងបានសប្បាយចិត្តមកវិញលែងចង់ធ្វើបាបខ្លួនដូច្នេះទៀត ។

ឮដំណឹងនេះភ្លាម ចរណៃក៏ញញឹមឡើងយ៉ាងបំព្រង ភ្លេចនូវ ការឈឺចាប់អស់រលីង ព្រោះនាងកំពុងតែនឹករលឹកដល់គេម្នាក់ឥត ឧបមា ហើយក៏ចង់ជួបគេណាស់ទៀតផង ។ បន្តិចមក មាណវីសួរ ទៅប្អូនស្រីថា :

- តើប៉ាម៉ាក់ជ្រាបហើយមែនទេ ថាបងត្រូវបុរសបំពាន... ?

ចំណានងក់ក្បាល :

- គឺប្អូនបានជំរាបគាត់ទាំងពីរហើយ ។ គាត់ក៏ភ្ញាក់ផ្អើលក្រៃលែង ព្រោះអាណិតបងណាស់ ។ ដូច្នេះហើយទើបគាត់សំរេចចិត្ត អោយ បងវិលត្រលប់ទៅស្រុកវិញ... ក្រែងបងបានសប្បាយចិត្ត ឈប់ នឹកចង់ធ្វើបាបខ្លួនឯងតទៅទៀត ។

- សូមទោសណាអូនណានដែល កាលនោះបងគិតខ្លី ត្បិតបងខឹង ចិត្តពេក កណ្តោចកណ្តែងឈឺចាប់ ហើយមិនអាចរកមធ្យោបាយណា ដោះស្រាយ ដើម្បីជួយសំរាលកំហឹងនិងការឈឺចាប់ផ្លូវចិត្តរបស់ខ្លួន ឯងបាន បានជាងងិតមុខ ប្រព្រឹត្តអំពើបាបដោយការធ្វើឃាតជីវិត របស់ខ្លួនឯងទៅ... ឥលូវនេះ បងសោកស្តាយណាស់ដែលបងបាន ធ្វើឲ្យប៉ាម៉ាក់រួមទាំងរូបអូនផង ត្រូវព្រួយអំពល់ដោយសារបង ។ ពេលនេះ បងដឹងហើយថាបងមានមនុស្សជាច្រើនដែលស្រលាញ់ បង ដែលបារម្ភពីសុខទុក្ខរបស់បង... ដូច្នេះបងត្រូវតែប្រឹងជំនះ ភាពឈឺចាប់ទាំងនេះឲ្យបាន ហើយប្រឹងរស់នៅម្តងទៀតសាជាថ្មី ដើម្បីមនុស្សដែលយើងស្រលាញ់ ជាពិសេសបំផុត បងត្រូវតែមាន ជីវិត ដើម្បីត្រលប់ទៅជួបបុរសម្នាក់ដែលតែងតែផ្តល់ក្តីសុខនិងក្តី មេត្តាសណ្តោសយ៉ាងត្រជាក់រមនារូបបងជានិច្ច មិនថាពេលណា...

- គឺជាបុរសដែលកំពុងរង់ចាំបងឯព្រះនេត្រព្រះនោះមែនទេ ?

CHANBOKEO .COM

- មែនហើយ... បងត្រូវតែជាសះស្បើយ ដើម្បីអោយបងឆាប់បាន ទៅជួបគេវិញ... បងកំពុងនឹកគេខ្លាំងណាស់!

ចំណានក៏ស្រវាអោបបងស្រី អង្អែលខ្នងអោយបន្តើរៗ ជា ការលួងលោមចិត្ត អោយនាងបានស្បើយកង្វល់ពីទុក្ខសោកចំពោះ រឿងអពមង្គលដែលទើបតែកន្លងទៅថ្មីៗ ។ ភ្លាមនោះ ចរណៃដាក់ ភ្នែកទៅមាត់ទ្វារបន្ទប់ពេទ្យ ស្រាប់តែប្រទះលោកដុកទ័រក្មេងនោះ ឈរមាត់ទ្វារ សម្លឹងមកនាងដោយក្រសែភ្នែកអំពល់ព្រួយបារម្ភ ។ នាងភ្ញាក់ព្រើត នឹករំភើបភើតៗក្នុងពោះពេលប្រទះនឹងក្រសែភ្នែក របស់គេ ។ ធិតាដាក់ភ្នែកចុះ គេចពីអនុភាពរបស់កែវភ្នែកមួយ គូនោះភ្លាម ។ លុះនាងលួចបែរទៅមើលម្តងទៀត គេនៅតែឈរ ទីនោះដដែល ។ ប៉ុន្តែស្នាមញញឹម ដែលគេធ្លាប់ប្រគល់អោយនាង រៀងរាល់ដងដែលគេជួបនាង បានបាត់ពីផ្ទៃមុខរបស់គេទៅហើយ នៅសល់តែក្រសែភ្នែកដែលសម្តែងនូវក្តីបារម្ភ និងទុក្ខសោកដ៏ជ្រាលជ្រៅមិនអាចថ្លាថ្លែងចេញបាន ។

ការពិត ចរណៃបានលួចសង្កេតឃើញកិរិយានោះច្រើនដង ហើយ ប៉ុន្តែមិនសូវជាចាប់ភ្លឹកប៉ុន្មានទេ ។ លុះដល់នាងប្រទះញយ ដងពេកទៅ ធិតាហាក់ដូចជាកើតមានចម្ងល់សង្ស័យចម្លែកក្នុងចិត្ត យ៉ាងណាមិនដឹងសោះ មិនដឹងថា ហេតុអ្វីលោកគ្រូពេទ្យម្នាក់នោះ មានអកប្បកិរិយាហាក់ដូចជាព្រួយបារម្ភពីសុខទុក្ខរបស់នាងម្ល៉េះ ? ម្យ៉ាងទៀត កិរិយានោះ ក៏មិនសមជាកិរិយាដែលពេទ្យគ្រប់គ្នាគេ ប្រព្រឹត្តលើអ្នកជំងឺដែរ ព្រោះគេហាក់ដូចជាយកចិត្តទុកដាក់ចំពោះ នាងយ៉ាងពិសេសក្រៃលែង លើសពីអ្នកជំងឺទូទៅ...

ប៉ុន្មានថ្ងៃក្រោយមក...

ចរណៃក៏ជាធូរស្រាលមកវិញ ហើយត្រូវបានទទួលការអនុញ្ញាត្ត ពីលោកគ្រូពេទ្យត្រលប់មកផ្ទះវិញ ។ នាងត្រេកអររំភើបតែម្តង ក៏ស្ទុះរៀបចំខ្លួន ធ្វើដំណើរទៅព្រះនេត្រព្រះជាប្រញាប់នៅថ្ងៃតែ មួយដដែលនោះដែរ មិនរង់ចាំថ្ងៃស្អែកថ្មីសិនឡើយ ។

ការពិត បើនិយាយអោយចំទៅ ចរណៃបានត្រូវឪពុករបស់ នាង ផ្សំផ្គុំជាមួយយុវជនមួយរូបឈ្មោះករុណាហៅនាយខ្លា ជាស្វាមី ភរិយានៅមុនពេលដែលគាត់ធ្វើមរណកាលនៅឆ្នាំ១៩៨៨ ។ កាល នោះ ចរណៃទើបតែមានវ័យ១៨ឆ្នាំ ចំណែកនាយខ្លាអាយុ១៧ឆ្នាំ ។

CHANBOKEO.COM

តាមាំងជាឱពុករបស់នាងមិនចង់អោយកូនស្រីនៅកំព្រាតែលតោល កាលបើអត់ពីគាត់ទៅ ។ ម្យ៉ាងគាត់ដឹងថានាយខ្លាបានស្រលាញ់កូន ស្រីរបស់គាត់យ៉ាងប្តូរផ្តាច់ រហូតហ៊ានប្តូរជីវិតដើម្បីរូបនាងទើបគាត់ សំរេចចិត្តរៀបចំអ្នកទាំងពីរទាន់មុនគាត់ផុតដង្ហើម ។ រីឯនាយខ្លា វិញក៏ជាយុវជនដ៏ល្អមួយរូប ។ ថ្វីបើគេជាអ្នកកូនអ្នកស្រែក្រីក្រមាន ការសិក្សាតិចតួចមែន តែគេក៏ជាមនុស្សដែលមានទឹកចិត្តបំផុត ។ ដែលពិសេសជាងគេនោះ គឺគេស្រលាញ់ចរណៃរកអ្វីប្រៀបមិនបាន ឡើយ ។ អ្វីក៏គេអាចឲ្យនាងបានទាំងអស់ ឲ្យតែចរណៃទាមទារ ។

ប៉ុន្តែនៅកាលនោះ ថ្វីបើគេបានរៀបការហើយក៏ដោយ ក៏គេ នៅក្មេងមិនទាន់ពេញវ័យសមសួនទាំងពីរនាក់នៅឡើយ ទើបគេ មិនបានរួមរស់ជាមួយគ្នាជាគូស្វាមីភរិយា ដូចអ្នកដទៃផងទាំងពួង ថ្វីបើគេមានចំណងចិត្តចំពោះគ្នា យ៉ាងមុតមាំក៏ដោយ ។ ថ្ងៃមួយ ថៃដន្យពួកចោរព្រៃដែលចូលប្លន់ក្នុងភូមិហើយបានបាញ់ត្រូវចរណៃ របួសជាទម្ងន់ ។ មាណវីក៏ត្រូវបែកគ្នាពីនាយខ្លាយ៉ាងអាសន្ន ព្រោះ លោកចំណាប់បានដឹករូបនាងយក ទៅព្យាបាលនៅ ឯទីក្រុងបាត់ ដំបង ។ ដោយហេតុថាការធ្វើ ដំណើរទៅមករវាងក្រុងបាត់ដំបង និងព្រះនេត្រព្រះ បានស្ថិតនៅក្នុងគ្រោះថ្នាក់ អស់រយៈជាយូរឆ្នាំ អ្នកទាំងពីរមិនដែលបានដឹងដំណឹងពីគ្នាម្តងណាឡើយ តាំងពីថ្ងៃ ដែលលោកចំណាប់ដឹករូបកាយស្គុកស្គីងរបស់ធិតាចាកចេញទៅ ។

ថ្ងៃនេះ ធិតាវិលមកដល់ស្រុកវិញសាជាថ្មី សុបិនទាំងឡាយ របស់នាងក៏បានក្លាយជាការពិត ដូចចិត្តដែលនាងគិតប៉ងប្រាថ្នា ។ ចរណៃក៏បានជួបនាយខ្លារបស់នាងដូចបំណង ហើយគេក៏នៅតែរង់ ចាំនាង នៅតែស្រលាញ់នាង... នៅតែបូជាអ្វីៗទាំងអស់ក្នុងជីវិត របស់គេ ដើម្បីរូបនាងដដែល ។ ចំណងដួងចិត្តដ៏ជ្រាលជ្រៅ ដែល គេធ្លាប់មានចំពោះគ្នាពីដើមយ៉ាងណា ពេលនេះក៏នៅតែមានសន្ទុះ អនុភាពបែបនោះដូចគ្នា ពេលអ្នកទាំងពីរបានជួបមុខគ្នាសាជាថ្មី ។ សូរសៀងភ្លេងការក៏បន្លឺឡើងយ៉ាងខ្ទ័រខ្ទារពេញភូមិ ។ នាយខ្លានិង ចរណៃក៏បានរៀបការនឹងគ្នាជាគូជីវិត ដោយមានព្រះគ្រូឧត្តរៈ តា ញ៉ៅមេឃុំនិងយាយព្រីង ប្រពន្ធគាត់ ព្រមទាំងក្រុមគ្រួសារលោក ចំណាប់ មកចូលរួមធ្វើជាអធិបតីដល់គេទាំងពីរថែមទៀតផង ។

នៅក្នុងបន្ទប់ផ្សំដំណេក នារាត្រីក្រេបទឹកឃ្មុំចន្ទ័...

CHANBOKEO.COM

- បងខ្លា!

- បាទ!

- ណៃមានរឿងមួយដែលចង់ជំរាបបងខ្លាអោយបាននឹង ព្រោះណៃ
មិនចង់អោយបងខឹងហើយអាក់អន់ចិត្តនៅពេលក្រោយទេ ។

- រឿងអ្វីទៅអូនណៃ ?

- បងប្រាប់អូនសិនមកថាបងនឹងអនុគ្រោះដល់ណៃ ពេលបងបាន
ដឹងរឿងពិតទាំងនោះហើយ ។

- អូននឹងស្រាប់ហើយតើ ថាបងអនុគ្រោះអោយណៃសព្វយ៉ាងទាំង អស់ ។ ប្រាប់បងមក...
បងចាំស្តាប់អូនហើយ ។

ធិតាឈ្ងោកមុខមួយស្របក់ទើបដាច់ចិត្តនិយាយឡើងថា :

- បងខ្លា... ប៉ុន្មានថ្ងៃមុនពេលអូនធ្វើដំណើរមកព្រះនេត្រព្រះនេះ
អូនបានប្រទះនឹងឧប្បត្តិហេតុដ៏សែនអាក្រក់បំផុតក្នុងជីវិត...

ធិតាស្រក់ទឹកភ្នែកច្រោក ។ នាយខ្លាឃើញដូច្នោះក៏ងើបឡើង ស្រដីទាំងភ្ញាក់ផ្អើលថា :

- អូនត្រូវគេបំពានរូបកាយ... មែនទេ ?

- ម៉េចបានជាបងដឹង ?

- គឺកិរិយារបស់អូន កំពុងបរិយាយប្រាប់បងណា៎!

ចរណៃឈ្ងោកមុខស្រក់ទឹកភ្នែកសាជាថ្មី ។

- នរណាគេ ចិត្តប្រេតនរកយ៉ាងនេះ អូនណៃ ?

នាយខ្លាយកដៃក្តោបក្បាល សំដែងការឈឺចាប់ក្នុងចិត្ត ។

- ខឹងនឹងអូនឬ បងខ្លា ?

មាណពបែរសម្លឹងមុខចរណៃ ហើយស្រវាអោបនាងពេញដៃ :

- អត់ទេ! បងមិនខឹង មិនបន្ទោសអូនទេ... ការពិត បងខឹងនឹង ព្រេងវាសនា
ដែលធ្វើអោយបងខ្វះលទ្ធភាពនឹងការពារអូនអោយ ផុតអំពើពាលនោះបានតើហ៎ !

រំពេចនោះ ស្រាប់តែ ខ្លាយកដៃជូតទឹកភ្នែកដែលកំពុងហូរធ្លាក់
មកលើផ្ទៃមុខរបស់នាយ រួចហើយក៏ជូតទឹកភ្នែកអោយនារីកំពូល
ដួងចិត្តរបស់គេ ។ បន្ទាប់មក បុរសយើងក៏ញញឹមមកវិញយ៉ាង រហ័ស
ព្រមទាំងស្រដីដោយក្តីត្រេកអរ ថា :

CHANBOKEO.COM

- តែពេលនេះ បងលែងខឹងនឹងព្រេងវាសនាទៀតហើយព្រោះគេ
បាននឹកដៃអូនអោយត្រលប់មកជួបបងវិញ ។ ទោះបីអូនមិនមែន
ជានារីបរិសុទ្ធក៏ដោយក៏បងនៅតែស្រលាញ់អូន ហើយចង់រួមរស់ជា មួយអូន
ប្រសើរជាងរស់នៅត្រមង់ត្រមោច ដោយគ្មានរូបអូននៅ ក្បែរនោះដែរ ។
បងបានរង់ចាំអូនជាច្រើនឆ្នាំយ៉ាងកណ្តោចកណ្តែង ពេលនេះ អូនក៏បានវិលមកជួបបងវិញជាថ្មី
រឿងអ្វីដែលបងត្រូវ បណ្តោយឲ្យអូនព្រាត់ពីបងទៅវិញ ? បងពិតជាខ្លាចភាពត្រមង់
ត្រមោចណាស់ ។ បងស្រលាញ់អូន ! បងនឹកអូន... ! កាលបើរូបអូន
បានវិលមកដល់រង្វង់ដៃរបស់បងវិញហើយ បងសន្យាថានឹងការ
ពាររូបអូនអោយមានសេចក្តីសុខបំផុតចាប់ពីពេលនេះតទៅ... មិន
ឲ្យអូនឃ្លាតទេណាឆ្ងាយពីរង្វង់ដៃរបស់បងជាដាច់ខាត ។
ចរណៃស្រវាអោយចង្កេះមាណព ទទួលនូវភាពកក់ក្តៅពីដើម
ទ្រូងរបស់គេ ។ មួយស្របក់ក្រោយមក នាងក៏ពោលសួរថា :
- ចុះបើអូនបែរជាមានផ្ទៃពោះដោយអំពើពាលមួយនោះ... ?
- បងក៏នឹងរក្សាគេជាកូនចៅរបស់បង ព្រោះគេជាទារកតូចដែល ជាដំណក់ឈាមរបស់អូន ។
គេមិនបានដឹងរឿងឧក្រិដ្ឋរបស់មនុស្ស ចាស់ទេ ដូច្នេះ យើងមិនគួរដាក់ទោសគេឡើយ ។
បងនឹងថែរក្សា គេអោយមានសេចក្តីសុខបំផុត ។ លុះគេធំឡើងនឹងបានប្រាសចាក
នូវអំពើពាលនរកអវិចីទាំងឡាយ ។
ចរណៃសម្លឹងមុខមាណពដោយក្តីរំភើបក្នុងចិត្ត :
- ណៃដឹងមុនរួចហើយថាបងនឹងសណ្តោសរូបអូននឹងកូនជានិច្ច ! ទោះបីបងមិននិយាយប្រាប់អូន
ក៏អូនបានដឹងជានិច្ចដែរថាបេះដូង របស់បងទូលាយណាស់
អាចទទួលយកអូននិងកូនៗជាច្រើននាក់ ទៅលាក់ទុក ហើយផ្តល់សេចក្តីសុខយ៉ាងរមនា ។
អរគុណណាស់ ប្តីសម្លាញ់ ដែលបងបានផ្តល់ម្លប់ដ៏ត្រជាក់ក្សេមក្សាន្តចំពោះជីវិត
របស់អូនដែលកណ្តោចកណ្តែងជាយូរមកហើយ ។
ខ្លាស្រវាអោបប្រពន្ធយ៉ាងណែនផ្ទឹបនឹងដើមទ្រូង :
- មែនហើយ ! ក្តីស្រលាញ់របស់បងធំធេងណាស់ អាចដណ្តប់រូប
អូនហើយនិងកូនៗបានគ្រប់គ្នាទាំងអស់... អូនឈប់បារម្ភអ្វីទៀត ទៅ ។ ចាប់ពីថ្ងៃនេះតទៅ
យើងច្រៀងតែចម្រៀងសុភមង្គលតែ ម្យ៉ាងប៉ុណ្ណោះ ។

CHANBOKEO.COM

- ចាំសបង! ហើយអូនក៏រំភើបចិត្តឥតឧបមា ដែលអូនមានឱកាស បានរៀបការនឹងមនុស្សល្អដូចជារូបបង ។ បងខ្លា! អូនស្រលាញ់ បងណាស់...!

គូស្នេហ៍ទាំងទ្វេហាក៏ញញឹមដាក់គ្នាយ៉ាងបំព្រង ដើម្បីទទួលនូវរសជាតិសុភមង្គលដ៏ផ្អែមល្ហែមបំផុត រវាងគេទាំងពីរនាក់ ។

តាំងពីថ្ងៃនោះមក គេក៏រួមរស់ជាមួយគ្នាជាគូស្វាមីភរិយាដោយ គ្មានរឱស្ឋានអ្វីបន្តិចឡើយ ។ អ្នកទាំងពីរបានទទួលសេចក្តីសុខ យ៉ាងពេញលក្ខណៈ ថ្វីបើគេរស់នៅជនបទដាច់ឆ្ងាយពីសង្គមហ៊ឺហា នានាទាំងឡាយនោះក៏ដោយ ។

ooooooooooooooo

ooooo

o

CHANBOKEO.COM

# វគ្គទី៨
# ពិរុទ្ធ

ក្រុងបាត់ដំបង ឆ្នាំ ១៩៦៣...

- លោកពេទ្យមិនស្រួលខ្លួនហ្អែសថ្ងៃនេះ ? (ពូខេមសួរ)
- បាទ! អត់ទេ ? មានអ្វីប្លែកឬពូខេម ? (វិចិត្រតបវិញ)
- ឃើញលោកពេទ្យមានភ្នែកក្រហមៗ ហើយធ្វើមុខស្រពោនៗ ទើបពូនឹកចម្លែកក្នុងចិត្ត... កំពុងខ្វល់ចិត្តរឿងអ្វី មែនទេ ?

វិចិត្រញញឹមតបវិញ :

- ភ្នែកក្រហមព្រោះស្រក់ទឹកភ្នែកអាណិតប្រពន្ធខ្ញុំហ្នឹងណា៎ពូ...
- អូហ៍... មានរឿងអ្វីហ្អែស បាទ ?
- មិនមានទេ... គ្រាន់តែខ្ញុំអាណិតគេ... គេងស្តាប់រឿងគេនិយាយ ប្រាប់ម៉ាយប់ ស្រាប់តែស្រក់ទឹកភ្នែកអាណិតគេពេញម៉ាយប់ដែរ ។
- ភ្នែកទន់ម្ល៉េះ លោកគ្រូពេទ្យ ?
- អត់ទេ... គឺចិត្តខ្ញុំតើហ៍ ដែលទន់...
- សង្ស័យតែចូលតួហើយ បានជាដូរអារម្មណ៍យ៉ាំងហ្នឹង ?
- មិនមែនចូលតួទេ... គឺបានដើរតួឯកតែម្តង...
- មែន ? នេះពូចង់ដឹងដែរ ហើយថារឿងរ៉ាវនោះមានខ្លឹមសារ យ៉ាងណាខ្លះទៅ ?
- នោះ ទាល់តែទុកអោយប្រពន្ធខ្ញុំគេនិយាយហើយ ព្រោះគេជាគ្រូ បង្រៀន មានសិល្ប៍សាស្ត្រអាចបរិយាយបានពិរោះជាងខ្ញុំនិទាន ។
- នរណាគេទៅហ៊ានសួរនោះ លោកគ្រូពេទ្យ ?

វិចិត្រញញឹម ហើយក៏ចេញទៅស្រស់ស្រូបអាហារពេលព្រឹកជា មួយប្រពន្ធឯបន្ទប់បាយ មុននឹងចេញទៅធ្វើការ ។ ស្រាប់តែអ្នក ស្រីផាន់ស៊ីមកដល់ :

CHANBOKEO.COM

- នាយចិត្រ! យើស! តាំងពីបានប្រពន្ធមក សំងំបាត់មុខ មិន
ឃើញនាំទៅលេងផ្ទះមីងអីបន្តិច...

វិចិត្ររត់ទៅទទួលផង ឆ្លើយផងថា :

- គឺក្មួយខ្លាចចិត្តមីងនោះអី!

ចរណៃឮមាត់រ៉ូសវ៉ាសរបស់អ្នកស្រីផាន់ស៊ី ក៏ចេញមកទទួល :

- ជំរាបសួរអ្នកមីង!

នាងក៏នាំកូនជំរាបសួរគ្រប់ៗគ្នា ។ ពេលដែលអ្នកស្រីផាន់ស៊ី ដាក់ភ្នែកទៅចំភក្ត្រា ក៏សម្លឹងមុខនាយឆ្ងើភាំង ហើយលាន់មាត់ថា:

- យី! អាចៅតូច... ឯងមានមុខមាត់ដូចនាយចិត្រម្ល៉េះ ហ្ន៎ស ? ដូចជាឪពុកនិងកូនបេះដាក់ ។

វិចិត្រឈ្ងោកមុខ លួចដៀងភ្នែកទៅចរណៃ តែមិនហ៊ានតបអ្វី ទៅគាត់វិញទេ ។ អ្នកស្រីផាន់ស៊ីក៏ចាប់ចៅប្រុស ពឡើង :

- ឯងស្រស់ណាស់ទើយ! គួរអោយស្រលាញ់តែម្តង ។

មើលទៅអ្នកស្រីផាន់ស៊ីដូចជាបន្ទន់កិរិយាបន្តិចហើយ ចំពោះ វិចិត្រនិងចរណៃ តាំងពីគាត់ដឹងថា ចំណងស្នេហារបស់គេទាំងពីរ រឹងមាំ មិនអាចបំបែកបាន ទើបគាត់ខ្ជិលប្រយុទ្ធប្រឆាំងអ្វីនឹងអ្នក ទាំងពីរតទៅទៀត ។

នាងតូចបារមីក៏រត់ត្រេ ទៅតោងដៃអ្នកស្រី ហាក់ដូចជាចង់សុំ អោយគាត់លើកនាងពឡើងដូចភក្ត្រាដែរ ។ កាលបើដាក់ភ្នែកមក ឃើញកែវភ្នែកភ្លឺថ្លាឆ្វង់ដ៏បរិសុទ្ធរបស់កុមារី អ្នកស្រីផាន់ស៊ីហាក់ ដូចជានឹកអាណិតស្រលាញ់នាងតែម្តង ។ គាត់ក៏បោះដៃឈោងយក កុមារីពឡើង រួចក៏ពចៅម្ខាងមួយដើរចូលផ្ទះ :

- អោយមីងសុំទឹកត្រជាក់ម៉ាកែវមក នាង!

ចរណៃឮដូច្នោះក៏ដាក់កន្ទុយភ្នែកទៅរកវិចិត្រ ហាក់ដូចជាដឹង ថា អ្នកស្រីផាន់ស៊ីកំពុងទទួលស្គាល់រូបនាងជាកូនចៅហើយ ។ នរ: លួចសម្លឹងមុខភរិយា រួចញញឹមតបវិញដោយចិត្តរំភើប ។ បន្តិច មក ចរណៃក៏កាន់កែវទឹកមកជូនអ្នកស្រី ។ អ្នកស្រីយកដៃទទួល ហើយស្រដីថា :

- ល្ងាចនេះ នាងនាំចៅទៅលេងផ្ទះមីងម៉ាក្លែតបានទេ ? បើចាំ នាយចិត្រវាជូនទៅដោយចិត្តវា មិនដឹងពេលណាទេ ព្រោះវាមិន ដែលនឹកឃើញមីងវាទេ ។

ការពិតមីងមានការចង់និយាយជាមួយ នាងបន្តិច ។

វិចិត្រលួចមើលមុខភរិយា សម្លេងទឹកមុខជឿងឆ្ងល់ តែក៏មិន ហ៊ានមាត់អ្វីទេ ។ ចរណៃក៏លួចសម្លឹងមុខស្វាមីវិញដែរ ត្បិតនាង មិនសូវស្គាល់អ្នកស្រីផាន់ស៊ី មិនដឹងថាត្រូវឆ្លើយបែបណាទើបសម រម្យ ។ ឃើញធិតានៅស្ងៀម អ្នកស្រីផាន់ស៊ី ក៏ងើបឈរឡើង ដើរ ចេញទៅ :

- អឺ! បើមានពេល នាងទៅកុំខាន តែបើមិនមានទេ ក៏មិនអីដែរ មានប្រសាសន៍ចប់ អ្នកស្រីក៏អោយសូហ្វ័រឡានបរដឹកអ្នកស្រី ចេញទៅ ។ វិចិត្រសម្លឹងមុខចរណៃទាំងជឿងឆ្ងល់ មិនដឹងថាគាត់ មានគំរោងការអ្វីទេ ។ បន្តិចមក មីងលឿមក៏មកដល់ដើម្បីមកជួយ មើលក្មេងតូចៗទាំងពីរ ។ វិចិត្រដឹកស្រីម៉ៅដាក់សាលាហើយក៏ដាក់ ភរិយានៅឯសាលាមួយទៀត ទើបចេញទៅធ្វើការខ្លួនឯង ។

រសៀលនោះ...

នៅផ្ទះអ្នកស្រីផាន់ស៊ី ម្ដុំពោធិហ្សស្រី ចំការសំរោង...

វិចិត្របើកទ្វាររថយន្តនាំភរិយានិងកូនទាំងបីមកដល់មុខផ្ទះធំ ស្អាតមួយប្រក់ក្បឿងក្រហម ។

- តោះអូន! ឡើងទៅលើផ្ទះ (វិចិត្រហៅភរិយា)

លុះឡើងមកដល់បន្ទប់ទទួលភ្ញៀវខាងលើផ្ទះ វិចិត្រមានការ ភ្ញាក់ផ្អើលណាស់ ដោយឃើញទីនោះមានការតុបតែងយ៉ាងប្លែក :

- អ្នកមីងធ្វើបុណ្យអ្វីមែនទេ ?

មាណពសួរទៅអ្នកស្រីផាន់ស៊ី ដែលកំពុងដើរដឹកដៃចៅម្ខាង មួយ ។ គាត់ធ្វើមុខមាំហើយឆ្លើយថា :

- គ្រាន់តែមីងរៀបចំអោយស្អាតម្ដងក៏មិនបានឬនាយចិត្រ ?

រំពេចនោះ ស្រាប់តែមានភ្ញៀវចាស់ទុំពីរបីនាក់ក៏ចូលមកដល់ ព្រមគ្នាដែរ ។ វិចិត្រធ្វើភ្នែកមូលក្រឡង់ ដោយការភ្ញាក់ផ្អើល ។ អ្នកស្រីផាន់ស៊ីក៏ចាប់ផ្ដើមមានប្រសាសន៍ថា :

- នេះ នាយចិត្រឯងរៀបការប្រពន្ធ មិនចង់អោយចាស់ៗចងដៃ ទេហ្អីហ្អ៎ស ? ណែ៎ក! អង្គុយចុះមក៏...

CHANBOKEO.COM

វិចិត្រនាំភរិយាដាក់ខ្លួនអង្គុយចុះនៅមុខចាស់ៗទាំងនោះដោយ
មានអ្នកស្រីផាន់ស៊ីអង្គុយជាកត្តិយសចំកណ្តាល :
- ចិត្រអើយ! មីងសូមទោសណាដែលធ្លាប់មាត់ធំមាត់តូចចំពោះ ឯង តែថ្ងៃនេះ
មីងចង់រៀបការចងដៃឯងសាជាថ្មី ព្រោះមីងមិន ទាន់បានចងដៃអ្នកទាំងពីរនៅឡើយទេ ។
វិចិត្រសម្លឹងមុខអ្នកស្រីផាន់ស៊ី ដោយក្តីរំភើបក្នុងចិត្ត :
- អ្នកមីង...!
បន្ទាប់មក អ្នកស្រីផាន់ស៊ីក៏យកអំបោះសមកចងដៃអោយអ្នក ទាំងពីរហើយស្រដីថា :
- ពិតមែនតែមីងមិនមែនម្តាយរបស់ឯងបង្កើត តែមីងក៏ស្រលាញ់ ឯងដូចជាកូនរបស់មីង ។
កាលបើជីវិតរបស់ឯងមានសេចក្តីសុខ មីងក៏សប្បាយរីករាយហើយរំភើបចិត្តជាទីបំផុត ។
មីងសូមជូនពរ អោយក្មួយទាំងពីរចាប់ដៃគ្នាសាងសុភមង្គលគ្រួសារសុខសាន្តរៀង រហូតទៅ ។
ក្មួយណែ! មីងផ្ញើវិចិត្រនឹងនាងផង! មើលទៅនាង ក៏ជាមនុស្សឆ្លាតវាងវៃ
ហើយចាស់ទុំចិត្តគំនិត សង្ឃឹមថាជីវិតគូ ស្រករបស់អ្នកទាំងពីរនឹងមានលំនឹងជានិច្ច ។
វិចិត្រក៏ចាប់ដៃភរិយាមកក្តោបហើយអោនសំពះព្រមគ្នាទទួល
ទឹកប្រស់ព្រំនិងពរជ័យសាធុការពីអ្នកស្រីផាន់ស៊ីដោយដួងចិត្តរំភើប ក្រៃលែង ។
គេមិននឹកស្មានទេថា ម្តាយមីងរបស់គេទទួលស្គាល់ ចរណៃ ។
តែពេលនេះគេដឹងច្បាស់ហើយថាគាត់ពិតជាស្រលាញ់ រូបនាយពិតមែន
ដែលគាត់មិនគិតធ្វើអ្វីក្រឡិចក្រឡុច បំបែករូប ចរណៃពីនាយទេ ។ ផ្ទុយទៅវិញ
គាត់បែរជាផ្ទុងផ្តើមលើកទឹកចិត្ត នាយយ៉ាងពេញមុខ ។ ភ្លាមនោះ វិចិត្រពោលទាំងទឹកភ្នែករលីង
រលោងទៅកាន់អ្នកស្រីផាន់ស៊ីវិញថា :
- ពរជ័យអ្វីក៏គ្មានតម្លៃចំពោះវិចិត្រ ស្មើនឹងពរជ័យដែលក្មួយបាន ទទួលពីអ្នកមីងនៅពេលនេះទេ
ព្រោះជាពរជ័យដែលអ្នកមីងបាន ប្រទានមកក្មួយដោយសេចក្តីស្រលាញ់ និងការយកចិត្តទុកដាក់
ចំពោះសុខទុក្ខរបស់ក្មួយ ។ វិចិត្ររំភើបចិត្តណាស់ នឹងរកពាក្យអ្វី
មកថ្លែងអោយសមស្មើមិនបានឡើយ ។
អ្នកស្រីផាន់ស៊ីក៏ញញឹមឡើង :
- ហើយមីងក៏សូមជូនពរអោយអ្នកទាំងពីររក្សាគ្នា រហូតចាស់ព្រឹទ្ធ
ចាស់ព្រេង ។

CHANBOKEO.COM

វិចិត្រនិងចរណៃក៏ក្រាបបង្គំអ្នកស្រីផាន់ស៊ី ក្បាលដល់កន្ទេល សំដែងនូវក្ដីគោរពយ៉ាងជ្រាលជ្រៅចំពោះអ្នកស្រី ។

ថ្ងៃនោះ អ្នកទាំងពីរនៅបរិភោគបាយ សំណេះសំណាលជាមួយ នឹងម្ដាយមីងក្នុងបរិយាកាសស្និទ្ធស្នាលជាងមុន ។ វិចិត្រសង្កេត ឃើញម្ដាយមីងរបស់ខ្លួនសាកសួរចរណៃនូវរឿងរ៉ាវជាច្រើន តែ នាងក៏ឆ្លើយតាមត្រង់ទៅវិញ មិនបញ្ឆិតបញ្ឆៀងអ្វីតបទៅវិញទេ ។ ម្យ៉ាងទៀត អ្នកស្រីផាន់ស៊ីក៏ហាក់ដូចជាស្រលាញ់ចៅតូចៗទាំងបី នាក់នោះទៀតផង មិនដូចកិរិយាដែលគាត់បានជួបពួកគេកាលពី លើកដំបូងនោះឡើយ ។ មើលទៅប្រហែលជាគាត់បានពិចារណា ច្រើនហើយ ទើបបានដូរអកប្បកិរិយាមកជាទន់ភ្លន់ដាក់ចរណៃនិង កូនយ៉ាងប្លែកបែបនោះទៅវិញ ។

ព្រលប់បន្តិច វិចិត្រក៏បររថយន្តនាំភរិយានិងកូនទាំងបីត្រលប់ មកផ្ទះវិញទាំងដួងចិត្តរីករាយ ។ ថៃដន្យ ពេលគេបត់រថយន្តចូល ដល់ផ្ទះភ្លាម ស្រាប់តែឃើញភក្ដីជិះសូឡិចមកដល់ដែរ ក្នុងកិរិយា ទំនងតក្កហល ហាក់ដូចជាទើបនឹងមានជម្លោះជាមួយនរណាម្នាក់ :

- បងចិត្រ! ខ្ញុំមានការចង់និយាយជាមួយបងបន្តិច...

ស្រាប់តែនាយដាក់ភ្នែកទៅឃើញចរណៃដឹកដៃកូនចេញពីឡាន ក៏លាន់មាត់ឡើងថា :

- ស្បៃរឿង... ? រួច... ម៉េចបានអូនស្គាល់បងចិត្រដែរ ?...

គេស្ទុះរឺងទៅរកនាងយ៉ាងរហ័ស តែចរណៃបែរជាដឹកដៃកូន ដើររឺងធ្វើមិនឃើញរូបនាយ ចូលទៅក្នុងផ្ទះយ៉ាងរហ័ស :

- ស្បៃរឿង! ឈប់សិន!...

ស្រាប់តែវិចិត្រយកខ្លួនពាំង :

- នរណាគេជាស្បៃរឿង ? នេះជាផ្ទះបងណា៎! ប្អូនឯងត្រូវរក្សា ឥរិយាបថអោយសមសួនផងបានទេ!

វិចិត្រឃាត់ប្អូន ថែមទាំងនឹកឆ្ងល់ក្នុងចិត្តផងថា ហេតុដូចម្ដេច បានជានាយហៅភរិយារបស់ខ្លួនថាស្បៃរឿងទៅវិញ ។ កំពុងតែ គិត ស្រាប់តែភក្ដីឧទានឡើង :

- តែខ្ញុំចង់និយាយជាមួយស្បៃរឿង ។

CHANBOKEO.COM

- អត់ទេ... ដរាបណាប្អូនមានអកប្បកិរិយាឆ្គេឆ្គា គ្មានរបៀបយ៉ាង នេះ
បងមិនអោយប្អូនជួបនិយាយជាមួយនាងទេ ។
- បងឯងអាងអី បានជា... ? ហើយចុះហេតុម៉េច... ស្បៃរឿងមក នៅទីនេះជាមួយបង ?
បងមានអ្វីលាក់នឹងខ្ញុំមែនទេ ?
- ប្អូននិយាយពីស្អីហ្នឹង ? បងស្តាប់មិនយល់ទេ ។
- បងចិត្រ ចៀសផ្លូវ !
- មិនចៀស..!
- ហេតុអ្វីបងធ្វើឫកហាក់ដូចជាហួងហែងរូបនាងម្ល៉េះ ? បងលួច ដើរផ្លូវកាត់
ពីក្រោយខ្នងរបស់ភក្តីមែនទេ បានជាបងធ្វើឫកដូចជា ឆ្កែលួចអង្កៀមឆ្អឹងដូច្នេះ ?
- តែផ្តាស ! ឯងនិយាយព្រហើនណាស់ !
 វិចិត្រសម្លុត ហើយលើកដៃបំរុងទះកំភ្លៀងប្អូន ស្រាប់តែ:
- ទះមក៍ បើចង់ទះប្អូនណាស់ ! ម៉េច ! ខ្ញុំនិយាយចំចំណុចខ្សោយ មែនទេ
បានជាច្រឡោតខ្លាំងម្ល៉េះ បងចិត្រ ?
 ដោយនឹកអាណិតប្អូន វិចិត្រដកដៃវិញ មិនហ៊ានទះ តែក៏ខឹង ច្រឡោតណាស់
ដែលប្អូនហ៊ានហើបមាត់ប្រដូចរូបនាយទៅនឹងសត្វ
ឆ្កែដូច្នោះ :
- ប្អូនប្រញាប់ចេញពីផ្ទះបងភ្លាមទៅ !
- មិនទៅ ! ដរាបណា ខ្ញុំមិនទាន់បាននិយាយជាមួយស្បៃរឿង...
- បើឯងសម្តែងកិរិយាដូចមនុស្សស្រវឹងយ៉ាងនេះ បងមិនអោយ ជួបទេ ឮហើយនៅ ?
 វិចិត្រអូសដៃប្អូនចេញទៅក្រៅ តែភក្តីរលាស់ដៃភ្លាម :
- អត់ទេ !
 រួចហើយក៏ស្ទុះរត់ឡើងទៅលើផ្ទះរបស់វិចិត្រ :
- ស្បៃរឿងចេញមក៍...បងចង់និយាយជាមួយអូន...
 ថៃដន្យវិចិត្រអូសនាយទម្លាក់ដីវិញ :
- កុំមកមានឫកពាច្រងេងច្រងាងនៅផ្ទះបងដូច្នេះ ភក្តី...
- អី ហួងហែងម្ល៉េះ ?

CHANBOKEO.COM

ថាហើយភក្តីក៏យកជើងធាក់បងប្រុស ដែលប្រទាញអូសនាយ ទំលាក់ពីជណ្តើរ ធ្វើអោយវិចិត្រដួលទៅដីអុកគូថទីស ។ កាលបើ ឃើញអ្នកទាំងពីរប្រវ៉ាយគ្នា ចរណៃក៏ហៅពូខេមហៅមើលក្មេងកុំ
គេភិតភ័យចំពោះហេតុការណ៍ខាងក្រៅ ហើយក៏ដើរចេញមកវិញ :

- ឈប់វ៉ាយគ្នាភ្លាមទៅ (ចរណៃស្រែកឃាត់)

ឮប្រយោគនេះភ្លាម ភក្តីទប់ដៃជើក់ ហើយបែរញញឹមទៅរក ចរណៃដែលកំពុងចុះជណ្តើរមក :

- ស្បៃរឿង អូនព្រមនិយាយជាមួយបងហើយហ្ន៎ស ?
- ខ្ញុំទុកពេលអោយប្រាំនាទី...បើលោកមានការអ្វីត្រូវនិយាយ ឆាប់ និយាយមកចុះ ទាន់ខ្ញុំចង់ស្តាប់... (ចរណៃនិយាយទៅភក្តី)

វិចិត្រក្រោកឈរឡើងសម្លឹងភរិយារួចសម្លឹងប្អូនប្រុសរួចហើយ ក៏ជ្រួញចញ្ចើម បញ្ចេញអាការៈហាក់ដូចជាមិនសប្បាយចិត្ត ។ ប៉ុន្តែ ចរណៃមិនបានចាប់ភ្លឹកទេ ។ ភក្តីស្ទុះមកដល់ជិតធិតាស្រវ៉ាដៃនាង កាន់ តែត្រូវនាងរលាស់វិញ ហើយស្រដីថា :

- សូមរក្សាឥរិយាបថអោយថ្លៃថ្នូរបន្តិចលោកភក្តី!

ភក្តីព្រលែងដៃទៅវិញ ហើយឈរស្ងៀមយ៉ាងយូរ ហាក់ដូចជា
កំពុងរំលត់នូវភាពពុះកញ្ជ្រោលក្នុងដើមទ្រូងរបស់គេ ។ នៅខាង ក្រោយខ្នង វិចិត្រឈរសម្លឹងមកអ្នកទាំងយ៉ាងស្ងៀមស្ងាត់ ប៉ុន្តែនៅ ក្នុងជំរៅបេះដូងរបស់គេវិញ ព្យុះសង្ស័យកំពុងបក់បោកលាន់គគ្រឹក គ្មានដាច់សូរឡើយ ។ គេខាំមាត់ ទប់ឥរិយាបថ មិនអោយភរិយា បានឃើញថា គេមានអារម្មណ៍ពុះកញ្ជ្រោលយ៉ាងណាទេ ហើយគេក៏ មិនព្រមគេចចេញទៅណាឆ្ងាយដែរ ព្រោះគេមិនទុកចិត្តថាអ្នកទាំង ពីរនឹងជជែកអ្វីជាមួយគ្នាខ្លះ ហើយតើភក្តីនឹងជះអារម្មណ៍ពុះពោរ កញ្ជ្រោលដាក់ចរណៃយ៉ាងណា ។

ភក្តីលេបទឹកមាត់ក្អឹក...ផ្ដើមបំពង់ក :

- ស្បៃរឿង...បងសូមទោស...ចំពោះរឿងពីអតីតកាល...
- លោកបានសូមទោសកាលពីថ្ងៃមុនម្តងនោះរួចហើយតើហ៎!
- តែបងមិនបានឮពាក្យអភ័យទោសពីអូននៅឡើយទេ ។
- បើលោកជាជនរងគ្រោះវិញ តើលោកនឹងអភ័យទោសដល់អ្នក
ដែលប្រព្រឹត្តបាបលើរូបលោកទេ ?

- មកពីកាលនោះបងនៅក្មេង ឆេវឆាវ ធ្វើអ្វីមិនគិតមុខគិតក្រោយ ទើបបណ្ដោយអោយភាពកម្លៅវាទន្ទ្រានចិត្តបាន ។
- ចុះឥឡូវ លោកមានវ័យចំណាស់ជាងមុនហើយ លោកឈប់ឆេវ ឆាវហើយឬនៅ ? លោកឈប់ប្រព្រឹត្តបាបលើនារីហើយឬនៅ ? ហើយមានផ្លាស់ប្ដូរជីវិតអោយប្រសើរជាងមុនដែរឬទេ ?

ភក្ដីឈ្ងោកមុខចុះ នៅស្ងៀម ។

- លោកនៅស្ងៀម គ្មានចម្លើយ បានន័យថា លោកមិនបានប្រែ ចរិតចាស់របស់លោកទេ (ចរណៃពោលបន្ត)
- គឺបងពិបាកចិត្ត មានអារម្មណ៍វិលវល់... មិនអាចគ្រប់គ្រងការ ប្រព្រឹត្តរបស់ខ្លួនបាន...
- មានន័យថា លោកមិនទាន់អាចទទួលការអភ័យទោសពីរូបខ្ញុំបាន នៅឡើយទេ ដរាបណា លោកមិនទាន់កែខ្លួនអោយប្រសើរឡើង ។
- អូនទុកពេលអោយបងបន្តិចទៅ នោះបងនឹងសម្ដែងអោយអូន ឃើញ នូវសេចក្ដីល្អរបស់បង...
- ម៉េចចាំសម្ដែងអោយខ្ញុំឃើញផង ? ឬក្នុងលោកនោះ មានតែខ្ញុំ ម្នាក់ទេមែនទេ ដែលអាចឃើញការសម្ដែងអំពើល្អរបស់លោក ? ចុះអ្នកដទៃ ហេតុអ្វីគេមិនអាចបានទទួល ឬក៏ឃើញអំពើល្អរបស់ លោកផង ? ហេតុអ្វី លោកចាំធ្វើអំពើល្អចំពោះតែមនុស្សម្នាក់ ? ហើយចុះអ្នកដទៃ គេជាប្រេតនរកឬយ៉ាងម៉េច បានជាលោកមិន អាចធ្វើអំពើល្អលើគេបាន ?

ភក្ដីនៅស្ងៀមស្ងាត់ម្ដងទៀត កាលបើឮចរណៃ សួរផ្ទាន់ៗ ដូច្នោះ ។ បន្តិចមក មាណពក៏ស្រដីថា :

- ប្រហែលជាមកពីជីវិតរបស់បងបាត់បង់អ្វីៗសព្វយ៉ាង ដែលបង ស្រលាញ់ ទើបបានជាបងវង្វេង... ឪពុកម្ដាយដែលធ្លាប់លើកស្ទួយ ថ្នាក់ថ្នមបងក៏លែងនៅ...ស្រីដែលបងស្រលាញ់ក៏បាត់ស្រមោលទៅ សង្ឃឹមលើបងវិចិត្រ ជួនក៏គាត់ជ្រោមជ្រែងលើកទឹកចិត្ត ជួនក៏គាត់ អាត្មានិយមមិនអាចជួយអ្វីបងបាន ។ ពេលនោះបងក្លាយជាមនុស្ស ដែលមានវិបត្តិផ្លូវចិត្ត... លង់ក្នុងភ្លឹងងងឹតរក សម្លឹងមើលផ្លូវល្អផ្លូវភ្លឺ ថ្លាមិនឃើញ... ឃើញតែជីវិតដ៏ខ្មៅកខ្វក់តែម្យ៉ាង...

ទឹកភ្នែកពីរតំណក់ក៏ហូរធ្លាក់មកលើផ្ទៃមុខរបស់ភក្ដី ជាលើក ដំបូងក្នុងជីវិតរបស់គេ ។ មួយស្របក់មកគេក៏វាចាបន្តទៀតថា :

CHANBOKEO.COM

- ជាតិជាកូនប្រុសដែលរងវិបត្តិផ្លូវចិត្តដូចបង ហាក់ដូចកំពុងលង់
ក្នុងភពងងឹត តើអោយបងដើរផ្លូវណា ដើម្បីរកពន្លឺឃើញ កាលបើ នៅជុំវិញខ្លួន
សុទ្ធតែងងឹតសូន្យទាំងអស់យ៉ាងនេះ ? បើនឹងហារ និយាយប្រាប់អ្នកដទៃ
គេនឹងសើចចំអកថាបងជាមនុស្សទន់ខ្សោយ បើបងបៀមទុក
នោះជីវិតនៅតែងងឹតមិនមានថ្ងៃធូរស្រាលមកវិញ តើអោយបងធ្វើដូចម្តេច ? បងខំចៀសស្រា
ចៀសអំពើបាប តែ បងប្រឹងទប់ចិត្តថាមិនពុះកញ្ជ្រោលមិនបានទេ ។
ចរណៃឈ្ងោកមុខនៅស្ងៀម ហាក់ដូចជាយល់បន្តិចហើយនូវ វិបត្តិផ្លូវចិត្តរបស់ភក្តី
ព្រោះនាងក៏ធ្លាប់បាត់បង់មនុស្សដែលនាង ស្រលាញ់អស់ទៅដែរ ។
ជីវិតរបស់នាងពេលនោះហាក់ដូចជាស្ថិត នៅក្នុងភពងងឹតឥចឹង
មិនអាចរកពាក្យអ្វីមកពណ៌នាអោយសមស្មើ បានឡើយ ។ ប៉ុន្តែ
នាងមិនមានកិរិយាណាដែលបង្ហាញថាធីរនឹង សំរាលទោសអោយភក្តីបន្តិចណាទេ ។
វីងវិចិត្រវិញក៏ឈ្ងោកមុខត្រដុសដៃហាក់ដូចជាកំពុងប្រឹងបន្លប់
នូវភាពពុះកញ្ជ្រោលក្នុងចិត្តដូចគ្នា ។ ថ្វីបើគេមិនមាត់មិនស្តី តែ
កិរិយាគេបានបញ្ជាក់អោយឃើញច្បាស់ថា គេក៏មានអ្វីនៅក្នុងដើម
ទ្រូងដែលត្រូវការបញ្ចេញមកដែរ គ្រាន់តែមិនដឹងត្រូវបញ្ចេញ របៀបណា ពេលណាតែប៉ុណ្ណោះ ។
បន្ទាប់មក ភក្តីក៏ស្រដីបន្តទៅទៀតថា :
- ស្មៀរឿង... បងពិតស្រលាញ់អូនមែន ថ្វីបើបងធ្លាប់ឆ្លងកាត់ មនុស្សស្រីជាច្រើន
តែបងនៅតែបំភ្លេចអូនមិនបាន... បងនៅតែ
នឹកស្តាយចំពោះអំពើពាលរបស់បងដែលធ្វើទៅលើអូននារាត្រីមួយ នោះ
ព្រោះអំពើដ៏អាក្រក់នោះបានបណ្តាយអោយអូនស្អប់បងហើយ រត់គេចទៅរៀបការនឹងគេដទៃ...
សូម្បីតែគេគ្មានអ្វីបន្តិចធៀបនឹង បងបាន...       តែអូនក៏ជ្រើសរើសគេ...
ចំណែកបងក៏ត្រូវរស់នៅ
បៀមទុក្ខវិប្បដិសារីនៅក្នុងដើមទ្រូង ។
ភ្លាមនោះ ចរណៃស្រក់ទឹកភ្នែកច្រោក... ក្នុងចិត្តរន្ធត់ញាប់ញ័រ ណាស់
រកអ្វីប្រៀបមិនបានទេ ។ នាងនៅតែខ្លាច...ខ្លាចហើយខ្ពើម រអើមរាត្រីមួយនោះឥតឧបមា ។
នាងឈឺចិត្តណាស់...ឈឺចិត្តសឹង តែយកកាំបិតមកចាក់សម្លាប់បុរស ដែលកំពុងឈរនៅចំពោះមុខ
នាងអោយស្លាប់ ។ ជាងប្រាំឆ្នាំហើយ... កំហឹងនោះនៅឆេះសន្ធោ ក្នុងចិត្តនារីយើងនៅឡើយទេ

CHANBOKEO.COM

ហើយក៏កំពុងឆាបឆេះឡើងវិញខ្លាំង ជាងមុនទៀតផង ។
តើនារីណាមួយទៅដែលអាចរំលត់កំហឹងនេះ បានបើសិនជាគេបានទទួលរងគ្រោះដូចរូបនាង ?
កាលបើឃើញភរិយាស្ថិតនៅក្នុងអារម្មណ៍មិនប្រក្រតី វិចិត្រ ស្ទុះមកជិតហើយស្រវាអោបនាងយ៉ាងណែន ដើម្បីផ្តល់នូវភាពកក់ក្តៅចំពោះភរិយាដែលកំពុងរន្ធត់ញាប់ញ័រ ស្រាប់តែភក្តីស្ទុះមកបេះ ដៃនាយរឹងឡើង ហើយស្រដីខ្លាំងៗដាក់បងប្រុសខ្លួនភ្លាមថា :
- ហើយបងជាស្អីនឹងស្បៀរឿងដែរ បានជាមកបញ្ចេញអាការៈហាក់ដូចជាបងនេះជាមនុស្សសំខាន់របស់នាងឥចឹង ? នេះយើងនិយាយគ្នារឿងចាស់របស់យើងមិនទាន់ចប់នៅឡើយទេ ។ បងកុំមកកាត់ ចង្វាក់អោយសោះ ។
ស្រាប់តែចរណៃដើបមុខឡើង ស្រដីយ៉ាងកំបុតកំបុយថា :
- ឈប់ភ្លាមលោកភក្តី! កុំវាលដាលទៅណាទៀតអី! ដឹងទេហ៍ ថាហេតុអ្វីបានជាស្បៀរឿងរត់គេចពីរូបលោកផង កាលបើលោកវាចាក្តែងៗថាស្រលាញ់ស្បៀរឿងពេញបេះដូងរបស់លោក ?
- អូននិយាយប្រាប់បងមក...នោះបងនឹងបានដឹង...! (ភក្តីតប)
- នោះគឺព្រោះតែភាពយង់ឃ្នងរបស់លោក ទាំងកាយវិការ ទាំងវាចានិងការប្រព្រឹត្តរបស់លោកតែម្តង ដែលធ្វើអោយខ្ញុំភ័យខ្លាច ជាទីបំផុត ។ លោកប្រើតែភាពកម្រោលដោយកម្លាំងបាយ ដើម្បី យកឈ្នះដើម្បីអោយបាននូវអ្វីៗដែលលោកប៉ងប្រាថ្នា ។ តើនារី ណាមួយទៅដែលមានចិត្តទូលំទូលាយរីករាយសោមនស្សទទួល យកភាពយង់ឃ្នងរបស់លោក ? តើគេអាចទ្រាំបានប៉ុនណាដែរ ដើម្បីរក្សាស្នេហាជូនលោកដោយស្មោះស្ម័គ្រជូនលោកនោះ ? គេប្រាកដជាទ្រាំមិនបានទេ ។ ការអត់ធ្មត់របស់នារីតែងតែមានកំរិត ។ កាលបើគេទ្រាំលែងបាន គេក៏នឹងចាកចេញទៅ ។ នារីខ្លះអាច ទ្រាំជាមួយលោកយូរឆ្នាំទើបចាកចេញ ។ តែចំពោះស្បៀរឿងវិញ នាងពិតជាទ្រាំមិនបានទេសូម្បីតែដប់នាទី! តើយើងនឹងធ្វើគូស្នេហ៍ជាគ្នាយ៉ាងណា បើយើងប្រព្រឹត្តតែហឹង្សា និងភាពយង់ឃ្នងដាក់គ្នា ទៅវិញទៅមកបែបនេះ ?
ភក្តីឈ្ងោកមុខ ហាក់ដូចជាកំពុងគិតអំពីកំហុសរបស់ខ្លួន បន្តិចមកក៏ស្រដីថា :

CHANBOKEO.COM

- មនុស្សយើងអាចមានកំហុសពិតមែន តែបើសិនជាផ្តល់ឱកាស អោយគេកែប្រែ គឺប្រហែលជាមនុស្សដែលមានកំហុសនោះរៀនកែ ប្រែខ្លួនគេអោយល្អមកវិញបាន ។ សូមអូនអោយឱកាសបងសំរាប់ កែប្រែខ្លួនផង ។

- នោះក៏សម្រេចនៅលើបុគ្គលនោះដែរថា តើគេនឹងកែប្រែសំរាប់ នរណាដែរ ? បើគេកែប្រែសំរាប់តម្រូវចិត្តអ្នកដទៃ នោះគឺជាការ កែប្រែក្លែងក្លាយ ព្រោះបើអត់ពីអ្នកដទៃនោះទៅ គេនឹងក្លាយជា មនុស្សយង់ឃ្នងដូចដើមវិញ ។ តែបើគេកែប្រែដើម្បីខ្លួនគេផ្ទាល់ មិនមែនដើម្បីអ្នកដទៃ នោះទើបជាការកែប្រែពិតប្រាកដ ព្រោះថា
ទោះបីគេទៅដល់ទីណា នៅជាមួយនរណា គេនៅតែជាមនុស្សល្អ ជានិច្ច រហូតទៅ ។

ភក្តីដាក់មុខជប់តែម្តង ។ មែនហើយ! ចរណៃនិយាយត្រូវ ណាស់ គឺថាបើគេត្រូវផ្លាស់ប្តូរចរិតមារយាទរបស់គេ ដើម្បីចរណៃ តែម្នាក់ នោះពេលដែលគេអត់ពីចរណៃទៅ គេនឹងក្លាយជាបុគ្គល វង្វេងនឹងភាពងងឹតសាជាថ្មី ។ ប៉ុន្តែបើគេកែខ្លួនធ្វើជាមនុស្សល្អ ដើម្បីខ្លួនគេផ្ទាល់ នោះគេនឹងជាមនុស្សល្អរហូតទៅ មិនថាគេនៅ ជាមួយនរណា ពេលណា កន្លែងណា ។

ភ្លាមនោះ វិចិត្រសង្កេតឃើញចរណៃញ័រដៃញ័រជើងហើយមាន ទឹកមុខស្លេកស្លាំងខុសធម្មតា ។ គេនឹកបារម្ភអំពីសុខទុក្ខរបស់នាង ភ្លាមតែម្តង :

- ភក្តី! អោយបងសូមកាត់បន្តិចបានទេ? មើលហ្ន៎! គេមិនសូវ ស្រួលខ្លួនហើយ... ប្អូនអោយគេសំរាកសិនទៅ... ចាំស្អែក ចាំយើង និយាយគ្នាទៀតណា៎...

ឃើញបងប្រុសកាន់ដៃកាន់ជើងចរណៃ យ៉ាងជិតដិតសិទ្ធស្នាល ភក្តីក៏ជ្រួញចិញ្ចើមឡើង :

- ហើយបងត្រូវជាអ្វីនឹងស្បៃរឿងដែរ... បានជាមកធ្វើឫកហាក់ដូច ជិតដិតនឹងរូបនាងខ្លាំងម្ល៉េះ ? នេះបងកំពុងដើរកាត់មុខប្អូនហើយ...

គេក៏យកដៃច្រានបងប្រុស អោយឃ្លាតចេញពីចរណៃយ៉ាង រហ័ស ។ ដោយមិនបានប្រយត្ន័ខ្លួន វិចិត្រក៏ធ្លាកច្រលោតតោតទៅ ម្ខាង ហើយចរណៃក៏រលំផ្អៀងដងខ្លួនដួលទៅម្ខាង :

- អ៊ុយ! (ចរណៃដួលដល់ថ្ងាសនឹងជញ្ជាំងលាន់ភឹង)

- អូនណៃ!

CHANBOKEO.COM

    វិចិត្រឧទានហើយក៏ស្ទុះទៅចាប់ផ្ទិតាទប់ខ្លួននាងឡើងរួចហើយ
ក៏បែរមកគំហកអោយភក្តីថា :
- នែ៎ភក្តី! ឯងធ្វើនេះជ្រុលពេកហើយ ។
    រំពេចនោះ ស្រាប់តែចរណៃងើបមុខឡើងសម្លក់ភក្តីយ៉ាងមុត :
- នេះឬសេចក្តីស្រលាញ់របស់លោក ? នេះឬសុភមង្គលដែល
លោកសន្យាថានឹងប្រគល់អោយស្បែរឿង... ជាការប្រព្រឹត្តដ៏សម ស្ទួនដល់ហើយនេ៎ះ!
ពិតជាសុភមង្គលដ៏អស្ចារ្យណាស់ ដែលប្រើ សុទ្ធតែកម្លាំងបាយ ដើម្បីយកឈ្នះស្ថានការណ៍ ។
    ភក្តីភ្ញាក់ខ្លួនក្រញាង :
- អត់ទេ..ស្បែរឿង! អត់ទេ... បងសូមទោស... បងគ្មានចេតនា នឹងធ្វើអោយអូនឈឺខ្លួនទេ...
សូមទោសណា៎ ។
- គ្មានចេតនាទេ... គ្មានចេតនាទេ...ភក្តីនិយាយបានស្រួលណាស់! អ្វីៗសុទ្ធតែគ្មានចេតនាទេ...
គ្មានចេតនាសូម្បីតែការចាប់ខ្លួនរបស់ ខ្ញុំយកទៅបំពានលើរូបកាយលេបព្រហ្មចារីយ៍បរិសុទ្ធ...
អំពើអ្វីៗ របស់លោក គឺសុទ្ធតែគ្មានចេតនាទាំងអស់ មែនទេ លោកភក្តី ?
    ភក្តីរិតតែភ្ញាក់ កាលបើឮនាងគំហកខ្លាំង ហាក់ដូចជាកំពុង ឈឺចាប់ហើយខឹងខ្លាំងណាស់ :
- អត់ទេ...ស្បែរឿង... កាលនោះបងចាប់ចងរូបកាយអូនមែន... ប៉ុន្តែ
បងមិនបានបំពានលើខ្លួនប្រាណអូនទេ...
- មុខក្រាស់...! (ចរណៃគំហក)
- មែនណា៎ស្បែរឿង... បងពិតជាមិនបានប៉ះពាល់រូបអូនជ្រៅរាក់ ទេ..
អូនជឿបងចុះ...បងសូមស្បថ !
    ស្រាប់តែនារីបែរមុខឡើងសម្លឹងភក្តីសឹងស៊ីសាច់ទាំងរស់ :
- បុរសទ្រូងប្រាំហត្ថត្រូវតែហ៊ានប្រឈមមុខនឹងការពិតហើយហ៊ាន
ទទួលខុសត្រូវនូវអំពើដែលខ្លួនបានប្រព្រឹត្ត ។ ពេលនេះ ខ្ញុំមិនជឿ
សោះថាលោកជាមនុស្សកំសាកដល់ម្លឹង!
    ស្រាប់តែភក្តីងើបមុខឡើង ហើយតមាត់យ៉ាងរឹងត្អឹង :
- ថាមិនបានប៉ះពាល់មិនបានប៉ះពាល់ហើយ សូមនាងកុំបង្ខំអោយ
ខ្ញុំឆ្លើយទទួលនូវអ្វីដែលខ្ញុំមិនបានប្រព្រឹត្ត...!
- តែថ្ងៃនោះ លោកគឺជាបុរសដែលចាប់ខ្ញុំបង្ខ្មកថ្នាំសន្លប់...

CHANBOKEO.COM

- ចៃដន្យ ខ្ញុំមិនមានឱកាសនឹងប្រព្រឹត្ត ព្រោះមានគេមកទាន់...

ពេលនោះ ចរណៃមិនជឿទេ... នាងក៏គំហកទៅភក្ដីវិញថា :

- បើភក្ដីមិនបានប្រព្រឹត្តអំពើលាមកនោះទេ ហេតុអ្វីក៏ខ្ញុំបាត់បង់ ព្រហ្មចារីយ៍ទៅកើត ? តើខ្ញុំមានផ្ទៃពោះមកពីណា បើអ្នកមិនបាន ប៉ះពាល់រូបខ្ញុំដល់ទីជំរៅនោះ ?
- ហ្ន៎ស ស្បែរឿងថាម៉េច ?

ភ្លាមនោះ ស្រាប់តែភក្ដីបើកភ្នែកមូលក្រឡង់ឡើង ដោយការ ភ្ញាក់ផ្អើល ។ ស្រាប់តែគេគិតឃើញរឿងមួយ ភ្លាមនោះក៏ស្ទុះទៅ ចាប់ក្របួចករអាវវិចិត្រឡើង ព្រមទាំងគំហកយ៉ាងរន្ថើនថា :

- គឺបងមែនទេ ? គឺបងមែនទេ ដែលធ្វើបាបស្បែរឿង..បងបាន ប្រព្រឹត្តអ្វីលើស្រីម្នាក់ដែលខ្ញុំបានចងដៃចងជើង បញ្ជ្រកថ្នាំសន្លប់ នៅថ្ងៃនោះ មែនទេ ? ឆ្លើយមក..! មែនទេ ? ព្រោះតែហេតុហ្នឹង មែនទេ ដែលស្បែរឿងត្រូវវត់ចោលបាត់ដំបង ទៅរៀបការនឹង បុរសស្រុកស្រែព្រះនេត្រព្រះ ?

ភក្ដីសួរទាំងរន្ធត់ក្នុងចិត្ត ហើយយោលអង្រួនវិចិត្រសឹងបាក់ក ពីស្មា ។ វិចិត្របើកភ្នែកធំៗហាក់ដូចជាភ្ញាក់ផ្អើលខ្លាំងណាស់ :

- ថាម៉េចភក្ដី ?... នោះគឺ...ជាស្បែរឿងរបស់ប្អូន ?
- បាទ..! មែនហើយ ។

វិចិត្រដាក់មុខជ្រប់ មិនតដៃនឹងប្អូនទេ ។ គេគ្រាន់តែចាប់ដៃ ភក្ដីចេញហើយពីខ្លួនរបស់គេ ហើយស្ទុះត្រលប់ទៅរកចរណៃ យក ដៃអង្អែលថ្ពាល់នាងដែលទម្លិចនឹងជញ្ជាំងអំបាញមិញហើយ រួចក៏ ស្រដីបន្លប់ថា :

- អូនមិនស្រួលខ្លួនហើយ ទៅសំរាកសិនទៅណ៎អូន!...

ចរណៃមើលមុខស្វាមី ហើយបែរមើលមុខភក្ដីធ្វើស្រលាំងកាំង ដូចគ្នាព្រោះកិរិយាបុរសទាំងពីរកំពុងមានពិរុទ្ធយ៉ាងចម្លែក ស្រាប់ តែភក្ដីស្ទុះហេមកសាជាថ្មី ម្ដងទៀត :

- បងចិត្រ កុំចង់គេចខ្លួន! បងត្រូវតែឆ្លើយនឹងខ្ញុំសិនទើបបាន ។

វិចិត្រយកដៃចាប់ប្អូនជាប់ ហើយស្រវាអោបយកភក្ដីអោយ ចេញឆ្ងាយពីចរណៃ ទើបស្រដីថា :

CHANBOKEO.COM

- គេបានប្រាប់ប្អូនហើយតើហ៎ថា គេមិនចូលចិត្តចរិតពាលយង់ ឃ្នងអន្ទះសា
មិនចេះទប់កំហឹងរបស់ប្អូននេះទេ... ឯងមានឮទេ ?

ភក្តីរលាស់ខ្លួនចេញពីក្រញាំដៃរបស់បងប្រុស :

- មែន! ខ្ញុំយង់ឃ្នង ខ្ញុំមានហឹង្សា ខ្ញុំជាមនុស្សកំរោលចូល ប៉ុន្តែ ក៏គង់គ្រាន់បើជាងមនុស្សខ្លះ
ដែលមើលពីក្រៅទៅ ល្អសែនល្អ សុភាពអើយសែនសុភាព តែខាងក្នុងវិញនោះ
គេគឺជាគំរង់លាមក សុទ្ធសាធ! !

ថៃដន្យ វិចិត្រមិនឆ្លើយថាម៉េចជាមួយប្អូនវិញទេ ។ គេបែរជា នៅស្ងៀមមិនស្រដី ។
ភក្តីឃើញបងប្រុសនៅស្ងៀម គេក៏ពោល បន្តទៀត ដោយដង្ហើមដង្ហក់ៗ
លាយជាមួយនឹងទឹកភ្នែករលីង រលោងផង ថា :

- ខ្ញុំមិនចង់ជឿទេថា ព្រោះបងប្រុសដែលខ្ញុំធ្លាប់គោរពបំផុត នោះ គឺជានរកបិសាច
អាក្រក់ជាងខ្ញុំទៅទៀត...!

ថាហើយ នាយក៏ក្ដោបក្បាលរត់ចេញទៅ ។ វិចិត្រឈរច្រងុក
នៅស្ងៀមស្ងាត់មិននិយាយអ្វីទេ គ្រាន់តែសម្លឹងពីក្រោយប្អូនប្រុស
រហូតដល់គេចេញពីបរិវេណផ្ទះបាត់ស្រមោលទៅ ។ លុះគេភ្ញាក់ ស្មារតីមកវិញហើយបែរក្រោយ
ស្រាប់តែប្រទះឃើញក្រសែភ្នែក ដ៏ស្រួរអាប់របស់ចរណៃដែលកំពុងសម្លឹងមកគេដោយក្ដីសង្ស័យ :

- តើអ្វីដែលភក្តីចោទបង អំបាញមិញនេះ ជាការពិតឬទេ ? តើ
បង...ធ្លាប់បានប្រព្រឹត្តដូចគេថាមែនដែរទេ ? (ធិតាសួរមាណព)

វិចិត្រមិនឆ្លើយទេ ។ គេបែរដើរទៅជិតនាង ហើយត្រកងស្មា នាងឡើង រួចស្រដីថា :

- អូនមានអារម្មណ៍មិនស្រួលហើយ...ទៅសំរាកសិនទៅអូន...
- អត់ទេ... អូនចង់ដឹងពេលនេះ ថាបងនិងភក្តីកំពុងមានរឿងអ្វី ?
ហើយវាទាក់ទងអ្វីនឹងរូបបងដែរ ? និយាយប្រាប់អូនសិនមក៏...

ចរណៃនិយាយដោយសម្លេងស្រាលៗ ប៉ុន្តែក្នុងចិត្តរបស់នាង កំពុងពុះកញ្ជ្រោលខ្លាំងណាស់
ព្រោះតែក្ដីសង្ស័យនៅក្នុងចិត្តយ៉ាង ធំមហិមាវាំរខាន ។
តែវិចិត្រនៅតែមានកិរិយាស្ងួតស្ងប់ដដែល :

- ទៅមុជទឹកសំរាកអោយត្រជាក់ខ្លួនសិនទៅ...ចាំបងនិយាយរឿង
ប្រាប់អូនណា៎...ណា៎...!
- បានន័យថា អ្វីដែលភក្តីចោទបងជាការពិតមែនទេ ?...

CHANEOKEO.COM

វិចិត្រសម្លឹងមុខភរិយា តែក៏មិនឃើញឆ្លើយអ្វីមួយម៉ាត់មកវិញ ដដែល ។ ធិតាញាប់ញ័រក្នុងចិត្តកាន់តែខ្លាំងឡើងៗ... រហូតដល់ ងងិតមុខឈឹង... រួចដួលប្រួសបាត់ស្មារតីតែម្តង ។

នៅក្នុងបន្ទប់គេង...

ចរណៃបើកភ្នែកឡើងសាជាថ្មី ។ ពេលនោះនាងមានអារម្មណ៍ ផែនដីកំពុងមានដំណើរឃ្លីងឃ្លោងយ៉ាងចម្លែក ។ ធិតាយកដៃខ្ទប់ ក្បាល ធ្វើកិរិយាហាក់ដូចជាកំពុងអោបទុក្ខមហិមា ។

- ណៃ! អូនដឹងខ្លួនហើយហ្ន៎ស ?...

ចរណៃប្រែខ្លួនឡើង ឃើញវិចិត្រកំពុងយកកូនកន្សែងពោះគោ ជ្រលក់ទឹកក្តៅឧណ្ហៗមកជូតខ្លួនអោយនាង ។ កាលបើឃើញធិតា ភ្ញាក់ដឹងខ្លួនឡើងវិញ គេត្រេកអរកខិបកខុបតែម្តង ហើយក៏ពោល ហៅនាងម្តងទៀត :

- អូនណៃ...!

ធិតាបើកភ្នែកសម្លឹងមើលមុខស្វាមីទាំងទឹកភ្នែករលីងរលោង :

- បងចិត្រ...

ថាបានតែប៉ុននេះ ស្រាប់តែនាងក៏ស្រក់ទឹកភ្នែកនិយាយតទៅ ទៀតលែងរួច ។

- អូនសម្រួលអារម្មណ៍បន្តិចទៅណា៎...ពេលណាអូនស្រួលខ្លួនហើយ មានអារម្មណ៍ល្អមកវិញ នោះបងមានរឿងសំខាន់ៗជាច្រើនណាស់ ដែលបងចង់និយាយប្រាប់អូន ។

វិចិត្រនិយាយលួងលោមភរិយា ។ ប៉ុន្តែនាងបែរជាគ្រវីក្បាល:

- ថៃដន្យ... អូន..ចង់ដឹងឥលូវនេះ...

វិចិត្រឈ្ងោកមុខយកនាសាថើបថ្ងាសភរិយា :

- បងមិនគេចពីការពិតទេ ហើយក៏មិនគេចពីអូនដែរ ។ បើបង មានកំហុស បងក៏រីករាយនឹងទទួលខុសត្រូវចំពោះកំហុសរបស់បង ជានិច្ច ។ បងស្រលាញ់អូនណាស់ណា៎អូនណៃ...បងអាចយល់ព្រម សព្វយ៉ាងតាមដែលអូនចង់បាន... សុំតែម្យ៉ាងទេ... គឺសុំអោយតែ អូនកុំខឹងហើយស្អប់បងបានហើយ...

ចរណៃសម្លឹងមុខស្វាមីម្តងទៀត ទំនងហាក់ចង់ដឹងថាតើគេ និយាយពិត ឬក៏គេគ្រាន់តែលួងលោមបញ្ឆោតចិត្តនាងមួយគ្រា ។ វិចិត្រឃើញដូច្នោះក៏ពោលបន្តថា :

- កុំសង្ស័យអំពីចិត្តបងអី... បងស្រលាញ់ប្រពន្ធរបស់បងដោយ

CHANBOKEO.COM

ស្មោះ... គ្មានថ្ងៃដែលបងបោះបង់អូនចោលទេ...
- តែអូននៅតែចង់ដឹងការពិត...ថាមានអ្វីកើតឡើងចំពោះរូបអូននា
គ្រាមួយនោះ ? បើអូនមិនបានដឹង នោះអូននឹងបែកទ្រូងស្លាប់...
- អូននឹងបានដឹង... ហើយក៏នឹងបានដឹងពីរូបបងផ្ទាល់មុនគេ...បង
មិនឲ្យអ្នកដទៃណាមកពន្យល់ការពិតដល់រូបអូន មុនបងទេ ។
- អញ្ចឹង បងនិយាយប្រាប់អូនពេលនេះមក៏...

វិចិត្រនៅស្ងៀម ដាក់មុខចុះ ។ ភ្លាមនោះ ចរណៃសួររន្ធើនថា:
- ដឹងទេ... ថាអូនធ្លាប់ស្អប់ ធ្លាប់ខឹង ធ្លាប់ចង់សម្លាប់បុរសដែល
ប្រព្រឹត្តយង់ឃ្នងលើរូបកាយអូននោះយ៉ាងណា ? គឺអូនចង់សម្លាប់ គេណាស់...!

ចរណៃនិយាយផងស្រក់ទឹកភ្នែកអណ្ដឺតអណ្ដក់ផង :
- ហើយ ពេលនេះ ហេតុអ្វីអូនបែរជាត្រូវសម្រក់ទឹកភ្នែកផង នៅ
ក្នុងខណៈដែលរង្វង់គ្រួសារកំពុងតែមានសុភមង្គលយ៉ាងល្អបំផុត ?
នេះយើងរៀបការនឹងគ្នាមិនទាន់បានបីខែស្រួលបួលទេណា៎ ?

វិចិត្រឃើញដូច្នោះ ហាក់ដូចជារន្ធត់ចិត្តណាស់ ក៏យកដៃជូត ទឹកភ្នែកអោយភរិយា
រួចលួងលោមនាងថា :
- ណៃ...! ឈប់យំសិនទៅអូន ។ បងមានដំណឹងល្អមកប្រាប់អូន ឥលូវនេះ...
បងក៏បានត្រៀមខ្លួនដែរ ថាបងនឹងនិយាយរឿងប្រាប់ អូនសព្វយ៉ាងដែលអូនចង់ដឹង....

ថាហើយ គេក៏ឈ្ងោកមុខថើបថ្ពាសភរិយាដោយក្ដីអាណិតក្នុង ជំរៅចិត្ត រួចហើយក៏ស្រដីបន្តថា
:
- អូនរំងាប់អារម្មណ៍ទៅ ហើយស្ដាប់បងនិយាយរឿងប្រាប់ណា៎...

ធិតាងក់ក្បាល រួចហើយក៏ផ្ដេកកេសាទៅលើទ្រូងស្វាមី ទទួល
យកនូវភាពកក់ក្ដៅ ដើម្បីរំលត់ភាពរងារន្ធត់ញាប់ញ័រនៅក្នុងឱរា ។
រីឯមាណពវិញក៏ស្រវាអោបភរិយានៅដៃម្ខាង ហើយលូកដៃម្ខាង
ទៀត ស្រវាចាប់ដៃនាងកាន់ឡើងយ៉ាងណែន :
- អូនណៃ... មួយជីវិតនេះ បងធ្លាប់បានលួចស្រលាញ់ស្រីម្នាក់...
ហើយគេងប្រាថ្នារង់ចាំនារីម្នាក់នោះ ជាគូជីវិតអស់រយៈពេលជាយូរ ឆ្នាំ ថៃដន្យ កាលណោះ
បងជាបុរសដ៏កំសាកមួយរូប....

CHANBOKEO.COM

វិចិត្រក៏ស្រវាយកសៀវភៅសរសេរមួយក្បាលយ៉ាងក្រាស់ មក
បង្ហាញធិតាយើងហើយស្រដីថា :
- បងបានកត់ត្រារឿងរ៉ាវរបស់បងផ្ទាល់ខ្លួនតាំងពីបងវិលមកដល់
បាត់ដំបងវិញពេលបងប្រលងពេទ្យជាប់ ។ អ្វីៗទាំងអស់ដែលបង បានជួបប្រទះនៅក្នុងជីវិត
រហូតដល់ថ្ងៃយើងបានរៀបការនឹងគ្នា បានចារទុកនៅក្នុងនេះហើយ ។ ពេលនេះ
យើងអានទាំងអស់គ្នា ដើម្បីអោយអូនបានដឹងថា ដំណើរជីវិតរបស់វិចិត្រយ៉ាងណាខ្លះ ?
នៅពេលអានចប់ អូននឹងជ្រះនូវក្តីសង្ស័យទាំងឡាយដែលមាននៅ
ក្នុងជំរៅចិត្តរបស់អូនមិនខាន ។

ធិតានៅសំងំស្ងៀមមិនមានស្រដីអ្វីទេ ។ បន្ទាប់មក វិចិត្រក៏ ចាប់បើកទំព័រឡើយ
អានសាច់រឿងអតិតកាលរបស់គេឡើង ដោយ សំនៀងយ៉ាងស្រទន់
ហាក់បីដូចជាកំពុងលួងលោមគូស្នេហ៍ឲ្យ
រំងាប់នូវភាពពុះកញ្ជ្រោលដែលកំពុងឆុតរោលបេះដូងរបស់នាង...

oooooooooooooooo

ooooo

o

CHANBOKEO.COM

# វគ្គទី៩
# ស្នាមញញឹម

ទីក្រុងបាត់ដំបង ឆ្នាំ១៩៥៨...

ម្តាយរបស់វិចិត្របានទទួលអនិច្ចកម្មដោយរោគបេះដូងថ្មីៗនេះ ចំណែកឪពុករបស់វិចិត្រក៏បាក់កម្លាំងចិត្តជាខ្លាំង តាំងពីភរិយារបស់ លោកចែកស្ថានទៅ ។ មិនយូរប៉ុន្មាន លោកក៏លាចាកលោកទៅ ដែរនៅខែបន្ទាប់មក ។ កាលណោះ វិចិត្រទើបតែរៀបចប់ ត្រលប់ មកពីប្រទេសបារាំង ត្រូវចេញធ្វើការនៅឆ្នាំនេះឯង ។ ឯភក្តីគេ រៀនចប់ដំណាលគ្នាដែរ តែខាងវិស្វកម្ម ។ ដោយសាររន្ធត់ចំពោះ ការបាត់បង់របស់អ្នកមានគុណ ភក្តីក្លាយទៅជាយុវជនដែលមាន វិបត្តិផ្លូវចិត្ត ដើរលេងប៉ោឡែ យប់ថ្ងៃលែងមានវិន័យ ហើយក្លាយ ទៅជាមនុស្សឆាប់មួម៉ៅ យកចិត្តខ្លួនឯងជាធំមិនសូវគិតពីអារម្មណ៍ របស់នរណាឡើយ ។ គេដើរលេងចាយវាយស្រេចតែអំពើចិត្តត្បិត ទ្រព្យសម្បត្តិដែលឪពុកម្តាយទុកអោយគេទាំងពីរ មានចំនួនយ៉ាង មហាសាល ។ ភក្តីជាមនុស្សមានរូបសង្ហាតែក្រអឺតក្រទមបន្តិច ។ លុះគេមកប្រទះនឹងមរណភាពទាន់ហន់ របស់ឪពុកម្តាយគេទាំងពីរ គេក៏រឹតតែផ្លាស់ប្តូរចរិត ទៅជាក្រអឺតក្រទមឆ្មើងឆ្មៃលើសដើមតែ ម្តង ។ ភក្តីជាមនុស្សដើរលេង មានមិត្តភក្តិច្រើនរាប់មិនអស់ទេ ផ្ទុយស្រឡះពីវិចិត្របងប្រុសរបស់គេ ដែលជាមនុស្សស្ងៀមស្ងាត់ មិនសូវចេញដើរហើរទៅណាទេ ហើយក៏មិនសូវសំបូរមិត្តដែរ ។ គេជាមនុស្សខ្វះមាត់ខ្វះក ទទួលរន្ធត់តក់ស្លុតនឹងមរណភាពរបស់ ម្តាយឪពុកគេទៀត គេក៏ក្លាយទៅជាមនុស្សអង្គុយភ្លឹក ដើរភ្លឹក មិន សូវមានវិញ្ញាណជាប់ខ្លួនប៉ុន្មានទេ ។

កាលពី៧ឆ្នាំមុន ពេលគេបញ្ចប់មធ្យមសិក្សា ឪពុកម្តាយរបស់ គេ បានចាប់វិចិត្រភ្ជាប់ពាក្យជាមួយនារីម្នាក់ឈ្មោះលិនដា ដែលជា

CHANBOKEO.COM

កូនស្រីរបស់សាច់ញាតិឆ្ងាយម្នាក់ ។ វិចិត្រធ្លាប់ឃើញលិនដាតាំងពី តូច ហើយធ្លាប់ទៅមកនឹងគ្នាយ៉ាងស្និទ្ធស្នាល តែគេសម្លឹងនាងត្រឹម តែជាប្អូនស្រីប៉ុណ្ណោះ ។ កាលណោះ នាងនៅរៀនមិនទាន់ប្រលង ឌីប្លូមផង ។ ថៃដន្យ ចាស់ទុំត្រូវរ៉ូវគ្នា ចាប់គេទាំងពីរផ្គូផ្គងឡើង ហើយសំរេចថានឹងរៀបការគេទាំងពីរជាគូស្វាមីភរិយានៅពេលណា ដែលវិចិត្ររៀនចប់ ។ ដោយហេតុថាគេស្រលាញ់លិនដាត្រឹមតែជា ប្អូនស្រីប៉ុណ្ណោះ វិចិត្រក៏គេចខ្លួនទៅសំងំរៀននៅប្រទេសបារាំង ហើយមិនដែលអើតមុខមកផ្ទះម្តងណាឡើយ ត្បិតគេខ្លាចចាស់ៗ ចាប់រូបគេអោយរៀបការ ។ វិចិត្រប្រឹងតែរៀនសូត្រម្យ៉ាងគត់ មិន សូវដើរលេងវឹកវរដូចប្អូនប្រុសរបស់គេទេ ។ ដោយសារហេតុនោះ ហើយទើបចាស់ៗ ចាប់បញ្ជូនភក្តីអោយទៅនៅរៀនបារាំងដែរ ដើម្បីអោយវិចិត្រជួយណែនាំគេ ។ នៅពេលដែលគេទាំងពីររៀន ចប់រួចហើយនោះ គេក៏គិតគ្នាថា នឹងមកលេងស្រុកកំណើតម្តង ស្រាប់តែ គេបានទទួលតេលេក្រាមមកថា ម្តាយរបស់គេបានចែក ឋានទៅហើយ ។ ដោយហេតុនោះហើយទើបពេលវេលាកំណត់ថ្ងៃ រៀបអាពាហ៍ពិពាហ៍រវាងលិនដានិងវិចិត្រ ក៏ត្រូវលើកទៅពេល ក្រោយទៀត ។ ថៃដន្យឪពុករបស់វិចិត្រក៏ធ្វើមរណកាលទៀតនៅ ខែបន្ទាប់មក ហើយអ្វីៗដែលគ្រោងទុក ក៏ត្រូវស្ទះផ្លូវទាំងអស់ ។

ក្រោយមក វិចិត្រក៏បានចូលធ្វើការនៅពេទ្យធំបាត់ដំបង ក្នុង ឱកាសដែលភក្តីដើរលេងដកដង្ហើមចោលឥតប្រយោជន៍ ។

ថ្ងៃមួយ...

- បងវិចិត្រ !
- អូហ៍ លិនដា !  សុខសប្បាយទេ ? ទៅណាមកណាហ្នឹង ?
- គឺមកបបួលបងទៅដើរលេង...
- ចាំបាច់ដើរទៅណា ? នៅមាត់ស្ទឹងសង្កែមុខផ្ទះបង ទេសភាព ស្រស់ស្អាតសឹងអី ។
- ស្លាប់ហើយ..ស្អែកនេះជាថ្ងៃចូលឆ្នាំខ្មែរ... គេដើរលេងគ្រប់គ្នា យើងនាំគ្នាទៅដើរលេងនឹងគេម្តងទៅណ៎ា...ណ៎ា
- អត់ទេហ៍... អូនទៅបបួលភក្តីទៅមើល៍..ក្រែងគេទៅជាមួយអូន ព្រោះគេជាមនុស្សចូលចិត្តដើរលេងស្រាប់ ។
- តែអូនចង់ទៅជាមួយបង...ព្រោះយើងជា....

CHANBOKEO.COM

- តែ...បងបែកពីស្រុកយូរឆ្នាំហើយ... បងមិនមានស្គាល់មិត្តភក្តិឯ ណាសោះ តើអោយទៅលេងឯណាសប្បាយកើតទៅ ?

- ទៅភ្នំសំពៅ ទៅសេកសក ពេជចិន្តា ទៅបាណន់ ទៅវត្តឯកភ្នំ ទៅដូនទាវ..យី...មិនខ្វះកន្លែងដើរទេណា៎បង អោយតែចាចង់ដើរ... ហើយក៏មិនចាំបាច់មានមិត្តភក្តិដែរ ព្រោះលិនដាទៅកំដរបងហើយ នោះអី...

ដោយធុញនឹងការទទូចរបស់ឆវី វិចិត្រក៏សំរេចចិត្ត :

- ចុះដើរលេងជិតៗផ្ទះយើងនេះមិនបានទេ ? បើត្រឹមវត្តកណ្តាល អី...បងជូនអូនទៅចុះ...

ការពិត នរៈគេកំពុងតប់ប្រមល់មិនសប្បាយចិត្តសោះ តាំងពី ឪពុកម្តាយគេអនិច្ចកម្មទៅ ។ អ្វីៗហាក់ដូចជាអស់ជីវិតទៅតាម លោកទាំងពីរទៅហើយ ។ តែវិចិត្រមិនហ៊ានបង្ហាញនូវភាពសោក សៅរបស់គេអោយនារីបានឃើញទេ ។ គេធ្វើឫកធម្មតាៗ ។

- អញ្ចឹងក៏បានដែរ...ហោចណាស់ យើងមានពេលជាមួយគ្នាខ្លះ ព្រោះលិនដានឹកបងណាស់ យើងបែកគ្នាជាង៧ឆ្នាំ លិនដាចាំមើល ផ្លូវបងយូរអើយសែនយូរ នឹកបងអើយសែននឹក ។

ការពិតលិនដាស្រលាញ់វិចិត្រណាស់ ព្រោះគេស្លូតបូត គ្រាន់ តែគេមានឫកពារបៀបមនុស្សចាស់ជាងវ័យរបស់គេបន្តិច ហើយ មិនចូលចិត្តចូលក្នុងរង្វង់ចំណោមមនុស្សអ៊ូអរប៉ុន្មានឡើយ ។

ស្អែកឡើង គេក៏នាំគ្នាទៅលេងបុណ្យចូលឆ្នាំ នៅវត្តកណ្តាល ដែលនៅមិនឆ្ងាយពីផ្ទះមាណពប៉ុន្មានទេ ។ លុះទៅដល់បរិវេណវត្ត ស្រាប់តែលិនដាបានជួបនឹងមិត្តភក្តិស្គាល់គ្នាជាច្រើននាក់ ដែលនាំ គ្នាមកលេងបុណ្យយ៉ាងអ៊ូអរ ។ លុះឃើញភាពខ្មៀវខ្វារបស់ហ្វូង មនុស្សដែលមានវ័យក្មេងៗជាងខ្លួនច្រើនពេក វិចិត្រនឹករអៀស ខ្លួនយ៉ាងណាមិនដឹង ព្រោះគេគិតថាខ្លួនគេចាស់បន្តិចសំរាប់មកចូល រួមសង្គមគេថ្ងៃនោះ ។ នរៈក៏បណ្តោយអោយលិនដាចេញទៅលេង ល្បែងប្រជាប្រិយ៍ផ្សេងៗជាមួយមិត្តភក្តិ ហើយក៏គេចខ្លួនទៅអង្គុយ ក្បែរតូបមួយដែលចងអីវ៉ាន់លក់រណិងរណោង ។ នៅលើរានតូច មួយក្បែរនោះ មានគេលក់កូនសៀវភៅកំប៉ិកកំប៉ុកដូចជាសៀវភៅ ច្បាប់ក្រមង៉ុយ ច្បាប់ប្រុស ច្បាប់ស្រី សៀវភៅរឿងខ្លីៗ និងក្បួន ទស្សន៍ទាយជាដើម ។ មាណពយើងក៏ទិញមួយក្បាលអានយកមក កំសាន្តលេង ។

នៅក្រោមដើមជ្រៃក្រឹម ក្បែររានលក់ទឹកអំពៅ វិចិត្រអង្គុយ

CHANBOKEO.COM

អានសៀវភៅទស្សន៍ទាយរាសីនិងគូព្រេងមួយក្បាល ។ គេក៏បើក ទំព័រមើលលេងៗ ស្រាប់តែឮសំដីមនុស្សស្រីពីរនាក់ជជែកគ្នានៅ ពីក្រោយខ្នងមាណពថា :

- បងចរណៃ! ម៉េចប្រញាប់ចង់ទៅផ្ទះម្ល៉េះបង ?
- គឺបងចង់ទៅផ្ទះសំរាកអានសៀវភៅជាជាង... ព្រោះឃើញភាព អ៊ូអរដូច្នេះ បងដូចជាវិលមុខណាស់ ។
- អញ្ចឹង បងសំរាកពិសារទឹកត្រជាក់អីខ្លះទៅ... ចំណានចង់នៅ លេងបុណ្យនឹងគេសិន! បងកុំទាន់អាលចង់ទៅផ្ទះធ្វើអី នៅកំដរ ប្អូនសិនទៅណ៎ាបង ចាំរសៀលបន្តិច ចាំយើងទៅផ្ទះ!
- អឺហ៍.. បើអូនចង់នៅលេង ក៏នៅចុះ បងអង្គុយចាំប្អូនទីនេះ ។

នារីឈ្មោះចំណានក៏ដើរចេញទៅ ។ ចំណែកនារីឈ្មោះចរណៃ ជាបងក៏ដើរទៅទិញសៀវភៅយកមកអានលេង កំដរពេលវេលា ។ បន្ទាប់មក នាងក៏ដាក់ខ្លួនអង្គុយនៅលើកៅអីថ្មមួយ នៅមិនឆ្ងាយពី កន្លែងដែលវិចិត្រអង្គុយប៉ុន្មានទេ ។ មិនដឹងជាយ៉ាងម៉េចទេ គ្រាន់ តែឮសំដីរបស់នារីទាំងពីរជជែកគ្នាភ្លាម ស្រាប់តែមាណពយើងនេះ ហាក់ដូចជាចាប់អារម្មណ៍តែម្តង ។ គេក៏លួចបែរចោលកន្ទុយភ្នែក សម្លឹងមើលទៅនារីដែលឈ្មោះចរណៃនោះ ថែមទាំងគិតថា :

- ហេតុអ្វីនាងមានអត្តចរិតដូចខ្ញុំម្ល៉េះ ? គេមិនចូលចិត្តអ៊ូអរ ហើយ គេចូលចិត្តអានសៀវភៅ ។ តើមាណវីជានរណាដែរ ?

លុះនាយចោលកន្ទុយភ្នែកទៅម្តងទៀត ស្រាប់តែភ្ញាក់ព្រើត ភើតស្រឹតដល់បាតពោះ ដោយសារតែឃើញសោភណ័របស់នាង ។ បេះដូងរបស់គេក៏រណ្តំឡើងយ៉ាងរន្ថើនតែម្តង កាលបើគេបានយល់ ឆវីមួយរូបមានកេសាវែងអន្លាយ សម្បុរសជ្រះ ហើយមានការស្លៀកពាក់សុភាពៗសមជានារីខ្មែរឥតទាស់ ។ ដែលចម្លែកណាស់ ទៅទៀតនោះគឺ នាងក៏កំពុងអានសៀវភៅទស្សន៍ទាយរាសីនឹង គូព្រេងដូចគ្នានឹងរបស់មាណពយើងដែរ ។

- ប្លែកណាស់! ហេតុអីក៏ជួនគ្នាចៃដន្យម្ល៉េះ ? (នរ:គិតក្នុងចិត្ត)

បន្តិចមក វិចិត្រក៏ធ្វើពើជាទៅទិញទឹកអំពៅមកអង្គុយបរិភោគ ហើយក៏បន្លំមករកកន្លែងអង្គុយក្បែររូបនាង នៅជាយម្ខាងទៀតនៃ កៅអីថ្មតែមួយដែលឆវីកំពុងអង្គុយ ហើយញញឹមដាក់នាងភ្លាម :

- អត់ទោស! ខ្ញុំសុំអង្គុយខាងនេះ បានទេអ្នកនាង ?

វិចិត្រសួរចរណៃ ។ ធិតាងើបមុខឡើងសម្លឹងមុខមាណពហើយ ញញឹមតបវិញថា :

CHANBOKEO.COM

- ចាស! ចាស! សូមអញ្ជើញ!

រួចហើយនាងក៏ខិតខ្លួនទៅចុងជាយម្ខាង ទុកអោយមាណពនៅ អង្គុយនៅជាយម្ខាងទៀត ។ ពុទ្ធោអើយ នាងញញឹមស្រស់ស្អាតអ្វី ម៉្លេះ! ថ្ពាល់ខួចទាំងគូរបស់នាង បានខាបយកបេះដូងនរៈយើងទៅ បាត់រូបនៅវិនាទីនោះភ្លាមតែម្តង ។ គេលួចចោលកន្ទុយភ្នែកគយ គន់សម្ផស្សរបស់នាងយ៉ាងភ្លន់ភ្លឹកស្មារតីតែម្នាក់ឯង ។ ចៃដន្យ ធិតាមិនបានចាប់អារម្មណ៍លើមាណព យើងដែលនៅអង្គុយក្បែរៗ នាងនោះទេ ។ រំពេចនោះស្រាប់តែមានស្ត្រីចំណាស់ម្នាក់មកដាក់ ខ្លួនអង្គុយលើកៅអីថ្ម ចំចន្លោះកណ្តាលរវាងអ្នកទាំងពីរ ធ្វើអោយ បុរសយើងខកចិត្តអស់មួយសន្ទុះធំ ព្រោះខ្លួនស្ត្រីនោះធំ បាំងអស់ មិនអាចអោយគេលួចគយគន់នារីបាន ។ មួយស្របក់មកទើបគាត់ ដើបឡើងដើរចេញទៅ ។ ថ្ងៃនោះ មាណពលួចសម្លឹងគយគន់ធិតា ឡើងបែកញើសស្និតជោគខ្លួនតែម្នាក់ឯង ទាំងរន្ធត់ញាប់ញ័រដោយ ដួងចិត្តប្រតិពទ្ធ័យ៉ាងមហិមា :

- នេះ ខ្លួនយើងឆ្កួតទេដឹង ? យើងមានដែលស្គាល់នាងឯណា ? ម៉េ្តចក៏យើងចាប់អារម្មណ៍លើរូបធិតាមួយរូបនោះខ្លាំងដល់ម្លឹង ?

វិចិត្រសួរខ្លួនឯងមិនអស់មិនហើយ ។ យូរៗម្តង គេឃើញ នាងដើបមុខសំលឹងតាមដានប្អូនស្រី ដែលចូលលេងអង្គុញជាមួយ ហ្វូងមិត្តរបស់នាងយ៉ាងសប្បាយ ។ ជូនកាល នាងក៏ធ្វើមុខស្មើៗ ធម្មតា ជួនកាលក៏ញញឹមរីករាយ ពេលដែលនាងឃើញភាពកំប្លុក កំប្លែងរបស់ប្អូនស្រី ។ បេះដូងរបស់គេហាក់ដូចជារំភើបនឹងស្នាម ញញឹមលើផ្ទៃមុខរបស់ធិតាណាស់ ។ ពេលនាងញញឹមបញ្ចេញថ្ពាល់ ខួចម្តងៗ បេដូងគេរណ្តំចង្វាក់យ៉ាងប្លែក ធ្វើអោយគេក្តៅមុខក្តៅ មាត់ដោយឯកឯង រកថាមិនត្រូវ ។

ពីរម៉ោងកន្លងទៅ...

ចំណានក៏ត្រលប់មកវិញ :

- បងណែឃ្លានពិសារអ្វីទេ ចាំខ្ញុំទៅទិញយកមកជូន ។
- អត់ទេ! ប្អូនទៅដើរលេងទៀតចុះ ។ កាលណាបងឃ្លាន បង នឹងទៅរកទិញញាំខ្លួនឯង ។
- អញ្ចឹង ខ្ញុំទៅវិញសិនហើយណា៎ បន្តិចទៀតប្អូនមកវិញ ។

CHIANBOKEO.COM

ចំណានក៏ដើរចេញទៅ ។ ចរណៃក៏ទុកសៀវភៅចោល លើ កៅអីថ្ម ហើយដើរទៅទិញចំណីបរិភោគ ។ ឃើញដូច្នេះ វិចិត្រក៏ ថ្មីម្នាសរសេរកំណាព្យខ្លីមួយ លើកម្រមខាងក្នុងសៀវភៅរបស់គេ មានសេចក្ដីថា :

ពេលបានជួបភក្ដ្រ័ជំពាក់ចិត្ត   បើនិស្ស័យពិតសូមជាគូ
ទោះមានឧបសគ្គក៏តស៊ូ   ជីវិតបងប្ដូរដើម្បីអូន...
ស្រលាញ់អូនតែម្នាក់!

រួចហើយក៏ស៊ីញេដាក់ថ្ងៃខែកត់ចំណាំ បន្ទាប់មក នរៈក៏លួច យកសៀវភៅទៅប្ដូរគ្នាជាមួយនឹងរបស់មាណវី ដែលទុកចោលនៅ លើកៅអីថ្មនោះ រួចហើយគេក៏អង្គុយធ្វើកិរិយាធម្មតាៗ ហាក់បីដូច ជាមិនដឹងអ្វីសោះឡើយ ។ នៅថ្ងៃនេះ លិនដាក៏បាត់ខ្លួនទៅជាមួយ ហ្វូងពួកម៉ាករ័យស្រករនាង មិនឃើញមករវីរវល់នឹងវិចិត្រសោះ ធ្វើអោយនាយយើងសប្បាយចិត្តមិនតិចទេ ដែលគេមានឱកាសលួច គយគន់សោភណ័នារីម្នាក់យ៉ាងអស់ចិត្តអស់ចង់ ។

រសៀលបន្តិច ចំណានក៏ត្រលប់មកដល់វិញ :

- ខ្ញុំហត់អស់កម្លាំងហើយបងណៃ! តោះទៅផ្ទះ ។

ចរណៃញញឹម ហើយក្រោកឈរឡើង ដឹកដៃប្អូនស្រីនាំគ្នាដើរ ចេញទៅ ។ វិចិត្របែរមើលតាមត្បិតមិនទាន់បានលួចមើលគេអស់ ចិត្តនៅឡើយ ។ ភ្លាមនោះ គេក៏ដើបឡើងដើរតាមពីក្រោយមិនឲ្យ នារីទាំងពីររូបនោះដឹងខ្លួនចាប់សង្ស័យ ។ មាណវីទាំងពីររូបដើរ បណ្ដើរជជែកគ្នាបណ្ដើរយ៉ាងស្និទស្នាលរីករាយ រហូតទាល់តែគេ បានមកដល់ផ្ទះថ្មតូចល្មមមួយនៅម្ដុំស្ងួនយុវវ័ន ដែលមានដាំដើម ចំប៉ាពីរដើមនៅពីមុខផ្ទះ ។ វិចិត្រឈរមើលគេពីចម្ងាយ យ៉ាងភ្លន់ ភ្លឹកតែម្នាក់ឯង ។ ទោះបីជានារីទាំងពីរបានចូលបាត់ស្រមោលទៅ ក្នុងផ្ទះរបស់គេហើយក៏ដោយ ក៏គេនៅតែរ៉េរ៉ៃមិនចង់ទៅណាសោះ ប្រៀបហាក់ដូចមានអ្វីមួយខាបព្រលឹងនាយ មិនអោយដើរចេញ ពីទីនោះបន្តិចណាសោះឡើយ ។

- បងចិត្រ នេះយប់ហើយណា៎! ទើបមកពីណា៎ បានថ្មើរណោះទើប មកដល់ផ្ទះវិញ ? នឹងទេចាលិនដាដើររកបងពេញវត្តឯណោះ ថែម ទាំងពឹងពួកម៉ាកអោយជួយជូនមកផ្ទះវិញផង ព្រោះខ្ញុំរកបងមិន ឃើញ ។

លិនដាស្ទុះមកទទួលវិចិត្រដែលទើបតែដើរមកដល់ផ្ទះវិញ ។ ក្រលេកឃើញវត្តមានធិតា
វិចិត្រសួរថា :

- ហើយចុះអូនម៉េចមិនត្រលប់ទៅផ្ទះ ? តិចប៉ាម៉ាក់ចាំផ្លូវទៅ!
- គឺលិនដាចាំបង អោយបងជូនទៅនោះអី ?
- ហើយចុះពីព្រលប់ ម៉េចមិនអោយមិត្តរបស់អូនជូនទៅតែម្តង ?
- គឺលិនដាខ្វល់ខ្វាយពីបង ទើបមកទីនេះ! ម៉េចបានបងធ្វើកិរិយា ដូចជាអន់ចិត្តនឹងអូនម្លេះ ?

វិចិត្រមិនឆ្លើយទេ បែរជាដើរឡើងទៅលើផ្ទះធ្វើព្រងើយ ។

- បងចិត្រ! (លិនដាស្រែកហៅ) ជូនអូនទៅផ្ទះសិន!

វិចិត្រឮហើយ ក៏ក្អកហៅពូខេម :

- ពូខេម! ទំនេរទេ ? សូមពូជួយជូនលិនដាទៅផ្ទះផង!
- បាទ (ពូខេមរត់ចេញមកទទួលពាក្យ)

វិចិត្រក៏ដើរឡើងទៅលើផ្ទះធ្វើមិនដឹង មិនទាំងលាលិនដាផង...
ឆវីឈរមើលតាមនាយពីក្រោយ សំដែងទឹកមុខហាក់ដូចជាខកចិត្ត ក្រៃលែង ។

នៅក្នុងបន្ទប់គេង...

វិចិត្រអង្គុយគូររូបនារីក្មេងម្នាក់ ញញឹមថ្គាល់ខ្លួច ម្តងហើយម្តង ទៀតមិនអស់មិនហើយ ។
នៅទីបំផុតគេក៏ចាប់ប៉ាកកាកត់សាវតារ ប្រចាំថ្ងៃរបស់គេទុកក្នុងសំណៅ ។ បន្ទាប់មក
គេក៏លើករូបមនុស្ស ស្រីក្មេងនោះយកថើបយ៉ាងយូរ ទើបបិទភ្លើងចូលនិទ្រា ។

រៀងរាល់ថ្ងៃ ចាប់តាំងពីថ្ងៃនោះមក គេតែងតែបររថយន្តទៅ ចតនៅសួនយុវវន័
ដើរលេងក្រវែលៗម្តុំនោះ ដើម្បីលួចមើលនារី ដែលគេលួចចាប់ចិត្តប្រតិពទ្ធ័ ថ្វីបើគេមិនដឹងថា
ត្រូវធ្វើយ៉ាងណា ទៀតដើម្បីអោយបានស្គាល់គ្នាជាមួយរូបនាងជិតដិត ។ ត្រូវនឹងរូប
គេជាមនុស្សមិនសូវជាអ្នករួសរាយ បានមាត់បានកផងថែមទៀត ផងនោះ
គេក៏ត្រូវទាល់ច្រកសុញគំនិត បានត្រឹមតែលួចឈរសម្លឹង
ធិតាពីចម្ងាយ ហើយលួចទំរើបចិត្តម្នាក់ឯង...តែប៉ុណ្ណោះ ។

ថ្ងៃមួយ...

វិចិត្រនៅអង្គុយក្រោមដើមក្ត្រោក បរិភោគទឹកកកឈូស បន្លំ ខ្លួនជាមួយហ្វូងអ្នកស្រុក
ដែលចរទៅមកម្តុំៗសួនយុវ័នទិញនំចំណី ដែលគេលក់ទីនោះរៀងរាល់ថ្ងៃជាប្រចាំ
មានតាំងពីចេកអាំង ទឹក កក អំពៅសាង បង្អែម ជាដើម ដើម្បីលួចមើលនារីម្ចាស់បេះដូង

CHANBOKEO.COM

របស់គេ ។ រំពេចនោះ នរៈបានឃើញភក្តី ព្រមទាំងមិត្តប្អូនដប់
នាក់ទៀតបានមកដល់ហើយក៏នាំគ្នាដើរចូលទៅក្នុងផ្ទះរបស់មាលាទី
ដែលគេកំពុងចាប់អារម្មណ៍នោះ :
- ភក្តីស្គាល់នាងក្រមុំផ្ទះនេះដែរ ? តើគេជាមិត្តរបស់នារីមួយណា ក្នុងចំណោមធិតាពីរនាក់នេះ ? ថ្ងៃនេះ គេមានធ្វើពិធីជប់លៀងអ្វី មែនទេ ?

រំពេចនោះ បេះដូងគេក៏រណ្តំភិបៗឡើង ហើយអារម្មណ៍របស់
គេក៏អណ្តែតរាយមាយគិតស្រម៉ៃយបន់ស្រន់ថា :
- ឱព្រះអើយ! សូមអោយភក្តីជាមិត្តរបស់នារីជាប្អូនស្រីរបស់នាង ចុះ ។
សូមកុំអោយខ្ញុំធ្លាក់ខ្លួនលួចប្រតិពទ្ធ័ ប៉ះចំនារីដែលជា សង្សាររបស់ប្អូនប្រុសខ្ញុំអី...!

មាលាពលយរបន់ព្រះទាំងបេះដូងញាប់ញ័រ ព្រួយផងភ័យផងតែ
ម្នាក់ឯងរហូតបែកញើសជោគខ្លាស ។ ដោយនឹកពិភាល់ក្នុងចិត្ត ពេក
គេក៏តាំងចិត្តក្លាហានដើរឆ្លងថ្នល់ទៅឈរនៅក្បែររបងផ្ទះខាង
ក្រៅហើយលួចចោលកន្ទុយភ្នែកទៅខាងក្នុងផ្ទះ ដើម្បីលបមើល ស្ថានការណ៍
ស្រាប់តែថៃងន្យក៏ទង្គិចគ្នានឹងមាលាទីដែលជាបងស្រី កំពុងដើរចេញមកក្រៅ
ដោយមានកាន់សៀវភៅមួយក្បាលមកជា មួយផង ។
វិចិត្រភ្ញាក់ក្រញាងស្ទើរគាំងបេះដូងកាលបើនាងដើរ ឈ្ងោកៗមកបុកគេចំកណ្តាលទ្រូង
ហើយនារីនោះក៏មិនមែននរណា ផ្សេងក្រៅពីនារីដែលខាបយកបេះដូងរបស់គេនោះទៅដែរ ។
ធិតា ក៏ភ្ញាក់ក្រញាងដូចគ្នា តែមើលទៅនាងហាក់ដូចជាភ្ញាក់ផ្អើលហើយ អៀនខ្មាសណាស់
ដែលសុខៗនាងដើរមកទង្គិចទ្រូងបុរសដូច្នោះ ។
ពេលនោះ នាងប្រឹងញញឹមសំដែងការគួរសម តែមិនហ៊ានងើប មើលមុខវិចិត្រទេ ។ បន្ទាប់មក
នាងក៏លើកដៃសំពះ ហើយស្រដី ទៅមាលាពថា :
- សូមទោស! សូមទោសចាស!

រួចហើយ មាលាទីក៏ឈ្ងោកមុខ ដើរឆ្លងថ្នល់សំដៅស្ទួនយុវន័
យ៉ាងរហ័សទំនងគេចមុខដោយខ្មាសអៀនដែលនាងដើរទង្គិចបុរស ចំដើមទ្រូងរបស់គេ ។
វិចិត្រលើកដៃឡើងសំពះទទួលវិញ ហើយ ក៏សម្លឹងតាមនាងពីក្រោយយ៉ាងភ្លន់ភ្លឹក!
នៅពេលនោះ គេមាន អារម្មណ៍រំភើបចិត្ត ព្រឺព្រួចនៅក្នុងខ្លួនយ៉ាងណាមិនដឹងទេ សប្បាយ
ផងរំភើបផង ព្រោះគេបានដឹងថា នាងមិនមែនជាសមាជិកនៅក្នុង

ក្រុមរបស់ភក្តីដែលមកជប់លៀងនៅផ្ទះមួយនោះ ។ មាណវីបែរជា
មកអង្គុយអានសៀវភៅតែម្នាក់ឯង នៅក្រោមដើមចំប៉ាក្នុងសួន យុវ័នធ្វើមិនដឹងទៅវិញ ។
គេឈរផ្អែកនឹងរថយន្តរបស់គេដែល ចតនៅក្រោមដើមចន្ទរីមុខផ្ទះរបស់ធិតា ។
ចរណៃអង្គុយអានយ៉ាង ស្ងៀមស្ងាត់ ។ យូរៗម្តង គេបានឃើញនាងលួចចោលកន្ទុយភ្នែក
មករកគេវិញ ។ មាណពត្រេកអរភើត ខំញញឹមតបវិញ ស្រាប់តែ
នាងគេចមុខពីគេទៅវិញយ៉ាងរហ័ស ធ្វើអោយនាយខកចិត្តស្រឹត ទៅវិញ ។
ធិតាបានធ្វើដូច្នោះជាញយដង ។ ឯវិចិត្រវិញ ក៏រំភើប
ភើតពោះ ភ័យអរៗជាច្រើនដងដូចគ្នាដែរ ។

- តើនាងកំពុងតែចាប់អារម្មណ៍លើរូបខ្ញុំដែរឬយ៉ាងណា ?

វិចិត្រឈ្លេចសួរខ្លួនឯងម្តងហើយម្តងទៀត ។

រសៀលបន្តិចនាងក៏ដើបដើរចូលផ្ទះវិញ ចៃដន្យនាងដាក់ភ្នែក
មករកវិចិត្រដែលឈរក្បែររថយន្ត ។ មាណពឃើញហើយខំញញឹម ដាក់នាងភ្លាម
ស្រាប់តែនាងឈ្ងោកគេចមុខដើរចូលទៅក្នុងផ្ទះយ៉ាង លឿនតែម្តង
ធ្វើអោយវិចិត្រនឹកខកចិត្តស្រលេតទៀតហើយ ព្រោះ
គេមិនបានទទួលការញញឹមតបពីចរណៃវិញ ។ ប៉ុន្តែគេមិនព្រម
បោះបង់ការព្យាយាមរបស់គេទេ ។ គេនៅតែលបលួចតាមមើលនារី
តាមចន្លោះចម្រឹងដែករបងដោយឥតព្រិចភ្នែក ស្រាប់តែគេប្រទះ
ឃើញនាងលួចចោលភ្នែកលបមើលនាយវិញដល់ទៅពីរបីដងតាម ចំហៀងផ្ទះ ។
វិចិត្រលេបទឹកមាត់ក្អឹក បំបាត់អារម្មណ៍រំជើបរំជួល ក្នុងបេះដូង... ភ័យផងអរផង យ៉ាងចម្លែក ។

នៅរាត្រីនោះ វិចិត្រចុះដើរទៅមាត់ស្ទឹងសង្កែ សំលឹងខ្សែទឹក ហូរតែម្នាក់ឯង
ក្នុងចិត្តនឹកមមៃទៅដល់ធិតាឥតឈប់ឈរសោះ ។ ថ្វីបើគេមិនទាន់បានជួបសំដីធិតា
ប្រស្រ័យគ្នាជាមិត្តជិតដិត ប៉ុន្តែគេ
មានអារម្មណ៍ថាខ្លួនគេបានធ្លាក់ទៅក្នុងសំណាញ់ស្នេហាមួយដែលគេ មិនអាចរើបំរះចេញបាន ។
គេនឹកចរណៃណាស់ នឹកគ្មានរសាយពី ដួងចិត្តបន្តិចណាសោះ ។
ថ្ងៃណាក៏គេលួចទៅលបមើលនាងដែរ ប៉ុន្តែគេខ្វះសេចក្តីក្លាហាននឹងរកមធ្យោបាយ
ថាគួរធ្វើយ៉ាងណា ដើម្បីអោយបានទៅជិតដិតនឹងរូបនាង សាងសម្ពន្ធ័ភាពជាមិត្ត រួច
ហើយជាសង្សារ... រួចក៏...កាន់តែឆ្ងាយទៅទៀត....

CHANBOKEO.COM

យូរថ្ងៃកន្លងទៅ...

វិចិត្របររថយន្តចេញពីធ្វើការតាមផ្លូវលេខមួយ បណ្ដោយមាត់ស្ទឹងសង្កែ ស្រាប់តែប្រទះឃើញភក្តីឈរនិយាយគ្នាជាមួយចរណៃ តាមដងផ្លូវជិតអាងនាគព្រួសទឹក មុខមន្ទីរឃោសនាកា រួចហើយក៏ ឃើញនាងដើរគេចចេញទៅ មិនដឹងថាភក្តីបាននិយាយអ្វីជាមួយ ចរណៃទេ មើលទៅប្រហែលជាភក្តីបបួលចរណៃជិះរថយន្តហើយ តែនាងមិនព្រម ។ វិចិត្រក៏បើករថយន្តនឹង យកទៅចតផ្ញើក្នុង ការិយាល័យសុរិយោដី ហើយក៏ដើរវាងផ្លូវយ៉ាងលឿន ទៅរង់ចាំ ស្កាត់ដំណើរចរណៃនៅខាងមុខការិយាល័យឧបនាយកយោធិន ម្ខាង ផ្លូវពីសាលាខេត្ត ។ ថ្ងៃដន្យ ពេលនោះ គេបានឃើញភក្តីចាប់កដៃ នាង តែចរណៃបម្រះរួចហើយក៏រត់ចេញលឿនស្ទើរទាំងភិតភ័យ មិនបានមើលមុខមើលក្រោយទេ ។ គេក៏យកខ្លួនទៅបាំងផ្លូវនាង ភ្លាម ។ ពេលនោះ និតាក៏រត់មកដល់ដើមទ្រូងរបស់គេជាលើកទីពីរ តែលើកនេះមិនមែនថៃដន្យទេ គឺវិចិត្រមានបំណងអោយនាងរត់ ទង្គិចទ្រូងនាយតែម្ដង ។ ដោយការភិតភ័យ ចរណៃមិនបានមើល មុខនាយទេ ។ មាណពក៏ចាប់និតាលាក់ក្រោយខ្នង ហើយបែរមុខ ទៅរកភក្តីដែលកំពុងរត់មកដល់ ។ កាលបើក្រលេកឃើញវត្តមាន របស់បងប្រុស ភក្តីភ័យមុខស្លាំងតែម្ដង ដែលបងប្រុសរបស់ខ្លួន មកតាមទាន់ស្ថានការណ៍មួយ ដែលរូបគេកំពុងបង្ខំចិត្តមនុស្សស្រី ទៅតាមទំនើងចិត្តភ្លើតភ្លើនឆៅឆាវរបស់ខ្លួន ។ ភក្តីក៏ឡើងរថយន្ត បរគេចខ្លួនយ៉ាងរហ័ស ត្បិតខ្លាចត្រូវមាត់បងប្រុសនៅចំពោះមុខ មនុស្សស្រី នាំតែអាមាសថែម ។

កាលបើភក្តីចេញទៅបាត់ វិចិត្រក៏បែរទៅលោមនាងថា :

- គេទៅបាត់ហើយ! ឈប់ភ័យទៅ ហើយផ្ទះអ្នកនាង នៅឯណា ដែរ ? បើមិនឆ្ងាយទេ ចាំខ្ញុំដើរតាមពីក្រោយ ជួយរក្សាសុវត្ថិភាព ជូនអ្នកនាងចុះ ។

ចរណៃឈ្ងោកមុខដោយខ្លាចចិត្តផង ដោយខ្មាសផង ដោយតក់ស្លុតចំពោះស្ថានការណ៍អំបាញមិញផង :

- ចាស...ផ្ទះនៅក្បែរសួនយុវ័ន...

មាណវីឆ្លើយតបវិញដោយ មិនព្រមសម្លឹងចំមុខបុរសវិញទេ មិនដឹងហេតុអ្វី ជួបគ្នាច្រើនដងហើយ... នាងមិនព្រមចាប់អារម្មណ៍

CHANBOKEO.COM

នឹងសម្លឹងមុខបុរសយើងអោយចំភ្នែកសោះ ។ វិចិត្រលួចខកចិត្ត តិចៗ ដែលនាងមិនព្រមងើបមើលមុខខ្លួនវិញ នឹងអាលឲ្យនាយ អាចចាប់ផ្ដើម និយាយទាក់ទងប្រស្រ័យនាងជាមិត្ត ។ បន្តិចមក គេក៏ដើរតាមពីក្រោយធិតា ជូននាងរហូតដល់ផ្ទះវិញ ។

គ្រាន់តែសំពះអរគុណវិចិត្រហើយ ធិតាគេចខ្លួនរឹងចូលផ្ទះបាត់ មិនឃើញហៅភ្ញៀវទទួលទឹកតែទឹកត្រជាក់អ្វីបន្តិច ។ វិចិត្រនៅ ទាន់អស់ចិត្តក៏នៅឈរវេរាមួយស្របក់ ស្រាប់តែគេឃើញនាងលួច ពន្លេចមុខចេញពីចំហៀងផ្ទះ លបមើលនាយវិញតាមចន្លោះចង្រឹង ដែករបង ។ កាលបើប្រទះក្រសែភ្នែករបស់នាង វិចិត្រញញឹមតប ភ្លាម ។ ស្រាប់តែនាងពួនមុខបាត់ទៅវិញ បន្តិចមកក៏លួចអើត មើលម្តងទៀតជាថ្មី ។ វិចិត្រឃើញហើយក៏ញញឹមហើយលើកដៃវា ជាសញ្ញាថាគេក៏បានឃើញនាងដែរ ។ ស្រាប់តែចរណៃក៏ធ្វើមុខ ក្រហមងាំង ទំនងអៀនខ្មាសរួចក៏គេចមុខបាត់ទៅវិញ ឈប់លែង អើតមកវិញរហូត ។

យប់នោះ វិចិត្រគេងញញឹមតែម្នាក់ឯង ក្នុងចិត្តនឹកត្រេកអរថា បើតាមមើកកិរិយារបស់នាង ប្រហែលជាឆវីកំពុងចាប់អារម្មណ៍ពី រូបនាយតិចៗខ្លះដែរមិនខាន ។ គេចាប់សៀវភៅកំណត់សាវតារ ប្រចាំថ្ងៃមកសរសេរ រួចហើយក៏គូររូបនាងភ្ជាប់នៅលើសន្លឹកនោះ ផង ។ បន្ទាប់មក គេក៏លើករូបនាងមកថើបយ៉ាងយូរ :

- ឱ ស្នាមញញឹមអើយ ! ហេតុអ្វីអ្នកមានមន្តស្នេហ៍ម្ល៉េះ ? ដឹងទេ ថាស្នាមញញឹមលើថ្ពាល់ខួចទាំងគូនេះ បានខាបយកបេះដូងរបស់ វិចិត្រទៅជាយូរហើយ ? ឱ ម្ចាស់ថ្ពាល់អើយ... តើអ្នកដឹងខ្លួនទេថា មានគេកំពុងលង់ក្នុងមន្តស្នេហ៍ថ្ពាល់ខួចដ៏ស្រស់ស្អាត ?

មាណពទាញយករូបមកមើលជាថ្មី ហើយយកម្រាមដៃរបស់គេ ទៅអង្អែលថ្នមៗលើផែនថ្ពាល់នារីគំនូរ :

- តើខ្ញុំមានវាសនា ត្រឹមតែថៃថើបថ្ពាល់ខួចលើក្រដាសសៀវភៅ ឬក៏អាចមានសំណាងរហូតដល់បានថើបថ្ពាល់ខួច លើរង្វង់ភក្ត្រ័ដ៏ ផូផង់មួយនោះ ? ថ្ងៃណា...ថ្ងៃណា... ខ្ញុំមានវាសនានឹងបានទទួល ស្នាមញញឹមលើថ្ពាល់ខួចជាចម្លើយតបមកដល់ដួងចិត្តប្រតិពទ្ធ័របស់ ខ្ញុំវិញ ?

CHANBOKEO.COM

តើរូបខ្ញុំគួរសាងក្តីសង្ឃឹមឬទេ ? ឱ ផ្កាល់ខ្លួចអើយ... អ្នកមានម្ចាស់ហើយឬនៅ ? បើនៅទេ អោយវិចិត្រសុំបានទេ... សុំខ្លួនជាម្ចាស់លើផ្កាល់ខ្លួចដែលញញឹមស្រស់ស្អាតនេះ ?

មាណពលើកយករូបគំនូរនារី ដែលមានភក្ត្រញញឹមដ៏ស្រស់ស្អាតនោះមកដាក់លើទ្រូងរបស់គេ ហើយលើកដៃអោបអង្អែល ហាក់ដូចជាចង់ប្រាប់នាងថា បេះដូងរបស់គេកំពុងតែប្រគល់ជូន រូបនាងហើយ ។ បន្ទាប់មក គេក៏បិទភ្នែកនិន្ទ្រាទៅដោយដួងចិត្ត ក្រេមក្សាន្តពោរពេញទៅដោយមនោសញ្ចេនារំភើបឥតព្រំដែន ។

OOOOOOOOOOOOOOOOOO

OOOOOO

O

CHANBOKEO . COM

# វគ្គទី១០
# វិបត្តិនៃកាមារម្មណ៍

ពេលវេលាចេះតែកន្លងទៅ...

នៅម៉ោងប្រហែលជាងនយប់... វិចិត្រចេញពីធ្វើការបររថយន្ត មកដល់ផ្ទះវិញ ស្រាប់តែពូខេមរត់មកប្រាប់ថា :

- លោកគ្រូពេទ្យ! អ្នកស្រីផាន់ស៊ី និងអ្នកស្រីលីណាដែលជាម្តាយ របស់លិនដាបានអោយមនុស្សមកជំរាបលោកពេទ្យថា គាត់ចង់ជួប លោកពេទ្យនៅផ្ទះអ្នកស្រីលីណាជាប្រញាប់ ។

- អូហ៍...ហើយគាត់មានប្រាប់ទេថាមានការអ្វីដែរ ?

- បាទ! អត់មានទេ គ្រាន់តែប្រាប់ថាមានការសំខាន់ ។

វិចិត្រក៏បររថយន្តថយក្រោយវិញ ។ ទៅដល់ផ្ទះអ្នកស្រីលីណា នៅម៉ុផ្លូវលេខបី ជិតផ្សារ គេបានជួបទាំងអ្នកស្រីលីណា អ្នកស្រី ផាន់ស៊ី និងលិនដាផង ។

- ជំរាបសួរបាទ! អ្នកមីងមានការអ្វីសំខាន់ជាមួយខ្ញុំមែនទេ ?

- មែនហើយ! (អ្នកស្រីលីណាតប) យើងចង់សំរេចជ្រើសរើស ថ្ងៃមង្គលការរបស់លិនដានិងវិចិត្រឯងឆាប់ៗនេះ ។

ដូចត្រូវរន្ទះបាញ់កណ្តាលថ្ងាស វិចិត្រឮកាលណា ធ្លាក់ថ្លើមក្តុក តែម្តង ។ នរ:ក៏ឆ្លើយវិញយ៉ាងរហ័សថា :

- ប៉ុន្តែ... ខ្ញុំមិនទាន់ត្រៀមខ្លួននៅឡើយទេបាទ!

- មិនបាច់ត្រៀមអីទេ ក្មួយអើយ (អ្នកស្រីផាន់ស៊ីបន្ថែម) ព្រោះ ឯងនិងលិនដាស្គាល់គ្នាជិតដិតស្រាប់ទៅហើយ ។

ភ្លាមនោះ រូបភាពស្នាមញញឹមលើថ្ពាល់ខួចដ៏ស្រស់ស្អាតរបស់ ចរណៃបានហោះកាត់អារម្មណ៍របស់គេភ្លាម ។ វិចិត្រក៏ប្រកែកឡើង ទៅវិញយ៉ាងម៉ឺងម៉ាត់ ថា :

CHANBOKEO . COM

- អត់ទេ! វិចិត្រមិនចង់រៀបការទេ...
- ប្រកែកមិនបានទេ (អ្នកស្រីលីណាស្រដីកាត់) ឯងបណ្តើរលិនដា
ចេញមុខចេញមាត់ក្នុងសង្គមញយដងហើយ... វាមិនល្អមើលទេ
ដែលឯងបណ្តើរគ្នាដោយគ្មានខន្ទ័ស្លានិងការដឹងឮរបស់ចាស់ទុំ ។
- តែនោះខ្ញុំដើរលេងជាមួយនាងក្នុងឋានៈជាសាច់ញាតិទេ មិនបាន
គិតអ្វីផ្សេងផ្តេសផ្តាសឡើយ ។
- តែសង្គមគេមើលមកវាមិនសមរម្យ!
- បើមិនសមរម្យទេ សូមអ្នកមីងឈប់អោយលិនដាទៅមកនឹងខ្ញុំ ទៀតទៅ ។ ការពិត
ខ្ញុំមិនដែលបានមកបបួលនាងដើរលេងម្តង ណាទេ គឺលិនដាតើហ៍
ដែលចេះតែមករំអុកមិនឈប់ឈរ ។
- បងចិត្រ! ម៉េចស្រដីអ្វីយ៉ាងនេះ បងហាក់ដូចជាមិនទុកមុខមាត់ អោយលិនដាសោះ ។
(លិនដាស្រដីឡើង)

វិចិត្រងាកមកលិនដាហើយតបថា :
- ខុសហើយ លិនដា! បងផ្តល់កត្តិយសដល់អូនសព្វយ៉ាង ប៉ុន្តែ ភ្នែកញាតិទេតើ
ដែលមិនផ្តល់កត្តិយសអោយបងនិងលិនដា!
- ទោះជាយ៉ាងណា ក៏ឯងត្រូវតែរៀបការដែរនាយចិត្រ! (អ្នកស្រី ផាន់ស៊ីពោលឡើង)
ព្រោះឪពុកម្តាយឯងបានភ្ជាប់ពាក្យអ្នកទាំងពីរ រួចហើយ
ហើយនោះក៏ជាបំណងរបស់គាត់មុនពេលគាត់ចែកស្ថាន
ទៅដែរ ។ នេះឯងបំរុងធ្វើអោយវិញ្ញាណក្ខន្ធ័ឪពុកម្តាយវិលវល់ផង
ហ្ស៎ស បានជាខំប្រឹងប្រកែកដល់ម្លឹង ?

វិចិត្រឈ្ងោកមុខមួយស្របក់ក៏ឆ្លើយវិញថា :
- អ្នកមីងមិនចង់ឲ្យវិញ្ញាណក្ខន្ធ័របស់ប៉ាម៉ាក់ខ្ញុំវិលវល់... ចុះដែល
មីងបង្ខំខ្ញុំធ្វើតាមរហូតដល់ខ្ញុំមានអារម្មណ៍វិលវល់ដែរនោះ មីងមិន គិតទេ ?
តើអោយខ្ញុំសាងសុភមង្គលយ៉ាងណាបើអារម្មណ៍ខ្ញុំវិលវល់
មិនសប្បាយចិត្តនឹងជីវិតគូស្រករបស់ខ្ញុំ ? តើជីវិតគូស្រកររបស់ខ្ញុំ
នឹងបានទទួលសេចក្តីសុខសេចក្តីរីករាយដែរទេ កាលបើយើងត្រូវ

CHANBOKEO.COM

រៀបការដោយការបង្ខិតបង្ខំនោះ ? ការពិត ខ្ញុំមិនដែលស្រលាញ់ លិនដា... ខ្ញុំមើលនាងត្រឹមជាប្អូនស្រី...មិនអាចរៀបការនាងទេ!

ថាហើយគេក៏ដើររត់ចេញទៅយ៉ាងលឿន រកតែនរណាឃាត់អ្វី ក៏មិនទាន់ដែរ ។ វិលវល់ចិត្តពេក វិចិត្រក៏ចូលរង្គសាល ផឹកស្រា បន្លប់អារម្មណ៍ហ្មូហ្មង ។ លុះស្រវឹងខ្លាំងទៅទៀតលែងរួច ព្រោះ គេមិនដែលផឹកពីមុនមក គេក៏គេចខ្លួនត្រលប់ទៅផ្ទះវិញ ។

គេបររថយន្តលើផ្លូវលេខមួយ កាត់តាមគ្លិនិករបស់នាយ ដែលទើបនឹងបើកថ្មីៗមិនបានប៉ុន្មានខែផង ។ ភ្លាមនោះ ស្រាប់តែគេ ចាប់ភ្លឹកថា នៅខាងក្នុងគ្លីនិកមានបើកភ្លើងភ្លឺៗ តែទ្វារបិទជិត ។ គេនឹកពិភាល់ណាស់ ហេតុអ្វីបានជាមានភ្លើងភ្លឺកាលបើគ្មាននរណា ដេកយាមគ្លីនិកទេ ហើយគេក៏ជាអ្នកចុងក្រោយដែរ ដែលចាក់សោរទ្វារគ្លីនិកមុននឹងចេញទៅផ្ទះ ។ រំពេចនោះ គេក្រលេកឃើញរថ យន្តរបស់ភក្តីចតនៅម្ខាងផ្លូវ ក៏នឹកភ្ញាក់ផ្អើលក្នុងចិត្តភ្លាម :

- តើភក្តីគេចូលគ្លីនិក រកអ្វីទាំងយប់ដូច្នេះ ?

វិចិត្រចតឡាន ហើយស្ទុះទៅបើកទ្វារយ៉ាងរហ័ស ។ ចៃដន្យទ្វារនោះគ្រាន់តែផ្ទិបមិនទាន់បានចាក់គន្លឹះពីក្នុងទេ ។ គេស្ទុះចូលទៅក្នុងបន្ទប់ព្យាបាលជំងឺយ៉ាងលឿន ស្រាប់តែប្រទះនឹងភក្តីក ំពុងឈ្ងោកចាប់ប្រលេះខ្សៀវអាវនារីម្នាក់ ដែលកំពុងគេងស្តូកស្តឹងលើគ្រែដោយមានខ្សែចងដៃចងជើងផង ។ ពេលនោះ ឆវីបានបាត់ ស្មារតី ទន់ខ្លួនល្វក់ទៅហើយ :

- ភក្តី! នេះ ឯងកំពុងធ្វើអីហ្នឹង ?

- ហ្ហ៎ាស! បងចិត្រ ? ហេតុអ្វីក៏ដឹងថាខ្ញុំចូលមកទីនេះ ?

ភក្តីឧទានទាំងភ្ញាក់ក្រញាង សម្តែងអាការៈដូចឃើញខ្មោចឆៅ អីចឹងកាលបើប្រទះវត្តមានរបស់បងប្រុសនៅពីក្រោយខ្នងរបស់ ខ្លួន ។ លុះវិចិត្រដាក់ភ្នែកទៅមើលមាណវីដែលកំពុងជាប់ចំណង ស្រាប់តែភើតពោះធ្លុងព្រោះនាងមិនមែននារីណាក្រៅពីចរណៃ ដែលគេកំពុងតែជំពាក់ចិត្តប្រតិពទ្ធ័យ៉ាងធំធេងមហិមានោះឡើយ :

- ភក្តី... ម៉េចបានប្អូនធ្វើយ៉ាងនេះ ?

- គឺ...គឺ...

CHANBOKEO.COM

ត្រូវបងប្រុសដេញទាន់ជាន់កែង ភក្តីនឹកភ័យផង ខ្មាសខ្លួនផង បន្ទាប់មកក៏ស្ទុះរត់គេចវឹងចេញទៅ បាត់ស្រមោលភ្លាមតែម្តង រក តែនិយាយអ្វីមិនទាន់ផង ព្រោះគេកំពុងញញើតកណ្តាប់ដៃរបស់បង ប្រុសគេ ។ វិចិត្រស្ទុះភ្លែតទៅបិទទ្វារ រួចហើយក៏ត្រលប់មក ស្រាយចំណងខ្សែចេញពីដៃជើងរបស់មាណវីយ៉ាងលឿន ។

ថ្វីបើពេលនោះ ធិតាបានបាត់ស្មារតីទៅមែន តែសោភ័ណរូប កាយរបស់នាងនៅតែអណ្តែតលេចធ្លោឡើង នៅចំពោះមុខវិចិត្រ យ៉ាងស្រស់ល្អត្រកាលគួរអោយគយគន់គាប់ទ័យា... វិចិត្រឃើញ ហើយ ញាប់ញ័រក្នុងចិត្តឥតឧបមា ។ គេឈរសម្លឹងរូបនាងយ៉ាង យូរ... មួយស្របក់មក គេក៏យកទឹកក្តៅមកជូតខ្លួននាងថ្នមៗ... ភ្នែកគេសម្លឹងសាច់ទ្រូងក្រពុំ ដែលអណ្តែតមកប្រលែងនឹងកែវ ភ្នែកបុរសតាមចន្លោះខ្សៀវអាវ ដែលភក្តីបានដោះប្រឡេះចេញពីគ្នា ...គេមិនហ៊ានព្រិចបិទភ្នែកទេ! ពិតជាល្អ! ពិតជាស្អាត! ពិតជា... គួរអោយចង់ថ្នាក់ថ្នមអ្វីម្ល៉េះទេ! មាណពលេបទឹកមាត់ក្អឹកៗ ម្តង ហើយម្តងទៀត ដើម្បីរំលត់ភាពពុះកញ្ជ្រោលនៅក្នុងបេះដូងរបស់ គេ តែក៏មិនអាចទប់ចិត្តដែលកំពុងរំភើបពុះពោរនោះបានឡើយ ។ ពេលនោះ គេយកម្រាមដៃរបស់គេ ទៅអង្អែលលើរាងកាយដ៏ល្អ ត្រសូលថ្នមៗ បន្តើរៗ រួចហើយអង្អែលបបូរមាត់នាង ដែលមាន ពណ៌ផ្កាឈូកតាមលក្ខណៈធម្មជាតិ :

- ឱ សម្រស់អើយ... អ្នកដឹងទេ ថាខ្ញុំកំពុងចុះចាញ់មន្តស្នេហ៍ របស់អ្នកហើយ... ពិតជាស្រស់ណាស់... ពិតជាស្អាតណាស់... សូមអនុញ្ញាត្តអោយខ្ញុំបានធ្វើជាម្ចាស់របស់អ្នកបានដែរទេ ?

រួចហើយ គេក៏ឱនឈ្ងោកយកនាសាទៅបបោសថ្នមៗលើបបូរ មាត់របស់នារីស្រាលៗ ដោយក្តីប្រតិពទ្ធ័យ៉ាងជ្រាលជ្រៅធំធេង ។ ជាតិសុរាបានជះឥទ្ធិពលយ៉ាងក្តៅគគុក ក្នុងចរន្តឈាមមាណព កាន់ តែខ្លាំងឡើងៗ ដណ្តប់លើស្មារតីរបស់នរៈយើងហើយ ។ បេះដូង គេរណ្តំ រំភើប ញាប់ញ័រ ដោយភាពវង្វេងក្នុងកាមារម្មណ៍ដ៏សែន ស្រើបស្រាល ។ គេហាក់ដូចជាភ្លេចភន្តំភាំងអស់ហើយថារូបគេ កំពុងធ្វើអ្វី... ក្រៅតែពីបណ្តោយរូបកាយនិងដួងចិត្តរបស់គេ ទោរ ទន់ទៅតាមទំនាញសន្ទុះកាមរាគដ៏សែនពុះកញ្ជ្រោល ដែលស្រូប

CHANBOKEO.COM

ទាញនាសារបស់គេឲ្យទៅផ្ដេកផ្ដិតថៃថើបរូបកាយដ៏ល្អត្រកាល គួរ អោយត្រកងនៃបនិត្យមួយនោះ ដោយមិនអាចតវ៉ាប្រកែកអ្វីបន្តិច បុនឡើយ ។

មិននឹងជាអស់ពេលយូរប៉ុន្មានទេ វិចិត្រប្រែខ្លួនឡើងមើល នាឡិកា ឃើញម៉ោងបួនជិតភ្លឺទៅហើយ ។ នៅក្នុងរង្វង់ដៃរបស់គេ នារីម្នាក់មានរូបកាយសត្រសូលដូចបណ្ដូលចេក នៅគេងស្ដូកស្ដឹង ន់ល្វក់មិនទាន់នឹងស្មារតីនៅឡើយ ។ ពេលនោះ បុរសយើងមាន អារម្មណ៍ថាស្វាងឆេងតែម្ដង :

- វិចិត្រ ឯងកំពុងធ្វើអ្វីហ្នឹង ? (សម្បជញ្ញៈសួរ)

មាណពស្ទុះដើបយ៉ាងរហ័ស ស្រវាខោអាវយកមកស្លៀក រួច ហើយបែរមើលទៅធិតាដែលកំពុងគេងស្ងៀមឈឹង ។ វិប្បដិសារី មួយបានមកប្រជ្រៀតខ្លួនក្នុងខួរក្បាលរបស់គេភ្លាម :

- វិចិត្រអើយ! ហេតុអ្វីបានជាអ្នកទប់ចិត្ត ទប់អារម្មណ៍មិនបាន ? អ្នកដឹងទេថា អ្នកកំពុងបំផ្លាញអនាគតនារីស្លូតត្រង់ម្នាក់ ?... ហេតុ អ្វីទៅបានជាអ្នកប្រែក្លាយជាមនុស្ស ដែលមានចរិតពាលយ៉ាងនេះ កើត ? ឯណាទៅភាពថ្លៃថ្នូររបស់កូនប្រុស ? ឯណាទៅកត្តិយស បុរស ? អ្នកមិនត្រឹមតែជាន់ឈ្លីអនាគតនារីទេ... អ្នកក៏កំពុងតែ ជាន់ឈ្លីជីវិតអនាគតរបស់ខ្លួនឯងដែរហើយ... តើនាងមានកំហុស អ្វីទៅទើបអ្នកបំផ្លាញរូបនាង ? វិចិត្រ...អ្នកឆ្កួតសតិហើយទេដឹង ?

មាណពក្ដោបក្បាល សម្ដែងការឈឺចាប់និងក្ដីអាមាសដ៏មហិមា ប៉ុន្ដែ ធ្វើម្ដេចនឹងអាចទាញពេលវេលាអោយថយក្រោយ ដើម្បីឲ្យ នាយអាចកែស្ថានការណ៍មកវិញបាន ? មិនអាចទេ..! ពិតជាមិន អាចឡើយ!... ចុះបើជ្រុលក្បាលក្រពើយ៉ាងនេះទៅហើយ តើគេ ត្រូវដោះស្រាយបញ្ហានេះយ៉ាងណាទៅវិញ ?

តប់ប្រមល់ពេក គេក៏ស្ទុះទៅបើកទ្វារ គិតថានឹងទៅសំកុកគិត នៅមាត់ស្ទឹង ក្រោមជំនោរត្រជាក់ពេលជិតភ្លឺ ក្រែងលោរកឃើញ មធ្យោបាយដោះស្រាយ ។ គ្រាន់តែទ្វាររបើកភ្លាម ស្រាប់តែគេភ្ញាក់ ក្រញាងតែម្ដង ត្បិតគេបានប្រទះនឹងមនុស្សស្រីម្នាក់ស្លៀកពាក់ ពណ៌ខ្មៅនៅឈរសំកុកចំពីមុខមាត់ទ្វារ :

- លិនដា ?

- ចា៎ស! មែនហើយ... គឺអូនសំកុកចាំបងទីនេះមួយយប់ហើយ...

CHANBOKEO.COM

ព្រោះឃើញឡានបងចតចោលនៅទីនេះ ។

កាលបើឃើញវត្ថុមានរបស់លិនដាភ្លាម វិចិត្រក៏ស្រវាទាញអាវ ដាក់ខ្សែវតម្រែតម្រង់ភាពខ្ជីខ្ជារបស់ខ្លួនអោយមានរបៀប រួចហើយ ក៏សួរនាងថា :

- លិនដាមករកបងមានការអ្វី ?
- គឺ...ចង់មកសួររឿងយើង មួយម៉ាត់ជាចុងក្រោយ...
- អូនបានឮចំលើយរួចហើយតើហ៍ កាលពីយប់មិញនៅចំពោះ មុខចាស់ៗ.... ហើយពេលនេះទៀតសោត ក៏មិនមែនជាវេលាល្អ សំរាប់យើងជជែកគ្នាដែរ ។

វិចិត្រឈរពាំងមាត់ទ្វារមិនព្រមអញ្ជើញលិនដាចូលផ្ទះទេ ថ្វីបើ ពេលនោះយប់ងងឹត មិនសមនឹងឲ្យឈរជជែកគ្នានៅខាងក្រៅក៏ ដោយ ។ ឃើញកិរិយារបស់នាយមានពិរុទ្ធ លិនដាក៏សួរឡើងថា :

- បងកំពុងលាក់នារីថ្មីនៅក្នុងចិត្តបងមែនទេ បានជាបងងួរចិត្តមិន ចង់រៀបការនឹងលិនដាតាមការរៀបចំផ្សំផ្គុំតាំងពី៧ឆ្នាំមុន ?

វិចិត្រនៅស្ងៀមមិនឆ្លើយទេ ។ រំពេចនោះ ស្រាប់តែនាងគិត ឃើញអ្វីម្យ៉ាង រួចក៏បើកភ្នែកធំៗ ហើយលាន់មាត់ឡើងថា :

- ឬក៏... បងកំពុងលាក់នារីកំណាន់របស់បងនៅក្នុងផ្ទះនេះ ?

ថាហើយ នាងក៏រុញវិចិត្រវឹងទៅម្ខាង ហើយស្ទុះរត់ចូលទៅ ក្នុងបន្ទប់ពិនិត្យជំងឺ ស្រាប់តែប្រទះរាងកាយនារីម្នាក់គេងអាក្រាត ស្ដូកស្ដឹងមិនដឹងខ្លួនដណ្ដប់ដោយក្រណាត់ភួយពណ៌សនៅលើគ្រែ :

- បងវិចិត្រ... ?

ធិតាញ័រខ្លួនចំប្រប់ ដោយការភ្ញាក់ផ្អើល :

- នេះបង...បានធ្វើអ្វីហ្នឹង ?...

វិចិត្រមិនឆ្លើយទេ ។ គេស្ទុះទៅចាប់លិនដាចេញពីបន្ទប់ :

- លិនដាទៅផ្ទះវិញសិនទៅ...ចាំថ្ងៃក្រោយបងពន្យល់ប្រាប់ ។
- អត់ទេ លិនដាចង់ដឹងពេលនេះ ថាបងចិត្រកំពុងធ្វើអ្វី ? តើនារី នេះជានរណា ? ហើយហេតុអ្វីក៏កិរិយារបស់បងមានពិរុទ្ធ ? នេះ បងបានបំពារបំពានលើរូបនារីនោះមែនទេ ? ... មែនទេ ?

CHANBOKEO .COM

វិចិត្រស្លោកមុខ ឈរស្ងៀមមិនឆ្លើយ ។ លិនដាសម្លឹងមុខនរៈ ហើយក៏ច្រានទ្រូងរបស់គេវឹង
រួចខ្ទប់មុខយំរត់ចេញទៅ ។ វិចិត្រ នៅឈរភន្ត់ភាំងមួយស្របក់
ដោយការរន្ធត់ស្មារតីដែលត្រូវលិនដា ប្រទះឃើញអំពើមិនប្រពៃរបស់គេពេលនោះ ។
ដោយគេបារម្ភពី សុវត្ថិភាពរបស់លិនដាដែលរត់ចេញទៅទាំងងងឹត នរៈក៏ស្ទុះចេញ
ទៅតាមរកនាងភ្លាម ។ លុះគេរត់បានប្រហែលបីរយម៉ែត្រ នាយក៏ វង្វេងលិនដាបាត់ទៅ
មិនដឹងថានាងរត់គេចទៅខាងណាទេ ។ ភ្លាមនោះ គេចាប់ភ្លឹកថា បានទុកទ្វារចំហចោល
ហើយក៏នឹកដល់ សុវត្ថិភាពរបស់ចរណៃ ។ គេក៏រត់បកក្រោយមកវិញ ។ ចៃដន្យ
មាណវីក៏បាត់ស្រមោលពីគ្លីនិកនោះទៅ ។ វិចិត្រប្រហោងពោះឆ្លុង
នឹកភ័យញាប់ញ័រក្នុងចិត្តតក្កមា ។ គេស្ទុះបិទទ្វាររួចហើយរត់តាម បណ្ដោយស្ទឹងសង្កែ
សម្លឹងរកស្រមោលចរណៃដែលបានរត់គេចខ្លួន ទៅ ។ មួយស្របក់មក
វិចិត្រក៏ប្រទះស្រមោលនារីកំពុងយកដៃ ច្រត់ទប់ខ្លួនទៅលើគល់ដូងមួយ
រួចហើយស្រាប់តែឃើញនាងដួល ប្រូសទៅដីដោយការល្ហិតល្ហៃអស់កម្លាំង :
- អ្នកនាង !
ស្រាប់តែនាងបើកភ្នែកព្រឹមៗ ហើយស្រដីខ្សាវតបមករកនរៈ
វិញថា :
- ខ្ញុំ...ចង់ទៅផ្ទះ...
រួចហើយ នាងក៏បាត់ស្មារតីទៅវិញ ។ វិចិត្រឃើញភាពទន់ ខ្សោយរបស់ធិតា
បេះដូងគេក៏រំដើបរំជួលឡើងរហូតទឹកភ្នែករលីង រលោងដោយក្ដីអាណិតអាសូរ
មិនគួរណារូបគេភ្លើតភ្លើនជ្រុលជ្រួស ទៅលើនាងដល់ម្លឹងទេ ។
គេក៏បីត្រកងនាងដើរត្រលប់ក្រោយចូល រថយន្តហើយក៏បរនាំខ្លួនធិតាយកទៅផ្ទះវិញ ។
ពេលនោះ គ្មាន នរណានៅផ្ទះទេ ។ មាណពបីយកចរណៃទៅដាក់នៅលើគ្រែថ្មមៗ
ហើយនៅកំដរនាងរហូតភ្លឺស្រាងៗ តែនាងនៅតែមិនទាន់ដឹងខ្លួន ដដែល ។ មិនអស់ចិត្ត
គេក៏បើកឡានត្រលប់ក្រោយ បំរុងថាទៅ យកថ្នាំមកព្យាបាលមាណវី ។ លុះទៅដល់មាត់ទ្វារគ្លីនិក
ស្រាប់តែ ប្រទះអ្នកស្រីផាន់ស៊ីនៅឈររង់ចាំទីនោះស្រេច :
- អ្នកមីង ?
- អឺ... ហើយវាយ៉ាងម៉េច បានជាឯងធ្វើមុខស្លេកដូចត្រូវខ្មោច ជញ្ជក់ឈាមអស់យ៉ាងនេះ ?
វិចិត្រស្លោកមុខនៅស្ងៀមមិនឆ្លើយអ្វីទេ ។ មួយស្របក់មក គេក៏សួរអ្នកស្រីផាន់ស៊ីថា :

CHANBOKEO.COM

- អ្នកមីងមានការអ្វីមករកខ្ញុំទាំងព្រហាម ?
- មានខ្លួនហ្វ៊េស បានរញីរញ៉័របែបនេះ ? ហើយឯងបានធ្វើអ្វីលើ លិនដាខ្លះដែរ បានជាគេខឹងនឹងឯងរហូតដល់ចង់សម្លាប់ខ្លួន ?
- លិនដាចង់សម្លាប់ខ្លួន ?
- អឺ ! នាងបានផឹកថ្នាំពុល កុំតែអ្នកស្រីលីណាប្រទះទាន់ពេល កុំអី.. ឥលូវគេដឹកនាងចូលពេទ្យធំទទួលការសង្គ្រោះហើយ ។

វិចិត្រភ្ញាក់ក្រញាងកាលបើឮដំណឹងដូច្នោះ ។ សម្បជញ្ញៈបានលេចឆ្លោឡើងក្នុងខួរក្បាលនរៈ :
- វិចិត្រអើយ ! អំពើភ្លើតភ្លើនរបស់អ្នកកាលពីយប់មិញកំពុងតែបំផ្លាញជីវិតនារីមួយរូបទៀតហើយ ។

ស្រាប់តែគេមានអារម្មណ៍តក្កហលមួយរំពេច ហើយក៏ស្ទុះចូល រថយន្តបរទៅមន្ទីរពេទ្យវីង ដោយការព្រួយបារម្ភ ចំពោះសុខទុក្ខ របស់លិនដា ។ ពេលនោះ គេជាប់រវល់នឹងរឿងលិនដាមិនបាន វិលត្រលប់ទៅថែរក្សាចរណៃវិញទេ ។ មិនទាន់បានពីរម៉ោងផង ស្រាប់តែគេប្រទះក្រុមគ្រួសារមួយ នាំខ្លួនអ្នកជំងឺស្រីវ័យក្មេងម្នាក់ មកដល់យ៉ាងបន្ទីរបន្ទាន់ដែរ ។ អ្នកគ្រូពេទ្យម៉ារ៉ាត់បានរត់មកតាម ហៅវិចិត្រប្រាប់ថា :
- លោកដុកទ័រ ជួយផង ! មានអ្នកជំងឺស្រីរងគ្រោះដោយការប៉ុនប៉ងធ្វើអត្តឃាតម្នាក់ទៀតហើយ ។ ឮថានាងអារកដៃសម្លាប់ខ្លួន ឥលូវរងគ្រោះធ្ងន់ធ្ងរណាស់ ។

វិចិត្រក៏ស្ទុះទៅមើលភ្លាម ស្រាប់តែគេភ្ញាក់ផ្អើលស្ទើរតែគាំង បេះដូងស្លាប់នឹងកន្លែង ត្បិតនារីនោះមិនមែននរណាក្រៅពីចរណៃ បណ្តូលចិត្តរបស់គេនោះឡើយ ។ វិប្បដិសារីក៏វិលមកប្រលែងក្នុង សតិអារម្មណ៍របស់គេទៀតហើយ :
- ឱ វិចិត្រអើយ ! ដឹងខ្លួនទេ ពេលនេះ រូបអ្នកកំពុងដើរធ្លាក់នរក ហើយ ព្រោះអំពើភ្លើតភ្លើនមិនបានគិតវែងឆ្ងាយរបស់អ្នកកំពុងតែធ្វើអោយនារីពីររូបយាយីជាជីវិតខ្លួនឯង ! !

ថ្វីបើនៅលើផ្ទៃមុខរបស់គេមានភាពនឹងន ស្ទើរៗមិនកំរើកឲ្យ ឃើញអារម្មណ៍ តែបេះដូងរបស់គេកំពុងត្រូវព្យុះវិប្បដិសារីញាំញី ស្ទើរខ្ទេចខ្ទាំហើយ ជាពិសេសគឺនៅពេលមាណពបានឃើញរង្វង់ ភក្រ្តដ៏សែនស្លេកស្លាំងរបស់ចរណៃ ។ កាលនោះ ធិតាហូរឈាមពី ខ្លួនច្រើនណាស់ នាងត្រូវបានទទួលការបញ្ចូលឈាមព្យួរសេរ៉ូម

CHANBOKEO.COM

អស់រយៈមួយយប់មួយថ្ងៃ ទើបនាងបានដឹងស្មារតីមកវិញ ។ វិចិត្រមិនដែលបានធ្មេចពេញភ្នែកឡើយ ។ គេតែងតែមកអង្គុយសំកុកកំដរចរណៃរៀងរាល់ថ្ងៃជានិច្ច រហូតដល់គ្រូពេទ្យទាំងឡាយដែលធ្វើការជាមួយគ្នាចាប់ភ្លឹកនឹកសង្ស័យ ប៉ុន្តែក៏គ្មាននរណាហ៊ើប មាត់និយាយស្តីអ្វីដែរ ខ្លាចរំខានចិត្តនាយ ព្រោះកិរិយារបស់វិចិត្រ បានបង្ហាញអោយឃើញថា គេកំពុងទទួលរងនូវទុក្ខសោកវិបត្តិ យ៉ាង ធំមហិមាមិនអាចនឹងថ្លាថ្លែងបានទៅហើយ ។

ដោយវិចិត្រជាមនុស្សស្ងៀមស្ងាត់ស្រាប់ផង កាលបើប្រទះ ហេតុការណ៍បៀបនេះ គេក៏រឹតតែបាត់មាត់ស្ងាត់ណាស់ថែមទៀត ត្បិតគេមានអារម្មណ៍ជំពាក់ច្របូកច្របល់មិនដឹងថា ត្រូវបង្កើបរឿង ដើម្បីដោះស្រាយបញ្ហាអោយធូរស្រាលតាមរបៀបណា ក្រៅតែពីមកពិនិត្យថែរក្សាអាការរោគរបស់ចរណៃយ៉ាងល្អបំផុត រៀងរាល់ថ្ងៃ ថ្វីបើនាងមិនព្រមបើកភ្នែកសម្លឹងរូបគេ ឬមើលនរណាផងទៀត ក៏ដោយ ។

អស់ជាយូរថ្ងៃកន្លងមក វិចិត្របានគេងគិតពិចារណាតែម្នាក់ ឯងដដែលដដែលថា តើគេត្រូវធ្វើយ៉ាងណា ដើម្បីផ្តល់យុត្តិធម៌ ដល់នារី ដែលរងគ្រោះដោយអំពើខុសតិរបស់គេ ។ មិនយូរប៉ុន្មាន ចរណៃក៏បានជាសះស្បើយ ហើយក៏ត្រូវបានទទួលការអនុញ្ញាតឲ្យទៅថែរក្សាខ្លួននៅផ្ទះវិញ ។ នៅថ្ងៃដដែលនោះ វិចិត្របានតាំងចិត្ត យ៉ាងមុតមាំថា គេនឹងទៅជួបលោកចំណាប់និងភរិយា នៅផ្ទះរបស់ លោក ដើម្បីសារភាពការពិតជំរាបលោកទាំងពីរ ហើយក៏នឹង សុំខ្លួនទទួលខុសត្រូវចំពោះអ្វីដែលខ្លួនបានប្រព្រឹត្តខុសទៅលើ ចរណៃកំពូលដួងចិត្ត ។

ថៃងន្យ នៅពេលគេចេញពីធ្វើការ ទៅរកជួបលោកចំណាប់ អ្នកយាមផ្ទះម្នាក់ បានប្រាប់គេថា លោកចំណាប់និងភរិយាបាននាំ កូនស្រីចេញទៅក្រៅក្រុងបាត់ទៅហើយ ហើយក៏មិនដឹងថា ថ្ងៃណា លោកនឹងវិលវិញដែរ ។ វិចិត្រធ្លាក់ថ្លើមក្តុក ស្លុតដង្ហក់ស្ទើរតាំងបេះដូងស្លាប់នៅពេលនោះតែម្តង ។ ពេលនោះ ពិភពលោកក្លាយ ជាងងឹតឈឹងលែងយល់រស្មី ។ វិចិត្របានប្រែក្លាយទៅជាបុគ្គល ដែលរស់ឥតវិញ្ញាណ ថ្ងៃណាក៏ឃើញតែសំកុក ថ្ងៃណាក៏ឃើញតែជ្រួញចិញ្ចើម ថ្ងៃណាក៏តប់ប្រមល់... គ្រាប់បាយក្លាយជាដុំគ្រួស ។ រីឯពូកគេងទន់ល្មើយក្លាយទៅជាភ្នក់ភ្លើងដុតរោលរូបគេមិនអោយ ចូលនិទ្រាបាន ។ តើគេត្រូវធ្វើដូចម្តេចនឹងដឹង ថាតើលោកចំណាប់ នាំកូនស្រីរបស់លោកទៅឯណា ?

CHANBOKEO.COM

រាល់ល្ងាច គេតែងតែទៅសំកុកនៅក្នុងសួនយុវ័ន ភ្នែកគេរំពៃ សម្លឹងទៅមើលលំនៅស្ថានរបស់លោកចំណាប់ ក្នុងចិត្តលួចបែបន់ តែម្នាក់ឯង សូមអោយចរណៃឆាប់បានវិលត្រលប់មកផ្ទះវិញសាជា ថ្មី ។ គេរស់នៅត្រមង់ត្រមោច កណ្តោចកណ្តែង ស្ងៀមស្ងាត់ មិនមើលមុខញាតិណាឡើយ ។

នៅរៀងរាល់ថ្ងៃអាទិត្យ មាណពតែងតែទៅអង្គុយសំកុកនៅវត្ត កណ្តាល បន់បារមីព្រះអង្គអោយដឹកដៃរូបគេទៅជួបនារីកំពូលដួង ចិត្តរបស់គេវិញ ។ ថ្វីបើគេមិនដែលស្រក់ទឹកភ្នែកម្តងណា... តែគេ បានលួចអារដៃសម្រក់ឈាមយកមិនអស់ ដើម្បីស្បថសច្ចាចំពោះ ភក្ត្រ័ព្រះពុទ្ធអង្គ បង្ហាញនូវវិប្បដិសារី និងភក្តីភាពដ៏ស្មោះស្មគ្រ័ របស់គេចំពោះចរណៃម្ចាស់ដួងចិត្តតែមួយ ។ តាំងពីថ្ងៃនោះមក គេក៏លែងមើលមុខនារីណាទាំងអស់ សូម្បីតែលិនដាដែលបានវិល ត្រលប់មកសម្រុះសម្រួលជាមួយមាណពសាជាថ្មីម្តងទៀត ។  ប៉ុន្តែ គេនៅតែបដិសេធដដែលជាដដែល រហូតដល់នាងដាច់ចិត្តរៀប ការជាមួយបុរសថ្មី ដើម្បីបញ្ឈឺចិត្តខ្លួនឯង ។

ថ្ងៃមួយ គេបានដំណឹងថា លោកចំណាប់បានវិលមកផ្ទះវិញ តែ ក៏បាត់កូនស្រីមិនឃើញត្រលប់មកជាមួយទេ ។ ព្រមជាមួយគ្នានោះ គឺគេក៏បានឮដំណឹងអាក្រក់មកជាមួយដែរថា ចរណៃបានរៀបការជា មួយបុរសកំណាន់ចិត្តរបស់នាង នៅឯស្រុកកំណើតនោះបាត់ទៅ ហើយ... ។ ពេលនោះ គេស្លុតស្រយុងក្នុងចិត្តណាស់ គិតអ្វី មិនឃើញទេ ក្រៅតែពីការលិចលង់នឹងសេចក្តីទុក្ខ សេចក្តីអាមាស និងវិប្បដិសារីយ៉ាងធំធេង ។ គេក៏ទាញកាំបិតអារកំភួនដៃខ្លួនឯង បាញ់ឈាមព្រលឡើង ទទួលពូខេមនិងភក្តីមកទាន់ល្មម ជួយ សង្គ្រោះរូបគេ ផុតពីគ្រោះថ្នាក់ទាន់ពេលវេលា ។

- បងចិត្រ! ហេតុអ្វីបងធ្វើយ៉ាងនេះ ?

វិចិត្រក្តោបក្បាលទ្រោបមុខមិននិយាយស្តី គ្រាន់តែធ្វើអាការៈ ហាក់ហ្វុហ្វុងនឹងជីវិតរបស់ខ្លួនក្រៃលែង ។ ឃើញដូច្នោះ ពូខេមក៏ លួងលោមថា :

- ខ្ញុំដឹងណា៎ ថាលោកគ្រូពេទ្យមិនមែនជាមនុស្សនិយាយស្តីច្រើន ទេ ។ ប៉ុន្តែជួនកាល ការនិយាយទំលាយចេញខ្លះនូវអារម្មណ៍របស់ ខ្លួនឯង ប្រហែលជាអាចជួយសម្រាលទម្ងន់ទុក្ខសោកដែលមាននៅ ដើមទ្រូងរបស់បានផងក៏មិនដឹង...

CHANBOKEO.COM

- បងវិចិត្រ! បងជាវេជ្ជបណ្ឌិតណា៎! បងព្យាបាលគេរាប់មិនអស់
ដើម្បីជួយជីវិតអ្នកដទៃអោយផុតគ្រោះថ្នាក់ តែហេតុអ្វីបងបែរជា
ប្រព្រឹត្តបាបគ្រោះលើជីវិតរបស់ខ្លួនឯងទៅវិញ ? (ភក្តីពោល)

មែនហើយ! គេជាគ្រូពេទ្យ ព្យាបាលមនុស្សអោយរួចជីវិត តែ
គេបែរជាចង់ផ្តាច់ជីវិតរបស់ខ្លួនឯង តើព្រោះអ្វី ? គឺ...គ្រូពេទ្យ ក៏ចេះធ្វើខុសដែរ បើកាលណា
គេមិនចេះគ្រប់គ្រងសតិអារម្មណ៍ របស់ខ្លួនឯង ។
នេះសូម្បីតែរូបគេរៀនសូត្រមានចំណេះដល់ម្លឹង ហើយ នៅតែគិតមិនដល់
ចុះទំរាំមនុស្សដែលមិនបានចូលសិក្សា តើគ្នានិងពិចារណាអ្វីឃើញទៅ
បើសិនជាគេលង់ដំណើរក្នុងផ្លូវ ខុស ? រួចបើសិនគេដឹងកំហុសហើយ តើគេត្រូវបង្អើបការពិត
ដោះស្រាយកំហុសរបស់គេយ៉ាងណា ? តើមាននរណាស្តាប់គេទេ ?
អោយឱកាសគេកែខ្លួនដែរឬទេ ? តើមាននរណានឹងជួយលើកទឹក ចិត្តខ្លះ
នៅពេលគេចង់ផ្លាស់ប្តូររូបគេដើម្បីកែតម្រូវអោយល្អវិញ ? សង្គមខ្មែរចូលចិត្តសើចយំចំអក
ចូលចិត្តបន្ទោស ចូលចិត្តប្រមាថ មាក់ងាយ ចូលចិត្តជឿពាក្យចាមអារាម ប៉ុន្តែ
តើនរណាខ្លះទៅហ្ន៎ ដែលចាប់ផ្តើមដើរផ្ទុយពីគន្លងនោះ ហើយវិលមកផ្តល់ទឹកចិត្តអ្នក
ដែលប្រព្រឹត្តខុស ស្តាប់រឿងអ្នកដែលប្រព្រឹត្តខុសនោះពីមាត់របស់ គេ
ថាហេតុអ្វីបានជាគេប្រព្រឹត្តឆ្គាំឆ្គងដូច្នោះ... រួចហើយជួយ អោយយោបល់ណែនាំតម្រែតម្រង់គេ
អោយដើរផ្លូវត្រូវមកវិញ ដោយមិនបាច់ប្រើហិង្សាអប់រំ ឬចងអាឃាត ប្រទុស្ត ឬការប្រមាថ
មាក់ងាយចោលទោសច្រំដែលៗ ?

វិចិត្រពិចារណាចុះឡើងៗ តែក្នុងចិត្តតែម្នាក់ឯងចុះឡើងៗ...
មនុស្សយើងខ្លះមានកំហុសហើយចេះតែធ្វើខុសតទៅទៀត ហើយ ចេះតែវង្វេងឆ្ងាយទៅៗ
ព្រោះគេបែរមុខទៅទិសងងឹត មើលមិន ឃើញពន្លឺដែលនៅក្រោយខ្នង
មិនអាចរកផ្លូវត្រលប់បែរក្រោយ បាន ។ មានតែអ្នកនៅខាងភ្លឺប៉ុណ្ណោះ ដែលអាចជួយដាស់ ជួយ
ទាញ អ្នកដែលបែរមុខស្លុងទៅខាងងងឹតអោយភ្ញាក់ស្មារតី ហើយ
បែរក្រោយមកប្រទះពន្លឺវិញបាន ។

ពេលនេះ ពូខេមក៏បានក្លាយជាប្រភពកម្លាំងចិត្តតែមួយរបស់
វិចិត្រ ។ ក្រោយពីបានរំសាយកង្វល់នៅក្នុងទ្រូង ជាមួយពូខេម
ស្ងាត់ៗតែពីរនាក់ ពូខេមក៏ស្រដីទៅវិចិត្រវិញថា :

- លោកគ្រូពេទ្យអើយ! នរជនណាមួយមិនធ្លាប់ធ្វើខុស ? មនុស្ស យើងជាបុថុជ្ជន តែងតែមានកិលេស មានតណ្ហា ។ ជនខ្លះក៏អាច ទប់អារម្មណ៍ទប់សតិបាន រួចហើយក៏ដើរក្នុងផ្លូវវិន័យ ផ្លូវជីវិតល្អ ប្រសើរ ។ ជនខ្លះមិនអាចគ្រប់គ្រងសតិខ្លួនបាន ក៏ជ្រុលមានកំហុស រួចហើយក៏ចងចាំវាជាមេរៀន បន្ទាប់មកក៏កែខ្លួនជាមនុស្សល្អឡើង វិញ ។ អ្នកខ្លះទៀតក៏វង្វេងឆ្ងាយទៅៗកែមិនឡើង... ប៉ុន្តែទោះជា យ៉ាងណា ក៏មនុស្សនោះនៅអាចដោះស្រាយបញ្ហាជីវិតរបស់ខ្លួន បានល្អមកវិញជានិច្ច បើគេសំរេចចិត្តចង់កែខ្លួន ហើយបើសង្គម ផ្តល់ឳកាសអោយគេកែខ្លួនដូចគ្នាដែរ ។ ការរស់នៅក្នុងសង្គម តែងតែមានតក់មាននាឡិ មានជោរមាននាច ។ នៅពេលដែល ជីវិតរបស់យើងកំពុងស្រកស្រុតកម្លាំងចិត្ត យើងត្រូវតែស្វែងរក មធ្យោបាយសំរាប់ជួយខ្លួនឯងឡើង ។ យើងមិនមែនរស់នៅលើ លោកនេះតែម្នាក់ឯងទេ ហើយយើងក៏មិនមែនជាមនុស្សដែល អភព្វជាងគេលើលោកនេះតែម្នាក់ឯងដែរ ។ ការធ្វើអត្តឃាដបញ្ចប់ ជីវិតរបស់ខ្លួនឯង មិនមែនជាការដោះស្រាយបញ្ហាឡើយ ។ ការ ពិត ការធ្វើអត្តឃាដជាការចងបញ្ហា ពង្រីកសេចក្តីទុក្ខសោកអោយ កាន់តែធំឡើង ធ្ងន់ឡើង ទម្លាក់ទៅលើអ្នកដែលរស់នៅជុំវិញខ្លួន យើងអោយគេជួយរែកទុក្ខជំនួសយើង នៅពេលយើងស្លាប់ទៅ នោះទៅវិញទេតើហ៎ ។ នោះជាការដោះស្រាយបញ្ហាដ៏អាមាស បំផុត ។ ដូច្នេះសូមពង្រឹងចិត្តឡើង សម្លឹងមើលអ្នកដែលនៅជុំវិញ ខ្លួនយើងវិញ ថាតើមានគេស្រលាញ់យើងដែរទេ ? កាលបើ យើងព្រាត់ទៅដោយសេចក្តីស្លាប់ទាន់ហន់ តើគេទាំងនោះនឹងកើត ទុក្ខសោកសង្រេងយ៉ាងណា ? បើយើងខូចចិត្តព្រោះតែមនុស្សម្នាក់ ហេតុអ្វីយើងត្រូវធ្វើបាបខ្លួន សម្លាប់ខ្លួន ធ្វើបាបទឹកចិត្តញាតិមិត្តជា ច្រើនទៀត ដែលស្រលាញ់យើងឲ្យលង់នឹងក្តីឈឺចាប់ដោយការ ព្រាត់ប្រាសរូបយើងផង ? ហេតុនេះហើយ យើងត្រូវតែរឹងប៉ឹង ត្រូវតែរស់ ហើយរស់ដោយល្អបំផុត សម្រាប់បុគ្គលទាំងអស់ដែល ស្រលាញ់យើងគ្រប់គ្នា ហើយយើងត្រូវសម្លឹងទៅមុខ ដើម្បីសាងក្តី សង្ឃឹមសាជាថ្មី ។ ព្រះអាទិត្យមិនចេះតែលិចរហូតទេ យ៉ាងណា មិញ ជីវិតមនុស្សក៏ដូចគ្នា គឺមិនដែលលិចលង់ងងឹតសូន្យរហូត ដែរ ។ ថ្ងៃណាមួយ ជិវិតនឹងភ្លឺស្វាងឡើងវិញមិនខាន ។ ដូច្នេះ យើងត្រូវតែពង្រឹងជំហរ រង់ចាំទទួលភាពភ្លឺស្វាងក្នុងជីវិតសាជាថ្មី ម្តងទៀតនៅថ្ងៃស្អែកដែលនឹងមកដល់ ។

វិចិត្រស្រវាអោបពូខេមដោយរំភើបចិត្ត :

CHANBOKEO.COM

- អរគុណពូក្រៃលែងនូវពាក្យលើកទឹកចិត្តទាំងឡាយនេះ ។ ពេលនេះវិចិត្រនឹងហើយថាខ្ញុំត្រូវធ្វើយ៉ាងណាតទៅទៀត ដើម្បីសាងជីវិតអោយគាប់ប្រសើរឡើងវិញ ។

ooooooooooooooo

ooooo

o

CHANBOKEO . COM

# វគ្គទី១១
# អម្រិតស្នេហា

នៅក្នុងគេហដ្ឋានរបស់លោកគ្រូពេទ្យវិចិត្រ...

ចរណៃទ្រោបមុខយំខ្សឹកខ្សួលលើខ្នើយ...

- ណៃមិនយល់ទេ ថាហេតុអ្វីបុរសពាលម្នាក់នោះក្លាយជារូបបង ទៅវិញ ? ពេលបានឮការពិតជ្រះស្រលះហើយ ម៉េចក៏ណៃនៅតែ ឈឺចាប់យ៉ាងនេះ ? ម៉េចបានរឿងរ៉ាវច្របូកច្របល់យ៉ាងហ្នឹង ?

វិចិត្រស្រវាអោបភរិយាពីក្រោយខ្នង និយាយថ្នមៗ :

- ចង់ដាក់ទោសបងយ៉ាងណាក៏បានដែរអូនណៃ! វិចិត្រទទួលយក បានទាំងអស់ សុំតែអូនកុំធ្វើបាបខ្លួនឯងចុះណា៎ ប្រពន្ធតែមួយ របស់បង!

ថាហើយ គេក៏ឈ្ងោកចុះថើបកញ្ចឹងករបស់នាង ហើយស្រដី បន្តទៀតដោយទឹកចិត្តស្នេហាភរិយាដ៏ធំធេង :

- បងបានដឹងថាបងធ្វើខុស ហើយបងក៏ចូលខ្លួនមកទទួលកំហុស របស់បងហើយ ។

ចរណៃងើបមុខឡើង រងំរងក្រ័ដក់ដោយទឹកភ្នែកជោគជាំ :

- បងដឹងទេ ថាកាលនោះ ណៃឈឺចិត្តយ៉ាងណា ? គឺអូនចង់តែ ទៅសម្លាប់បុរសពាលនោះណាស់! តែអូនក៏ធ្វើមិនបានហើយអូនក៏ ត្រូវគេងខឹង គេងកើតទុក្ខមិនរសាយ ព្រោះគេបានបំផ្លាញអនាគត របស់អូន ។ ពេលនោះ បើកុំតែអូនបានជួបបុរសដែលមានទឹកចិត្ត សណ្ដោសរូបអូន ដោយយកកត្តិយសរបស់គេមកជួយបិទបាំង មិន ដឹងថា នៅពេលនោះ ណៃត្រូវយកមុខទៅលាក់ទុកត្រង់ណាទេ ជាពិសេសនៅពេលដែលខ្លួនកំពុងមានផ្ទៃពោះដោយឥតខន្ធស្លា..!

ចរណៃនិយាយផង ខ្សឹកខ្សួលផង ។ វិចិត្ររលីងរលោងទឹក ភ្នែក នឹកអាណិតភរិយារបស់គេរកថ្លែងមិនបាន ។ គេក៏ឈ្ងោក មុខសំដែងការឈឺចាប់យ៉ាងធ្ងន់ធ្ងរក្នុងដួងចិត្តដូចគ្នា :

CHANBOKEO . COM

- ចៃដន្យ បុរសពាលនោះក៏ជាមនុស្សកំសាកម្នាក់ ដែលរស់នៅ ត្រមង់ត្រមោចកណ្ដោចកណ្ដែង គ្មានការកក់ក្ដៅ គ្មានញាតិមិត្ត ។ កាលបើគេដឹងខ្លួនថាបានប្រព្រឹត្តអំពើមិនគប្បី រូបគេក៏ធ្លាក់ទៅក្នុង អវិចីដូចគ្នា ។ ច្រើនឆ្នាំកន្លងទៅ គេរស់នៅក្នុងភក់ភ្លើងវិប្បដិសារី ដែលដុតរោលបេះដូងរបស់គេគ្មានថ្ងៃរលត់ សូម្បីតែព្រះក៏លោក មិនអាចយាងមកប្រោសរូបគេ អោយផុតភក់ភ្លើងកម្មក្នុងដួងចិត្ត នោះឲ្យបានធូរស្បើយឡើយ... ហើយគេនៅតែរង់ចាំ... រង់ចាំទទួល ការអភ័យទោសពីនារីដែលគេបានបំពាន ដើម្បីឲ្យដួងចិត្តរបស់គេ បានស្ងប់រំងាប់មកវិញ...មិនថាការរង់ចាំនោះយូរប៉ុណ្ណាទេ...

រំពេចនោះ វិចិត្រក៏រំកិលខ្លួនចុះពីលើគ្រែ ចុះទៅលើកម្រាល ឥដ្ឋ ហើយលុតជង្គង់ក្បែរភរិយារបស់គេ រួចហើយចាប់ដៃនាងយក មកកាន់យ៉ាងណែន :

- ណៃ! អភ័យទោសអោយបងផងណា៎អូន ដែលបងបានប្រព្រឹត្ត អំពើមិនប្រពៃលើរូបអូននាគ្រាមួយនោះ ។

ចរណៃសម្លឹងមុខស្វាមី ទាំងចិត្តរន្ធត់ញាប់ញ័រ ។ ទឹកភ្នែកក៏ នៅតែហូរស្រក់មកដដែល ។ នាងរន្ធត់ចិត្តណាស់ នឹងរកពាក្យអ្វី មកនិយាយ អោយសមស្មើនឹងភាពច្របូកច្របល់ក្នុងចិត្តរបស់នារី បានឡើយ ។ បន្តិចមក វិចិត្រក៏ស្រដីបន្តថា :

- អូនណៃ ម្ចាស់ដួងចិត្តតែមួយរបស់បង! ប្ដីនឹងទុកពេលវេលា ឲ្យអូនរំសាយចិត្ត ។ បងមិនបង្ខំចិត្តអូនទេ ។ ទោះបីជាយ៉ាងណា សូមអូនចងចាំផងថា វិចិត្រគ្មានថ្ងៃឈប់ស្រលាញ់អូនឡើយ ហើយ ក៏គ្មានថ្ងៃនឹងដើរចេញពីជីវិតអូនដែរ ទោះបីជាអូនមិនអភ័យអោយ បងក៏ដោយ ។ បងសុខចិត្តរស់នៅក្បែរអូនជាទាសករស្នេហា ក៏បានដែរ ឲ្យតែបងបានលាងកំហុសដែលបងបានប្រព្រឹត្តខុសកាល ពីអតីតកាល ហោចណាស់ ក៏បងមិនបណ្ដោយអោយអូន ទៅរស់ នៅកណ្ដោចកណ្ដែងជាមួយកូនៗឡើយ ព្រោះបងចង់ឃើញមុខអ្នក ដែលបងស្រលាញ់រៀងរាល់ថ្ងៃ ។ បងនឹងបានស្ងប់ចិត្តពេលដឹងថា គេទាំងអស់គ្នាបានសុខសប្បាយ...ឯកូនរបស់យើងក៏នឹងបានទទួល សេចក្ដីកក់ក្ដៅពីបង ត្បិតគេមិនដែលបានទទួលពីឪពុករបស់គេ ជាយូរមកហើយ ។ សេចក្ដីស្រលាញ់របស់បង មានទំហំធំធេង មហិមា សំរាប់ស្នងជូនអូននិងកូនវិញ ជំនួសកំហុសដែលបងបាន ប្រព្រឹត្តមិនគប្បី ។ ណៃ! បងស្រលាញ់អូន តាំងពីថ្ងៃដែលបង បានឃើញរូបអូនជាលើកដំបូងនៅវត្តកណ្ដាល រួចសេចក្ដីស្រលាញ់ នោះបានចាក់ឫសជ្រៅឡើងៗ

CHANBOKEO.COM

នៅក្នុងបេះដូងរបស់បងជារៀង រាល់ថ្ងៃដែរ ។ មិនថាអូនខឹងឬស្អប់បងយ៉ាងណាទេ ចំពោះបងវិញ គឺមានតែសេចក្តីស្រលាញ់តែប៉ុណ្ណោះ សំរាប់សងអូនវិញជាថ្នូរ ។ ពេលនេះ ជីវិតបងដែលនៅសល់ បងសូមប្រគល់ជូនអូននិងកូន របស់យើង ស្លាប់រស់ គឺស្ថិតនៅលើរូបអូនហើយជាអ្នកសម្រេច ។

រំពេចនោះ ទឹកភ្នែកពីរដំណក់បានហូរធ្លាក់ចុះមកលើថ្ពាល់នរៈ ជាលើកដំបូងបង្អស់ក្នុងជីវិតរបស់គេ ។ ពីដើម គេមិនដែលយំទេ គេធ្លាប់តែអារសាច់សម្រក់ឈាម តែហេតុអ្វីពេលនេះ គេបែរជា ហូរទឹកភ្នែកទៅវិញ ? ការពិតនោះជាទឹកភ្នែកនៃសេចក្តីស្នេហាដ៏ ធំធេងឥតព្រំដែនលាយឡំនិងទំហំវិប្បដិសារីរបស់គេ ដែលគេបាន រក្សាទុក ដើម្បីមកសារភាពចំពោះមុខមាណវី ព្រោះគេគ្មានឱកាស នឹងលាតត្រដាងចំពោះមុខនាង ជាយូរឆ្នាំកន្លងមកហើយ ។

គ្រាន់តែក្រលេកឃើញ បុរសយើងស្រក់ទឹកភ្នែកភ្លាមកាលណា ចរណៃហាក់ដូចជារំជួលចិត្តខ្លាំងឡើងៗ ។ ទ្រាំមិនបាន នាងក៏ស្ទុះ ទៅស្រវាអោបស្វាមីរបស់នាងយ៉ាងណែនពេញរង្វង់ដៃ ហើយក៏យំ ខ្សឹកខ្សួលកាន់តែខ្លាំងជាងមុនថែមទៀត ។ មាណពភ្ញាក់ព្រើត រួចហើយក៏លាតដៃទទួលខ្លួននាងមកក្នុងរង្វង់ដៃរបស់គេទាំងរំជើប រំជួលក្នុងចិត្ត :

- ណៃ...! ភរិយាបណ្តូលចិត្តរបស់បង!

គេស្រវាអោបគ្នាទៅវិញទៅមកយ៉ាងណែនដោយសេចក្តីរំភើប ចំពោះសេចក្តីស្នេហា ដែលគេមានចំពោះគ្នាទៅវិញទៅមក ។ នរៈ ញាប់ញ័ររំជួលចិត្តឥតឧបមា កាលបើបានដឹងថា ភរិយារបស់គេ កំពុងបន្ទន់ចិត្តរបស់នាង អោយអភ័យទោសរូបគេហើយ :

- អូនណៃ! បងស្រលាញ់អូនណាស់! ដឹងទេ ? បងស្រលាញ់ អូនណាស់ តាំងពីយូរមកហើយហើយក៏ស្រលាញ់រៀងរហូតទៅ...

រួចហើយ គេថែថើបភរិយា ដោយអារម្មណ៍រំជើបរំជួល លើស ពេលណាទាំងអស់ក្នុងជីវិតរបស់គេ ។ ចរណៃខ្សឹកខ្សួលកាន់តែខ្លាំង ដោយការរំភើបចិត្តចំពោះវិចិត្រដែលកំពុងលាតត្រដាងដួងចិត្តនិង អារម្មណ៍ពិតប្រាកដរបស់គេចំពោះធិតា ។

មួយស្របក់ក្រោយមក វិចិត្រក៏យកម្រាមដៃទៅផ្តិតទឹកភ្នែក ចេញពីរង្វង់មុខរបស់ប្រពន្ធ :

CHANBOKEO.COM

- ដល់ពេលហើយណា៎ ដែលយើងទាំងពីរត្រូវញញឹមឡើង ដើម្បី
ទទួលរសជាតិសុភមង្គលដ៏ល្អប្រសើរដោយឥតមានរខិស្ថាននៅក្នុង គ្រួសារយើង !
ឈប់ស្រក់ទឹកភ្នែកទៀតទៅណា៎អូនណា៎...!

ឮវាចាស្វាមីដ៏ផ្អែមល្ហែម ចរណៃសម្លឹងមុខមាណពរួចហើយ ញញឹមទាំងទឹកភ្នែក ឆ្លើយថា :

- ថ្ងៃមុន អូនយំ ព្រោះឈឺចិត្តនឹងអតីតកាលល្អក់កករ ។ ចៃដន្យ ថ្ងៃនេះ
អូនយំព្រោះរំភើបចិត្តនឹងសុភមង្គលដ៏កក់ក្ដៅ ដែលណៃ កំពុងបានទទួលពីស្វាមីជាទីស្រលាញ់...!

រួចហើយ កល្យាណីក៏លូកដៃទៅផ្ដិតទឹកភ្នែកនៅលើវង្វង់មុខ ស្វាមីរបស់នាង រួចពោលបន្តថា
:

- បងចិត្រក៏ដូចគ្នាដែរ...ឈប់ជ្រួញចិញ្ចើម ហើយឈប់សោកសៅ នឹងអតីតកាលទៀតទៅ ។
ណៃសូមរំសាយរឿងអាក្រក់នោះចេញ ពីដួងចិត្តណៃហើយ ។ ពីថ្ងៃនេះតទៅ
យើងមានតែបច្ចុប្បន្នដ៏ល្អ ត្រកាល ប្រកបដោយសេចក្ដីស្រលាញ់យ៉ាងកក់ក្ដៅចំពោះគ្នា ទៅ
វិញទៅមក ដែលជាគ្រឹះសុភមង្គលដ៏រមនារបស់គ្រួសារយើងតែ ម្យ៉ាងប៉ុណ្ណោះ ។

ឮវាចាភរិយាដូច្នោះ វិចិត្រក៏ញញឹមឡើងយ៉ាងបំព្រង រលាយ នូវភាពសៅហ្មងពីក្នុងចិត្ត
អស់រលីងតែម្ដង :

- ពេលនេះ គ្មានអ្វីដែលធ្វើអោយបងរំភើបចិត្ត ជាជាងការដែល
អូនបានអភ័យទោសអោយបងទេ ។ ពីថ្ងៃនេះទៅ បងសន្យាថា នឹងកែឆ្នៃជីវិត
អោយយើងបានស្គាល់តែសេចក្ដីសុខរហូតតទៅ
មិនអោយទឹកភ្នែកវិលមកប្រលែងថ្ពាល់អូនសាជាថ្មីទៀតឡើយ !

រួចហើយ នរៈក៏ឈ្ងោកខ្សិបតិចៗដាក់ត្រចៀកភរិយាបណ្ដូល ចិត្តរបស់ថា :

- ហើយច្រមុះរបស់បងច្បាស់ជាច្រណែនប្រចណ្ឌពេកក្រៃ កាលបើ អូនបណ្ដោយ
ឲ្យទឹកភ្នែកហូរចេញមកប្រលែងថ្ពាល់អូនជាញឹកញាប់ ជំនួសនាសារបស់បង ។ ដឹងទេ
ថាច្រមុះបងមួយនេះនឹកថ្ពាល់
ខួចទាំងគូរបស់អូនខ្លាំងប៉ុនណាដែរ ?

ចរណៃញញឹមឡើងហើយឆ្លើយថា :

- ចៃដន្យ ថ្ពាល់ខួចទាំងគូនេះ មិនដែលចូលចិត្តទឹកភ្នែកទេ ។ គេ
ចូលចិត្តការថ្នាក់ថ្នមពីច្រមុះរបស់បងជាជាង ។

វិចិត្រឮហើយក៏យកនាសាទៅបបោសនឹងថ្ពាល់ភរិយាថ្នមៗ រួច ហើយតបទៅវិញថា :

CHIANBOKEO.COM

- អញ្ចឹង បងសុំច្បាប់ទុកមុនអោយហើយ ថាចាប់តាំងពីថ្ងៃនេះទៅ
ច្រមុះបងសុំប្រលែងលោងលោមថ្ពាល់អូនរាល់ថ្ងៃហើយណា៎ ។

- អត់ទេ ព្រោះបងនៅជំពាក់អូន រឿងមួយទៀត ។

- រឿងអ្វីទៅ អូនណៃ ?

- ចុះឯណាដែលថា បងមានដំណឹងល្អប្រាប់អូននោះ ?

ស្រាប់តែវិចិត្រញញឹមឡើងយ៉ាងស្រស់តែម្តង :

- អូនញញឹមដាក់បងមួយសិនមក៍ ចាំបងប្រាប់ ។

ចរណៃក៏ញញឹមភ្លាម បង្ហាញនូវសោភណ័ភក្រ្តាយ៉ាងត្រកាល
ធ្វើអោយវិចិត្រសម្លឹងឡើងភ្លឹកអារម្មណ៍ ។ បន្តិចមក នរៈក៏អោន ខ្សិបដាក់ត្រចៀកមាណវីថា :

- ដំណឹងល្អនោះគឺ... វិចិត្រតូចម្នាក់ទៀត កំពុងតែចាប់កំណើតនៅ ក្នុងផ្ទៃរបស់អូនហើយ
ដឹងហើយនៅ ?

- យី! ម៉េចក៏បងបានដឹងមុនអូនអញ្ចឹង ?

- អូនណៃភ្លេចហើយហ៎្អែសថា បងជាគ្រូពេទ្យ ?

- ចា៎សៗ ប្តីសម្លាញ់... អូនដឹងហើយ ។

សូរសំណើចរអឹកក៏លាន់ឮឡើងយ៉ាងពិរោះ ជំនួសសំនៀងខ្សឹក
ខ្សួលកាលពីព្រលប់ នៅក្នុងបន្ទប់របស់គូស្នេហ៍មួយគូ ដែលកំពុង
ចាប់ផ្តើមយល់ចិត្តគ្នាទៅវិញទៅមកយ៉ាងជាក់ច្បាស់ជាលើកដំបូង...

ថ្ងៃស្អែកឡើង...

ណារីកំពុងអង្គុយកោសខ្យល់អោយភក្តី ដែលមានទឹកមុខមិន សូវសប្បាយចិត្ត
ស្រាប់តែឮសម្លេងរថយន្តមកដល់មុខផ្ទះ ។ លុះ នាងដាក់ភ្នែកទៅ
ក៏ប្រទះឃើញវិចិត្រនាំស្ត្រីមួយរូបនិងក្មេងបីនាក់ មកដល់ ។ នាងក៏គោះភក្តីប្រាប់
ហើយក៏នាំគ្នាស្ទុះចុះទៅទទួល ។

- បងចិត្រ ? ស្បៀរឿង ? (ភក្តីលាន់មាត់)

- មែនហើយ ភក្តី! (វិចិត្រតបវិញ) បងកំពុងនាំភរិយារបស់បង និងកូនៗមកលេងនឹងប្អូន ។
សុំអាហារមួយពេលជុំគ្នាបានទេ ?

- បាទ...! បាន!

CHIANBOKEO.COM

ភក្តីឆ្លើយទាំងរតាក់រតុប ត្បិតមិនដឹងថាត្រូវឆ្លើយដូចម្ដេចឲ្យ សម កាលបើស្បែរឿងដែលឈរនៅចំពោះមុខរបស់គេនោះ បាន ក្លាយជាភរិយារបស់វិចិត្រ បងប្រុសខ្លួនទៅហើយ ។ ការពិត តាំង ពីគេត្រលប់មកពីផ្ទះវិចិត្រវិញពីយប់មិញមក គេគេងគិតក្រឡូវម៉ូវ មិនបានមួយឆ្អេចយប់ហើយ រហូតដល់ខ្យល់ចាប់តែម្ដង ព្រោះគេ កំពុងតែតក់ស្លុតចំពោះហេតុការណ៍ផ្លាស់ប្ដូរខុសពីចិត្តដែលគេធ្លាប់ បានគេងផ្សេង ហើយក៏ពិចារណាមិនអស់មិនហើយដែរ ។

នៅក្នុងបន្ទប់ទទួលភ្ញៀវ វិចិត្របានណែនាំអ្នកទាំងអស់គ្នាឲ្យ ស្គាល់គ្នាទៅវិញទៅមក ។ ចរណៃបាននិយាយទៅកាន់ភក្ដីថា :

- លោកភក្តី! ថ្ងៃនេះ ខ្ញុំសូមសម្រុះសម្រួលគ្នាពីរឿងចាស់ៗរបស់ យើងថាខ្ញុំបានរំសាយអតិតកាលនោះចោលហើយ ហើយសុំរាប់អាន លោកជាសាច់ញាតិនឹងគ្នាវិញ តើលោកយល់យ៉ាងណាដែរ ?

ពុទ្ធោ! តើអោយភក្ដីគិតយ៉ាងណា បើចរណៃលែងទំនេរហើយ នោះ ? ភក្ដីថ្លោះទឹកមុខតែម្ដង ។ ភ្លាមនោះចរណៃក៏វាចាបន្តថា :

- បងវិចិត្រប្រាប់ខ្ញុំថា លោកមានសង្សារជានារីដ៏ល្អម្នាក់ ទើបខ្ញុំសុំ អោយគាត់ជូនមកលេង នឹងអាលបានជូនពរលោកដោយផ្ទាល់ ។

ភក្ដីឮហើយក៏លួចដៀងភ្នែកទៅណារីដែលអង្គុយកៀនៗនោះ ហើយក៏តបវិញថា :

- យើងកំពុងតែមើលចិត្តគ្នាទៅវិញទៅមក អ្នកនាងស្បែរឿង ។

ភ្លាមនោះ វិចិត្រក៏ញញឹមឡើងហើយស្រដីថា :

- បងក៏មានដំណឹងល្អមួយទៀតមកសំរាប់ប្អូនទាំងពីរដែរ ។

- រឿងអ្វីទៅ បងចិត្រ ? (ភក្ដីសួរ)

- នៅចុងសប្ដាហ៍នេះទៅផ្ទះបងកុំខានណា៎ នោះប្អូននឹងបានដឹង! ហើយកុំភ្លេចនាំណារីទៅតាមផង ។

ព្រឹកថ្ងៃអាទិត្យមកដល់...

ភក្ដីឌុបណារីមកដល់មុខផ្ទះរបស់បងប្រុស ស្រាប់តែប្រទះនឹង រោងការដ៏ធំមួយ ។ ពេលនោះ គេក៏បានប្រទះសាច់ញាតិនិងភ្ញៀវ ជាច្រើនមកចូលរួម មានទាំងអ្នកស្រីផាន់ស៊ីម្ដាយមីងរបស់គេទៀត ផង ។

CHANBOKEO.COM

ចរណៃដើរចេញមកទទួលអ្នកទាំងពីរក្នុងសម្លៀកប្រពៃណី យ៉ាងស្រស់ស្អាត ។ នាងនិយាយទៅកាន់ណារីថា :

- ថ្ងៃនេះ ប្អូនត្រូវតុបតែងខ្លួនអោយស្រស់ស្អាតបំផុត ឮនៅ ?

ណារីងក់ក្បាលតែមិនហ៊ានឆ្លើយអ្វីទេ ត្បិតនាងខ្លាចចិត្តម្ចាស់ ផ្ទះ ។ មួយសន្ទុះក្រោយមក ភ្លេងការក៏ចាប់ផ្តើមប្រគំឡើងយ៉ាង រងំ ។ អ្នកស្រីផាន់ស៊ីក៏ឡើងប្រកាសថា :

- ជំរាបភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី! ថ្ងៃនេះជាថ្ងៃនក្ខតបក្ស បំផុតដែលនាងខ្ញុំមានឱកាសរៀបការកូនចៅដល់ទៅពីរគូ ក្នុងថ្ងៃ តែមួយជាមួយគ្នា ។ ការពិត គេទាំងពីរបានរៀបការម្តងហើយ នៅស្រុកកំណើតខាងស្រី គ្រាន់តែពួកយើងដែលនៅក្រុងបាត់ដំបង នេះ មិនទាន់មានឱកាសបានចងដៃគេនៅឡើយទេ ។ ដូច្នេះនាងខ្ញុំ ជាម្តាយមីងសូមប្រកាសពីពិធីមង្គលការ ជាលើកទីពីររបស់ក្មួយប្រុស ទាំងពីររូបរបស់ខ្ញុំនៅវេលានេះតែម្តង ។ សូមភ្ញៀវកិត្តិយសទាំង អស់អញ្ជើញចូលរួមជាអធិបតីផង ។

សូរឃ្មោះបន្លឺឡើង លាយឡំនឹងស្នូរទះដៃរបស់ភ្ញៀវនិងញាតិ មិត្តទាំងឡាយ បានបង្កើនភាពរីករាយរំភើបដល់គូស្រករថ្មីទាំងពីរ គូ ។ ភក្តិហាក់ដូចមានអារម្មណ៍រំភើបប្លែកខុសធម្មតា ហើយដែល គេញាប់ញ័រចិត្តចម្លែកបំផុតនោះ គឺណារីកូនក្រមុំតែមួយរបស់គេ នៅពេលនេះ ស្រស់ស្អាតសោភាគួរអោយចង់ថៃថើបដល់ហើយ ។ រីឯវិចិត្រវិញក៏រីកច្រើមប៉ុនចង្អេរតែម្តង ដែលគេមានឱកាសបាន រៀបការសាងសុភមង្គលជាមួយនារី ដែលគេគេងស្រម័យរង់ចាំ អស់ជាយូរឆ្នាំមកហើយ ។ ថ្ងៃនេះសុបិនរបស់គេបានក្លាយជាការ ពិតដូចបំណងប្រាថ្នារបស់គេមែន ។ គេឈរញញឹមបិទមាត់មិនជិត ទេ...ស្ទើរតែស្ពឹកជើងធ្មេញអស់ទៅហើយ ។ ពូខេមបានសង្កេត ឃើញថា ថ្ងៃនេះជាថ្ងៃលើកដំបូងបំផុតដែលវិចិត្រយើងចេះញញឹម ឡើងស្រស់បំព្រងមកវិញដោយគ្មានភាពល្អក់ករនៅក្នុងចិត្តរបស់ គេ ព្រោះភាពញញឹមដ៏ស្រស់ត្រកាលមួយនេះបានវង្វេងបាត់ពី ផ្ទៃមុខរបស់មាណពអស់រយៈជាយូរឆ្នាំមកហើយ ។ នៅពីក្រោយ ខ្នងគាត់វិញ មីងលឿមកំពុងតែឈរឃ្នាន់ខ្នាញ់ក្នុងចិត្ត ដែលពូខេម មិនព្រមយកចិត្តគាត់អ្វីបន្តិចសោះ

ពេញមួយថ្ងៃហើយ ។ តាមពិត គាត់ទាំងពីរសុទ្ធតែកម្លោះចាស់ក្រមុំចាស់ដូចគ្នា ។ ព្រោះតែនៅឆៅ ខាងល្បិចល្បួងស្នេហ៍យ៉ាងនោះឯងហើយ ទើបគាត់នៅព្រៅទាំងពីរនាក់ទល់សព្វថ្ងៃ ។ មើលទៅ ថ្ងៃនេះ គ្មាននរណាអាចជួយគាត់ ទាំងពីរបានទេ ព្រោះគេម្នាក់ៗអាល័យតែសប្បាយជូនពរគូស្វាមី ភរិយាថ្មីទាំងពីរគូឯណោះ ។

ផានេតលួចដើរមកឱ្យបដាក់ត្រចៀក

របស់វិចិត្រថា :

- នែ៎! ចិត្រឯងនេះ... គ្នាមិនដែលឮឯងនិយាយអ្វីមាម៉ាត់សោះ សុខៗស្រាប់តែចូលរោងការមុនគ្នាទៅទៀត ។

- ហេតុតែព្រេងនិស្ស័យនោះអី... មិនបាច់និយាយច្រើនទេ ឃើញ ភ្លាម ស្រលាញ់ភ្លែត រៀបការយកតែម្តង ។

វិចិត្រឆ្លើយទៅមិត្តវិញតាមរបៀបប្រុសៗនិយាយគ្នា ។ គេទាំង ពីរក៏សើចកក្អឹកឡើង ។ នៅខាងក្នុងបន្ទប់កូនក្រមុំ លិនដាស្រដី ទៅកាន់ចរណៃថា :

- ខ្ញុំសូមជួយអរផង ដែលអ្នកនាងនឹងគេបានយល់ចិត្តគ្នាវិញ ។

- អ្នកនាងលិនដា...ដឹងរឿងអតីតកាលរបស់យើងដែរ ?

- គឺរឿងអ្នកនាងនឹងបងវិចិត្រនោះហ្ន៎ស... ខ្ញុំមិនដឹងអ្វីទេ គ្រាន់ តែយល់ស្ថានការណ៍ប៉ុណ្ណោះ ។ ទោះជាយ៉ាងណា ខ្ញុំនៅតែស្អប់បង ចិត្រ ដែលចូលចិត្តដើរផ្លូវកាត់លើស្រីៗ ។ ប៉ុន្តែលុះដល់ឃើញ អ្នកនាងអាចអភ័យទោសអោយគេបានហើយ ខ្ញុំក៏ជួយត្រេកអរ រួចខ្ញុំក៏សូមរំសាយអតិតកាលរបស់យើងចាប់ពីពេលនេះតទៅ ។

លិនដានិងចរណៃក៏ចាប់ដៃគ្នាឡើង ដើម្បីផ្តើមមិត្តភាពថ្មីម្តងទៀតដោយអារម្មណ៍ជ្រះស្រឡះ ។ នៅខាងក្រៅ សារិកានិង ផានេត កំពុងលលេងវិចិត្រអោយខ្មាសអៀនឡើងក្រហាមមុខងាំង ដូចកូនក្រមុំកៅស៊ូតែម្តង ព្រោះអីគេទាំងពីរមិនដែលបានឃើញ វិចិត្រញញឹមរីករាយស្រស់ស្អាតបំព្រង ដូចថ្ងៃនេះ ពីមុនមកម្តងណាឡើយ ។

នៅក្នុងបន្ទប់ដំណេក...

- ណៃ... អូនមានដែលចំណាំរូបបងអ្វីបន្តិចទេ ថាយើងធ្លាប់ជួបគ្នាជាញយដង មុនពេលអូនគេចខ្លួនទៅនៅព្រះនេត្រព្រះ ?

- បងចិត្រ ចង់ដឹងធ្វើអ្វី ?

- ដើម្បីអោយចិត្តបងស្ងប់អារម្មណ៍នោះអី ។
- រឿងអតិតកាល...ណៃភ្លេចអស់ហើយ...បងកុំសួរមើល៍ ។
- អូនកុំលាក់បងអី... នេ៎ះ អូនចំណាំសៀវភៅមួយក្បាលនេះទេ ?
- សៀវភៅទស្សន៍ទាយរបស់ខ្ញុំហ្នឹង ? តើមានអ្វីសំខាន់ទៅ ?
- អូនបើកនៅទំព័រខាងក្នុងមើល៍... ឃើញអ្វីដែរ ?

វិចិត្រហុចសៀវភៅទៅភរិយា តែនាងគេចមិនយកទេ បែរជា សើចខឹកៗ តបទៅស្វាមីវិញថា :

- បងចង់នឹងពីកំណាព្យដ៏ខ្លីមួយក្នុងនោះមែនទេ ?
- មែន ? អូនឃើញកំណាព្យមួយនោះដែរ ?
- ថីមិនឃើញ ថែមទាំងទន្ទេញចាំមាត់ទៀតផង ។
- ហើយអូនមានដឹងទេ ថានរណាគេសរសេរអោយអូន ?

ចរណៃនៀលលើពូក រួចហើយច្រត់ចង្កាសម្លឹងមុខស្វាមី បន្ទាប់មក ក៏សើចកខឹកដាក់គេបន្តទៀត :

- អ្នកសរសេរម្នាក់ហ្នឹង ឈ្មោះលោកដុកទ័រ សួន វិចិត្រ...
- អូហ្វ៎! ស្គាល់ដល់ត្រកូលរបស់គេទៀតផង ។
- មានទៅពិបាកអី ណៃទៅហើយ ! !
- នេះ អូនធ្លាប់លួចតាមដានបងដែរ ព្រលឹងមាសបង ?
- ខុសហើយ ណៃមិនបានតាមដានបងទេ គឺតាមដានតែចោរដែល លួចដូរសៀវភៅរបស់អូននោះតើហ៏ ?
- ថាម៉េច ? ម៉េចក៏អូនដឹងថាបងលួចដូរសៀវភៅរបស់អូនដែរ ?
- ថីមិនដឹង ! ហើយចុះបងមានទុកសៀវភៅដែលបងលួចដូរយក ពីអូនទៅ កាលនោះទេ ?
- មាន ! បងទុកនៅទីនេះ ។

វិចិត្រក៏ស្ទុះទៅបើកទូសៀវភៅយកក្បាលនោះចេញមក ។

- ហើយបងមានដែលយកសៀវភៅមកបើកអានទំព័រខាងក្នុងទេ ពេលដែលបងបានលួចដូរគ្នារួចហើយ ? (ចរណៃសួរ)

CHANBOKEO.COM

- អត់ទេ! បងគ្រាន់តែបើកមើលលេងត្រួសៗ កំនររអផ្សុកនៅថ្ងៃ បុណ្យចូលឆ្នាំនោះ រួចហើយក៏ទុកមកក្នុងទូសៀវភៅចោល មិន ដែលបានអានទៀតទេ ។
- ពុទ្ធោ ស្រេចបាត់! (ធិតាយកសៀវភៅនោះគ្របមុខនាង)
- ស្រេច ? ស្រេចរឿងអ្វីទៅអូនណៃ ?
- គឺព្រោះចោរម្នាក់នោះ គាត់ភ្លេចបើកអានកំណាព្យ ដែលខ្ញុំបាន សរសេរលើសៀវភៅរបស់ខ្ញុំ ដើម្បីចំណាំដូចគ្នាដែរ ។ បើមិន អញ្ចឹងទេ ធ្វើម៉េចនឹងណៃបានដឹងថាមានចោរលួចដូរសៀវភៅ ?
- អូហ៎ មែនហ្មែស ? អូនឯងគិតវែងឆ្ងាយដល់ម្លឹងផង ?

វិចិត្រភ្ញាក់ក្រញាងតែម្តង ។ គេក៏ស្រវាសៀវភៅនោះពីដៃ ភរិយា មកបើកមើលចុះមើលឡើង :
- នៅឯណា ? ម៉េចមិនឃើញ មានស្អីនៅក្នុងហ្នឹងអញ្ចឹង ?
- ពុទ្ធោ! មនុស្សមិនដែលធ្វើចោរ ធ្វើម្តង ឆ្គងដូច្នេះឯង! យ៉ាប់ ណាស់ បងឯងនេះ ។

ធិតាសើចកខឹក ហើយក៏ចាប់សៀវភៅនោះពីដៃស្វាមីមកវិញ រួចក៏បើកទំព័រលេខ១០០ ហុចអោយទៅវិចិត្រអានភ្លាម :
- នេះនែ៎! របស់សំខាន់យ៉ាងហ្នឹង កោតតែបងចេះរំលងកើត!
- អូនមានសរសេរអ្វីនៅខាងក្នុងសៀវភៅដែរហ្មែ៎ស ?

វិចិត្រធ្វើភាំង កាលបើឃើញភរិយាស្គាល់សៀវភៅនោះ ជាង រូបនាយដែលថែរក្សាទុកដាក់វាច្រើនឆ្នាំមកហើយ ។ គេទទួលយក មកអានភ្លាម ស្រាប់តែប្រទះឃើញកូនកំណាព្យតូចមួយសរសេរលើ ទំព័រទំនេរ មានសេចក្តីថា :

ស្នាមញញឹម

ឱ ! ស្នាមញញឹមលើភក្ត្រា សមកែវនេត្រាភ្លឺផ្លេកក្រៃ
ឃើញភ្លាមជំពាក់ជាប់និស្ស័យ លង់ស្នេហ៍ប្រុសថ្លៃម្ចាស់វរមិត្រ ។
ឱ ! ស្នាមញញឹមដ៏សៃមស្រស់ មន្តស្នេហ៍ហើរហោះខាបដួងចិត្ត
ឆក់យកបេះដូងម៉ុំមាសស្និទ្ធ ឲ្យលង់ផ្តេកផ្តិតស្នាមញញឹម ។
តើថ្ងៃស្អែកនេះស្រស់ធិតា នឹងមានវាសនាគួរសង្ឃឹម
បានយល់ទៀតទេភក្ត្រប៉ប្រិម នាំស្នាមញញឹមល្អមង្គល...
តើយើងជួបគ្នាទៀតទេ ? ថ្ងៃណា ?
ហត្ថលេខា : ចរណៃ

CHANBOKEO.COM

គ្រាន់តែអានចប់ វិចិត្រញញឹមឡើងដោយត្រេកអរកខិបកខុប ហើយចាប់ប្រពន្ធថើបខ្សឹតៗ ម្តងហើយម្តងទៀត មិនព្រមលែង សោះ ហាក់ដូចជាគេរំភើបចិត្តណាស់ ទប់មិនបាន កាលបើបាន អានហើយយល់អត្ថន័យរបស់កំណាព្យនោះភ្លាម :

- កាលនោះ អូនលួចសរសេរកំណាព្យនោះផ្ញើអោយបងមែនទេ ? - កាលនៅថ្ងៃចូលឆ្នាំនោះ តើអូនសរសេរកំណាព្យផ្ញើបុរសណាមួយ ទៅហ្ន៎ ដែលនៅអង្គុយក្បែរណៃ មួយថ្ងៃវាស់ល្ងាច មិនព្រមងើប ដើរទៅណាមកណាសោះ ឃើញតែគេលួចចោលកន្ទុយភ្នែក រួច ហើយឃើញតែលួចញញឹមពព្រាយដាក់ណៃអត់ឈប់... ?

វិចិត្រយកដៃបូតច្រមុះភរិយាដោយរំភើបចិត្ត :

- មុខនេះខូចណាស់តើហ៎ លួចផ្ញើសារ មិនឲ្យគេដឹងខ្លួនអ្វីបន្តិច ។
- បើអោយដឹងមុនទៅ ក្រែងគេផ្អើលរត់បាត់ ឈប់អង្គុយជិតណៃ ខ្លាចណៃវង្វេងរកស្នាមញញឹមដ៏ស្រស់មួយនោះរកមិនឃើញទៀត...
- បានន័យថាកាលនោះអូនក៏លួចចាប់អារម្មណ៍ពីបងដែរមែនទេ ?
- បើណៃមិនបានចាប់អារម្មណ៍លើគេ ធ្វើម៉េចនឹងតាមដានដឹងថា នរណាគេជាអ្នកលួចដូរសៀវភៅរបស់អូន ? តើគេឈ្មោះអី នៅ ឯណា ? ធ្វើការអីដែរទៅ ?
- ណៃតាមដានល្អិតល្អន់ដល់ហើយហ្ន៎! បងកុំអោយតែដឹងខ្លួនអ្វី បន្តិច! ការពិតវិញនោះ គឺបងបានលួចប្រតិពទ្ធ័លើរូបអូនខ្លាំង ណាស់ ហើយលួចនឹកអូនជានិច្ចតែក្នុងចិត្តម្នាក់ឯង ។ រាល់ថ្ងៃ បង ទៅឈរលបមើលអូននៅផ្ទះមិនដែលខានទេព្រោះបងនឹក... ប៉ុន្តែ ហេតុអ្វីកាលនោះ ម្តេចក៏អូនព្រងើយមិនមើលមុខបងម្តងណា សោះអញ្ចឹង ?
- គឺអូនខ្មាសបងនោះអី...! នរណាគេទៅហ៊ានសម្លឹងមើលប្រុស កម្លោះចំៗវិញនោះ លោកអើយ... ជាពិសេស ចំពោះបុរសដែល យើងកំពុងលួចចាប់អារម្មណ៍ដែរនោះ... ? គ្រាន់តែគេដើរក្បែរៗ អូនភ័យញ័រខ្លួន ទប់មិនជាប់ទៅហើយ ។

វិចិត្រអង្អែលខ្នងភរិយាថ្នមៗ :

- ស្តាយណាស់ កាលនោះ មិនគួរណាបងធ្វើអោយឆ្លោយការសោះ កុំអីយើងបានជួបគ្នាដោយល្អទៅហើយ មិនពិបាកព្រាត់គ្នាដល់ទៅ ជាងប្រាំឆ្នាំ.... ខាតពេលវេលាដ៏មានតម្លៃរបស់យើងអស់ ។
- ណៃមិនបន្ទោសបងតែម្នាក់ឯងទេ ។ រឿងនោះក៏មកពីភក្តីខ្លះៗ ដែរ ។ តែពេលនេះ រឿងរ៉ាវបានកន្លងទៅហើយ ។ ណៃលែងយក

CHANBOKFO.COM

មកទុកក្នុងចិត្តទៀតហើយ យើងនៅសល់តែរឿងល្អៗតែប៉ុណ្ណោះ !

បន្តិចមក វិចិត្រដាក់កេសាកើយលើភ្លៅភរិយាហើយស្រដីថា :

- អូនដឹងទេ ថានៅរាត្រីមានព្យុះសង្ឃរាធំនោះ ហេតុអ្វីបងជ្រើស
រើសផ្ទះរបស់អូន ដើម្បីសុំចូលជ្រកភ្លៀង ?
- បងចូល... សាកមើលក្រែងលោជួបអូន មែនទេ ?
- មែនហើយអូន! ព្រោះម្ចាស់បេះដូងរបស់បងធ្លាប់រស់នៅផ្ទះ មួយនោះ
កាលបើឃើញភ្លើងបើកភ្លឺៗ បងក៏ប្រថុយចូលទៅ ។
- លុះដល់ជួបហើយ ក៏....
- ប្រញាប់ទាក់ទងតែម្តង មិនបណ្តោយអោយរបូតទៀតទេ! លើក នេះ
បើបងមិនរហ័សដៃរហ័សជើងទេ ខ្លាចគេរត់ចោលបងបាត់ ស្រមោលម្តងទៀត ។
ពេលនោះជីវិតបងច្បាស់ជាអស់ន័យហើយ..
- ថៃដន្យ យើងក៏ជួបគ្នា...
- ប៉ុន្តែ អូននៅតែមានកិរិយាតោះតើយនឹងបងដដែល ។
- គេជាមនុស្សប្រុសចម្លែកម្នាក់ ដែលអូនស្គាល់មិនច្បាស់ តើឲ្យ អូនចេញមុខរាក់ទាក់ប៉ុនណាទៅ
ជាពិសេសនៅពេលយប់ផង នោះ ? ចុះបើគេមានគំនិតមិនល្អ... ណែមិនស៊យទៅហើយទេហ៍ ?
- បើមិនទុកចិត្ត ហេតុអ្វីក៏បណ្តោយអោយគេស្នាក់នៅផ្ទះរបស់អូន ដល់ទៅមួយយប់ទាល់ភ្លឺ ?
- គឺសាកចិត្តនោះអី! ណែមិនទទួលទេ បើសង្ហាតែរូបសម្បត្តិ ប៉ុន្តែខ្វះទឹកចិត្តនិងភាពថ្លៃថ្នូរ ។
- សំណាងល្អ នៅលើកថ្មីនោះ បងឈប់ហ៊ានលូកថ្លើមអូនហើយ
ខ្លាចទទួលលទ្ធផលអវិជ្ជមានដូចកាលលើកទីមួយទៀត...
- អូហ៍... បងដឹងខ្លួនដែរ ?
- ដឹងហើយយល់ច្បាស់ណាស់ ព្រោះបងបានធ្វើអោយជីវិតរបស់
បងបានធ្លាក់ក្នុងនរកងងឹតអស់យូរឆ្នាំ ។ ការពិត ការប្រព្រឹត្តអំពើ អ្វីៗដោយខ្វះការពិចារណា
ខ្វះសតិហើយ វាតែងតែផ្តល់លទ្ធផល អវិជ្ជមានលើខ្លួនយើង ដែលជាអ្នកប្រព្រឹត្តជានិច្ច ។
កាលនោះ បងបានធ្វើអោយអូនឈឺចាប់... បងវិញក៏ទទួលការឈឺចាប់មិនតិច ជាងអូនទេ
ព្រោះអំពើរបស់បងបានធ្វើអោយរូបអូនចាកចេញទៅ យ៉ាងទាន់ហន់ ។
បងនឹកអាមាសចំពោះអំពើមិនគប្បីរបស់ខ្លួនឯង រកអ្វីប្រៀបស្មើមិនបានទេ ។

CHIANBOKEO.COM

- អញ្ចឹងតើហ៎ បានជាដំណើរចូលមកទាក់ទងជាមួយណោលើកនេះ
មានរសជាតិផ្អែមល្ហែមស្អិតល្មួតតែម្តង ។
- គឺបងចង់សងជំងឺចិត្តជូនអូនវិញនោះអី ជំនួសពេលប្រាំឆ្នាំដែល
យើងបានទទួលឈឺចាប់ក្នុងចិត្តទាំងពីរនាក់ ។
- ខំយកចិត្តណោដល់ហើយហ្ន៎!...
- គេជាម្ចាស់បេះដូងរបស់បងទៅហើយ! បើបងមិនថ្នាក់ថ្នមគេ
តើអោយបងទៅថ្នាក់ថ្នមនរណាវិញទៅ ? ជាពិសេសកាលបើនឹង
ថាគេជាម្តាយរបស់កូនប្រុសបងទៀត តើនរណាម្នាក់ទៅដែលមិន
រំភើបញាប់ញ័ររន្ធត់ក្នុងចិត្តនោះ ?
- អូហ៎..! បងនឹងដែរ ថាភក្ត្រាជាកូនរបស់បង ?
- នឹង! ហើយយល់ស្ថានការណ៍ តាំងពីមុនពេលអូននិយាយរឿង អូនប្រាប់បងទៅទៀត
គឺ...នឹងតាំងតែពីរាត្រីដែលបងប្រទះភក្ត្រា
លើកដំបូងនៅផ្ទះរបស់អូននារាត្រីមួយនោះមកម្ល៉េះទើបបងប្រញិប ប្រញាប់
សុំអូនរៀបការមិនទុកពេលអោយអូនគិតយូរទេ ។ ម្យ៉ាង ទៀត
បងក៏ធ្លាប់បានជួបភក្ត្រាជាច្រើនដងនៅសួនយុវ័ន ហើយគេ ធ្លាប់ហៅបងថា "ប៉ា" ថែមទៀតផង!
បងចេះតែមានប្រផ្នូលនៅក្នុង ចិត្តតាំងពីថ្ងៃនោះមកម្ល៉េះ ។ អូនណោដឹងទេ នោះគឺឈាមកំពុង
រត់រកឈាមវិញណាំអូន... ជានិស្ស័យដែលនាំឲ្យយើងឲ្យជួបគ្នាវិញ
ចរណោញញឹមឡើង បន្ទាប់មកក៏វាចាថា :
- អញ្ចឹងបងស្រលាញ់តែភក្ត្រាទេ ? ចុះកូនរបស់ខ្ញុំពីរនាក់ទៀត ?
- អ្នកណាថាបងស្រលាញ់តែភក្ត្រាម្នាក់ ? ការពិត សេចក្តី
ស្រលាញ់របស់បងមានទំហំធំធេងណាស់! កុំថាត្រឹមតែកូនពីរកូនបី
កូនម៉ាឡូក៏បងទទួលបានដែរណាំអូន ។
- បងចិត្តទូលាយដល់ម្លឹងផងហ្ន៎ស ?
វិចិត្រចាប់ដៃភរិយាមកថើប ហើយឆ្លើយបន្តថា :
- អូននឹងទេ... បុរសម្នាក់ដែលគេមិនដែលស្គាល់បងសោះ តែគេ អាចអភ័យទោសអោយបងបាន
ព្រមទាំងបានចិញ្ចឹមរក្សាកូនប្រុស របស់បង ផ្តល់កត្តិយសដល់ប្រពន្ធរបស់បងយ៉ាងពេញមុខ...
រឿង អ្វីដែលបងសងគុណគេវិញ ដោយប្រពៃមិនបាន ?

- ចុះចំពោះស្រីម៉ៅវិញនោះ ?
- នាងម៉ៅជាក្មេងដែលគួរអោយអាណិត ព្រោះគ្មានខ្វះការកក់ក្ដៅ នៅក្នុងគ្រួសារដើមរបស់គេ ។ កាលបើគ្រួសាររបស់យើងនេះមាន សុភមង្គលរមនាដល់ម្លឹងទៅហើយ រឿងអ្វីដែលយើងចែករំលែក សេចក្ដីសុខរបស់យើងដល់រូបគេមិនបានដែរនោះ ?
- ចិត្តថ្លើមរបស់បងពិតជាទូលំទូលាយមែន ។ ណៃសូមអរគុណ ចំពោះទឹកចិត្តដ៏ថ្លៃថ្លានេះ ។ កាលមុន ណៃគិតថា ឪពុករបស់ភក្ត្រា ជាមនុស្សពាលហើយតែងតែលួចសំរក់ទឹកភ្នែកអាណិតកូន ។ ប៉ុន្តែ ពេលនេះ ទឹកភ្នែកដែលធ្លាប់ស្រក់ដោយក្ដីអាណិត បានក្លាយជា តំណក់ទឹកភ្នែកនៃការរំភើបចិត្ត ដែលគេមានសំណាងបានមកជួប ឪពុករបស់គេវិញ ហើយថែមទាំងជាឪពុកដ៏ល្អទៀតផង ថ្វីបើ កាលនោះភក្ត្រាមិនបានកើតមកពីសេចក្ដីស្រលាញ់ក៏ដោយ ។
- នរណាថាគេមិនបានកើតមកដោយក្ដីស្រលាញ់ ? ការពិតភក្ត្រាគឺ ជាតំណាក់ឈាមនៃក្ដីស្រលាញ់និងក្ដីរំភើប ដែលបងមានចំពោះរូប អូនបំផុត... ថ្វីបើពេលនោះ បងដើរផ្លូវកាត់បន្តិចមែន...
- ឆ្លៀតឱកាសបង្ហាញសេចក្ដីស្រលាញ់ដោយវិធីបែបនោះ វាធ្វើឲ្យ យើងឈឺចាប់ណាស់... បងដឹងទេ ?
- បាទ! បងដឹងហើយយល់ច្បាស់ទៀតផង ។ នេះជាមេរៀនជីវិត ដ៏ធំធេងមួយដែលបងត្រូវតែចងចាំ... ចាប់ពីថ្ងៃនេះទៅ បងសន្យា ថាមិនដើរផ្លូវកាត់បែបនេះទៀតទេ... ព្រោះបងខ្លាចត្រូវធ្លាក់នរក ទាំងរស់ដូចកាលពីលើកមុនទៀត ។

ចរណៃញញឹមហើយយកដៃអង្អែលដើមទ្រូងស្វាមី :

- អរគុណបងណាស់ នូវការផ្លាស់ប្ដូរជាថ្មី ហើយសូមអរគុណ ចំពោះ សុភមង្គលដ៏ថ្លៃថ្លា ដែលបងប្រគល់មកក្រុមគ្រួសាររបស់ យើងនៅពេលនេះនិងរហូតតរៀងទៅ ។

វិចិត្រញញឹមឡើងដោយដួងចិត្តត្រជាក់ក្សេមក្សាន្ត :

- បងសប្បាយចិត្តឥតឧបមាដែលយើងបានជជែកគ្នាថ្ងៃនេះ ហើយ បានដឹងជាក់ច្បាស់នូវជំរៅចិត្តរបស់យើងចំពោះគ្នាទៅវិញទៅមក.. ថ្វីបើយើងបានបែកគ្នាអស់ជាងប្រាំឆ្នាំពិតមែន តែយើងនៅសល់ ពេលវេលាច្រើនបំផុតក្នុងជីវិត

CHANBOKEO.COM

ចាប់ពីពេលនេះតទៅ សំរាប់សាង សេចក្តីសុខរបស់យើងសាជាថ្មី ដើម្បីជាម្លប់ត្រជាក់ដល់កូនរបស់ យើងទាំងអស់គ្រប់គ្នាណា៎អូន ។

គូស្នេហ៍ទាំងពីរស្រវាត្រកងគ្នាឡើង ដោយក្តីស្នេហាចំពោះគ្នា ទៅវិញទៅមក យ៉ាងជ្រាលជ្រៅឥតព្រំដែន ។

ស្អែកឡើង នៅព្រះវិហារវត្តកណ្តាល...

វិចិត្រនិងចរណៃនាំកូនទាំងបី ទៅអុជធូបថ្វាយបង្គំព្រះអង្គនៅ ក្នុងវិហារ ។ គេបែរមើលមុខភរិយាហើយពោលថា :

- ណៃ! បងបានប្រទះស្នាមញញឹមដ៏ស្រស់មួយ នៅលើថ្ពាល់ខួច មួយគូ នាបរិវេណវត្តកណ្តាលនោះ នៅថ្ងៃបុណ្យចូលឆ្នាំ ហើយនៅ ពេលដែលបងបានព្រាត់ស្នាមញញឹមនោះទៅ បងតែងតែមកបែ បន់ សុំអោយពុទ្ធបារមីសក្តិសិទ្ធិជួយណែនាំផ្លូវអោយបងបានជួប ស្នាមញញឹមនោះ សាជាថ្មី ។ ពេលនេះ បងក៏បានជួបវិញដូច ប្រាថ្នារបស់បងហើយ គឺព្រះជាម្ចាស់បានប្រទានសេចក្តីសុខយ៉ាង ពេញលេញបំផុតមកជីវិតរបស់បង ។ បងពិតជារំភើបណាស់ នឹង ពាក្យអ្វីមកថ្លែងអោយសមស្មើមិនបានឡើយ ។

- ពេលនេះ ចរណៃកំពុងទទួលសុភមង្គលយ៉ាងកក់ក្តៅ ពីស្វាមីជា ទីស្រលាញ់ ។ អូនគិតថាព្រះលោកបានដឹកដៃអូនឲ្យមកជួបបងវិញ តាមបំណន់របស់បង ត្បិតព្រះអង្គបានឈ្វេងយល់ថា បងស្រលាញ់ អូនដោយចិត្តបរិសុទ្ធ គ្មានភាពឫស្យាប្រទុស្តរាយនៅក្នុងចិត្ត  ថ្វីបើ វេលាមួយនោះបងបានប្រព្រឹត្តមិនប្រពៃក៏ដោយ ។ អូនវិញក៏រំភើប ចិត្តដូចគ្នាដែលយើងមានឱកាសកែឆ្នៃកំហុសអតីតកាលហើយ បែរ មកសាងសុភមង្គលយ៉ាងរមនា ជាម្លប់ត្រជាក់ដល់កូនគ្រប់គ្នាទាំង អស់...នេះជាភព្វវាសនាយ៉ាងឧត្តង្គឧត្តមរបស់យើងហើយណា៎បង!

វិចិត្រកាន់ដៃភរិយាអង្អែលថ្នមៗ :

- អរគុណណាស់ភរិយាសម្លាញ់ ដែលផ្តល់នូវទឹកចិត្តដ៏ទន់ភ្លន់មក បងវិញ ។ សូមអោយយើងបានរួមរស់ជាមួយគ្នា លុះចាស់ព្រឹទ្ធ ចាស់ព្រេងណា៎អូន!

- ចា៎ស! យើងនឹងស្រលាញ់គ្នា ថែរក្សាគ្នា ដោយចិត្តស្មោះស្មគ្រ័ ភក្តីបំផុត លុះលង់អវសាននៃជីវិតរបស់យើង ។

CHIANBOKEO.COM

*00000* **ចប់ដោយបរិបូរណ៍** *00000*

*000000000000*

CHANBOKEO . COM

# វាចាចុងក្រោយ

- ការប្រព្រឹត្តភ្លើតភ្លើនដោយការខ្វះសតិ មិនត្រឹមតែនាំទុក្ខដល់អ្នកដទៃទេ គឺនាំទុក្ខដល់ជីវិត របស់ខ្លួនឯងថែមទៀតផង ។
- ការកែប្រែមារយាទពីយង់ឃ្នងទៅជាមនុស្សល្អ សម្រេចនៅលើបុគ្គលសាម៉ីខ្លួនថា តើគេនឹង កែប្រែរូបគេសំរាប់នរណាដែរ? បើគេកែប្រែសំរាប់តម្រូវចិត្តអ្នកដទៃ នោះគឺជាការកែប្រែ ក្លែងក្លាយ ព្រោះបើអត់ពីអ្នកដទៃនោះទៅ គេនឹងក្លាយជាមនុស្សយង់ឃ្នងដូចដើមវិញ ។ តែបើគេកែប្រែដើម្បីអោយខ្លួនគេល្អ មិនមែនដើម្បីអ្នកដទៃ នោះទើបជាការកែប្រែពិត ប្រាកដ ព្រោះថា ទោះបីគេទៅដល់ទីណា នៅជាមួយនរណា គេនៅតែជាមនុស្សល្អជានិច្ច រៀងរហូតទៅ ។
- បើសិនជាឪពុកម្តាយថែរក្សាកូនដោយក្តីស្រលាញ់និងភាពកក់ក្តៅ នោះកូនចៅនឹងចងចាំ ជានិច្ចនៅក្នុងជំរៅចិត្តរបស់គេ នូវមេត្តាធម៌ដែលគេធ្លាប់បានទទួលហើយពីឪពុកម្តាយ ហើយ គេនឹងទៅសំដែងកតញ្ញូចំពោះអ្នកមានគុណវិញមិនខាន ដោយមិនបាច់មានការរំលឹក ឬការ បង្ខំចិត្តពីនរណាឡើយ ។ តែបើគេទទួលតែការឈឺចាប់និង ការគម្រាមកំហែងដោយអំពើ ហឹង្សារបស់ឪពុកម្តាយ កូន១នឹងខ្លាចរអាហើយតូចចិត្តបំផុត ។ គេប្រាកដជាមិនហ៊ានវិលវិញ មកឃើញស្ថានភាពបែបនោះសាជាថ្មីទៀតទេ ព្រោះគេដឹងថាបេះដូងរបស់គេនឹងទទួលនូវការ ឈឺចាប់សាជាថ្មីម្តងទៀត ពេលគេប្រទះមុខឪពុកម្តាយដែលមិនព្រមកែមារយាទ ។
- មនុស្សយើងខ្លះមានកំហុសហើយ ចេះតែធ្វើខុសតទៅទៀត រួចក៏ចេះតែវង្វេងឆ្ងាយទៅ១ ព្រោះគេកំពុងតែដើរបែរមុខទៅទិសងងិត មើលមិនឃើញពន្លឺដែលនៅក្រោយខ្នង មិនអាច រកផ្លូវត្រលប់បែរក្រោយអោយឃើញពន្លឺបាន ។ មានតែអ្នកនៅខាងភ្លឺប៉ុណ្ណោះទេដែលអាច លូកដៃទៅគោះខ្នងអ្នកដែលបែរមុខទៅភពងងិត ជួយដាស់ បំភ្លឺស្មារតី អោយគេភ្ញាក់ខ្លួន ស្វាងពីការលង់ជ្រៅក្នុងភាពងងិត ហើយបែរក្រោយមករកពន្លឺវិញ ។
- ទោះពាក់មាសស្រោចខ្លួនយ៉ាងណា ក៏មាសមិនអាចស្រោបជិតនូវគំនិត គិតល្អក់កករ របស់បុគ្គលនោះបានដែរ ។
- សុភមង្គល ស្ថិតនៅលើការសំរេចចិត្តរវាងបុគ្គលមនុស្សពីរនាក់ដែលស្រឡាញ់គ្នា ហើយ ដែលចេះទទួលខុសត្រូវលើជីវិតរបស់ខ្លួនឯង ។ សេចក្តីស្នេហាតែម្យ៉ាង មិនអាចបណ្តុះ សុភមង្គលបានឡើយ កាលបើរូបយើងមិនចេះទទួលខុសត្រូវ ហើយការសមរម្យទៀតសោត ក៏មិនមែនស្ថិតនៅលើភ្នែកញាតិតែម្យ៉ាងនោះដែរ បើសិនជាញាតិទាំងឡាយនោះជាមនុស្ស ដែលប្រកបដោយគំនិតអគតិពេញខ្លួន ខ្វះសេចក្តីថ្លៃថ្នូរ សូម្បីតែការគិតល្អចំពោះញាតិផង ។
- អ្នកដែលខ្វះជំនឿចិត្តលើខ្លួនឯងតែងពឹងផ្អែកលើការវាយតម្លៃពីសង្គម អោយគេកាត់តម្លៃ ជីវិតយើងថាគួរធ្វើដូចម្តេចអោយសមរម្យ ។ តែចំពោះបុគ្គលដែលមានជំនឿមុតមាំលើខ្លួនឯង និងជឿលើសច្ចភាព នោះគេមិនខ្លាចសង្គមសើចចំអកទេ ហើយសង្គមក៏មិនហ៊ានសើច ចំអកអោយគេវិញដែរ ព្រោះបុគ្គលនោះមានគុណសម្បត្តិបរិបូរណ៍រួចទៅហើយ ។
- តើអំពើហឹង្សាបំផ្លាញក្រុមគ្រួសារយើងយ៉ាងណាខ្លះ? ហើយតើខ្លួនយើងដែលជាអ្នក ប្រព្រឹត្តអំពើហឹង្សានោះ បានទទួលជោគជ័យ មានសុភមង្គលក្នុងជីវិតដែរឬទេ បន្ទាប់ពីបាន ប្រព្រឹត្តអំពើហឹង្សាទៅលើអ្នកដទៃ ឬវត្ថុអ្វី១ជុំវិញខ្លួនរួចហើយ?
- ពេលជីវិតរបស់យើងកំពុងស្រកស្រុតកម្លាំងចិត្ត យើងត្រូវតែស្វែងរកមធ្យោបាយសំរាប់ ជួយលើកកម្លាំងចិត្តខ្លួនឡើង ។ យើងមិនមែនរស់នៅលើលោកនេះតែម្នាក់ឯងទេ ហើយយើង ក៏មិនមែនជាមនុស្សដែលអភ័ព្វជាងគេលើលោកនេះតែម្នាក់ឯងដែរ ។ ការធ្វើអត្តឃាដបញ្ចប់ ជីវិតរបស់ខ្លួនឯងមិនមែនជាការដោះស្រាយបញ្ហាឡើយ ។ ការពិត ការធ្វើអត្តឃាដជាការចង បញ្ហា ពង្រីកសេចក្តីទុក្ខសោកអោយកាន់តែធំឡើង ធ្ងន់ឡើង ទម្លាក់ទៅលើអ្នកដែលរស់នៅ ជុំវិញខ្លួនរបស់យើង អោយគេជួយរែកទុក្ខជំនួសយើង នៅពេលយើងស្លាប់ទៅនោះទេវិញ ទេតើហ៎ ។ ហេតុនេះហើយ យើងត្រូវតែរឹងប៉ឹង ត្រូវតែរស់ ហើយរស់ដោយល្អបំផុត សំរាប់ បុគ្គលទាំងអស់ដែលស្រលាញ់យើងគ្រប់គ្នា ហើយយើងត្រូវសម្លឹងទៅមុខ ដើម្បីសាងក្តី សង្ឃឹមសាជាថ្មី ។ ព្រះអាទិត្យមិនចេះតែលិចរហូតទេ យ៉ាងណាមិញ ជីវិតមនុស្សក៏ដូចគ្នាដែរ គឺមិនដែលលិចលង់ងងិតសូន្យរហូតទៅឡើយ ។ ថ្ងៃណាមួយ ជីវិតនឹងភ្លឺស្វាងឡើងវិញជា មិនខាន ។

អ្នកស្រីកែវចន្ទ័បូរណ៍
អ្នកនិពន្ធ

CHANBOKEO.COM